# ជំពូកទី១
# សេចក្តីផ្តើមនៃកម្មសិទ្ធិបញ្ញា

## អ្វីទៅដែលហៅថាកម្មសិទ្ធិបញ្ញា?

ប្រហែលជាអ្នកយល់ហើយពីសំណួរនេះ យើងដឹងថាអ្នកបង្កើតម៉ាស៊ីន អ្នកនិពន្ធសៀវភៅ ឬអ្នកសរសេរបទភ្លេង គឺជាម្ចាស់ស្នាដៃ ដោយមូលហេតុនេះយើងមិនអាចថតចម្លង ឬយកផលិតផលរបស់គេដោយគ្មានការយល់ព្រមពីម្ចាស់កម្មសិទ្ធិឡើយ ដូចជា: រូបគំនូរឧស្សាហកម្មនៃគ្រឿងសង្ហារឹម ក្រដាស់ផ្សាយពាណិជ្ជកម្ម គឺតែងតែមានម្ចាស់កម្មសិទ្ធិ ។

រាល់ពេលយើងទិញផលិតផលនោះ គឺជាផ្នែកមួយដែលយើងបានសងប្រាក់ទៅគេវិញ នៅពេលវេលានៃកិច្ចប្រឹងប្រែង និងគំនិតដែលម្ចាស់ស្នាដៃបានបង្កើតឡើង ។ ការធ្វើបែបនេះមានរយៈពេលជាយូរឆ្នាំមកហើយ ក្នុងតំណាក់កាលអភិវឌ្ឍផ្នែកឧស្សាហកម្មដូចជាផ្នែកតន្ត្រីដែលកំពុងតែរីកចំរើនក្នុងសាកលលោកយើងនេះ ហើយការលើកទឹកចិត្តនូវទេពកោសល្យថ្មីៗដើម្បីផលិតឱ្យបានច្រើន និងការបញ្ចេញគំនិត ព្រមទាំងអត្ថបទស្នាដៃផ្សេងៗ ។

តារាងខាងក្រោមនេះ ចាត់ទុកថាជាស្នាដៃដែលត្រូវទទួលបាននូវការការពារដូចកម្មសិទ្ធិបញ្ញា ដោយស្ថិតនៅក្រោមច្បាប់កម្មសិទ្ធិបញ្ញារបស់ជាតិនីមួយៗ ឬការការពារដោយសន្ធិសញ្ញាអន្តរជាតិ ។

| | | |
|---|---|---|
| ហ្វូណូក្រាម | គំនូរប្លង់ | ការកំណត់ប្រភពដើមនៃផលិតផល |
| ការសម្តែង | រូបភាព | ឈ្មោះក្រុមហ៊ុន |
| អង្គភាពទូរផ្សាយ | ផ្លាកសញ្ញា | ដំណើរការផ្នែកឧស្សាហកម្ម |
| វីដេអូ | ពាណិជ្ជសញ្ញា | រូបមន្តគីមី |
| កុំព្យូទ័រហ្គាម | ប្រព័ន្ធសៀគ្វី | សំភារៈផ្សេងៗ |
| កម្មវិធីកុំព្យូទ័រ | ផលិតផលថ្មី | ទឹកអប់ |

ចូរយើងចាប់ផ្តើមជាមួយនឹងការកំណត់និយមន័យផ្លូវការជាច្រើនស្តីពីកម្មសិទ្ធិបញ្ញា ដើម្បីជាមូលដ្ឋាននៃការពន្យល់ពីប្រភេទផ្សេងៗនៃកម្មសិទ្ធិបញ្ញា និងបន្ទាប់មក មានការពន្យល់ពីសន្ធិសញ្ញា

អន្តរជាតិ ។ ចូរយើងពិចារណាទៅលើអត្ថន័យនៃពាក្យកម្មសិទ្ធិ ។

ដើម្បីឱ្យកាន់តែច្បាស់ ពាក្យកម្មសិទ្ធិគឺយើងសំដៅទៅលើម្ចាស់ទ្រព្យសម្បត្តិ ហើយខ្លួនមានសិទ្ធិប្រើសម្បត្តិនេះដោយសេរី និងស្របច្បាប់ លើកលែងតែអ្នកដទៃ ដែលប្រើប្រាស់កម្មសិទ្ធិនេះ ។

ឥឡូវនេះពាក្យថា "កម្មសិទ្ធិបញ្ញា" គឺសំដៅទៅលើប្រភេទនៃទ្រព្យសម្បត្តិ ដែលផ្តើមចេញពីការបង្កើតចេញពីគំនិតរបស់មនុស្ស គឺបញ្ញានេះតែម្តង ។ ជាពិសេសពាក្យថាកម្មសិទ្ធិបញ្ញានេះ នៅក្នុងសន្ធិសញ្ញាដែលចែងក្នុងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក World Intellectual Property Organization (WIPO) មិនមាននិយមន័យផ្លូវការច្រើនទេ ។ រដ្ឋដែលបានព្រាងសន្ធិសញ្ញានេះបានផ្តល់នូវបញ្ជីមួយដែលទាក់ទងសិទ្ធិនេះដូចខាងក្រោម:

ស្នាដៃសិល្បៈ អក្សរសាស្ត្រ វិទ្យាសាស្ត្រ ការសម្តែងសិល្បៈ ហ្វូណូក្រាម និង ទូរផ្សាយ ។ ការបង្កើតឡើងថ្មីគ្រប់វិស័យពីកិច្ចប្រឹងប្រែងរបស់មនុស្ស ការរកឃើញ ផ្នែកវិទ្យាសាស្ត្រ គំនូរឧស្សាហកម្ម ម៉ាក ពាណិជ្ជនាម និងគំនូរប្លង់ ។ ការការពារនូវការប្រកួតប្រជែងមិនស្មោះត្រង់ ព្រមទាំងសិទ្ធិផ្សេងៗទៀតដែលកើតចេញពីសកម្មភាពខាងបញ្ញា និងផ្នែកឧស្សាហកម្ម វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬវិស័យសិល្បៈ ( សន្ធិសញ្ញាដែលបង្កើតអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលបានចុះហត្ថលេខានៅទីក្រុង ស្តុកខម (Stockholm)ថ្ងៃទី១៤ ខែមិថុនាឆ្នាំ១៩៦៧ មាត្រា២ SViii ) ។

ចំពោះមូលហេតុនៃការគ្រប់គ្រងរដ្ឋបាល និងប្រវត្តិសាស្ត្រ កម្មសិទ្ធិបញ្ញា គឺតែងតែមានការទំនាក់ទំនងជាចម្បងដូចខាងក្រោម:

១-ស្នាដៃអក្សរសាស្ត្រ សិល្បៈ និងវិទ្យាសាស្ត្រ មានដូចជាសៀវភៅ: ការការពារលើកម្មសិទ្ធិទាំងនេះ គឺផ្អែកលើច្បាប់សិទ្ធិអ្នកនិពន្ធ ។

២-ការសម្តែង ការផ្សព្វផ្សាយតាមរយៈទូរផ្សាយ ដូចជាការប្រគុំតន្ត្រី: ការការពារលើកម្មសិទ្ធិនេះ គឺផ្អែកលើច្បាប់សិទ្ធិប្រហាក់ប្រហែល ។

៣-តក្កកម្ម មានដូចជា: ទម្រង់ថ្មីនៃម៉ាស៊ីនយន្តហោះប្រតិកម្ម ការការពារលើការបង្កើតថ្មីនេះគឺផ្អែកលើច្បាប់ប្រកាសនីយបត្រតក្កកម្ម ។

៤-គំនូរឧស្សាហកម្ម មានដូចជារូបរាងដបភេសជ្ជៈ: គំនូរឧស្សាហកម្មអាចត្រូវបានការពារតាមច្បាប់ពិសេស ឬច្បាប់គំនូរឧស្សាហកម្ម ឬ ច្បាប់សិទ្ធិអ្នកនិពន្ធ។

៥-ម៉ាក ពាណិជ្ជកម្មនាម មានដូចជា: រូបសញ្ញា ឈ្មោះលើផលិតផលដែលភ្ជាប់ជាមួយនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដូចជាឈ្មោះស្រាChampane។ ជាធម្មតាកិច្ចការពារនេះអាចនៅក្រោមច្បាប់ផ្សេងៗទៀត ក្នុងករណីនេះត្រូវស្ថិតនៅក្រោមច្បាប់ម៉ាក ពាណិជ្ជនាម ។

៦-ការការពារលើការប្រកួតប្រជែងមិនស្មោះត្រង់ មានដូចជា ការក្លែងបន្លំ ឬការចម្លងនូវផលិតផលរបស់អ្នកប្រកួតប្រជែង ដើម្បីបន្លំអ្នកប្រើប្រាស់ ។

<u>សំនួរវាយតម្លៃដោយខ្លួនឯង</u>

ចំពោះឧទាហរណ៍កម្មសិទ្ធិបញ្ញានីមួយៗ ដូចខាងក្រោម មួយណាដែលត្រូវចាំបាច់ការពារដោយច្បាប់កម្មសិទ្ធិបញ្ញាណាមួយៈ

១-ក្រុមហ៊ុនមួយមានបំណងធានាថាមិនឲ្យនរណាម្នាក់ ប្រើប្រាស់រូបសញ្ញារបស់ខ្លួន ។

២-អ្នកចម្រៀងម្នាក់មានបំណងប្រគល់សិទ្ធិឱ្យគេផលិតជាវីដេអូនូវការសម្តែងរបស់ខ្លួន ។

៣-វិធីផលិតទឹកដោះគោដោយមានជាតិប្រូតេអ៊ីនធាត់ចំនួនតិច ។

៤-ក្រុមហ៊ុនមួយបានសំរេចចិត្តវិនិយោគកញ្ចប់ ដែលមានលក្ខណៈខុសពីគេ ហើយគេមានបំណងធានាការប្រើប្រាស់ផ្តាច់មុខ ។

៥-ក្រុមហ៊ុនសម្រេចចចិត្តប្រើរូបសញ្ញាមួយ ដែលមានរូបរាងដូចគ្នាទៅនឹង រូបសញ្ញារបស់អ្នកដ៏ទៃ ប៉ុន្តែគ្រាន់តែមានពណ៌ខុសគ្នា ។

<u>ចម្លើយ</u>

១-ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម

២-សិទ្ធិប្រហាក់ប្រហែល

៣-ប្រកាសនីយបត្រតក្កកម្ម

៤-គំនូរឧស្សាហកម្ម

៥-ការប្រកួតប្រជែងមិនស្មោះត្រង់

កុំបារម្ភប្រសិនបើអ្នកមិនអាចឆ្លើយបាននូវសំណួរទាំងអស់នេះទេ យើងធ្វើការពិភាក្សា និងពន្យល់នៅក្នុងជំពូកក្រោយ ។

<u>ការផ្តល់យោបល់ខាងលើផ្អែកលើកត្តាសំខាន់ពីរ ៖</u>

-ម្ចាស់កម្មសិទ្ធិបញ្ញាអាចទទួលបាននូវសិទ្ធិទៅតាមស្នាដៃរបស់ខ្លួន

-សិទ្ធិស្នាដៃនោះអាចប្រគល់ ឬអនុញ្ញាតឱ្យអ្នកផ្សេង ។

## ហេតុអ្វីបានជាមានបញ្ហាខាងផ្នែកកម្មសិទ្ធិបញ្ញា?

មូលហេតុចម្បងទី១: គឺថាមនុស្សបង្កើតស្នាដៃ និងការប្រឹងប្រែងផ្នែកបញ្ញាត្រូវតែបានទទួលនូវផលប្រយោជន៍ពីកិច្ចខំប្រឹងនេះ ។ មូលហេតុទី២: គឺថាការផ្តល់នូវការការពារកម្មសិទ្ធិបញ្ញានៃការប្រឹងប្រែងជាច្រើន តាមរយៈការលើទឹកចិត្ត និងការប្រឹងប្រែងធ្វើការ ដើម្បីឲ្យមនុស្សយល់ថា ការងារនោះនាំមកនូវប្រាក់ត្រលប់មកវិញ ។

ជាឧទាហរណ៍ ករណីរោងចក្រផលិតថ្នាំពេទ្យ គេធ្វើការវិនិយោគជាច្រើនឆ្នាំ ព្រមទាំងចំណាយលើការស្រាវជ្រាវ និងការអភិវឌ្ឍន៍ ដូចជាការបង្កើតមន្ទីរពិសោធន៍ ការធ្វើតេស ការគ្រប់គ្រង ឬបង្កើត

ភ្នាក់ងារត្រួតពិនិត្យ ដោយចំណាយទុនរាប់រយលានដុល្លារ ប្រហែលជាការចាំបាច់ណាស់មុនពេលថ្នាំពេទ្យនេះឈានចូលក្នុងទីផ្សារ ។ ប្រសិនបើគ្មានច្បាប់កម្មសិទ្ធិបញ្ញាដើម្បីការពារទេ ក្រុមហ៊ុនថ្នាំពេទ្យដែលផលិត ឡើងនូវផលិតផលថ្មី មិនអាចចំណាយពេល ឬខំប្រឹងបង្កើតថ្នាំទាំងនោះទេ ។

ប្រសិនបើគ្មានច្បាប់ប្រកាសនីយបត្រតក្កកម្មទេ ក្រុមហ៊ុននោះនឹងប្រឈមនឹងការខាតបង់ ពីដៃគូប្រជែងផ្សេងទៀត ។ ប្រសិនបើគ្មានច្បាប់ម៉ាក ពាណិជ្ជនាមទេ ក្រុមហ៊ុននេះមិនអាចបង្កើតបាននូវដៃគូដ៏ស្មោះត្រង់នោះទេ ។

ដូចនេះប្រសិនបើគ្មានច្បាប់កម្មសិទ្ធិបញ្ញា និងសន្ធិសញ្ញាទាំងនោះដើម្បីការពារទេ ក្រុមហ៊ុនផលិតថ្នាំពេទ្យ មិនអាចប្រឹងប្រែងធ្វើការពិសោធន៍ ឬស្រាវជ្រាវរកផលិតផលថ្មី ដើម្បីការពារសុខភាពឡើយ ។ ដូចបានឃើញពីឧទាហរណ៍សង្ខេបនេះ បើគ្មានការការពារ ដូចខាងលើនេះទេ ពិភពលោកច្បាស់ជាគ្មានសុខភាពល្អទេ ។

កម្មសិទ្ធិបញ្ញាអាចជួយផងដែរ ក្នុងការការពារមិនឱ្យផលិតឡើងវិញ ឬថតចម្លងឡើងវិញនូវវប្បធម៌របស់ប្រទេសកំពុងអភិវឌ្ឍជាច្រើនដូចជាសិល្បៈ ប្រពៃណី ។ ការការពារបែបនេះគេអាចធ្វើពាណិជ្ជកម្ម ដើម្បីទាញយកប្រយោជន៍វប្បធម៌ដើម ។

មូលហេតុដែលរដ្ឋផ្សេងៗអនុវត្តច្បាប់ជាតិ និងចូលរួមចុះសន្ធិសញ្ញាទាំងច្បាប់ក្នុងតំបន់ និងអន្តរជាតិនៃច្បាប់កម្មសិទ្ធិបញ្ញាក្នុងគោលបំណង ៖

-ផ្តល់នូវការលើកទឹកចិត្តដល់ការខំប្រឹងបង្កើតឡើងតាមគំនិត ដោយទទួលបាននូវការការពារ

- ផ្តល់នូវការទទួលស្គាល់ជាផ្លូវការនៃអ្នកបង្កើតស្នាដៃ

- បង្កើតឡើងនូវឃ្លាំងរក្សាទុកសម្រាប់ជាព័ត៌មាន

-សម្រួលដល់ការរីកចម្រើនផ្នែកឧស្សាហកម្មក្នុងស្រុកទាំងវប្បធម៌ ទាំងពាណិជ្ជកម្មអន្តរជាតិតាមសន្ធិសញ្ញាការពារពហុភាគី ។

# ជំពូកទី២
# សិទ្ធិអ្នកនិពន្ធ

**<u>វត្ថុបំណង:</u>**

បន្ទាប់ពីបានបញ្ចប់ការសិក្សាជំពូកនេះ អ្នកអាចៈ

១-យល់អត្ថន័យច្បាប់សិទ្ធិអ្នកនិពន្ធ និងអាចផ្តល់ឧទាហរណ៍ពីប្រភេទស្នាដៃ ដែលស្ថិតនៅក្រោមច្បាប់សិទ្ធិអ្នកនិពន្ធ។

២-អាចពន្យល់បានប្រហែល២៥០ពាក្យពីសិទ្ធិ ដែលត្រូវបានការពារដោយច្បាប់សិទ្ធិអ្នកនិពន្ធ ( សិទ្ធិផលិតឡើងវិញ សិទ្ធិនៃការសម្តែង សិទ្ធិបកប្រែ និងសិទ្ធិក្នុងការកែសម្រួល )។

៣-អាចពិពណ៌នាបាន២៥០ពាក្យ ពីព្រំដែនកំណត់នៃសិទ្ធិដែលមានចែងក្នុងច្បាប់នេះ ។

៤-អាចបញ្ជាក់ពីរយៈពេលការពារដែលបានចែងក្នុងសន្ធិសញ្ញា Bern Convention សហគមន៍អឺរុប និងសហរដ្ឋអាមេរិច ។

៥-អាចពន្យល់ពីភាពជាម្ចាស់សិទ្ធិ ដែលអាចទទួលបាននិងការផ្ទេរសិទ្ធិ។

៦-អាចធ្វើបញ្ជីវិធានការ៥ ប្រើដើម្បីបង្ខំឱ្យអនុវត្តសិទ្ធិនេះ ។

៧-អាចផ្តល់នូវករណីសិក្សាមួយដែលទាក់ទងដល់បញ្ហាសិទ្ធិអ្នកនិពន្ធ ដំបូងកំណត់ពីបញ្ហាទាំងនោះ បន្ទាប់មកកំណត់ពីការអនុវត្តន៍នៃសន្ធិសញ្ញាមួយណាដែលទាក់ទងដល់បញ្ហាទាំងនេះ ។

## សេចក្តីផ្តើម

ជំពូកសិទ្ធិអ្នកនិពន្ធនេះពន្យល់ពីប្រភេទស្នាដៃ ដែលត្រូវបានការពារស្ថិតនៅក្រោមច្បាប់សិទ្ធិអ្នកនិពន្ធ យល់ពីសិទ្ធិដែលម្ចាស់សិទ្ធិមាន ហើយរបៀបដែលអាចប្រើប្រាស់ដើម្បីផលប្រយោជន៍ពាណិជ្ជកម្ម ។ ច្បាប់ជាច្រើនដែលទាក់ទងដល់សិទ្ធិអ្នកនិពន្ធ គឺមានលក្ខណៈស្រដៀងគ្នាគ្រប់ប្រភេទដែលបានចុះសន្ធិសញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងពាណិជ្ជកម្ម ។ តែទោះបីជាយ៉ាងណាក៏ដោយ ការឆ្លើយសំណួរដែលទាក់ទងដល់ច្បាប់សិទ្ធិអ្នកនិពន្ធរបស់ប្រទេសមួយត្រូវបានពិគ្រោះ ។ អ្នកឃើញនិងឮតាមអនុសញ្ញាប៊ែន (Bern Convention) និងកិច្ចព្រមព្រៀងទ្រីព (TRIPS Agreement) នៅក្នុងជំពូកនេះ នឹងត្រូវបានពន្យល់លំអិត ។ ពេលនេះវាគ្រាន់តែជាកិច្ចព្រមព្រៀងពីរដែលទាក់ទងដល់កិច្ចព្រមព្រៀងអន្តរជាតិ ក្នុងវិស័យកម្មសិទ្ធិបញ្ញាព្រមទាំងបានពន្យល់ផងដែលពីដំណោះស្រាយដែល

ម្ចាស់សិទ្ធិអាចចាត់វិធានការផ្សេងៗ រាល់ការរំលោភបំពានសិទ្ធិរបស់ខ្លួន ។ ដំណោះស្រាយទាំងនេះអាចធ្វើបាននៅក្នុងប្រទេសជាច្រើន ប៉ុន្តែអ្នកគួរតែពិនិត្យលើច្បាប់សិទ្ធិអ្នកនិពន្ធរបស់ប្រទេសអ្នកផ្ទាល់ ដើម្បីធានាស្ថានភាពក្នុងប្រទេសរបស់ អ្នករៀងៗខ្លួន ។

## តើអ្វីខ្លះដែលត្រូវការពារដោយច្បាប់សិទ្ធិអ្នកនិពន្ធ?

ទាក់ទងដល់គ្រប់វិស័យនៃច្បាប់កម្មសិទ្ធិបញ្ញា គឺទាក់ទងដល់កិច្ចការពារលើ ស្នាដៃដែលបង្កើតឡើងដោយបញ្ញារបស់មនុស្ស ។ ផ្នែកដែលសំខាន់នៃសិទ្ធិនេះគឺការពារលើស្នាដៃអក្សរសាស្ត្រ និងស្នាដៃសិល្បៈ មានដូចជាអត្ថបទសរសេរ តន្ត្រី រូបគំនូរ ចម្លាក់ ព្រមទាំងបច្ចេកវិទ្យាដូចជាកម្មវិធីកំព្យូទ័រ និងប្រព័ន្ធទិន្នន័យ អេឡិចត្រូនិច ។



ចូរកំណត់សម្គាល់ថាកិច្ចការពារស្នាដៃគឺសំដៅលើការសរសេរ ឬការសម្តែងចេញពីគំនិត មិនមែនការពារលើយោបល់ទេ ។ ដូច្នេះប្រសិនបើអ្នកគិតពីគម្រោងសម្ងាត់ណាមួយ គឺមិនត្រូវបានការពារទេ ប៉ុន្តែនៅពេលដែលអ្នកសរសេរសង្ខេបចេញមក ឬក៏និយាយចេញនូវគម្រោងការសម្ងាត់នោះទើបត្រូវបានការពារអ្នកនិពន្ធដ៏ទៃទៀត អាចបង្កើតស្នាដៃជាច្រើនផ្សេងៗទៀតដោយផ្អែកលើ គម្រោងការនោះ ។

សន្ធិសញ្ញា Berne Convention(១៨៨៦)គឺជាសន្ធិសញ្ញាអន្តរជាតិដំបូងបំផុត ដែលគ្រប់គ្រងលើសិទ្ធិអ្នកនិពន្ធដែលចែងក្នុងមាត្រា២:

ការសម្តែងចេញនូវគំនិតនៃស្នាដៃអក្សរសាស្ត្រ ស្នាដៃសិល្បៈរួមមានផលិតផលនៃស្នាដៃអក្សរសាស្ត្រ វិទ្យាសាស្ត្រ និងសិល្បៈ ទោះបីស្ថិតនៅក្នុងម៉ូដ ឬទម្រង់បែបណាក៏ដោយ ដូចជាសៀវភៅ សៀវភៅផ្ទត់ ឬអត្ថបទផ្សេងៗ បទឧទ្ទេសនាម សន្ទរកថា ធម្មទេសនា និងស្នាដៃផ្សេងទៀត ដូចជារឿងល្ខោន ឬបទភ្លេង ស្នាដៃរៀបចំឆាក និងការកំសាន្ត ការសរសេបទភ្លេងដោយមាន ឬគ្មានទំនុបច្រៀង ស្នាដៃថតកុន ឬស្នាដៃស្រដៀងនឹងថតកុន គំនូរ ស្ថាបត្យកម្ម ចម្លាក់ ចម្លាក់ពុម្ព ឆ្លាក់ ស្នាដៃថតរូប ស្នាដៃផ្សេងទៀត ដែលស្រដៀងនឹងស្នាដៃថតរូប ស្នាដៃសិល្បៈអនុវត្តតុបតែង ផែនទីប្លង់ រឿងល្ខោនខ្លីៗ ភូមិសាស្ត្រ តូប៉ូសាស្ត្រ ឬវិទ្យាសាស្ត្រ ការបកប្រែ ការកែសម្រួល ឬការសម្រួលតន្ត្រី ត្រូវបានការពារដូចស្នាដៃដើមដែរដោយមិនធ្វើឲ្យមានព្យសនកម្មនៃស្នាដៃដើមឡើយ ។ ការប្រមូលចងក្រងស្នាដៃអក្សរសាស្ត្រ សិល្បៈជាសព្វវចនាធិប្បាយ កវីនិពន្ធតាមរយៈការរៀបចំចំណងជើង ការបង្កើតឡើងដោយបញ្ញាត្រូវទទួលបានកិច្ចការពារដោយមិនធ្វើឲ្យមានព្យសនកម្មស្នាដៃដើមឡើយ ។

ស្នាដៃទាំងនោះមិនទាមទារល្អ ឬមានទេព្យកោសល្យអ្វីទេ គឺគ្រាន់តែជា ស្នាដៃដើម ។ អត្ថន័យជាក់ស្តែងអាស្រ័យលើច្បាប់នៅក្នុងប្រទេសនីមួយៗ ។ ជាទូទៅក្នុងប្រទេស Common Law គឺមានការ

ទាមទារតិចតួចណាស់ គឺស្នាដៃមួយ មិនត្រូវបានចតចម្លងពីស្នាដៃមួយផ្សេងៗទៀត គឺស្នាដៃនោះត្រូវតែកើតចេញពីការ ប្រឹងប្រែងផ្ទាល់ និងពីជំនាញពិតប្រាកដរបស់ខ្លួន ។

ក្នុងប្រទេសCivil Law ការទាមទារភាពដើមនៃស្នាដៃនោះគឺមានភាពខ្លាំងគឺមានន័យថាស្នាដៃនោះត្រូវតែមានបោះត្រាបញ្ជាក់ពីអ្នកនិពន្ធដែលបានប្រឹងប្រែងបង្កើតឡើងដោយជំនាញត្រឹមត្រូវរបស់អ្នកនិពន្ធ ។

### តើស្នាដៃដែលស្ថិតនៅក្រោមកិច្ចការពារ Berne Conventionសុទ្ធតែមានចែងក្នុងមាត្រា២ឬ?

ត្រូវចាំថាស្នាដៃដែលទទួលបាននូវកិច្ចការពារនោះ មិនមានត្រឹមតែស្នាដៃដែលបានបញ្ជាក់ក្នុង Berne Convention ប៉ុណ្ណោះទេគឺក្នុងBerne Convention បញ្ជាក់ថាគឺជាស្នាដៃដែលបានសម្តែងចេញតាមរយៈគំនិតនៃស្នាដៃអក្សរសាស្ត្រ និងសិល្បៈ រួមទាំងផលិតផលទាំងអស់ក្នុងវិស័យសិល្បៈ វិទ្យាសាស្ត្រ និងគ្រប់ទម្រង់ទាំងអស់នៃការសម្តែងចេញជាជាងការកំណត់ក្នុងបញ្ជី ។ ជាឧទាហរណ៍ប្រទេសផ្សេងៗ អាចចេញសេចក្តីសម្រេចការពារដូចជា:

-ទម្រង់លិខិតឯកជន

-លិខិតលែងលះ

-ម៉ូដសក់

-រចនាសម្ព័នតុបតែងស្ពាន

-ឯកសារប្រឡង

### តើដូចម្តេចដែលហៅថាស្នាដៃបន្ត?

សំខាន់ចាងមាត្រា២នៃBerne Conventionទៅទៀតគឺស្នាដៃបន្ត នេះជាស្នាដៃដែលធ្វើបន្តពីស្នាដៃផ្សេងទៀតដែលមានពីមុនមក ដូចជា:

-ការបកប្រែជាភាសាផ្សេងទៀត

-ការសម្រួលជាស្នាដៃខ្សែភាពយន្តតាមរយៈស្នាដៃប្រលោមលោក

-ការសម្រួលតន្ត្រីOrchestra ទៅជាPiano

-ការផ្លាស់ប្តូរទៅជាស្នាដៃផ្សេងទៀតពីស្នាដៃអក្រសាស្ត្រ

-ការប្រមូលចងក្រងស្នាដៃអក្សរសាស្ត្រ សិល្បៈដូចជាសព្វវចនាធិប្បាយ អត្ថបទសម្រាំងកវីនិពន្ធ ។

អ្នកត្រូវចងចាំថា មុនបង្កើតស្នាដៃបន្ត អ្នកត្រូវគោរពសិទ្ធិអ្នកនិពន្ធ ។ ជាឧទាហរណ៍មុននឹងបកប្រែស្នាដៃមួយ ត្រូវតែមានការអនុញ្ញាតពីម្ចាស់សិទ្ធិជាមុនសិន ។ ការបកប្រែដោយគ្មានការអនុញ្ញាតិពីអ្នកនិពន្ធគឺជាការរំលោភបំពាន។

**តើប្រភេទស្នាដៃអ្វីខ្លះដែលអាចទទួលបាននូវកិច្ចការពារដោយច្បាប់សិទ្ធិអ្នកនិពន្ធ?**

សិទ្ធិអ្នកនិពន្ធ គឺការពារលើស្នាដៃអក្សរសាស្ត្រ និងសិល្បៈដូចមានចែងក្នុងសន្ធិសញ្ញា Bern Convention ។ មានទស្សនៈទូលាយ២គឺ ពាក្យអក្សរសាស្ត្រ មិនត្រឹមតែអត្ថបទរឿងប្រលោមលោក កំណាព្យ ឬរឿងខ្លីៗប៉ុណ្ណោះទេ ថែមទាំងសៀវភៅតូចៗស្តីពីការថែរក្សារថយន្តព្រមទាំងអ្វីៗដែលបានសរសេរ ដោយមិនចាំបាច់ទាល់តែមនុស្សយល់ទេ ដូចជាកម្មវិធីកុំព្យូទ័រជាដើម ។ ពាក្យគន្លឹះគឺការបង្កើតឡើងនូវស្នាដៃ ។ អ្វីដែលចង់មានន័យនៅទីនេះគឺការបង្កើតឡើងដោយមនុស្សជាកត្តាចម្បង ដូចនេះប្រសិនបើខ្ញុំមាន គំនិតគូរូបព្រះអាទិត្យអស្តង្គតនៅមាត់សមុទ្រ មនុស្សផ្សេងទៀតក៏អាចមានគំនិតដូចគ្នា ដែរវាមិនអាចការពារបានទេ ប៉ុន្តែនៅពេលដែលខ្ញុំបានគូរូបនេះចេញមក គឺត្រូវបានទទួលនូវកិច្ចការពារ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

១-តើអ្វីជាស្នាដៃកម្មសិទ្ធិបញ្ញាដ៏សំខាន់ដែលបានបង្ហាញខាងលើ មិនមានចែងក្នុងបញ្ជីស្នាដៃអក្សរសាស្ត្រ និងសិល្បៈនៃBerne Convention?

<u>ចម្លើយ</u>

ករណីសំខាន់លើកលែងដែលមិនមានចែងក្នុងបញ្ជីនៃស្នាដៃខាងលើគឺកម្មវិធិកុំព្យូទ័រ ផលិតផលទាំងនេះគឺជាស្នាដៃកម្មសិទ្ធិបញ្ញាហើយត្រូវចាត់ទុកជាស្នាដៃ ។ ចំណុចសំខាន់ដែលកំណត់ក្នុងបញ្ជីBerne Conventionគឺមានន័យមិនគ្រប់គ្រាន់ វាមានន័យត្រឹមស្នាដៃអក្សរសាស្ត្រ និងសិល្បៈ ។ ជាបន្ថែមទៀតស្នាដៃមិនត្រឹមតែកំណត់ក្នុងបញ្ជីនៃមាត្រា២នៃBerne Conventionប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងការបង្កើតឡើងក្នុងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ និងសិល្បៈដែលជាផលិតផលពហុ ។ នៅពេលនិយមន័យតាមផ្លូវច្បាប់មិនទាន់បានកំណត់ច្បាស់លាស់ រួមទាំងសម្លេង អត្ថបទ រូបភាព និងទម្រង់ឌីជិថលដែលអាចធ្វើឡើងដោយកម្មវិធីកុំព្យូទ័រ រួមផ្សំជាមួយការសម្តែងចេញនូវភាពគ្រប់គ្រាន់របស់អ្នកនិពន្ធនៃផលិតផលចម្រុះដែលស្ថិតនៅក្រោមកិច្ចការពារនៃច្បាប់សិទ្ធិអ្នកនិពន្ធ ។

**តើសិទ្ធិអ្វីខ្លះដែលត្រូវបានការពារដោយច្បាប់សិទ្ធិអ្នកនិពន្ធ?**

នៅវគ្គនៃសេចក្តីផ្តើមនេះ គឺយើងបានពន្យល់ថាលក្ខណៈសំខាន់បំផុតនៃកម្មសិទ្ធិ គឺថាម្ចាស់សិទ្ធិអាចប្រើប្រាស់ផ្តាច់មុខទៅតាមបំណងរបស់ខ្លួន ដោយគ្មាននរណាម្នាក់អាចប្រើប្រាស់ទ្រព្យនោះដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិឡើយ ។ ជាការពិតពាក្យថាតាមបំណងនេះមានន័យថា ពួកគេអាចប្រើប្រាស់វាដោយស្របច្បាប់ និង ទាញយកផលប្រយោជន៍បាន ។ ឧទាហរណ៍ ម្ចាស់រថយន្តអាចប្រើវាទៅតាមបំណង តែមិនមានន័យថាគេបើកវាបង្កគ្រោះថ្នាក់ដល់អ្នកដ៏ទៃឡើយ ឬក៏រំលោភទៅលើច្បាប់ចរាចរឡើយ ។ សិទ្ធិអ្នកនិពន្ធគឺជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា ម្ចាស់សិទ្ធិអាចប្រើប្រាស់ស្នាដៃ

នោះតាមបំណងប្រាថ្នា ហើយអាចការពារមិនឱ្យអ្នកដ៏ទៃប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីខ្លួន ។ ដូចនេះតាមច្បាប់ជាតិ សិទ្ធិដែលផ្តល់ឱ្យម្ចាស់សិទ្ធិ គឺសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ស្នាដៃ ឬអនុញ្ញាតអោយអ្នកផ្សេងប្រើប្រាស់ ។

មានសិទ្ធិ២ប្រភេទស្ថិតនៅក្រោមច្បាប់សិទ្ធិអ្នកនិពន្ធគឺសិទ្ធិបេតិកភណ្ឌ(សិទ្ធិសេដ្ឋកិច្ច): ជាសិទ្ធិដែលអនុញ្ញាតឱ្យម្ចាស់សិទ្ធិទទួលបាននូវថវិកាពីការប្រើប្រាស់ស្នាដៃរបស់ខ្លួនតាមរយៈ អ្នកដ៏ទៃនិងសិទ្ធិសីលធម៌: ជាសិទ្ធិតំរូវឱ្យគេគោរពឈ្មោះអ្នកនិពន្ធ បែបបទនៃការបោះផ្សាយ និងការកែប្រែខ្លឹមសារដែលនាំឱ្យខូចកេរ្តិ៍ឈ្មោះ ។

**តើសិទ្ធិអ្វីខ្លះដែលម្ចាស់សិទ្ធិមាន?**

ម្ចាស់សិទ្ធិមានសិទ្ធិផ្សេងៗជាច្រើនដែលចែងក្នុង Bern Convention វាជាសិទ្ធិអប្បរមា និងផ្អែកលើច្បាប់ក្នុងប្រទេសដែលបញ្ជាក់បន្ថែមពីសិទ្ធិទាំងនោះ ។ ជាទូទៅសិទ្ធិនៃការផលិតឡើងវិញ គឺជាពាក្យគន្លឹះមួយដែលទាក់ទងដល់សិទ្ធិអ្នកនិពន្ធ មានន័យថាសិទ្ធិនៃការផលិតឡើងវិញ គឺគ្រប់គ្រងលើការបោះពុម្ពសៀវភៅ និងការថតចម្លង ឬចម្លងឡើងវិញ ប៉ុន្តែថែមទាំងគ្រប ដណ្តប់ទៅលើវិធីផ្សេងៗទៀតនៃការផលិតឡើងវិញ ដូចជាការថតបញ្ចូលក្នុងឌីស ឬការថតចម្លងជាហ្វូណូក្រាមឡើងវិញ ឬរក្សាទុកស្នាដៃនៅក្នុងប្រព័ន្ធកុំព្យូទ័រ និង កម្មវិធីកុំព្យូទ័រតាមរយៈ Diskettes , CD-ROM, CD-Write able ROMs, Flash និងវត្ថុផ្សេងៗទៀតដែលអាចផ្ទុកទិន្នន័យបាន ។ល។

សិទ្ធិផ្សេងទៀតគឺ សិទ្ធិក្នុងការសម្តែង អ្នកសម្តែងស្នាដៃណាមួយ ដូចជាអ្នកលេងភ្លេង ឬអ្នកសម្តែងសកម្មភាពលើឆាកពេញមួយឆ្នាំ សិទ្ធិនោះត្រូវបានការពារក្នុងការចាក់ផ្សាយតាមទូរទស្សន៍ និងសិទ្ធិក្នុងការផ្សព្វផ្សាយជាសាធារណៈ តែជួនកាលមានភាពផ្សេងគ្នាទៅតាមច្បាប់ជាតិ ការចាក់ផ្សាយតាមទូរផ្សាយ និងតាមប្រព័ន្ធInternet គឺជាផ្នែកមួយនៃការផ្សាយជាសាធារណៈ ។

<u>សំណួរវាយតម្លៃខ្លួនឯង</u>

តើប្រភេទសិទ្ធិពីរដែលបានបង្ហាញខាងលើជាប្រភេទសិទ្ធិអ្វី? លើកឧទាហរណ៍សិទ្ធិនីមួយៗ

<u>ចម្លើយ</u>

ប្រភេទសិទ្ធិសំខាន់ពីរដែលបានបង្ហាញខាងលើគឺ:

-សិទ្ធិផលិតឡើងវិញ ឧទាហរណ៍សិទ្ធិនេះជាសិទ្ធិក្នុងការអនុញ្ញាតឲ្យផលិតឡើងវិញ បោះពុម្ព ឬថតចម្លងកាសែតឡើងវិញ

-សិទ្ធិមួយទៀតគឺសិទ្ធិនៃការសម្តែងជាសិទ្ធិក្នុងការសម្តែងស្នាដៃមួយដូចជាបទចម្រៀង ឬផ្សព្វផ្សាយតាមទូរផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈ ។

**<u>សិទ្ធិក្នុងការផលិតឡើងវិញ</u>**

ម្ចាស់សិទ្ធិ មានសិទ្ធិការពារនូវការថតចម្លងស្នាដៃរបស់ខ្លួនដោយអ្នកដទៃ ផ្អែកលើច្បាប់សិទ្ធិអ្នកនិពន្ធជាតិ ។ ឧទារហណ៍ ការថតចម្លងស្នាដៃដែលទទួលបាននូវការការពារមួយដើម្បីបោះផ្សាយ ឬមានបំណងចែកចាយនូវស្នាដៃ ជាសាធារណៈទោះជាការបោះពុម្ព ឬផ្សព្វផ្សាយជាឌីជីថលដូចជា CD-ROMs ក៏ដោយ ។ ផលិតករហ្វូណូក្រាមមានសិទ្ធិផលិត ចែកចាយឌីសរបស់ខ្លួនរួមទាំងការផលិតស្នាដៃតន្ត្រីដោយមានការយល់ព្រមពីអ្នកនិពន្ធបទភ្លេងនៃស្នាដៃនោះ និងសិទ្ធិក្នុងការគ្រប់គ្រងលើការផលិតឡើងវិញដោយស្របច្បាប់ក្នុងការធ្វើអាជីវកម្មស្នាដៃ ។

សិទ្ធិផ្សេងទៀតត្រូវបានទទួលស្គាល់ក្នុងច្បាប់ជាតិ គឺផ្អែកលើសិទ្ធិនៃការផលិតឡើងវិញ ។ ឧទាហរណ៍ ច្បាប់ខ្លះរួមមានសិទ្ធិក្នុងការអនុញ្ញាតបោះផ្សាយនូវស្នាដៃ ។ ជាការពិត សិទ្ធិនៃការផលិតឡើងវិញអាចបាត់បង់ចំណូលសេដ្ឋកិច្ចច្រើនដល់ម្ចាស់សិទ្ធិ បើសិនជាម្ចាស់សិទ្ធិអាចអនុញ្ញាតឱ្យគេបោះផ្សាយ ។ សិទ្ធិនៃការផ្សព្វផ្សាយ គឺជាកម្មវត្ថុមួយនៃការលក់ ឬផ្ទេរសិទ្ធិទៅអ្នកផ្សេងដើម្បីធ្វើអាជីវកម្ម ។ នេះមានន័យថាបន្ទាប់ពីអ្នកនិពន្ធបានលក់ ឬផ្ទេរសិទ្ធិថតចម្លងមួយផ្នែណាមួយនៃស្នាដៃរបស់ខ្លួន ពេលនោះម្ចាស់សិទ្ធិដែលបានទិញនោះអាចយកស្នាដៃនោះទៅបោះចោល ឬលក់វាបន្តទៀត ។

តែទោះបីជាយ៉ាងណាក៏ដោយការជួលនេះ ច្បាប់សិទ្ធិអ្នកនិពន្ធរបស់ជាតិ ព្រមទាំងកិច្ចព្រមព្រៀង TRIPS បានទទួលស្គាល់មានការបែងចែកខុសគ្នានូវស្នាដៃកម្មវិធីកុំព្យូទ័រ ស្នាដៃហ្វូណូក្រាម សិទ្ធិជួលនេះត្រូវបានកំណត់ព្រោះបច្ចេកទេសអាចធ្វើបានយ៉ាងស្រួលដើម្បីថតចម្លង ។ បទពិសោធន៍ខ្លះក្នុងប្រទេសផ្សេងៗបានបង្ហាញឱ្យឃើញថា ការថតចម្លងត្រូវបានធ្វើឡើងដោយអតិថិជម្ចាស់ហាងនោះគឺជាសិទ្ធិដើម្បីគ្រប់គ្រង លើការជួល ឬការធានាសិទ្ធិនៃការផលិតឡើងវិញរបស់ម្ចាស់សិទ្ធិ ។ ជាចុងបញ្ចប់ ច្បាប់សិទ្ធិអ្នកនិពន្ធ រួមទាំងការគ្រប់គ្រងលើសិទ្ធិនាំចូលគឺត្រូវការពារនៅក្នុងដែនដី គឺជាផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ចនៃម្ចាស់សិទ្ធិ ។

មានការផលិតស្នាដៃឡើងវិញខ្លះៗដែលជាករណីលើកលែងនៃច្បាប់ទូទៅ ព្រោះគេមិនតម្រូវឲ្យមានការអនុញ្ញាតពីអ្នកនិពន្ធ ឬម្ចាស់សិទ្ធិឡើយ ទាំងនោះត្រូវបានទទួលស្គាល់ថាព្រំដែនកំណត់នៃសិទ្ធិ ។ ឧទាហរណ៍ ច្បាប់ជាតិជាច្រើនបានអនុញ្ញាតឱ្យបុគ្គលម្នាក់ធ្វើការថតចម្លងបានមួយច្បាប់សម្រាប់ប្រើប្រាស់ជាឯកជន មិនមែនក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ។ ការកើតឡើងនូវប្រព័ន្ធបច្ចេវិទ្យាឌីជីថលដែលមានលទ្ធភាពច្រើនក្នុងការថតចម្លងស្នាដៃដោយមានគុណភាពខ្ពស់ទាំងការថតចម្លងខុសច្បាប់ និងស្របច្បាប់ ។

## សិទ្ធិសម្ដែងជាសាធារណៈ សិទ្ធិចាក់ផ្សាយតាមទូរផ្សាយ និងផ្សព្វផ្សាយជាសាធារណៈ

ជាធម្មតាសិទ្ធិនេះស្ថិតនៅក្រោមច្បាប់ជាតិ ការសម្ដែងជាសាធារណៈ គឺជាការសម្ដែងស្នាដៃណាមួយនៅកន្លែងសាធារណៈ ឬនៅកន្លែងមិនមែនសាធារណៈ ប៉ុន្តែមិនមែនជាការសម្ដែង ក្នុងរង្វង់គ្រួសារ ។

មូលដ្ឋានចម្បងនៃសិទ្ធិសម្ដែងជាសាធារណៈ អ្នកនិពន្ធ ឬម្ចាស់សិទ្ធិអាចមាន សិទ្ធិអនុញ្ញាតឲ្យផ្សាយបន្តផ្ទាល់នៃការសម្ដែងស្នាដៃរបស់ខ្លួនពីកន្លែងសម្ដែង ឬតាមរោងល្ខោន ឬក្នុងសាលប្រគុំតន្ត្រី ។ ការសម្ដែងជាសាធារណៈគឺជាការសម្ដែងតាមគ្រប់មធ្យោបាយនៃការថតបញ្ចូលស្នាដៃតន្ត្រី ថតបញ្ចូលក្នុងហ្វូណូក្រាម ហើយយកទៅផ្សព្វផ្សាយជាសាធារណៈនៅក្នុងហាង បារ ឬយន្តហោះ ឬភោជនីយដ្ឋាន ។

សិទ្ធិចាក់ផ្សាយតាមទូរផ្សាយគឺគ្របដណ្ដប់លើការចាក់ផ្សាយទោះធ្វើតាមខ្សែលួស ដែលអាចទទួលបានសម្លេង រូបភាព និងសម្លេង តាមវិទ្យុ ទូរទស្សន៍ ឬផ្កាយរណប ។

នៅពេលស្នាដៃមួយត្រូវបានចាក់ផ្សព្វផ្សាយជាសាធារណៈ គឺសញ្ញាត្រូវបានបញ្ជូនផ្សាយតាមខ្សែលួស ឬតាមខ្សែកាបដែលអាចទទួលបានដោយមនុស្សម្នាក់ ហើយអាចទាក់ទងដល់ប្រព័ន្ធនេះ ។

យោងតាមសន្ធិសញ្ញា Berne Convention ម្ចាស់សិទ្ធិមានសិទ្ធិផ្ដាច់មុខក្នុងការអនុញ្ញាតិលើការសម្ដែងជាសាធារណៈ ការចាក់ផ្សាយតាមរយៈទូរផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈនៃស្នាដៃរបស់ពួកគេ ។ តាមច្បាប់ជាតិខ្លះ សិទ្ធិផ្ដាច់មុខរបស់អ្នកនិពន្ធ ឬម្ចាស់សិទ្ធិដ៏ទៃទៀតមានសិទ្ធិលើការចាក់ផ្សាយត្រូវបានគេធ្វើជំនួស ។ ក្នុងករណីខ្លះគាត់ អាចទទួលនូវប្រាក់ខ្លះពីស្នាដៃតាមរយៈការប្រមូលលាភការទោះបីជាមានការកំណត់ព្រំដែននៃសិទ្ធិក៏ដោយ ។

## សិទ្ធិក្នុងការបកប្រែ និងការកែសម្រួល

អំពើនៃការបកប្រែ ឬកែសម្រួលស្នាដៃមួយ ត្រូវសុំការអនុញ្ញាតពីម្ចាស់សិទ្ធិ ។ ការបកប្រែមានន័យថាការសម្ដែងចេញនូវស្នាដៃជាភាសាផ្សេងទៀត ក្រៅពីភាសាដើមនៃស្នាដៃ ។ ការកែសម្រួលគឺជាការកែប្រែលដើម្បីបង្កើតស្នាដៃមួយផ្សេងទៀត ឧទាហរណ៍ ការកែសម្រួលរឿងប្រលោមលោកទៅជាខ្សែភាពយន្ត ឬក៏ការកែសម្រួលស្នាដៃ១ផ្សេងទៀតទៅជាលក្ខខណ្ឌផ្សេង ។ ឧទាហរណ៍ការកែសម្រួលអត្ថបទសម្រាប់សិស្សវិទ្យាល័យ ទៅជាអត្ថបទសម្រាប់សិស្សកម្រិតទាបជាង ។

ការបកប្រែ និងការកែសម្រួលគឺជាស្នាដៃដែលត្រូវបានការពារដោយច្បាប់សិទ្ធិអ្នកនិពន្ធ ។ ទន្ទឹមនឹងការផលិតឡើងវិញ ការបោះផ្សាយនូវស្នាដៃបកប្រែ ឬការកែសម្រួលនោះ ត្រូវតែមានការអនុញ្ញាតពីម្ចាស់សិទ្ធិ ។ សិទ្ធិសេដ្ឋកិច្ចនៃប្រភេទសិទ្ធិដែលបានលើកខាងលើអាចត្រូវបានផ្ទេរ ឬប្រគល់ឲ្យអ្នកផ្សេងជាប្រាក់លក់ផ្ដាច់ ឬបង់តាមប្រភេទនៃការប្រើប្រាស់ស្នាដៃ ។ តែទោះបីជាយ៉ាងណាក៏

ដោយ ប្រភេទសិទ្ធិសីលធម៌មិនអាចផ្ទេរបានទេ គឺសិទ្ធិនេះស្ថិតនៅជាប់ជាមួយអ្នកនិពន្ធ ។

**តើអ្វីជាសិទ្ធិខាងសីលធម៌ ?**

សិទ្ធិដែលបានបញ្ជាក់ខាងលើគឺសិទ្ធិសេដ្ឋកិច្ច ។ សិទ្ធិខាងសីលធម៌ គឺជាសិទ្ធិផ្សេងពីនេះ រួមមានភ្ជាប់នូវ២ផ្នែក ។ ទី១គឺជាសិទ្ធិភាពជាអ្នកនិពន្ធ នោះគឺជាសិទ្ធិឋានៈជាអ្នកនិពន្ធនៅភ្ជាប់នឹងស្នាដៃដែលត្រូវបានគេទទួលស្គាល់ ជាមូលដ្ឋានជាសិទ្ធិដែលត្រូវគេទទួលស្គាល់ឈ្មោះ នៅពេលស្នាដៃនោះត្រូវបានបង្កើតឡើង ប្រសិនបើអ្នកបានសរសេរសៀវភៅមួយ ពេលនោះអ្នកមានសិទ្ធិតាមផ្លូវច្បាប់ដាក់ឈ្មោះឬមានឋានៈជាអ្នកនិពន្ធក្នុងសៀវភៅនោះ ។ ប៉ុន្តែយើងមិនសង្ឃឹមថា ការចាក់ផ្សាយឌីស disc នៅក្នុងឌីស្កូតែត គេអាចវាយឈ្មោះសមាសភាពគ្រប់ទាំងអស់បានទេ ដូចជាអ្នកនិពន្ធ អ្នករៀបចំ ។ល។ និង ។ល។ នេះមិនមែនមានន័យថាបំបាត់ឈ្មោះរបស់ពួកគេទេ តែប្រសិនបើអ្នកសម្តែងស្នាដៃណាមួយនៅក្នុងការប្រគុំតន្ត្រី ពេលនោះអ្នកនិពន្ធបទភ្លេងត្រូវបានគេប្រាប់ឈ្មោះនៅលើកម្មវិធី នោះជាការចាំបាច់ក្នុងការសម្តែងតន្ត្រីនោះ ជាគោលការណ៍យើងត្រូវតែប្រាប់ឈ្មោះអ្នកនិពន្ធ ។ ចំពោះការចាក់ផ្សាយតាមទូរផ្សាយ គឺមិនគ្រប់ពេលនោះទេ ការវាយលំអិតឈ្មោះណាមួយគឺអាស្រ័យលើច្បាប់របស់ជាតិ ។

សិទ្ធិសីលធម៌ គឺជាសិទ្ធិនៃការគោរពឈ្មោះ ជៀសវាងការបង្ខូច ឬបង្កព្យសនកម្មធ្វើឱ្យប៉ះពាល់ដល់កិត្តិយសអ្នកនិពន្ធ ។ ជាឧទាហរណ៍អ្នកនិពន្ធអាចជំទាស់ការប្រើប្រាស់ស្នាដៃរបស់គាត់នៅក្នុងអត្ថបទកាមសាស្ត្រ ប្រសិនបើស្នាដៃនោះមិនមែនជាស្នាដៃកាមសាស្ត្រទេ ហើយគាត់អាចជំទាស់រាល់ការធ្វើឲ្យប៉ះពាល់ដល់បូរណភាពនៃស្នាដៃរបស់គាត់ ។

<u>សំណួរវាយតម្លៃខ្លួនឯង</u>

ឧបមាថាអ្នកក្លាយជាវិចិត្រករដ៏ឆ្នើមម្នាក់ដែលត្រូវបានគេកោតសរសើរជាអន្តរជាតិនូវរូបគំនូររបស់អ្នកក្នុងការរួមចំណែកការអភិរក្សធម្មជាតិ បន្ទាប់មកអ្នកដឹងថាស្នាដៃនោះត្រូវបានគេយកមកប្រើដោយបង្អាប់ បន្ទោកតម្លៃក្នុងការដាក់បង្ហាញដោយគ្មានការអនុញ្ញាតិពីអ្នក តាមរយៈក្រុមនយោបាយមួយក្រុម តើអ្នកត្រូវធ្វើយ៉ាងម៉េច?

<u>ចម្លើយ</u>

ប្រសិនបើអ្នកនៅមានសិទ្ធិបេតិកភណ្ឌ អ្នកមានសិទ្ធិហាមការប្រើប្រាស់ ។ តែប្រសិនបើអ្នកបានផ្ទេរសិទ្ធិបេតិកភណ្ឌរួចហើយ អ្នកក៏នៅមានសិទ្ធិបញ្ឈប់ការប្រើប្រាស់នេះក្រោមសិទ្ធិសីលធម៌ ។

ឥឡូវនេះអ្នកគួរតែដឹងពីប្រភេទនៃស្នាដៃសិល្បៈ និងអក្សរសាស្ត្រដែលស្បិតនៅក្រោមច្បាប់សិទ្ធិអ្នកនិពន្ធ និងប្រភេទសិទ្ធិដែលម្ចាស់សិទ្ធិមាន ។ ហើយអ្នកអាច ឆ្លល់ថាតើអ្នកនិពន្ធនៃស្នាដៃមួយនេះមានសិទ្ធិអ្នកនិពន្ធយ៉ាងម៉េច ។

**តើអ្នកអាចប្រាប់យើងថាតើសិទ្ធិនេះមានលក្ខខណ្ឌយ៉ាងម៉េច?**

ជាសាមញ្ញ អ្នកមិនចាំបាច់មានសន្ធិសញ្ញា Berne Convention ចែងទេ ។ ជាគោលការណ៍ស្នាដៃរបស់អ្នកត្រូវបានការពារនៅពេលបង្កើតឡើង ដូចមានចែងក្នុងច្បាប់ជាតិ ទោះជាក្នុងប្រទេស Common Law ដែលបានចែងថា ស្នាដៃអាចទទួលបាននូវកិច្ចការពារទាល់តែបានថតបញ្ចូលក្នុងទម្រង់ណាមួយសិន ។

**តើមានន័យយ៉ាងម៉េចចំពោះពាក្យថាការថតបញ្ចូលក្នុងទម្រង់ណាមួយ?**

ការថតបញ្ចូលមានន័យថាអ្នកសសេរបទភ្លេង ហើយបានធ្វើការថតជាសម្លេង នោះត្រូវទទួលបាននូវកិច្ចការពារ ប្រសិនបើខ្ញុំប្រើបទភ្លេងនោះដើម្បីផលិតឡើងវិញដោយគ្មានការអនុញ្ញាត នោះជាការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ ។ ភាពខុសគ្នានៅទីនេះពិតជាមិនសំខាន់ទេ វាផ្អែកលើប្រភេទនៃភស្តុតាងដែលអ្នកត្រូវបង្ហាញនៅឯតុលាការ ។ សព្វថ្ងៃនេះអ្នកអាចថតបញ្ចូលនូវរបាំបាលេជាវិដេអូដើម្បីប្រើជាប្រភេទពិសេសក្នុងការបង្កើតស្នាដៃនាដសាស្ត្រ ប៉ុន្តែការធ្វើបែបនោះមិនត្រឹមត្រូវឡើយ ។ អ្នកអាចមានបញ្ហាប្រសិនបើអ្នកប្រកាសថាអ្នកបង្កើតឡើងនូវស្នាដៃរបាំបាលេ ហើយអ្នកផ្សេងបានធ្វើរបាំនោះដែរ ពេលនោះតុលាការអាចនិយាយថាសូមបង្ហាញភស្តុតាងនៃស្នាដៃនោះ ប្រសិនបើស្នាដៃនោះមិនបានសរសេរក្នុងទម្រង់ណាមួយនោះពិតជាពិបាកក្នុងការបង្ហាញភស្តុតាង ។ ក្នុងប្រទេស Civil Law ចែងថាស្នាដៃមួយត្រូវទទួលបាននូវកិច្ចការពារភ្លាមបន្ទាប់ពីបានបង្កើតឡើង ដូចនេះប្រសិនបើកំណាព្យមួយអ្នកបានសូត្រក្នុងចិត្ត ត្រូវបានការពារដែរ ។ នេះជាបញ្ហាក្នុងការបង្ហាញភស្តុតាងនូវកំណាព្យដែលអ្នកបានគិតនោះ តើអ្នកអាចធ្វើយ៉ាងម៉េច ។ ក្នុងប្រទេសCommon Law អ្នកត្រូវបញ្ចូលវាក្នុងទម្រង់មួយ ដូចជាសរសេរវា ឬថតវាបញ្ចូលក្នុងឌីស ។

**តើមានកន្លែងណាមួយនៅក្នុងពិភពលោកដែលអ្នកសង្កេតឃើញមានទម្រង់ណាមួយដែលទទួលបានសិទ្ធិអ្នកនិពន្ធ?**

ក្នុងប្រទេសដែលស្ថិតនៅក្រោម Berne Convention គ្រប់ម្ចាស់ស្នាដៃជាជនជាតិបរទេសឬអ្នកនិពន្ធនៃបណ្តាលប្រទេសជាសមាជិក Berne Convention ត្រូវបានការពារក្រោមអនុសញ្ញានេះដោយមិនមានទម្រង់ណាមួយឡើយ ដូច្នេះវាមិនចាំបាច់ឱ្យមានការចុះបញ្ជីឡើយ ។ នៅប្រទេសខ្លះគេបានដាក់បញ្ចូលជាបែបបទមួយទៅតាមជនជាតិរបស់ខ្លួនដែលពួកគេអាចធ្វើទៅតាមអនុសញ្ញាអន្តរជាតិ តាមរបៀបស្នាដៃជនបរទេស ។ ជាគោលការណ៍ប្រទេសមួយអាចដោះស្រាយតាមរបៀបច្បាប់ជាតិរបស់ខ្លួនបាន ។ ចំពោះសហរដ្ឋអាមេរិចវិញ មានប្រវត្តិតម្រូវឱ្យមានការចុះបញ្ជីស្នាដៃនៅក្នុងការិយាល័យសិទ្ធិអ្នកនិពន្ធ Copyright Office ហើយអាចប្រកាសអះអាងពីសិទ្ធិអ្នកនិពន្ធបាន មានន័យថារក្សាសិទ្ធិគឺមានអក្សរ©ដែលអ្នកអាចជួបនៅក្នុងសៀវភៅជាច្រើននៅពេលបោះពុម្ព ។

បញ្ហាទាំងនេះវាជាបញ្ហាសំខាន់ណាស់ចំពោះស្នាដៃជនជាតិអាមេរិក ដូច្នេះចំពោះស្នាដៃជនជាតិអាមេរិក ប្រទេសអាមេរិកមានការយកចិត្តទុកដាក់ពិសេស ជាបន្ថែមទៀតស្នាដៃបរទេសអាចការពារបានគឺមានចែងក្នុង Bern Convention ។ ដូចនេះចំពោះស្នាដៃខ្លះ ដែលចាត់ទុកថាមានលក្ខណៈពិសេសចំពោះទីផ្សារសហរដ្ឋអាមេរិចត្រូវតម្រូវឲ្យមានការចុះបញ្ជី បើមិនដូច្នេះទេវាមិនអាចទទួលបាននូវការពារទេ ។ ជាការពិតវាគ្មានចាំបាច់អ្វីធ្វើបែបនេះទេ បើយោងទៅតាមប្រទេសដែលជាសមាជិក Berne Convention ។

<u>សំនួរវាយតម្លៃខ្លួនឯង</u>

សំណួរ-ចូរគិតថាប្រទេសរបស់អ្នកគឺជាប្រទេសមួយក្នុងចំណោមប្រទេសដែលបានចុះហត្ថលេខា Berne Convention ហើយអ្នកបានបង្កើតស្នាដៃអក្សរសាស្ត្រមួយ តើជំហ៊ានអ្វីដែលត្រូវការពារស្នាដៃរបស់អ្នក?

<u>ចម្លើយ</u>

ក្នុងពាក្យទូទៅ វាងាយស្រួលណាស់ គ្មានអ្វីត្រូវធ្វើទេ អនុសញ្ញា Berne Convention មិនបានកំណត់ពីគំរូបែបបទទេ ស្នាដៃដែលបានបង្កើតឡើងត្រូវទទួលបាននូវការការពារទាំងអស់ ។

ក្នុងប្រទេសច្បាប់ Common Law ការដាក់បញ្ចូលក្នុងទម្រង់មួយគឺជាការចាំបាច់ ស្នាដៃមួយត្រូវបានសរសេរឡើង ឬថតបញ្ចូល ជាឧទាហរណ៍ ៖ របាំBallet ត្រូវតែសសេរឡើង ហើយត្រូវបានថតជាវីដេអូទៀតផង ។

នៅក្នុងប្រទេស Civil Law ស្នាដៃត្រូវបានទទួលកិច្ចការពារចាប់តាំងពីពេលបានបង្កើតឡើង ដែលពិបាកក្នុងការផ្តល់ភស្តុតាងចំពោះមុខតុលាការ ។ ទោះបីជាយ៉ាងនាក៏ដោយមានការកត់សម្គាល់ឃើញថាត្រូវមានបែបបទទៅតាមច្បាប់ជាតិដើម្បីទទួលបាននូវកិច្ចការពារក្នុងប្រទេសនោះ ។ ប្រទេសដែលជាសមាជិក Berne Convention រាល់ស្នាដៃជនបរទេសទាំងអស់ត្រូវទទួលបាននូវកិច្ចការពារដោយមិនចាំបាច់មានការចុះបញ្ជីទេ ។

**<u>ការផ្ទេរសិទ្ធិ</u>**

ស្នាដៃដែលបានបង្កើតឡើងជាច្រើនត្រូវទទួលបានការពារដោយការចំណាយទុនវិនិយោគ និងជំនាញពិសេសសម្រាប់ផលិតផលរបស់ពួកគេ និងការផ្សព្វផ្សាយ ។ ដូចជាការបោះពុម្ពសៀវភៅ ថតជាសម្លេង ឬផលិតជាខ្សែភាពយន្តដែលជាធម្មតាស្ថិតនៅក្រោមការធ្វើពាណិជ្ជកម្មពិសេស និងជាលក្ខណៈក្រុមហ៊ុន មិនមែនធ្វើឡើងដោយអ្នកនិពន្ធផ្ទាល់នោះទេ ។ ជាទូទៅអ្នកនិពន្ធ និងអ្នកបង្កើតស្នាដៃ ផ្ទេរសិទ្ធិទាំងនេះទៅឲ្យក្រុមហ៊ុនតាមរយៈកិច្ចព្រមព្រៀងក្នុងប្រាក់តម្លៃមួយ ។ ប្រាក់តម្លៃនេះអាចមានលក្ខណៈផ្សេងៗគ្នា ខ្លះជាប្រាក់លក់ផ្តាច់ ខ្លះទៀតអាចជាប្រាក់កំរៃបង់ទៅតាមភាគរយនៃប្រាក់ចំណូលពីការធ្វើអាជីវកម្មស្នាដៃនោះ ។

ការផ្ទេរសិទ្ធិអាចប៉ះពាល់ដល់សិទ្ធិបេតិកភណ្ឌ (សិទ្ធិសេដ្ឋកិច្ច)របស់ពួកគេ ។ ជាឧទាហរណ៍ អ្នកនិពន្ធស្នាដៃអត្ថបទប្រលោមលោកចាភាសាអង់គ្លេសម្នាក់អាចលក់ទៅឲ្យអ្នកបោះពុម្ពផ្សាយ និង ចែកផ្សាយ ព្រមទាំងសិទ្ធិបកប្រែ និងកែសម្រួលនូវស្នាដៃរបស់ខ្លួន ។ ប៉ុន្តែអ្នកនិពន្ធអាចជ្រើសរើសវិធី ផ្សេងទៀត ដោយសម្រេចផ្ទេរសិទ្ធិនេះទៅបុគ្គលផ្សេងៗពីគ្នា ។ ដូចនេះអ្នកនិពន្ធមានសិទ្ធិផ្ទេរសិទ្ធិក្នុង ការបោះពុម្ពក្នុងការផលិតឡើងវិញជាភាសាអង់គ្លេសទៅអ្នកបោះពុម្ពផ្សាយមួយ ហើយគាត់អាចផ្ទេរ សិទ្ធិបកប្រែជាភាសាបារាំង រូស្សី អារ៉ាប់ទៅអ្នកបោះពុម្ពផ្សេងទៀត ។ លើសពីនោះទៀតគាត់អាច ផ្ទេរសិទ្ធិក្នុងការបកប្រែ កែសម្រួលទៅអ្នកនិពន្ធផ្សេងទៀត ។

ការផ្ទេរសិទ្ធិនេះអាចធ្វើឡើងមានរយៈពេលកំណត់ ឬក្នុងរង្វង់ដែនកំណត់ ឬអាចធ្វើឡើងក្នុង រយៈពេលយូរ និងក្នុងពិភពលោក ។

ដូចនេះម្ចាស់សិទ្ធិអាចផ្ទេរសិទ្ធិទៅឲ្យអ្នកបោះពុម្ពផ្សាយ ជាអត្ថបទភាសាអង់គ្លេសមួយរយៈ ពេលកំណត់ជាក់លាក់ ជាឧទាហរណ៍ក្នុងសហរដ្ឋអាមេរិចមានរយៈពេល២០ឆ្នាំ ឬគាត់អាចសម្រេច ចិត្តផ្ទេរសិទ្ធិនេះក្នុងពិភពលោកក្នុងរយៈពេលសិទ្ធិអ្នកនិពន្ធ ។ ទាំងអស់នេះគឺអាស្រ័យលើការចរចារ រវាងភាគីទាំងពីរ ។

ដូចយើងបានឃើញថាការផ្ទេរសិទ្ធិជាកត្តាចម្បងរបស់អ្នកនិពន្ធ ។ ជាផ្លូវច្បាប់បុគ្គលដែលគេ ផ្ទេរសិទ្ធិនោះគឺជាអ្នកទទួលបានសិទ្ធិតាមរយៈកិច្ចសន្យា ហើយក្លាយជាម្ចាស់សិទ្ធិស្របច្បាប់ក្នុងមួយ រយៈពេលកំណត់ ។ ដូចនេះអ្នកនិពន្ធត្រូវយល់ដឹងពីកិច្ចការផ្ទេរសិទ្ធិនេះ ហើយនេះដោយសារតែច្បាប់ ជាតិចែងពីការផ្ទេរសិទ្ធិទាមទារឲ្យធ្វើឡើងជាលាយលក្ខណ៍អក្សរនិងមានចុះហត្ថលេខាពីអ្នកផ្ទេរសិទ្ធិ ដើម្បីឲ្យមានប្រសិទ្ធភាព ។ ការតម្រូវបែបនេះគឺក្នុងគោលបំណងធានាឲ្យអ្នកនិពន្ធយល់កាន់តែច្បាស់ អំពីសិទ្ធិដែលទាក់ទងនឹងប្រាក់កំរៃ និងលក្ខខណ្ឌអ្វីខ្លះ?

### តើសិទ្ធិអ្នកនិពន្ធអាចទទួលបានកិច្ចការពារបានរយៈពេលប៉ុន្មានឆ្នាំ?

ជាគោលការណ៍ រយៈពេលមានចែងនៅក្នុងច្បាប់ជាតិ ប៉ុន្តែយោងទៅតាម Berne convention រយៈពេលអប្បរមាដែលត្រូវការពារគឺ៥០ឆ្នាំ ក្រោយពីថ្ងៃដែលអ្នកនិពន្ធស្លាប់ អ្នកមិនចាំបាច់ដឹងថ្ងៃ អ្នកនិពន្ធស្លាប់ទេ គឺគ្រាន់តែដឹងឆ្នាំ ។ ប៉ុន្តែនាពេលថ្មីៗនេះគេមាននិន្នាការបន្ថែមរយៈពេលការពារយូរ ជាង៥០ឆ្នាំ ។ នៅក្នុងប្រទេសអឺរ៉ុប និងក្នុងតំបន់សេដ្ឋកិច្ចអឺរ៉ុប រយៈពេលការពារ៧០ឆ្នាំ ចាប់ពីថ្ងៃដែល អ្នកនិពន្ធស្លាប់ ហើយរយៈពេលនេះដូចគ្នាដែរ ចំពោះច្បាប់សហរដ្ឋអាមេរិក ដូចនេះវានៅចន្លោះពី ៥០ ទៅ ៧០ឆ្នាំ ។

ទោះបីជាយ៉ាងណាក៏មានការកត់សម្គាល់ឃើញថាមានករណីជាច្រើនដែលBerne Convention បានកំណត់រយៈពេលការពារអប្បរមា៥០ឆ្នាំ ។ ជាឧទាហរណ៍ ចំពោះស្នាដៃថតរូប រយៈពេលការពារ

អប្បរមា២៥ឆ្នាំបន្ទាប់ពីបានបង្កើតឡើង ។

សំណួរវាយតម្លៃដោយខ្លួនឯង

យោងទៅតាមBerne Convention តើរយៈពេលអប្បរមានៃកិច្ចការពារសិទ្ធិអ្នកនិពន្ធមានប៉ុន្មានឆ្នាំ ? តើវាមានការផ្លាស់ប្តូរតាំងពីពេលណាមក?

ចំលើយ

រយៈពេលអប្បរមានៃកិច្ចការពារ គឺ៥០ឆ្នាំ ចាប់ពីថ្ងៃអ្នកនិពន្ធស្លាប់ដោយ យោងទៅតាម Berne Convention ។ រយៈពេលការពារនេះអាចពន្យាពេលមក៧០ឆ្នាំ ចំពោះប្រទេសសហគមអឺរ៉ុប និង អាមេរិច ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏មានករណីខ្លះ កិច្ចការពារមមានរយៈពេលខ្លីជាងរយៈពេលដែលបានចែងក្នុងBerne Convention ។

ឥឡូវនេះដល់ពេលសួរអ្នកឲ្យពិចារណាអំពីព្រំដែននៃសិទ្ធិដែលមានចែងនៅក្នុងច្បាប់ជាតិ ។

**ព្រំដែននៃសិទ្ធិ**

ជាការពិតដែនកំណត់នៃសិទ្ធិគឺសិទ្ធិដែលបានលើកលែងពីកិច្ចការពារនៃប្រភេទស្នាដៃខ្លះ ។ ដូចអ្នកបានលឺនៅក្នុងប្រទេសខ្លះ ស្នាដៃដែលមិនត្រូវបានទទួលកិច្ចការពារ ប្រសិនបើគេមិនបានបញ្ចូលក្នុងទម្រង់ជារូបបិយ៍ណាមួយ ជាឧទាហរណ៍ ស្នាដៃនាដសាស្ត្រត្រូវបានការពារ នៅពេលដែលបានសរសេរឡើង ឬថតបញ្ចូលក្នុងឌីស ។ ជាងនោះទៅទៀត ក្នុងប្រទេស ខ្លះអត្ថបទច្បាប់ សាលក្រមតុលាការ ក៏មិនបានទទួលនូវកិច្ចការពារដែរ ។

ប្រភេទទី២នៃព្រំដែនកំណត់សិទ្ធិរបស់អ្នកនិពន្ធ និងម្ចាស់សិទ្ធិផ្សេងទៀតទាក់ទងជាមួយសកម្មភាពធ្វើអាជីវកម្ម ប៉ុន្តែក៏មានករណីមិនទាមទារឲ្យមានការអនុញ្ញាតពីម្ចាស់សិទ្ធិដោយយោងតាមបទបញ្ញត្តិពិសេសនៃច្បាប់ជាតិ ។ ករណីនេះមានពីរប្រភេទដូចខាងក្រោមៈ

១-ការប្រើប្រាស់ដោយសេរី ដើម្បីស្រាវជ្រាវ គឺមិនចាំបាច់សុំការអនុញ្ញាត ឬបង់ប្រាក់កម្រៃដល់ម្ចាស់សិទ្ធិឡើយ ។

២-ការអនុញ្ញាតដោយមិនស្មគ្រ័ចិត្ត ដើម្បីស្រាវជ្រាវ គឺធ្វើឡើងដោយមិនបាច់សុំការអនុញ្ញាត ប៉ុន្តែត្រូវបង់ប្រាក់កម្រៃជូនម្ចាស់សិទ្ធិ ។

ជាឧទាហរណ៍ៈ ការប្រើប្រាស់ដោយសេរីរួមមានការដកស្រង់ខ្លះៗចេញពីស្នាដៃដែលត្រូវបានការពារតែត្រូវបញ្ជាក់ប្រភេទ រួមទាំងឈ្មោះអ្នកនិពន្ធសម្រាប់ប្រើក្នុងគោលបំណងត្រឹមត្រូវ ។ ការប្រើប្រាស់សម្រាប់ការបង្រៀន ឬរាយការណ៍ ។ ទាក់ទងដល់ការផលិតឡើងវិញ អនុសញ្ញា Berne Convention មានចែងវិធានទូទៅមួយ ជាងការកំណត់ពីព្រំដែននៃសិទ្ធិត្រង់ មាត្រា៩(២) ចែងថា៖ រដ្ឋជាសមាជិកត្រូវផ្តល់ការផលិតឡើងវិញដោយសេរីក្នុងករណីខ្លះ នៅពេលដែលសកម្មភាពនេះមិន

បង្កព្យសនកម្មដល់ការធ្វើអាជីវកម្មជាធម្មតា ហើយត្រូវមានមូលហេតុត្រឹមត្រូវចំពោះអ្នកនិពន្ធ ។ ដូចបានបញ្ជាក់ខាងលើ ច្បាប់មួយចំនួនបានអនុញ្ញាតឱ្យផលិតឡើងវិញនូវស្នាដៃណាមួយជាលក្ខណៈបុគ្គលឯកជនមិនសម្រាប់ធ្វើអាជីវកម្ម ។ តែទោះបីជាយ៉ាងណាក៏ដោយការថតចម្លងសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ ប្រទេសខ្លះមានច្បាប់កំណត់អនុញ្ញាតអោយថតចម្លង តែត្រូវបង់ប្រាក់ឱ្យម្ចាស់សិទ្ធិដែលជាផលប្រយោជន៍សេដ្ឋកិច្ចដោយតម្លៃនេះបញ្ចូលទៅក្នុងថាស ឬហ្វូណូក្រាមសម្រាប់ការថតចម្លង ។

ជាបន្ថែមទៀត ច្បាប់ជាតិមានកំណត់ជាក់លាក់លើការប្រើប្រាស់ដោយត្រឹមត្រូវ ច្បាប់ប្រទេសផ្សេងទៀតទទួលស្គាល់ការប្រើប្រាស់ដោយត្រឹមត្រូវ ហើយអាចអោយប្រើប្រាស់ស្នាដៃគេបានដោយមិនចាំបាច់មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ តែត្រូវយកចិត្តទុកដាក់ទៅលើកត្តាដូចជាៈប្រភេទនិងគោលបំណងនៃការប្រើប្រាស់ រួមទាំងប្រភេទគោលបំណងពាណិជ្ជកម្ម ប្រភេទស្នាដៃទាំងមូលនិងលទ្ធផលនៃការប្រើប្រាស់ស្នាដៃ ។

ដូចដែលបានបញ្ជាក់ខាងលើការអនុញ្ញាតដោយមិនស្មគ្រ័ចិត្ត Non voluntary license អនុញ្ញាតអោយប្រើប្រាស់ស្នាដៃដោយមិនបាច់សុំការអនុញ្ញាតពីម្ចាស់សិទ្ធិ ប៉ុន្តែត្រូវអនុវត្តទៅតាមច្បាប់ ហើយបង់ប្រាក់កម្រៃខ្លះនៃការប្រើប្រាស់នោះ " នេះហៅថាការអនុញ្ញាតដោយមិនស្ម័គ្រចិត្ត " ព្រោះវាត្រូវអនុញ្ញាតតាមច្បាប់មិនមែនអនុញ្ញាតពីម្ចាស់សិទ្ធិទេ ។ ការអនុញ្ញាតដោយមិនស្ម័គ្រចិត្តនេះធ្វើឡើងក្នុងករណីបច្ចេកវិទ្យាថ្មី ដែលច្បាប់ជាតិមានការព្រួយបារម្ភពីការហាមប្រើប្រាស់ពីម្ចាស់សិទ្ធិ ក្នុងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីនោះ ។ នេះជាការពិតដែលត្រូវទទួលស្គាល់តាមរយៈអនុសញ្ញា Bern Convention មានពីរទម្រង់នៃការអនុញ្ញាតដោយមិនស្មគ្រចិត្ត ។ ទី១: ការអនុញ្ញាតឱ្យផលិតស្នាដៃតន្ត្រីឡើងវិញតាមរយៈម៉ាស៊ីន និងទី២: តាមរយៈទូរផ្សាយ ។

ទោះបីជាយ៉ាងណាក៏ដោយ គួរឲ្យកត់សម្គាល់ថាការអនុញ្ញាតិដោយមិនស្ម័គ្រចិត្តគឺត្រូវបានបង្កើនឡើងនូវសំណួរជាច្រើនដែលអាចធ្វើការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃរបស់អ្នកនិពន្ធ រួមទាំងទម្រង់អង្គភាពគ្រប់គ្រងសិទ្ធិរួម ។

ទោះបីជាស្ថានភាពបែបនេះនៅក្នុងប្រទេសរបស់អ្នកទាក់ទងនឹងសិទ្ធិអ្នកនិពន្ធក៏ដោយ ក៏ត្រូវមានការរំលោភបំពានសិទ្ធិអ្នកនិពន្ធ ដូចនេះវាជាការចាំបាច់ពិចារណាលើវិធានការជួសជុលសំណងខូចខាត ។

## ការអនុវត្តបទប្បញ្ញត្តិ

សន្ធិសញ្ញា Bern Convention រួមមានពីរមាត្រាដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនេះ ប៉ុន្តែវាមានការប្រែប្រួលទៅតាមច្បាប់ជាតិ និងអន្តរជាតិនាពេលថ្មីៗនេះដោយផ្អែកលើកត្តា២ចំបងគឺ ៖

កត្តាទី១-គឺដោយសារការរីកចំរើនផ្នែកបច្ចេកវិទ្យា ដើម្បីរួមចំណែកការពារ ( ទាំងការអនុញ្ញាត និងការមិនអនុញ្ញាតនៃសិទ្ធិ ) លើសម្ភារ:ជាពិសេសបច្ចេកវិទ្យាឌីជីតថលដែលអាចធ្វើឱ្យមានការថតចម្លងយ៉ាងរហ័ស និងបានល្អនៃពត៌មានទាំងឡាយដែលមានក្នុងទម្រង់ឌីជីថតរួមមានស្នាដៃត្រូវការពារគ្រប់ទីកន្លែងនៅក្នុងពិភពលោក ។ កត្តាទី២-ការកើនឡើងនូវសេដ្ឋកិច្ចដ៏សំខាន់នូវការបំលាស់ប្តូរទំនិញឬសេវាកម្មផ្សេងៗ ដែលត្រូវបានការពារដោយច្បាប់កម្មសិទ្ធិបញ្ញា ។ ជាធម្មតានៅក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ ផលិតផលពាណិជ្ជកម្មផ្នែកកម្មសិទ្ធិបញ្ញាបានផ្ទុះឡើងយ៉ាងខ្លាំងក្នុងពិភពលោក ។ កិច្ចព្រមព្រៀង TRIPSដែលនិយាយលំអិតពីការអនុវត្តច្បាប់ គឺជាសាក្ខីភាពនៃចរន្តថ្មីមួយនៃការទំនាក់ទំនងកម្មសិទ្ធិបញ្ញាជាមួយពាណិជ្ជកម្ម ។ ឃ្លាខាងក្រោមនេះសង្ខេបទៅលើបទបញ្ញត្តិនៃការអនុវត្តដែលគេជួបប្រទះ៖ នៅក្នុងបទបញ្ញត្តិជាតិនាពេលថ្មីៗដែលត្រូវបានចែកជាប្រភេទដូចជា: វិធានការបណ្តោះអាសន្ន សំណងរដ្ឋប្បវេណី ទណ្ឌកម្ម វិធានការតាមព្រំដែន និងវិធានការផ្សេងៗទៀត ព្រមទាំងទណ្ឌកម្ម ប្រឆាំងនឹងការរំលោភដោយឧបករណ៍បច្ចេកវិទ្យា ។

វិធានការបណ្តោះអាសន្ន:មានគោលបំណង២:ទី១-ការការពារការរំលោភបំពានដែលបានកើតឡើង ជាពិសេសការពារនូវការហូរចូលនៃទំនិញដែលបំពានតាមផ្លូវពាណិជ្ជកម្ម រួមទាំងច្រកចូលនៃការនាំចូល ទំនិញបន្ទាប់ពីឆ្លងកាត់រដ្ឋបាលគយ ។ ទី២-ការពាររាល់ភស្តុតាងទាំងឡាយដែលទាក់ទងដល់ការរំលោភបំពាន ។ ដូច្នេះតុលាការក្នុងប្រទេសខ្លះអាចចេញនូវវិធានការបណ្តោះអាសន្នឱ្យអនុវត្ត ដោយមិនជូនដំណឹងជាមុនដល់អ្នករំលោភបំពានសិទ្ធិ ។ ក្នុងវិធីនេះអ្នកប្រព្រឹត្តិល្មើសអាចត្រូវបានគេផ្អាក ឬឃាត់ទុកនូវសំភារ:ទាំងនោះ ។ វិធានការសាមញ្ញ សម្រាប់វិធានការបណ្តោះអាសន្នគឺការស្រាវជ្រាវរកអ្នកប្រព្រឹត្តិល្មើស ហើយរឹបអូស ឬឃាត់ទុកសំភារ:ដែលបានប្រើប្រាស់ក្នុងការផលិតនោះ និងរាល់ឯកសារទាំងអស់ដែលទាក់ទង ព្រមទាំងសកម្មភាពជំនួញដែលបានរំលោភបំពានសិទ្ធិ ។

សំណងរដ្ឋប្បវេណី: ការសងសំណងការខូចខាតទៅឱ្យម្ចាស់សិទ្ធិ ដោយសារតែការប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃការរំលោភបំពាននោះ ជាទូទៅគេគិតទៅលើការខូចខាតផ្នែកហិរញ្ញវត្ថុ និងការខូចខាតនៅពេលខាងមុខទៀត ។ ភាគច្រើនតុលាការបញ្ជាឱ្យបំផ្លាញចោលនូវទំនិញ និងសម្ភារ:ដែលប្រើក្នុងបំណងរំលោភបំពានសិទ្ធិ តុលាការចេញសាលក្រមឱ្យសងការរំលោភបំពាន

វិធានការតាមព្រំដែន: មានលក្ខណ:ខុសគ្នាពីវិធានការអនុវត្តដោយចាប់បង្ខំដូចបានពិពណ៌នាខាងលើក្នុងនោះគឺទាក់ទងដល់ស្ថាប័នគយជាងអំណាចតុលាការ ។ វិធានការតាម ព្រំដែនអនុញ្ញាតឱ្យម្ចាស់សិទ្ធិស្នើសុំស្ថាប័នគយដើម្បីផ្អាក ឬឃាត់ទុកទំនិញដែលសង្ស័យថាក្លែងបន្លំសិទ្ធិ ។ គោលបំណងនៃការផ្អាកនេះ គឺផ្តល់ឱ្យម្ចាស់សិទ្ធិនៅពេលវេលាសមរម្យ ដើម្បីធ្វើតាមនិតិវិធីតុលាការ តទល់ជាមួយអ្នកប្រព្រឹត្តិល្មើសឱ្យបានច្បាស់លាស់ទំនិញដែលបានរំលោភបំពាននោះ ។ ជាទូទៅម្ចាស់សិទ្ធិចចង់

បង្ហាញភស្តុតាងឱ្យបានច្បាស់ចំពោះមុខអាជ្ញាធរគេយថា ទំនិញនោះពិតជាមានការរំលោភបំពាន មិនត្រឹមតែប៉ុណ្ណោះត្រូវតែលំអិតពីទំនិញដើម្បីអាចឱ្យគេទទួលស្គាល់ ពិតជាមានការក្លែងបន្លំមែន និងត្រូវតែផ្តល់នូវការធានាសងជួសជុលដល់អ្នកនាំចូល ហើយគេយត្រូវតែបង្វិលទំនិញនោះទៅម្ចាស់ដើមវិញ នៅពេលដឹងថាមិនមែនជាការរំលោភបំពាន ។

ប្រភេទចុងក្រោយនៃការអនុវត្តច្បាប់ ដែលដែលសំខាន់បំផុតគឺប្រព័ន្ធឌីជីតថល រួមទាំងវិធានការផ្សេងៗទៀត ដូចជាជួលជុលសំណង និងទណ្ឌកម្ម ដែលបំពានដោយប្រើឧបករណ៍បច្ចេកវិទ្យា ។ ក្នុងករណីខ្លះ អន្តន័យនៃការប្រតិបត្តិនៃការការពារសិទ្ធិនេះ ត្រូវហៅថាការការពារការថតចម្លង ឬប្រព័ន្ធគ្រប់គ្រងការថតចម្លងដែលរួមមាន ទាំងឧបករណ៍បច្ចេកវិទ្យា ដែលនាំចូលដើម្បីធ្វើការថតចម្លង ឬសម្រាប់រារាំងក្នុងការថតចម្លង ។ ឧបករណ៍បច្ចេកវិទ្យាទាំងនេះដែលបានដាក់បញ្ចូលលេខកូដដើម្បីការពារការធ្វើពាណិជ្ជកម្ម ពីកម្មវិធីទូរទស្សន៍លើកលែងតែការប្រើដើម្បីកែលំអរបស់ម្ចាស់ តែទោះបីជាយ៉ាងណាក៏ដោយ ជាលក្ខណៈបច្ចេកវិទ្យា គេអាចផលិតឧបករណ៍ក្នុងការការពារការលួចថតចម្លង និងប្រព័ន្ធគ្រប់គ្រងការថតចម្លង ព្រមទាំងប្រព័ន្ធបញ្ចូលលេខកូដ ។ តាមទ្រឹស្តីបទប្បញ្ញត្តិស្តីពីការរំលោភបំពាន ឧបករណ៍ទាំងនោះ គឺការផលិត ការនាំចូល ការចែកផ្សាយ ត្រូវចាត់ទុកជាការរំលោភបំពានសិទ្ធិ ហើយត្រូវផ្តន្ទាទោសក្នុងកំរិតដូចគ្នា ។

<u>កិច្ចព្រមព្រៀងអន្តរជាតិដែលទាក់ទងច្បាប់សិទ្ធិអ្នកនិពន្ធ</u>

តើចំណុចសំខាន់នៃអនុសញ្ញា ឬសន្ធិសញ្ញាណាដែលគ្រប់គ្រងលើសិទ្ធិអ្នកនិពន្ធ?

សិទ្ធិដែលសំខាន់ជាងគេបំផុតមានចែងក្នុង Berne Convention សម្រាប់ការពារលើស្នាដៃអក្សរសាស្ត្រ និងសិល្បៈ ដែលបានធ្វើឡើងក្នុងឆ្នាំ១៨៨៦ ប៉ុន្តែត្រូវបានធ្វើការកែប្រែជាច្រើនលើក ហើយនៅលើកចុងក្រោយ គឺនៅប៉ារីសឆ្នាំ១៩១៧ ។

Bern Convention ទាក់ទងកិច្ចការពារសិទ្ធិអ្នកនិពន្ធ គឺផ្អែកលើគោលការណ៍ នៃសន្ធិសញ្ញាជាតិមានន័យថាស្ថិតនៅក្រោមច្បាប់ជាតិ ។ អ្នកមិនអាចរើសអាងចំពោះស្នាដៃណាមួយពីប្រទេសដែលជាភាគីអនុសញ្ញានេះឡើយ គឺមានរយៈពេលការពារ តាមស្តង់ដារជាអប្បរមាដែលមានចែងក្នុងច្បាប់ជាតិ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ជាតិអាចបន្ថែម ឬបង្កើតគោលការណ៍ផ្សេងៗទៀត ។

ពេលថ្មីៗនេះយើងមានកិច្ចព្រមព្រៀងទ្រីព TRIPS គឺជាកិច្ចព្រមព្រៀងលើវិស័យកម្មសិទ្ធិបញ្ញាដែលទាក់ទងដល់ពាណិជ្ជកម្ម វាជាកិច្ចព្រមព្រៀងមួយផ្តើមចេញពី កិច្ចព្រមព្រៀងអ៊ុយរ៉ាហ្គាយនៃការ

ចរចារពាណិជ្ជកម្ម ហើយស្ថិតនៅក្រោមការគ្រប់គ្រងពីអង្គការពាណិជ្ជកម្មពិភពលោក WTO ។

កិច្ចព្រមព្រៀង TRIPS មានបទបញ្ញត្តិផ្សេងៗជាច្រើន រួមមានអនុសញ្ញា Berne Convention ដែលមានទាក់ទងសិទ្ធិសីលធម៌ ដែលត្រូវគេចាត់ថាគ្មានការទំនាក់ទំនងខាងវិស័យពាណិជ្ជកម្ម ។ ក្នុង

គោលបំណងអនុវត្តតាម TRIPS Agreement ប្រទេសជាច្រើនត្រូវតែអនុវត្តតាម Berne Convention បន្ទាប់មកទៀតគឺអនុវត្តបន្តនូវកិច្ចការពារផ្សេងៗទៀតដែលមានចែងក្នុងកិច្ចព្រមព្រៀង TRIPS ។ សំខាន់គឺការបង្កើតឡើងនូវកម្មវិធីកុំព្យូទ័រ និងទន្នន័យ និងទម្រង់ផ្សេងៗទៀតនៃការធ្វើអាជីវកម្ម ។

ដូចនេះប្រទេសដែលឲ្យសច្ចាប័នលើកិច្ចព្រមព្រៀងទ្រីពត្រូវតែអនុវត្តតាមBerne Convention ជាពិសេសកិច្ចព្រមព្រៀងទ្រីពTRIPSចែងពីសិទ្ធិអ្នកនិពន្ធជាមួយបច្ចេកវិទ្យាថ្មី ។

តាមរយៈសន្និសីទការទូតដែលធ្វើឡើងនៅក្នុងខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីកិច្ចព្រមព្រៀងអន្តរជាតិដើម្បីការពារលើសិទ្ធិអ្នកនិពន្ធ ។ សន្ធិសញ្ញាសិទ្ធិអ្នកនិពន្ធនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក World Copyrights Traty (WCT) គឺការពារលើស្នាដៃដែលបញ្ជូនតាម Digital រួមទាំងតាម Internet ។ បញ្ហាដែលត្រូវការពារតាមច្បាប់សិទ្ធិអ្នកនិពន្ធ គឺសន្ធិសញ្ញា WCT ក្នុងនោះរួមមានកម្មវិធី Computer ទោះបីជាស្ថិតក្នុងគំរូ ឬទម្រង់បែបណាក៏ដោយ និងប្រព័ន្ធទិន្នន័យគ្រប់ទម្រង់តាមរយៈមធ្យោបាយនៃការជ្រើសរើស ឬរៀបចំនៃការបង្កើតដោយគំនិតបញ្ញា ។ សិទ្ធិរបស់អ្នកនិពន្ធដូចជាសិទ្ធិចែកផ្សាយជួលស្នាដៃ និងតែងតែបញ្ជាក់យ៉ាងច្បាស់ពីសិទ្ធិផ្សព្វផ្សាយជាសាធារណៈ វាគ្របដណ្តប់លើការបញ្ជូនស្នាដៃតាមរយៈឌីជីថល ឬតាមរយៈអ៊ីនធឺណិត ។ វាក៏បានបញ្ជាក់ផងដែលសិទ្ធិផលិតឡើងវិញដែលមានចែងក្នុងកិច្ចព្រមព្រៀង Berne Convention ដែលអនុវត្តយ៉ាងពេញលេញក្នុងបរិបទនៃឌីជីថល ។ ដូច្នេះការថតរក្សាទុកស្នាដៃមួយឌីជីថលជាទម្រង់អេឡិចត្រូនិចដូចជារក្សាទុកក្នុងMemory Computer ចាត់ទុកថាជាការផលិតឡើងវិញ ។ ជាធម្មតាសិទ្ធិទាំងនេះមានព្រំដែនកំណត់ និងមានករណីលើកលែងខ្លះ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

តើអ្វីខ្លះដែលស្ថិតនៅក្រោមសិទ្ធិសញ្ញា WCT ?

<u>ចម្លើយ</u>

សន្ធិសញ្ញា WCT ត្រូវបានគេរាប់បញ្ចូលដោយសារតែប្រទេសដែលជារដ្ឋហត្ថលេខី បានទទួលស្គាល់នូវដំណោះស្រាយកើងឡើងតាមរយៈសេដ្ឋកិច្ចថ្មី សង្គម វប្បធម៌ និងការអភិវឌ្ឍបច្ចេកវិទ្យា ។ នេះទាក់ទងលើកិច្ចការពារស្នាដៃអក្សរសាស្ត្រ សិល្បៈ ដែលបានបញ្ជូនតាមរយៈអ៊ីនធឺណិត ។ ស្នាដៃដែលបានកំណត់ក្នុងសន្ធិសញ្ញាWCT រួមមានកកម្មវិធី Computer និងទិន្នន័យ ។

សន្ធិសញ្ញាWCTបានបន្ថែមទំហំនៃកិច្ចការពារសិទ្ធិអ្នកនិពន្ធគឺការសម្តែងចេញមកក្រៅ គឺមិនការពារលើគំនិត នីតិវិធី របៀបប្រតិបត្តិ ឬទស្សនៈគណិតវិទ្យាទេ ។ តាមរយៈសន្ធិសញ្ញាWCTអ្នកនិពន្ធមានសិទ្ធិចែកចាយ ជួល និងផ្សព្វផ្សាយជាសាធារណៈ ។

**តើមានប្រយោជន៍អ្វីចំពោះប្រទេសកំពុងអភិវឌ្ឍពីកិច្ចការពារសិទ្ធិអ្នកនិពន្ធ?**

វាមានផលប្រយោជន៍ខាងវប្បធម៌ និងផលប្រយោជន៍ខាងសេដ្ឋកិច្ច ។ ជាការពិតយើងមិនអាចបំភ្លេចបានទេចំពោះសិទ្ធិអ្នកនិពន្ធគឺទាក់ទងជាមួយវប្បធម៌ ។ គ្រប់ប្រទេសកំពុងអភិវឌ្ឍទាំងអស់មានជាប់ទាក់ទងនឹងវិចិត្រករយ៉ាងខ្លាំង នៅលើពិភពលោកនេះគ្មានមនុស្សណាមិនបង្កើតស្នាដៃទេ ។ ប្រសិនបើគ្មានកិច្ចការពារសិទ្ធិអ្នកនិពន្ធទេ វិស័យសិល្បៈត្រូវបានគេលួច និងមិនអាចរកប្រាក់ចំណេញពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនឡើយ ។ បច្ចុប្បន្ននេះស្នាដៃអក្សរសាស្ត្រ សិល្បៈបានក្លាយទៅជាទស្សនៈដ៏ទូលាយរួមទាំងវិស័យវប្បធម៌ សហគមសិល្បៈ ប៉ុន្តែថែមទាំងព័ត៌មានឧស្សហាកម្មវប្បធម៌ ឬឧស្សាហកម្មនៃកម្មវិធីកុំព្យូទ័រ ។

ប្រាក់មួយចំនួនធំអាចត្រូវបានវិនិយោគលើកម្មវិធីកុំព្យូទ័រ ឬ ខ្សែភាពយន្ត ឬកម្មវិធីទូរទស្សន៍ ប៉ុន្តែនៅពេលស្នាដៃនេះបានបញ្ចេញលើទីផ្សារភ្លាម ម្នាក់បានថតចម្លងភ្លាម ពេលនោះនឹងបាត់បង់ចំណូលភ្លាម ជាហេតុធ្វើឲ្យបាក់ទឹកចិត្តដល់អ្នកបង្កើត ។ ដូចនេះការបង្កើតឡើងត្រូវអស់ទឹកចិត្តដោយការលួចក្លែងបន្លំ និងប៉ះពាល់ដល់វប្បធម៌ជាតិ ។ ការឆ្លើយតបចំពោះបញ្ហានេះគឺស្នាដៃក្នុងស្រុកត្រូវការពារ ហើយមិនចាំបាច់ការពារស្នាដៃបរទេសឡើយ ព្រោះប្រាក់ទាំងនោះត្រូវបញ្ចេញទៅបរទេស ។

ប៉ុន្តែនេះជាទស្សនៈមួយជ្រុង មានភស្តុតាងជាច្រើនដែលបង្ហាញពីផលប្រយោជន៍ក្នុងការចូលរួមការពារស្នាដៃបរទេស ។

ទី១-ប្រសិនបើកិច្ចការពារនោះធ្វើឡើងចំពោះតែស្នាដៃក្នុងស្រុក ពេលនោះស្នាដៃបរទេសត្រូវបាន អនុញ្ញាតឲ្យចូលក្នុងទីផ្សារក្នុងស្រុកដោយមិនចាំបាច់មានកិច្ចការពារសិទ្ធិអ្នកនិពន្ធ ។ ស្នាដៃទាំងនោះ ត្រូវលក់ក្នុងតម្លៃថោក ហើយអតិថិជនអាចទទួលផលប្រយោជន៍ពីតម្លៃថោកនោះ ។ ប៉ុន្តែការអនុវត្តបែបនេះ ធ្វើឲ្យប៉ះពាល់ដល់ផលិតផលក្នុងស្រុក ដែលប្រកួតប្រជែងជាមួយស្នាដៃបរទេសក្នុងតម្លៃពិសេសមួយ ។ លទ្ធផលគ្រោះថ្នាក់គឺអតិថិជនបែរទៅទិញស្នាដៃបរទេសដែលមានតម្លៃថោក ពេលនោះទាំងវិស័យវប្បធម៌ជាតិ តន្ត្រី ឧស្សាហកម្មត្រូវទទួលរងការវិនាស ។

ទី២-មិនអាចជួយការពារឲ្យបានខ្លាំងចំពោះស្នាដៃរបស់សិល្បករ អ្នកបង្កើតនៅក្នុងស្រុកនៅឯបរទេស ។ ទីផ្សារនៅក្នុងស្រុកមានព្រំដែនកំណត់ គឺត្រូវការប្រាក់ចំណូលនៃផលិតផលវប្បធម៌នោះពីការនាំចេញទៅទីផ្សារខាងក្រៅ ។ បច្ចុប្បន្ននេះមធ្យោបាយទំនើបនៃទំនាក់ទំនង ស្នាដៃត្រូវបានគេស្តាប់ អាន ទស្សនាមិនត្រឹមតែសហគម ក្នុងប្រទេសប៉ុណ្ណោះទេ ថែមទាំងបរទេសទៀតផងនូវស្នាដៃដែលគេបាន បង្កើតឡើង ។ កាន់តែច្រើនទៅៗប្រាក់ចំណូលពីការធ្វើអាជីវកម្មស្នាដៃនៅក្រៅប្រទេសជាងការធ្វើអាជីវកម្មស្នាដៃនោក្នុងប្រទេសដូចជាផ្នែកតន្ត្រី កម្មវិធីទូរទស្សន៍ កម្មវិធីSoftware ខ្សែភាពយន្ត សៀវភៅ ។ ល ។ កិច្ចការពារនៅបរទេស នៅទីផ្សារក្រៅប្រទេសគឺជាកត្តាសំខាន់បំផុតសម្រាប់អ្នកនិពន្ធ និងអ្នកបង្កើត ។

## សង្ខេប

ជំពូកនេះបង្ហាញពីរចនាសម្ព័ន្ធទូទៅនៃច្បាប់សិទ្ធិអ្នកនិពន្ធ និងផ្តល់នូវទស្សនៈ ជាច្រើនៈ

១-កិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈតាមរយៈច្បាប់សិទ្ធិអ្នកនិពន្ធ

២-សិទ្ធិដែលបានប្រគល់ជូនម្ចាស់សិទ្ធិអ្នកនិពន្ធ

៣-ភាពជាម្ចាស់សិទ្ធិ និងការផ្ទេរសិទ្ធិ និង

៤-រយៈពេលការពារសិទ្ធិ

៥-ព្រំដែននៃសិទ្ធិ

៦-ការអនុវត្តច្បាប់

៧-កិច្ចព្រមព្រៀងអន្តរជាតិដែលទាក់ទងសិទ្ធិអ្នកនិពន្ធ

សន្ធិសញ្ញា Berne Convention បានធ្វើបញ្ជីស្នាដៃសិល្បៈ និង អក្សរសាស្ត្រ ដើម្បីឲ្យផលិតផលទាំងអស់ជាស្នាដៃអក្សរសាស្ត្រ វិទ្យាសាស្ត្រ និងសិល្បៈ ដែលស្ថិតក្នុងទម្រង់នៃការសម្តែងចេញត្រូវបានគ្របដណ្តប់ទាំងអស់ ។

ម្ចាស់ស្នាដៃអាចប្រើប្រាស់ស្នាដៃរបស់ខ្លួនតាមបំណងប្រាថ្នា ហើយអាចការពារមិនឱ្យអ្នកផ្សេងប្រើប្រាស់ដោយគ្មានការអនុញ្ញាតិពីខ្លួន ។ ដូចនេះម្ចាស់សិទ្ធិមានសិទ្ធិប្រឆាំងជាមួយសកម្មភាពផ្សេងទៀតដើម្បីការពារប្រយោជន៍របស់ខ្លួន សិទ្ធិនេះហៅថាសិទ្ធិផ្តាច់មុខ ។ មានសិទ្ធិ២ដែលមានចែងនៅក្នុងច្បាប់សិទ្ធិអ្នកនិពន្ធគឺសិទ្ធិបេតិកភណ្ឌ និងសិទ្ធិសីលធម៌ ។ នៅក្រោមសិទ្ធិសេដ្ឋកិច្ច គឺជាសិទ្ធិដែលអាចលក់បាន ផ្ទេរសិទ្ធិបាន អាចរកប្រាក់ចំណូល ប៉ុន្តែមានកំណត់ពីព្រំដែននៃសិទ្ធិ ដោយឡែកសិទ្ធិសីលធម៌ តែងតែមាននៅជាប់ជាមួយម្ចាស់សិទ្ធិ ទោះបីជាសិទ្ធិបេតិកភណ្ឌនោះត្រូវបានផ្ទេរទៅឱ្យអ្នកផ្សេងក៏ដោយ ។

បន្ថែមលើប្រភេទស្នាដៃដែលបានបង្ហាញខាងលើស្នាដៃប្រភេទថ្មីមួយទៀត ស្ថិតនៅក្រោមច្បាប់សិទ្ធិអ្នកនិពន្ធ គឺជាផលិតផល ចំរុះ ទោះបីជាគ្មាននិយមន័យត្រឹមត្រូវតាមច្បាប់ក៏ដោយ ក៏ការបញ្ចូលគ្នានៃសម្លេង អត្ថបទ និងរូបភាពក្នុងឌីជីតថល គឺធ្វើឡើងតាមរយៈកុំព្យូទ័រត្រូវចាត់ទុកជាស្នាដៃដើមរបស់អ្នកនិពន្ធហើយស្ថិតនៅក្រោមច្បាប់សិទ្ធិអ្នកនិពន្ធ។

# ជំពូកទី៣
# សិទ្ធិប្រហាក់ប្រហែល

**វត្ថុបំណង:**

បន្ទាប់ពីបានសិក្សាផ្នែកនេះ អ្នកនឹងអាចៈ

១-ធ្វើបញ្ជីអ្នកទទួលផលប្រយោជន៍ពីសិទ្ធិប្រហាក់ប្រហែល

២-បង្ហាញរយៈពេលនៃសិទ្ធិប្រហាក់ប្រហែល ដូចដែលបានកំណត់នៅក្នុងRome Convention និងកិច្ចព្រមព្រៀងទ្រីព TRIPS

៣-អាចពន្យល់បានចំនួន២៥០ពាក្យពីទស្សនៈនៃសិទ្ធិប្រហាក់ប្រហែលនិង អាចឈានទៅដល់ការយល់ដឹងពីស្នាដៃប្រពៃណី ។

## សេចក្តីផ្តើម

សិទ្ធិប្រហាក់ប្រហែលជាសិទ្ធិមួយដែលជាប់ទាក់ទងសិទ្ធិអ្នកនិពន្ធ ។ គោលបំណងនៃសិទ្ធិប្រហាក់ប្រហែល គឺដើម្បីការពារផលប្រយោជន៍របស់បុគ្គលខ្លះ និងក្រុមហ៊ុនដែលបានរួមចំណែកក្នុងការបង្កើតស្នាដៃឱ្យបានច្រើនជូនសាធារណជន ។ ដូចជាអ្នកចម្រៀង តន្ត្រីករដែលបានសម្តែងជាសាធារណៈ ។ គោលបំណងពិសេសនៃសិទ្ធិប្រហាក់ប្រហែលគឺការពារឱ្យមនុស្សទាំងអស់នោះ ឬក្រុមហ៊ុនទាំងនោះដែលបានបង្កើតស្នាដៃបច្ចេកទេស ឬ ជំនាញផ្សេងៗក្នុងការបញ្ចេញស្នាដៃជាសាធារណៈ ។

ជំពូកនេះនឹងពន្យល់ពីប្រភេទផ្សេងៗនៃសិទ្ធិប្រហាក់ប្រហែល តើពួកគេទទួលបានសិទ្ធិអ្វីខ្លះ រយៈពេលការពារ និងសិន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិសំខាន់ៗ ដែលពាក់ព័ន្ធជាមួយសិទ្ធិប្រហាក់ប្រហែល ។

## សិទ្ធិប្រហាក់ប្រហែល

បញ្ហាដំបូងដែលត្រូវនិយាយគឺថា សិទ្ធិប្រហាក់ប្រហែលជាពាក្យស័ព្ទថ្មី និងឯកសារមួយចំនួនទាក់ទងដល់សិទ្ធិដូចគ្នានេះ ស្ថិតនៅក្រោមច្បាប់សិទ្ធិប្រហាក់ប្រហែល ។ ជំពូកនេះ នឹងប្រើប្រាស់បានត្រឹមត្រូវនូវពាក្យស័ព្ទសិទ្ធិប្រហាក់ប្រហែល ។

### តើអ្នកអាចកំណត់អត្ថន័យសិទ្ធិប្រហាក់ប្រហែលនេះបានទេ?

សិទ្ធិប្រហាក់ប្រហែលខុសពីសិទ្ធិអ្នកនិពន្ធ ប៉ុន្តែវាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតជាមួយគ្នា

វាជាស្នាដៃដែលត្រូវបានការពារដោយសិទ្ធិអ្នកនិពន្ធ ។ ដូច្នេះសិទ្ធិទាំងពីរ នេះជាទូទៅត្រូវជាប់ទាក់ទងគ្នា ហើយទទួលបាននូវប្រភេទសិទ្ធិផ្តាច់មុខដូចសិទ្ធិអ្នកនិពន្ធដែរ ប៉ុន្តែវាមិនគ្របដណ្តប់លើស្នាដៃជាក់ស្តែងទេ វាគ្របដណ្តប់លើបញ្ហាផ្សេងៗដែលទាក់ទងនឹងស្នាដៃមួយឈានទៅធ្វើការផ្សព្វផ្សាយជាសាធារណៈ ។ ជាឧទាហរណ៍ ចម្រៀងមួយបទដែលត្រូវទទួលកិច្ចការពារតាមច្បាប់សិទ្ធិអ្នកនិពន្ធដែលត្រូវមានច្រើនដំណាក់កាល ។

ឧបមាថា យើងមានចម្រៀងដើមមួយបទ ជាការពិតត្រូវការការពារអ្នកសសេរបទភ្លេង និងអ្នកសរសេរទំនុបភ្លេងដែលជាម្ចាស់សិទ្ធិអ្នកនិពន្ធដើម ពួកគេគឺជាអ្នកផ្តល់ឱ្យអ្នកចម្រៀងច្រៀង ឬសម្តែងនេះជាស្នាដៃមួយស្ថិតក្នុងទម្រង់ការពារ ប្រសិនបើត្រូវបានថតបញ្ចូលក្នុងឌីស ឬផ្សព្វផ្សាយតាមទូរផ្សាយ សកម្មភាពទាំងនោះជាប់ទាក់ទងជាមួយក្រុមហ៊ុនផ្សេងៗ ត្រូវតែទទួលបានកិច្ចការពារមុនចូលទៅក្នុងកិច្ចព្រមព្រៀងណាមួយ ។ ដំបូងសិទ្ធិប្រហាក់ប្រហែលទាំងនេះ បន្ទាប់មកសិទ្ធិអ្នកសម្តែងឈ្មោះអ្នកសម្តែង អ្នកច្រៀង អ្នករបាំ អ្នកភ្លេង និងអ្នកផ្សេងៗទៀត ។

បន្ទាប់មកមានក្រុមទី២ គឺផលិតករហ្វូណូក្រាម ជាពិសេសផលិតករថតសម្លេង ថតរូបភាពព្រមទាំងអ្នកបានថតបញ្ចូលក្នុងឧបករណ៍ផ្សេងៗទៅក្នុងCD និងឌីជីថល ។ នេះគឺជាប្រភេទការពារពាណិជ្ជកម្មថែមទៀត ដូចជាការធ្វើឱ្យគុណភាពការថតសម្លេងកាន់តែប្រសើរ ដើម្បីការពារវិនិយោគជាជាងការពាក់ព័ន្ធផ្នែកសិល្បៈ ដូចជាការសរសេរ ឬការផលិតចម្រៀងជាដើម ។ បើមិនអញ្ជឹងទេនៅក្នុងដំណើរការទាំងស្រុងនៃការជ្រើសរើសឧបករណ៍ជំនួយ បញ្ជីចម្រៀង ឬល្ខោន ការសំរួលតន្ត្រីនិងផ្នែកផ្សេងៗទៀត វាមានដំណាក់កាលបង្កើត ព្រមទាំងដំណាក់កាលសេដ្ឋកិច្ចសំខាន់ៗខ្លះទៀត ។ យើងគួរចងចាំថាផលិតករទាំងនោះ គឺស្ថិតក្នុងចំណោមជនរងគ្រោះនៃការលួចចម្លង ខណៈដែលពួកគេមិនបានទទួលលុយ តែបែរជាអ្នកលួចចម្លងទទួលផលចំណេញទៅវិញ ពេលនោះអ្នកសម្តែងអ្នកនិពន្ធ ត្រូវខាតបង់ ផ្នែកហិរញ្ញរបស់គេ នេះជាមូលហេតុដែលតំរូវឱ្យផលិតករទទួលបានសិទ្ធិ ។

ក្រុមទី៣ អ្នកទទួលបាននូវកិច្ចការពារសិទ្ធិប្រហាក់ប្រហែល គឺស្ថានីយទូរផ្សាយ ។ សិទ្ធិរបស់ពួកគេកើតចេញពីការបង្កើតស្នាដៃរបស់ពួកគេដើម្បីផ្សព្វផ្សាយ មិនត្រឹមតែជាមាតិកានៃការផ្សព្វផ្សាយភាពយន្តប៉ុណ្ណោះទេថែមទាំងសកម្មភាពនៃការចាក់ផ្សាយ ។ ជាងនោះទៅទៀត ពួកគេមានសមត្ថភាពដើម្បីបញ្ជូនសញ្ញាផ្សព្វផ្សាយ ហើយទទួលបាននូវកិច្ចការពារសិទ្ធិ នៃសញ្ញាបញ្ជូនទាំងនោះ ។ ជាថ្មីម្តងទៀត ក្នុងការវិនិយោគពួកគេខំប្រឹងប្រែងរួមគ្នាដើម្បីបញ្ចូលក្នុងកម្មវិធីផ្សេងៗដែលទាក់ទង ។

ការបញ្ជាក់ខាងលើនេះគឺបង្ហាញថាសិទ្ធិប្រហាក់ប្រហែលមិនដូចសិទ្ធិអ្នកនិពន្ធឡើយ ប៉ុន្តែវាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និតបំផុតគឺស្នាដៃនោះត្រូវបានការពារតាមរយៈច្បាប់សិទ្ធិអ្នកនិពន្ធ ។

ជួនកាលសិទ្ធិប្រហាក់ប្រហែលទាក់ទងជាមួយស្នាដៃផ្សេងៗ ដែលមិនត្រូវការការពារដោយសិទ្ធិអ្នកនិពន្ធ ។ ដូចជាស្នាដៃស្ថិតនៅក្នុងវិស័យសាធារណៈ ជាឧទាហរណ៍ស្នាដៃPanio របស់លោក

Beethovenគេអាចយកទៅសម្តែង ឬថតឡើងវិញជាCDដោយសារតែគាត់បានស្លាប់តាំងពីឆ្នាំ១៨២៧ ស្នាដៃទាំងអស់របស់គាត់ត្រូវចាត់ទុកជាប្រយោជន៍សាធារណៈ គឺមិនមានកិច្ចការពារឡើយ ហេតុនេះនរណាម្នាក់ក៏អាចមានសិទ្ធិប្រើប្រាស់ដោយសេរីដោយពុំចាំបាច់សុំការឯនុញ្ញាតោឡើយ ។

ទោះបីជាយ៉ាងណាក៏ដោយក្នុងឧទាហរណ៍ខាងលើអ្នកសម្តែង និងផលិតករហ្វូណូក្រាមដែលបានថតការប្រគុំតន្ត្រីនោះនឹងទទួលបានសិទ្ធិប្រហាក់ប្រហែល ។ ទន្ទឹមនឹងនោះមានឧទាហរណ៍ខាងក្រោមគ្មាននរណាអាចថតការសម្តែងផ្ទាល់នោះដោយមិនមានការយល់ព្រមពីអ្នកសម្តែងឡើយ ព្រមទាំងគ្មាននរណាម្នាក់មានសិទ្ធិថតចម្លងឡើងវិញនូវឌីសនៃការសម្តែងនោះដោយមិនមានការយល់ព្រមពីផលិតករហ្វូណូក្រាមឡើយ ។

ជាការកត់សម្គាល់ថា:ផលិតករហ្វូណូក្រាមមានសិទ្ធិការពារនូវស្នាដៃដែលបានថតនោះទោះជាសម្លេងនោះជាសម្លេងពីធម្មជាតិ សម្លេងសត្វយំ សម្លេងរលកសមុទ្រ សម្លេងទាំងនេះមិនមែនជាស្នាដៃដែលបានបង្កើតឡើងទេ ។

<u>សំណួរវាយតំលៃខ្លួនឯង</u>

តើក្រុមមនុស្សបីប្រភេទណាដែលបានបង្ហាញខាងលើ មានសិទ្ធិប្រហាក់ប្រហែល?

<u>ចម្លើយ</u>

ក្រុមមនុស្សបីប្រភេទដែលបានបង្ហាញខាងលើគឺ:

-អ្នកសម្តែង ដូចជាអ្នកច្រៀងចម្រៀង

-ផលិតករហ្វូណូក្រាមដូចជាក្រុមហ៊ុនថតបញ្ចូលហ្វូណូក្រាម

-អង្គភាពទូរផ្សាយ

ដូចដែលបានពន្យល់ពីសិទ្ធិប្រហាក់ប្រហែលរួចមកហើយ សិទ្ធិនេះបានផ្តល់ អត្ថប្រយោជន៍ដល់ក្រុមបីគឺ: អ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ។

សិទ្ធិអ្នកសម្តែងត្រូវបានគេទទួលស្គាល់ពីព្រោះការបង្កើតឡើងរបស់ពួកគេ ជាការសំខាន់ដើម្បីផ្តល់ជីវិតថ្មី ជាឧទាហរណ៍ កិច្ចការតន្ត្រី ល្ខោន និងនាដកម្ម ព្រមទាំងភាពយន្ត ព្រោះពួកគេទទួលបាននូវកិច្ច ការពារស្របច្បាប់ក្នុងការបកប្រែផ្ទាល់ខ្លួន ។



សិទ្ធិផលិតករហ្វូណូក្រាមត្រូវបានទទួលស្គាល់ព្រោះការបង្កើតស្នាដៃរបស់ពួកគេ ដោយមាន ផ្នែកហិរញ្ញវត្ថុ និងប្រភពធនធានរបស់ពួកគេ គឺជាកត្តាសំខាន់ដើម្បីថត បញ្ចូលសម្លេងដែលអាចផ្សព្វផ្សាយជាសាធារណៈ ក្នុងទម្រង់ហ្វូណូក្រាម ផ្នែកពាណិជ្ជកម្ម (ឧទាហរណ៍ ហ្វូណូក្រាម កាសែ្សត ស៊ីឌី មីនីឌីស ...។ល។)

ពួកគេអាចទទួលបាននូវកិច្ចការពារស្របច្បាប់ដែរ ក្នុងការប្រឆាំង

ការប្រើប្រាស់ស្នាដៃ ដោយគ្មានការអនុញ្ញាត ទាំងការផលិត និងការចែក ផ្សាយនូវរបស់ចម្លង ឬក្នុងទម្រង់នៃការផ្សព្វផ្សាយទូរផ្សាយ ឬការផ្សព្វ ផ្សាយជាសាធារណៈនៃហ្វូណូក្រាមរបស់ពួកគេ ដោយគ្មានការអនុញ្ញាត ។

ដូចគ្នាដែរសិទ្ធិអង្គភាពទូរផ្សាយត្រូវបានទទួលស្គាល់ ពីព្រោះតួនាទីរបស់ពួកគេអាចបង្កើត ស្នាដៃដើម្បីផ្សព្វផ្សាយ ហើយទទួលបាននូវសិទ្ធិក្នុងការត្រួតពិនិត្យការបញ្ជូន និងការបញ្ជូនត្រលប់មកវិញ តាមរយៈទូរផ្សាយរបស់ពួកគេ ។

## សិទ្ធិប្រហាក់ប្រហែលសម្រាប់អង្គភាពទូរផ្សាយនូវព្រឹត្តិការណ៍កីឡា

សិទ្ធិរបស់អង្គភាពទូរផ្សាយមានសារសំខាន់ណាស់ក្នុងកម្មវិធីកីឡា។ នៅក្នុងប្រទេសជាច្រើន កម្មវិធីកីឡាមិនចាត់ទុកថាទទួលបានសិទ្ធិអ្នកនិពន្ធ ទេ ។ មានប្រទេសមួយចំនួន និងសហរដ្ឋអាមេរិក ជាឧទាហរណ៍ដំបូងដែល គិតថាការប្រកួតបាល់ទាត់គឺជាស្នាដៃសោតទស្សន៍ ប៉ុន្តែក្នុងប្រទេសដ៏ទៃទៀត ច្បាប់បានចែងថាល្បែងមិនមែនជាការបង្កើតស្នាដៃ ហើយមិនទទួល បាននូវកិច្ចការពារទេ ។ ជាងថតបានតាមថតសកម្មភាពនៃព្រឹត្តិការណ៍ និងព្រឹត្តិការណ៍ចៃដន្យផ្សេងៗ គាត់ជាអ្នកប៉ិនប្រសព្វជំនាញថតរូប ប៉ុន្តែគាត់មិនមែនជាអ្នកសិល្បៈទេ ។ ពេលនោះប្រាកដ ជាមានការចាក់ផ្សាយដ៏តិចតួចណាស់ ប្រសិនបើមានការការពារបែបនេះ ។

នៅពេលនោះសិទ្ធិរបស់ទូរទស្សន៍នឹងទទួលបានផលប្រយោជន៍ច្រើនពីល្បែងកីឡាអូឡាំពិច នោះលុយរាប់ម៉ឺន ឬរាប់លានដុល្លារអាចផ្លាស់ពីមួយទៅមួយទៀត សម្រាប់ចាក់ផ្សាយកីឡាអូឡាំពិចបែបនេះ ។

ប៉ុន្តែបើមិនការពារ វាមិនអាចទាក់ទាញវិនិយោគបាន ព្រោះពួកគេចំណាយទឹកប្រាក់ដ៏ច្រើន សម្រាប់អាជ្ញាប័ណ្ណផ្តាច់មុខ ដើម្បីទទួលបាននូវការផ្សាយទាំងស្រុងនូវ ព្រឹត្តិការណ៍កីឡាសំខាន់ៗ និងទប់ស្កាត់ក្រុមហ៊ុនដ៏ទៃ ក្នុងការថត ឬថតឡើងវិញដើម្បីផ្សព្វផ្សាយកម្មវិធីនេះ ។

ឧទាហរណ៍ខ្លីនេះបញ្ជាក់ឱ្យដឹងថាតើហេតុអ្វីបានជាប្រភេទក្រុមទាំងនេះ អ្នកសម្តែង ផលិតករហ្វូណូក្រាម និង អង្គភាពទូរផ្សាយ ត្រូវទទួលបានសិទ្ធិប្រហាក់ប្រហែល ។

ការឆ្លើយតបជាអន្តរជាតិដែលចាំបាច់ការពារស្របច្បាប់ នូវប្រយោជន៍ដល់ក្រុមសិទ្ធិប្រហាក់ប្រហែលទាំងបីនេះ គឺយោងទៅតាមអនុសញ្ញាទីក្រុងរ៉ូម Rome Convention ឆ្នាំ១៩៦១ ឬអនុសញ្ញាអន្តរជាតិសម្រាប់ការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ មិនដូចអនុសញ្ញាអន្តរជាតិផ្សេងទៀតដែលមានពីមុន ។ អនុសញ្ញាក្រុងរ៉ូមមានបំណងរួមចំណែកបង្កើតនូវបទប្បញ្ញត្តិអន្តរជាតិនាពេលថ្មីៗនេះ ។ នេះមានន័យថារដ្ឋភាគីច្រើនត្រូវតែព្រាង និងអនុម័តច្បាប់ទាំងឡាយតាមអនុសញ្ញានេះ ។

ចាប់តាំងពីមានការកែសម្រួលអនុសញ្ញាឆ្នាំ១៩៦១មក ប្រទេសមួយចំនួនធំ បានធ្វើបទប្បញ្ញត្តិតាមអនុសញ្ញានេះ ហើយច្បាប់ជាច្រើនមានចែងពីរយៈពេលការពារជាអប្បរមាតាមអនុសញ្ញានេះ ។

ការឆ្លើយតបជាអន្តរជាតិថ្មីបំផុតដើម្បីការពារស្របច្បាប់ ប្រទេសទាំងនេះត្រូវចុះហត្ថលេខាលើសន្ធិសញ្ញាហ្វូណូក្រាម ការសម្ដែងនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកដែលបានសម្រេចឡើងនៅទីក្រុងហ្សឺណែវថ្ងៃទី២០ ខែធ្នូឆ្នាំ១៩៩៦ ។ ការអភិវឌ្ឍន៍សន្ធិសញ្ញានេះ បានផ្ដល់កិច្ចការពារបន្ថែមនៃសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសីលធម៌របស់អ្នកសម្ដែង និងផលិតករហ្វូណូក្រាម ក្នុងការធ្វើអាជីវកម្មទោះជាក្នុងទម្រង់ឌីជីថល ឬអ៊ីនធឺណិតក៏ដោយ ។ សន្ធិសញ្ញានេះចូល ជាធរមាននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ ។

ឥឡូវនេះ អ្នកដឹងពីប្រភេទក្រុមផ្សេងៗ ដែលទទួលបាននូវកិច្ចការពារក្រោមច្បាប់សិទ្ធិប្រហាក់ប្រហែល បន្ទាប់គឺពិចារណាលើអ្វីដែលជាសិទ្ធិទាំងនោះ? ជាគោលការណ៍ ជាសិទ្ធិដែលគេផ្ដល់ជូនទៅម្ចាស់សិទ្ធិ ។ នោះជាសិទ្ធិដើម្បីរារាំងពីការធ្វើអាជីវកម្មដោយគ្មានការអនុញ្ញាតដូចជាការសម្ដែង ការថតហ្វូណូក្រាម ឬការផ្សព្វផ្សាយ ។

## <u>សិទ្ធិដែលគេផ្ដល់ជូនទៅអ្នកទទួលផលប្រយោជន៍ពីច្បាប់សិទ្ធិប្រហាក់ប្រហែល</u>

សិទ្ធិទាំងនេះបានផ្ដល់ជូនទៅបីក្រុមអ្នកទទួលផលប្រយោជន៍នៃសិទ្ធិប្រហាក់ប្រហែលពីច្បាប់ជាតិ ទោះបីជាសិទ្ធិទាំងអស់នោះមិនមានកំណត់ដូចៗគ្នានៅក្នុងច្បាប់ជាតិក៏ដោយ ។

អ្នកសម្ដែងត្រូវទទួលបានសិទ្ធិដើម្បីការពារការថតបញ្ចូល ការចាក់ផ្សាយតាមទូរផ្សាយ និងការផ្សព្វផ្សាយជាសាធារណៈនៃការសម្ដែងរបស់ពួកគេដោយមិនមានការយល់ព្រម និងសិទ្ធិការពារក្នុងការផលិតឡើងវិញនូវស្នាដៃរបស់ពួកគេ ។ សិទ្ធិពាក់ព័ន្ធការចាក់ផ្សាយតាមទូរផ្សាយ និងផ្សព្វផ្សាយជាសាធារណៈតាមហ្វូណូក្រាមដើម្បីធ្វើពាណិជ្ជកម្មដែលអាចទទួលបានលាភការប្រកបដោយសមធម៌ជាជាងកិច្ចការពារ ។ នេះហៅថាការអនុញ្ញាតដោយមិនស្ម័គ្រចិត្តដែលបានពិភាក្សានៅក្នុងជំពូកសិទ្ធិអ្នកនិពន្ធរួចហើយ ។ ច្បាប់ជាតិមួយចំនួនបានផ្ដល់សិទ្ធិផងដែរដល់អ្នកសម្ដែងនូវសិទ្ធិសីលធម៌ដែលទាក់ទងដល់រូបវន្តបុគ្គល ហើយអាចជំទាស់ការប្រើឈ្មោះរបស់គេ ឬការប្ដូរអត្ថន័យស្នាដៃរបស់គេមិនសមហេតុផល ។

ផលិតករហ្វូណូក្រាមត្រូវទទួលបានសិទ្ធិអនុញ្ញាត ឬហាមឃាត់ដោយផ្ទាល់ ឬដោយប្រយោលរាល់ការផលិត ការនាំចូល ការចែកចាយហ្វូណូក្រាម និងការថតចម្លង និងសិទ្ធិទទួលបាននូវលាភការពីការផ្សព្វផ្សាយជាសាធារណៈនៅហ្វូណូក្រាមរបស់ខ្លួន ។

សិទ្ធិអង្គភាពទូរផ្សាយត្រូវបានគេផ្ដល់សិទ្ធិអនុញ្ញាត ឬហាមឃាត់ នូវការចាក់ផ្សាយតាមទូរផ្សាយឡើងវិញ ការថតបញ្ចូល និងការផលិតឡើងវិញនៃកម្មវិធីទូរផ្សាយណាមួយ ។ តាមច្បាប់ខ្លះ

សិទ្ធិនេះត្រូវទទួលបានបន្ថែមទៀត ឧទាហរណ៍ ក្នុងប្រទេសសហភាពអឺរ៉ុប ផលិតករហ្វូណូក្រាម និងអ្នកសម្តែងត្រូវបានគេផ្តល់សិទ្ធិជួល និងទាក់ទងនឹងអ្នកសម្តែង ឬស្នាដៃសោតទស្សន៍ ប្រទេសខ្លះផ្តល់សិទ្ធិផ្តាច់មុខទៅលើការបញ្ជូនតាមខ្សែកាប ។ ក្រោមកិច្ចព្រមព្រៀងTRIPS ផលិតករហ្វូណូក្រាម (ក៏ដូចម្ចាស់សិទ្ធិហ្វូណូក្រាមដ៏ទៃ ទៀតក្រោមច្បាប់ជាតិ) ត្រូវបានច្បាប់ផ្តល់សិទ្ធិក្នុងការជួល ។

ដូចជាក្នុងករណីសិទ្ធិអ្នកនិពន្ធនៃអនុសញ្ញាទីក្រុងរ៉ូម និងច្បាប់ជាតិនានាមានព្រំដែនកំណត់ ជាឧទាហរណ៍ការប្រើប្រាស់ជាឯកជន សម្រង់ខ្លីៗក្នុងការធ្វើរបាយការណ៍ និងការប្រើប្រាស់ សម្រាប់កិច្ចការបង្រៀន ឬកាស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រនៃការសម្តែងហ្វូណូក្រាម ។ ប្រទេសជាច្រើនបានកំណត់នូវព្រំដែនសិទ្ធិដែលច្បាប់របស់គេផ្តល់កិច្ចការពារតាមរយៈសិទ្ធិអ្នកនិពន្ធ ។

រយៈពេលការពារសិទ្ធិប្រហាក់ប្រហែលក្រោមអនុសញ្ញាទីក្រុងរ៉ូមគឺ ២០ឆ្នាំ បន្ទាប់ពីចុងឆ្នាំនៃ ៖

-ការសម្តែងបានធ្វើឡើង នៅពេលហ្វូណូក្រាមមិនបានថតបញ្ចូល

-ការថតបញ្ចូលក្នុងហ្វូណូក្រាមត្រូវបានធ្វើឡើង

-ការផ្សព្វផ្សាយតាមទូរផ្សាយបានធ្វើឡើង

អ្នកគួរកត់សំគាល់ថាច្បាប់ជាតិជាច្រើន ដែលការពារសិទ្ធិប្រហាក់ប្រហែល ផ្តល់រយៈពេលវែងជាងរយៈពេលអប្បបរមាដែលមានចែងក្នុងអនុសញ្ញាទីក្រុងរ៉ូម ។

ក្នុងកិច្ចព្រមព្រៀងTRIPS សិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាមត្រូវទទួល បានកិច្ចការពាររយៈពេល៥០ឆ្នាំបន្ទាប់ពីឆ្នាំចុងបញ្ចប់នៃការថតបញ្ចូល ឬការសម្តែងនោះបានធ្វើឡើង ហើយសិទ្ធិរបស់អង្គភាពទូរផ្សាយត្រូវការពាររយៈពេល២០ឆ្នាំ ចាប់ពីឆ្នាំចុងបញ្ចប់នៃការផ្សព្វផ្សាយ ។ ដូច្នេះមានន័យថា ប្រទេសដែលប្រកាន់យកកិច្ចព្រមព្រៀងTRIPS គួរតែផ្តល់ ឬកែប្រែច្បាប់ដើម្បីផ្តល់កិច្ចការពារ វែងជាងកិច្ចការពារក្នុងអនុសញ្ញាទីក្រុងរ៉ូម ។

ក្នុងការអនុវត្តសិទ្ធិ សំណងរដ្ឋប្បវេណីលើការរំលោភបំពានសិទ្ធិប្រហាក់ប្រហែល មានលក្ខណៈ ប្រហែលទៅនឹងការរំលោភសិទ្ធិលើម្ចាស់សិទ្ធិអ្នកនិពន្ធដែរ ។ ទាំងនេះជាវិធានការបណ្តោះអាសន្ន សំណងរដ្ឋប្បវេណី ការដាក់ទោសទណ្ឌ វិធាននានាតាមមាត់ច្រកព្រំដែន ព្រមទាំងវិធានការផ្សេងៗទៀត និងទណ្ឌកម្មនានាប្រឆាំងការរំលោភបំពាន ដូចជាការប្រើឧបករណ៍បច្ចេកទេស ។

គំនិតសិទ្ធិប្រហាក់ប្រហែលនេះ ក្នុងគោលបំណងការពារនូវការលួចចម្លងវប្បធម៌ប្រទេសកំពុងអភិវឌ្ឍដែលជាផ្នែកនៃប្រពៃណីអ្នកស្រុក ។ រហូតមកដល់ពេលនេះ វាជាញឹកញាប់តាមរយៈអ្នកសម្តែងដែលបង្ហាញប្រពៃណីអ្នកស្រុកត្រូវបានភ្ជាប់ទំនាក់ទំនងទៅសាធារណៈជន ។ ដោយផ្តល់នូវកិច្ចការពារសិទ្ធិប្រហាក់ប្រហែល ប្រទេសកំពុងអភិវឌ្ឍន៍នានាអាចផ្តល់ផងដែរ នូវមធ្យោបាយការពារវប្បធម៌សប្បុរបែប និងមានតម្លៃដែលមានពីមុន និងអត្តសញ្ញាណពិត មិនតែប៉ុណ្ណោះបង្ហាញនូវអ្វីដែលខុសពីវប្បធម៌មួយទៅមួយ ឬពីអ្នកជិតខាងរបស់ខ្លួនឆ្លងកាត់ព្រំដែន ឬឆ្លងកាត់ពិភពលោក ។

ដូចគ្នាដែរកិច្ចការពារផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ ជួយកសាងនូវមូលដ្ឋានសម្រាប់ឧស្សាហកម្មជាតិ ដែលមានសមត្ថភាពបង្ហាញវប្បធម៌ជាតិនៅខាងក្នុង ប្រទេស ហើយក្នុងទីផ្សារខាងក្រៅប្រទេស ។ ប្រជាប្រិយភាពសព្វថ្ងៃដែលខ្លាំងបំផុតគឺ តន្ត្រីពិភពលោក បង្ហាញឱ្យឃើញថាមានទីផ្សារ ប៉ុន្តែវាមិនតែងតែគ្រប់ករណីដែលទទួលផលប្រយោជន៍ពីការធ្វើអាជីវកម្មនៃទីផ្សារបែបនេះត្រលប់ទៅក្នុងប្រទេសរបស់ខ្លួនវិញឡើយ ។

ជាសង្ខេបកិច្ចការពារសិទ្ធិប្រហាក់ប្រហែលមានគោលដៅពីរគឺ រក្សាវប្បធម៌ជាតិ និងផ្តល់នូវមធ្យោបាយសម្រាប់ធ្វើអាជីវកម្មពាណិជ្ជកម្មនៃទីផ្សារអន្តរជាតិ ។

## សង្ខេប

ក្នុងផ្នែកនេះអ្នកបានសិក្សាអំពីសិទ្ធិប្រហាក់ប្រហែល គោលបំណងសិទ្ធិប្រហាក់ប្រហែលគឺត្រូវបានការពារផលប្រយោជន៍ស្របច្បាប់នៃបុគ្គលខ្លះ ឬអង្គភាពទូរផ្សាយដែលចូលរួមបង្កើតកិច្ចការដែលមានតំលៃដល់សាធារណៈជន ឬអ្នកទាំងនោះដែលបង្កើតបន្ថែមជំនាញបច្ចេកទេស ឬជំនាញកិច្ចការផ្សេងៗទៀត ។

ជាធម្មតាសិទ្ធិប្រហាក់ប្រហែលបានផ្តល់ប្រយោជន៍ដល់បីក្រុមៈ អ្នកសម្តែង ផលិតករហ្វូណូ-ក្រាម និងអង្គភាពទូរផ្សាយ ។ ភាពចាំបាច់សម្រាប់កិច្ចការការពារស្របច្បាប់នៃក្រុមទាំងបីនេះ ត្រូវបានកំណត់ក្នុងអនុសញ្ញាទីក្រុងរ៉ូមក្នុងឆ្នាំ១៩៦១ ដែលជាបំណងមួយបង្កើតនូវបទប្បញ្ញត្តិអន្តរជាតិនៅក្នុងវិស័យថ្មីមួយដែលច្បាប់ជាតិមួយចំនួនបានចែងរួចហើយ ។ ក្នុងន័យម៉្យាងទៀត រដ្ឋភាគច្រើនត្រូវព្រាង និងអនុម័តមុនចូលជាសមាជិកនៃអនុសញ្ញានេះ ។ អនុសញ្ញាទីក្រុងរ៉ូមទោះបីមិនពេញលេញនិងចាំបាច់ធ្វើវិសោធនកម្មក៏ដោយ ក៏នៅតែជាខ្នាតអន្តរជាតិសម្រាប់កិច្ចការពារក្នុងវិស័យនេះ ។ ដូចជាច្បាប់សិទ្ធិអ្នកនិពន្ធ អនុសញ្ញាទីក្រុងរ៉ូម ព្រមទាំងច្បាប់ជាតិនានាធ្វើការកំណត់ព្រំដែនលើសិទ្ធិដែលកំពុងអនុញ្ញាត សម្រាប់ការប្រើប្រាស់ជាលក្ខណៈឯកជន សម្រង់ខ្លីៗ និងប្រើសម្រាប់ការស្រាវជ្រាវ ឬកិច្ចការបង្រៀន ឬវិទ្យាសាស្ត្រ ។

រយៈពេលកិច្ចការសិទ្ធិប្រហាក់ប្រហែល ដូចបានកំណត់ក្នុងអនុសញ្ញាទីក្រុងរ៉ូមគឺ ២០ឆ្នាំបន្ទាប់ពីឆ្នាំចុងក្រោយនៃៈ

-ការថតចម្លងត្រូវបានធ្វើឡើង

-ការសម្តែងត្រូវបានប្រព្រឹត្តិឡើង។

-ការចាក់ផ្សាយតាមទូរទស្សន៍ត្រូវបានធ្វើឡើង។

វិធានការបណ្តោះអាសន្នសំដៅចំពោះសំណងរដ្ឋប្បវេណី សម្រាប់អំពើរំលោភបំពានដល់សិទ្ធិប្រហាក់ប្រហែល រួមមានការប្រើយន្តការសំណងរដ្ឋប្បវេណី ដាក់ទណ្ឌកម្ម និងវិធានការនានាតាម

មាត់ច្រកព្រំដែន និងវិធានការផ្សេងៗទៀត ដើម្បីប្រឆាំងការរំលោភបំពានដល់ការប្រើឧបករណ៍បច្ចេកទេស ។

សិទ្ធិសញ្ញាថ្មីបំផុតក្នុងវិស័យសិទ្ធិប្រហាក់ប្រហែលគឺសន្ធិសញ្ញា WPPT បានបន្ថែមទំហំនៃកិច្ចការពារសិទ្ធិរបស់អ្នកសម្តែង និងផលិតករហ្វូណូក្រាមក្នុងសម័យឌីជីថលជាមួយកិច្ចការពារ Design ចំពោះការធ្វើអាជីវកម្មស្នាដៃដែលត្រូវបានការពារក្នុងទម្រង់ឌីជីថលដោយរាប់បញ្ចូលអ៊ីនធឺណិត ។

គួរកត់ចំណាំថាសិទ្ធិប្រហាក់ប្រហែលអាចជួយការពារវប្បធម៌ដែលពុំបានសសេរទុក ឬមិនបានថតបញ្ចូលទុកនៃបណ្តាលប្រទេសកំពុងអភិវឌ្ឍន៍ ។ កិច្ចការពារសិទ្ធិប្រហាក់ប្រហែលបានក្លាយជារូបភាពដ៏ធំបំផុតមួយ ហើយចាំបាច់ដើម្បីចូលរួមក្នុងប្រព័ន្ធវិនិយោគ និងពាណិជ្ជកម្មជាអន្តរជាតិ ។

# ជំពូកទី៤
# ម៉ាក ពាណិជ្ជនាម

__វត្ថុបំណង:__

នៅពេលអ្នកបានរៀនចប់ជំពូកនេះអ្នកនឹងអាចៈ

-ធ្វើបញ្ជី និងពិពណ៌នាយ៉ាងសង្ខេបពីសញ្ញាទាំងឡាយដែលអាចចាត់ថា ជាម៉ាក ។

-ពិពណ៌នាពីលក្ខខណ្ឌពីរដើម្បីការពារម៉ាក។

-ចូលកំណត់ពីភាពខុសគ្នារវាងCollective MarkនិងCertificate Mark

-កំណត់ពីសិទ្ធិផ្តាច់មុខរបស់ម្ចាស់ម៉ាក

-ពិពណ៌នាពីតើម៉ាកល្បីត្រូវការពារយ៉ាងណាក្រោមអនុសញ្ញាទីក្រុងប៉ារីស និងកិច្ចព្រមព្រៀងTRIPS

## សេចក្តីផ្តើម

ម៉ាកសញ្ញាបានកើតមានជាយូរមកហើយ រយៈពេលជាង៣០០០ឆ្នាំកន្លងទៅ សិប្បករជនជាតិឥណ្ឌាធ្លាប់ឆ្លាក់ហត្ថលេខារបស់ខ្លួននៅលើផលិតផលសិល្បៈទាំងឡាយ មុនបញ្ជូនទៅប្រទេស អ៊ីរ៉ង់ ។ ដូចជាម៉ាកគ្រឿងក្អមរ៉ូម៉ាំង និងវត្ថុផ្សេងៗទៀត ជាង១០០មុខបានដាក់ប្រើប្រាស់ដោយរាប់បញ្ចូលម៉ាកFORTIS ដែលល្បីល្បាញបំផុត រហូតត្រូវបានគេថតចម្លង និងក្លែងបន្លំ ដោយសារម៉ាកសញ្ញាមានការរីកចំរើនខ្លាំងក្នុងយុគ្គសម័យកណ្តាល ។

សព្វថ្ងៃម៉ាកជាញឹកញយត្រូវបានសរសេរកាត់TM ជាភាសាអង់គ្លេសដើម្បីប្រើប្រាស់ រួមទាំងមនុស្សភាគច្រើនលើពិភពលោកនេះ អាចបែងចែករវាងម៉ាកភេសជ្ជៈពីរប្រភេទ Soft drinks Pepsi-Cola® និង Coca-Cola® ។

ការរីកចំរើនយ៉ាងខ្លាំងនៃម៉ាកសញ្ញាក្នុងសកម្មភាពពាណិជ្ជកម្ម គឺដោយសារការកើនឡើងនៃការប្រកួតប្រជែងក្រុមហ៊ុនក្នុងការធ្វើពាណិជ្ជកម្មក្នុងប្រទេសជាច្រើន ។ ម៉ាកសញ្ញាត្រូវបានគេប្រើដើម្បីកំណត់អត្តសញ្ញាណយ៉ាងសាមញ្ញតាមរយៈអ្នកប្រើប្រាស់ទំនិញ ឬសេវាព្រមទាំងគុណភាព និងតម្លៃ ។ ដូចនេះម៉ាកសញ្ញាមួយអាចចាត់ទុកថាចំណុចសំខាន់នៃការទំនាក់ទំនងដែលបានប្រើប្រាស់ដោយអ្នកផលិត ដើម្បីទាក់ទាញអ្នកប្រើប្រាស់ទំនិញ ។

ក្នុងជំពូកនេះអ្នកនឹងសិក្សាអ្វីដែលជាប្រភេទសញ្ញាផ្សេងៗអាចត្រូវបានប្រើម៉ាកសញ្ញា និងអ្វីដែលកំណត់ពីលក្ខណៈរបស់វា ។ អ្នកនឹងសិក្សាផងដែរនូវប្រភេទម៉ាកប្រមូលផ្តុំ និងម៉ាកដែលទទួល

ស្គាល់ ។ ជំពូកនេះនឹងមានការពន្យល់ពីម៉ាកដែលល្បីត្រូវផ្តល់នូវកិច្ចការពារក្រោមសន្ធិសញ្ញាParis Convention និងTRPS Agreement ។

## ម៉ាក ពាណិជ្ជនាម

### តើម៉ាកជាអ្វីពិតប្រាកដ?

ម៉ាកគឺជាសញ្ញាមួយដែលត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីភាពខុសគ្នានៃទំនិញ ឬ សេវាដែលបានផ្តល់ដោយពាណិជ្ជករ ឬអ្នកដ៏ទៃទៀត ។ នោះជានិយមន័យយ៉ាងសាមញ្ញបំផុតមួយ ប៉ុន្តែវាមិនបានពន្យល់លំអិតនូវអ្វីជាម៉ាកនោះទេ ។ តើលក្ខណៈអ្វីដែលម៉ាកត្រូវមាន? ជាមូលដ្ឋានមានលក្ខណៈធំៗពីរសម្រាប់សំគាល់ម៉ាក វាត្រូវតែខុសប្លែកពីគ្នា និងគ្មានការក្លែងបន្លំ ។

ហេតុដូច្នេះនិយមន័យជាផ្លូវការនៃពាក្យថាម៉ាកអាចជា "សញ្ញាផ្ទាល់ខ្លួនមួយនៃទំនិញ របស់សហគ្រាសផលិតមួយ ដែលមានភាពខុសគ្នាពីទំនិញរបស់អ្នកប្រកួតប្រជែងរបស់ខ្លួន" ។

ម៉ាកអាចជាពាក្យ គំនូរ អក្សរ លេខ សំបកកញ្ចប់ ពាក្យស្លោក រូបឧបករណ៍ ឬនិមិត្តសញ្ញា ។ ដូចជាThe Coca-Cola Company ® PepsiCo, Inc. ® ។

វាមានសារសំខាន់ណាស់សេវាសញ្ញាគឺជាម៉ាកដែរ ភាពខុសគ្នាគឺនៅត្រង់មួយការពារទំនិញ និងមួយទៀតការពារលើសេវា ។ ជាទូទៅកាលណាប្រើពាក្យម៉ាកវាមានន័យរួមពីរគឺម៉ាកសញ្ញា និងសេវាសញ្ញា ។

### តើឥឡូវអ្នកអាចឱ្យឧទាហរណ៍ប្រភេទសញ្ញាមួយចំនួនដែលយើងគិតដល់?

ជាកាពិតមានម៉ាកជាអក្សរដោយរួមមាន តួអក្សរ លេខ អក្សរកាត់ ឬឈ្មោះផ្សេងៗដូចជានាមត្រកូល ។ យើងគ្រាន់តែគិតដល់ការផលិតម៉ាកឡានល្បីមួយ ឧទាហរណ៍ឈ្មោះFORT បន្ទាប់ពីលោក HENRY FORT ដែលជាអ្នកផលិតមុនដំបូង និងបន្ទាប់មកមានលោកWH-Smith ជាអ្នកលក់សៀវភៅ និងមានបន្តបន្ទាប់ទៀត ។ យើងរកឃើញការប្រើឈ្មោះអក្សរកាត់ដូចជាIBM ជាម៉ាក ប៉ុន្តែម៉ាកអាចត្រូវបានប្រើលើឧបករណ៍ ឬសមាសធាតុដែលចង្អុលបង្ហាញដូចជា ក្រុមហ៊ុនប្រេងShell ។

### ដូច្នេះនៅពេលអ្នកនិយាយគ្រឿងសម្ភារៈ មានន័យថាវត្ថុនានាដូចសញ្ញាShell?

បាទជាការពិត,តែវាគឺជាប្រភេទរូបរាង២ប្រភេទ ដែលម៉ាកត្រូវមាន រួមទាំងកញ្ចប់ខ្ចប់វិចទំនិញ ឬរូបរាងទំនិញតែម្តង ពេលនោះម៉ាកទាំងនោះត្រូវទទួលកិច្ចការពារ ។ ហើយនាពេលថ្មីៗនេះ យើងឃើញប្រភេទម៉ាកសញ្ញាថ្មីមួយលេចឡើងលើទីផ្សារ គឺជាម៉ាកដែលប្រែប្រួល ជារូបភាពដែលប្រែប្រួលអាស្រ័យទៅលើគែមរបស់វានៅពេលដែលអ្នកមើល ។ មានម៉ាកជាសម្លេង ពាក្យស្លោកផ្សាយពាណិជ្ជកម្មអាចចាត់ជាម៉ាកសញ្ញាបានដែរ ។ នៅក្នុងប្រទេសខ្លះ សូម្បីតែក្លិនក៏អាចជាម៉ាកផងដែរ

ហើយអាចត្រូវបានគេការពារ ។ ដូច្នេះមានប្រភេទសញ្ញាផ្សេងៗច្រើនអាចត្រូវបានប្រើប្រាស់ជាម៉ាកសញ្ញា ប៉ុន្តែជានិច្ចកាល ឈរលើលក្ខខ័ណ្ឌពីដូចគ្នា: ម៉ាកត្រូវតែខុសគ្នា និងមិនក្លែងបន្លំ។




ក្នុងការសង្ខេបនេះអាចធ្វើឲ្យអ្នកយល់ពីអ្វីជាម៉ាកសញ្ញា រួមទាំងសេវាសញ្ញា គឺ:

ពាក្យ:Apple' for computers; Deutsche Bank for a bank, Arbitrary or fanciful designations: Coca-Cola, Nikon, Sony, NIKE, Easy Jet.

ឈ្មោះFord, Peugeot, Hilton (hotel)

រូបរាង ផ្កាយសម្រាប់រថយន្តMercedes Benz

លេខ........

អក្សរ GM, IBM

រូបភាព ឬនិមិត្តសញ្ញា: រូបក្រពើ

ដូចដែលបានបង្ហាញខាងលើ លក្ខណ:ពីយ៉ាងនៃម៉ាកសញ្ញាត្រូវតែមាន ។ ទី១ត្រូវតែខុសគ្នា ហើយទីពីរវាមិនក្លែងបន្លំ ដើម្បីសិក្សា បន្ថែមអំពីតម្រូវការទាំងពីរ នេះសូមពិនិត្យបន្តទៀត ។

**តើអ្នកអាចផ្តល់ឧទាហរណ៍ម៉ាកខុសគ្នាយ៉ាងម៉េច?**

ដើម្បីញែកឱ្យដាច់ពីគ្នា គឺត្រូវតែបែងចែកទំនិញ និងសេវា ដូចដែលបាន អធិប្បាយបន្តិចទៀតនេះ មានឧទាហរណ៍ដ៏ល្អមួយគឺពាក្យ Apple គឺមានលក្ខណ:មិនទាក់ទងនឹង Computer ដែលខុសគ្នាស្រឡះពីកុំព្យូទ័រ ពីព្រោះវាមិនធ្វើឲ្យច្រលំគ្នាទេ។ ម្យ៉ាងទៀតនណាម្នាក់ដែលនាំ និងលក់ផ្លែប៉ោមមិនអាចចុះបញ្ជីពាក្យ Apple ជាម៉ាកសញ្ញាដើម្បីការពារនោះទេ ពីព្រោះអ្នកប្រគួត ប្រជែងរបស់គាត់អាចប្រើពាក្យនេះដើម្បី ពិពណ៌នានូវទំនិញ ។ ដូចនេះតាមន័យទូទៅ ម៉ាកសញ្ញាមិនអាចខុសគ្នាបានទេ ប្រសិនបើធ្វើការពិពណ៌នា ។ ប៉ុន្តែវាអាចពិពណ៌នាផងដែរនៅពេលពិពណ៌នាលើប្រភេទ អត្តសញ្ញាណ

នៃទំនិញ ឬសេវាដែលបានប្រើ ។ ម៉ាកសញ្ញាអាចត្រូវបានគេក្លែងបន្លំ នៅពេលម៉ាកសញ្ញានោះមានគុណភាពល្អដែលអ្នកប្រកួតប្រជែងផ្សេងទៀតគ្មាន ។

**តើអ្នកអាចឱ្យឧទាហរណ៍ ម៉ាកណាដែលអាចក្លែងបន្លំបាន?**

ជាតួយ៉ាងការក្លែងបន្លំម៉ាកសញ្ញា គឺនៅពេលដែលទំនិញនោះមានគុណភាពល្អ ហើយអ្នកដ៏ទៃគ្មាន ។ ឧទាហរណ៍ ម៉ាកសញ្ញា រោមសត្វសុទ្ធ ជាទំនិញដែលមិនផលិតពីស្បែកសត្វពិតប្រាកដ ។

ចំណុចមួយក្នុងចំណោមចំណុចចំបងៗដែលបានលើកឡើងគឺថានៅពេលដែល វាយតំលៃពីភាពខុសគ្នានៃសញ្ញាមួយរបស់ម៉ាក ត្រូវបានវិនិច្ឆ័យរួមគ្នាជាមួយទំនិញ ឬសេវាដែលនៅជាមួយគ្នានោះ ។

<u>សំនួរវាយតំលៃដោយខ្លួនឯង</u>

តើអ្នកគិតថាពាក្យដែលប្រឌិតឡើងដូចនេះFRUMATOអាចជាម៉ាកល្អសម្រាប់ភេសជ្ជៈ ដែលបានផលិតពីការផ្សំបញ្ចូលគ្នានៃទឹកផ្លែឈើគ្រប់មុខ និងទឹកប៉េងបោះ ឬទេ?

<u>ចម្លើយ</u>

ចូរក្រឡេកមើលភាពជាក់លាក់នៃទំនិញដែលមានម៉ាកច្បាស់លាស់ វាជាការបញ្ចូលគ្នានូវពាក្យFRUIT និងពាក្យTOMATO វាមិនមែនជាពាក្យដែលមានចែងក្នុងវាចនានុក្រម ហើយវាមិនមែនជាពាក្យមួយដែលកើតឡើងជាធម្មតាសម្រាប់អ្នកពាណិជ្ជករប្រើប្រាស់ទេ ។ ហេតុនេះវាអាចត្រូវបានគេនិយាយថាវាមានលក្ខណៈខុសគ្នា ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានការប្រើពាក្យបន្លំក្នុង Drug Company ដែលត្រូវបានគេសម្គាល់ថាឱសថនោះផលិតចេញពីជាតិថ្លើម (Liver)និងជាតិដែក (Iron) ដោយប្រើឈ្មោះLIVERON ដើម្បីកំណត់ផលិតផលនោះ ។ ជាសំណាងមិនល្អការប្រគួតប្រជែងនេះមានក្រុមហ៊ុនឱសថមួយបានផលិតឱសថទាំងនោះក្នុងប្រទេសបារាំងទីក្រុងLIVERON ។ ពេលនោះការប្រើប្រាស់ពាក្យនេះបានត្រូវគេជំទាស់ ។

<u>សំណួរវាយតម្លៃខ្លួនឯង</u>

ចងចាំនូវសេចក្តីត្រូវការពីរនៃភាពខុសគ្នា និងការមិនក្លែងបន្លំ ចូរភ្ជាប់ឲ្យស៊ីគ្នានូវម៉ាក និងការពន្យល់ខាងក្រោម

| | |
|---|---|
| 1. MOOTEL | Portable cowsheds |
| 2. SWISS FLAG | Wrist watches |
| 3. GOLD CAP | Whisky |
| 4. FYNPOWDA | Cleaning preparations |

ក-ពិពណ៌នាពីលក្ខណៈធម្មតានៃផលិតផលនានា ដែលអាចផ្តល់ការប្រើប្រាស់បានយូរអង្វែង និងគ្រប់បែបយ៉ាង ដោយផ្សព្វផ្សាយជាសាធារណៈដែលទាក់ទងនឹងផលិតផលល្បីរបស់ពាណិជ្ជករ ។

គ្មានពាណិជ្ជករណាមួយប្រើប្រាស់ការផ្សព្វផ្សាយបែបនេះនេះទេ ។ ជាការពិត ម៉ាកនេះត្រូវតែមានភាពខុសគ្នា ហើយការប្រើប្រាស់ម៉ាកនេះអាចទទួលបានតាមផ្លូវ ច្បាប់នៅទីកន្លែងដែលបានប្រើប្រាស់ជាក់លាក់ ។

ខ-រឿងកំប្លែងគួរឱ្យអស្ចារ្យមួយ មានលក្ខណៈខុសគ្នា និងមានលទ្ធភាពចុះបញ្ជី ។ ម៉ាកនេះត្រូវតែចុះបញ្ជីដើម្បីទទួលបាននូវការការពារប្រសិនបើគ្មានការជំទាស់ ។

គ-ការផ្សព្វផ្សាយបន្លើសការពិតពីផលិផលរបស់ខ្លួន នេះជាម៉ាកដែលមិនត្រឹមត្រូវ។

ឃ-ការប្រើប្រាស់នូវលក្ខណៈខ្លះចំពោះម៉ាក គឺជាទូទៅត្រូវបានហាមឃាត់ ក្នុងប្រទេសជាច្រើនដូចជាការប្រើប្រាស់ម៉ាកទង់ជាតិ ឬសញ្ញាជាតិ ដូច្នេះម៉ាកនេះមិនត្រឹមត្រូវទេ ។

<u>ចម្លើយ</u>

ចម្លើយ: ១-B ២-D ៣-A ៤-C

ម៉ាកសញ្ញាខ្លះអាស្រ័យលើលើរូបភាពផ្សេងៗ ឬគំនូសនានា ឬការបញ្ចូលគ្នានៃរូបភាព និងពាក្យ ។ ឧទាហរណ៍ សញ្ញាឡូហ្គូនៃ Open University ក្នុងចក្រភពអង់គ្លេស ។

<u>សំនួរវាយតំលៃដោយខ្លួនឯង</u>

តើអ្នកគិតថាគំនូរសម្រាប់ភេជ្ជៈខាងក្រោម ជាផលិតផលផលិតចេញពីផ្លែឈើឬ?

<u>ចម្លើយ</u>

ដើមឈើមួយដើម ដូចជាដើមប៉ោមអាចពិពណ៌នាបាន តែមិនអាចវែកញែកឱ្យខុសគ្នាដាច់បានទេ មតិមួយអាចបង្ហាញថា រូបផ្លែប៉ោមអាចប្រើសម្រាប់ឱហ្សាញ ។ តែទោះបីជាយ៉ាងណាក៏ដោយដើមឈើនោះបង្ហាញនូវផ្លែឈើជាច្រើនមុខដែលមិនអាចកើតមានក្នុងធម្មជាតិ ។ ផ្លែទពាំងបាយជូ សណ្តែកដី ផ្លែប័រ ផ្លែក្រូច ផ្លែហ្សីរី ត្រូវបានបង្ហាញក្នុងដើមឈើតែមួយ និមិត្តសញ្ញានេះកើតឡើងមានភាពខុសគ្នា ចាំបាច់ត្រូវការចុះបញ្ជី នេះជាឧទាហរណ៍ដ៏ល្អមួយនៃរបៀបដែលមិនអាចញែកបាន តែអាចត្រូវបានប្រមូលមធ្យោបាយបង្កើតដែលធ្វើឲ្យមានលក្ខណៈខុសគ្នា ។

ដើម្បីទទួលម៉ាកល្បី និងបានការពិចារណាក្នុងការវិនិយោគ សំរាប់រយៈពេលពិតប្រាកដមួយ ។ ទាល់តែវាមានផលប្រយោជន៍គ្រប់ៗគ្នាក្នុងការប្រើប្រាស់ ដោយធានាថាម៉ាកនោះត្រូវបានការពារជាតម្លៃនៃកម្មសិទ្ធិបញ្ញា ។

**ក្រុមហ៊ុនបានចំណាយប្រាក់ច្រើនលើការបង្កើតម៉ាក តើគេអាចការពារបានដោយរបៀបណា?**

ជាការពិតពួកគេត្រូវតែផ្អែកលើច្បាប់ម៉ាកសញ្ញា ប៉ុន្តែវិធីសាមញ្ញបំផុតនៃកិច្ចការពារម៉ាកសញ្ញាគឺត្រូវចុះបញ្ជី ហើយប្រទេសធំៗជាច្រើនបង្កើតលក្ខខ័ណ្ឌនៃកិច្ចការពារម៉ាកសញ្ញានេះ ។ ត្រូវតែចុះបញ្ជីទើបទទួលបាននូវកិច្ចការពារ ពេលនោះម្ចាស់កម្មសិទ្ធិអាចហាមឃាត់ពីកាប្រើប្រាស់វា ។ ការចុះបញ្ជី

មិនមែនជាវិធីតែមួយគត់នៃកិច្ចការពារម៉ាកសញ្ញាទេ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានម៉ាកសញ្ញាខ្លះមិនចាំបាច់ចុះបញ្ជីក៏ត្រូវទទួលបានកិច្ចការពារផងដែរនៅប្រទេសមួយចំនួន ប៉ុន្តែមានតិចតួចណាស់ ។ ពីព្រោះម៉ាកដែលមិនចុះបញ្ជី មិនទទួលកិច្ចការពារទេ រហូតទាល់តែម៉ាកនោះចាប់ផ្តើមល្បីក្នុងទីផ្សារ។

**ប្រសិនបើម៉ាកមិនបានចុះបញ្ជីរយៈពេលយូរ ហើយគេស្គាល់គ្រប់គ្នាតើប្រទេសខ្លះទៀតចាត់វិធានការការពារឬ?**

ទោះបីជាយ៉ាងណាក៏ដោយវាពិតជាត្រូវការពារ ប្រសិនបើអ្នកចាប់ផ្តើមលក់ផលិតផលដែលមានម៉ាកសញ្ញាថ្មីនៅលើទីផ្សារគ្មាននរណាម្នាក់ស្គាល់ ហើយម៉ាកសញ្ញានោះងាយស្រួលគេចម្លង ។ នោះវាអាចទទួលបាននូវកិច្ចការពារតាមរយៈច្បាប់ស្តីពីការប្រកួតប្រជែងមិនស្មោះត្រង់ ប៉ុន្តែបញ្ហាសំខាន់គឺម៉ាកសញ្ញានោះត្រូវតែល្បីល្បាញ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

តើមានវិធីសាស្ត្រសំខាន់អ្វីដែលថែងថាក្រុមហ៊ុនមួយអាចការពារនូវការធ្វើវិនិយោគលើម៉ាករបស់ខ្លួន ?

<u>ចម្លើយ</u>

ការលើកឡើងដោយផ្អែកលើមូលដ្ឋាននៃកិច្ចការពារម៉ាកសញ្ញា គឺយោងតាមច្បាប់ក្នុងប្រទេសឬក្នុងតំបន់នោះ ។ ការចុះបញ្ជីម៉ាកសញ្ញាទើបទទួលបាននូវកិច្ចការពារ ប៉ុន្តែវាអាចទទួលបាននូវកិច្ចការពារក្នុងករណីខ្លះដោយសារការពន្យាពេលនៃការប្រើប្រាស់ ។

ម៉ាកវាកំណត់ពីភាពខុសគ្នានៃសហគ្រាស ជាប្រភពដើមនៃផលិតផលដែលបានធ្វើ ឬសេវា ។ ប្រទេសខ្លះតម្រូវឲ្យចុះបញ្ជីម៉ាករួមនៃសហគ្រាស និងម៉ាកសម្គាល់គុណភាពនៃទំនិញដែលត្រូវបានគេប្រើសម្រាប់កំណត់ពីការប្រមូលផ្តុំចូលគ្នានៃសហគ្រាសក្នុងការប្រើប្រាស់ម៉ាក និងទាក់ទងជាមួយការកំណត់ស្តង់ដារនៃផលិតផលក្នុងការប្រើម៉ាក។

ម៉ាករួមគឺជាកម្មសិទ្ធិរបស់ក្រុមនៃសហគ្រាស គេប្រើវាសម្រាប់ក្រុមសមាជិកនៃក្រុមហ៊ុនរបស់គេ ហេតុនេះម៉ាករួមគឺខុសគ្នាពីទំនិញ ឬសេវារបស់ក្រុមសមាជិកមួយទៅក្រុមសមាជិកមួយទៀត ។

តួនាទីម៉ាករួមគឺផ្សព្វផ្សាយជាសាធារណៈអំពីលក្ខណៈពិសេសខ្លះនៃផលិតផលដែលម៉ាករួមត្រូវបានគេប្រើប្រាស់ ។ ជាបន្ថែមទៀតសហគ្រាសមួយដែលប្រើប្រាស់ម៉ាករបស់ខ្លួន ។ ជាឧទាហរណ៍ សមាគមស្ថាបត្យករ និងវិស្វករ សមាជិករបស់គេអាចប្រើប្រាស់ម៉ាកសញ្ញារបស់សមាគម ។

ម៉ាកគុណភាព គឺជាម៉ាកកំណត់ពីសេវា ឬទំនិញដែលត្រូវបានគេប្រើបញ្ជាក់ពីគុណភាពនៃទំនិញ និងសេវាដែលម៉ាកនេះត្រូវបានគេប្រើសម្រាប់បញ្ជាក់ពីភាពត្រឹមត្រូវរបស់ផលិតផល គុណភាព ឬលក្ខណៈពិសេសផ្សេង ម៉ាកគុណភាពត្រូវបានគេប្រើជាការកំណត់ស្តង់ដារ ឧទាហរណ៍ ISO 9000 ។

ភាពខុសគ្នារវាងម៉ាករួម និងម៉ាកគុណភាព គឺម៉ាករួមប្រើសម្រាប់សហគ្រាសនៃសមាគម ចំណែកម៉ាកគុណភាពប្រើសម្រាប់បញ្ជាក់ពីកម្រិតគុណភាព ។

មានក្រុមហ៊ុនខ្លះបានទទួលជោគជ័យក្នុងលើម៉ាក និងសេវាសញ្ញាលើពិភពលោក ដោយអតិថិជនមិនចាំបាច់ចង់ដឹងពីអត្តសញ្ញាណនៃទំនិញ ឬសេវា ឬប្រភេទពិសេសនៃទំនិញរបស់ក្រុមហ៊ុនមួយណាផលិតនៅទីកន្លែងណាទេ ។ ម៉ាកទាំងនោះគេទទួលស្គាល់ថាជាម៉ាកល្បីដូចជាSony, Versace,....។

ដូចអ្នកបានដឹងហើយថា មានក្រុមហ៊ុនជាច្រើនចង់ទទួលប្រយោជន៍ដោយមិនត្រឹមត្រូវពីម៉ាកល្បីទាំងនោះតាមរយៈការបង្កើតម៉ាកដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាដែលធ្វើឲ្យអតិថិជនមានការយល់ច្រលំ ។ ដើម្បីជៀសវាងបញ្ហានេះParis Convention, TRIPS Agreement និងច្បាប់ជាតិជាច្រើនបានចែងការពារម៉ាកល្បីទាំងនេះ ។

វាគ្មាននិយមន័យជាក់លាក់ណាមួយពីម៉ាកល្បីទេ ទោះបីជាយ៉ាងណាក៏ដោយ មានកត្តាមួយចំនួនកំណត់ពីម៉ាកល្បី ។ កត្តាទាំនោះរួមទាំងកម្រិតចំណេះដឹង ឬការទទួលស្គាល់ម៉ាកនៅគ្រប់វិស័យនៃសាធារណជនក្នុងរយៈពេលមួយ និងបន្តបន្ទាប់គ្រប់តំបន់ភូមិសាស្ត្រនៃម៉ាក ។

**តើអ្នកអាចទទួលបាននូវការការពារនៅលើពិភពលោកលើម៉ាក ដោយចុះបញ្ជីតែប្រទេសមួយ ?**

បាទអ្នកត្រូវតែទៅចុះបញ្ជីនៅប្រទេសនីមួយៗផ្សេងៗគ្នា ច្បាប់កម្មសិទ្ធិបញ្ញា ម៉ាកគឺជាសិទ្ធិនៅក្នុងបូរណភាពដែនដី ជាគោលការណ៍មានន័យថា កិច្ចការពារសិទ្ធរបស់គេគឺត្រូវទទួលបានតាមរយៈការចុះបញ្ជីក្នុងប្រទេស ។ មានប្រពន្ធ័ចុះបញ្ជីក្នុងតំបន់ដែលធ្វើឲ្យមានភាពងាយស្រួលក្នុងការចុះបញ្ជីម៉ាក គឺសន្ធិសញ្ញាអន្តរជាតិ ។ អ្នកត្រូវចាំថាម៉ាកនៅពេលចុះបញ្ជីនៅក្នុងប្រទេសមួយគឺគេអាចចុះបញ្ជីជាមួយស្ថាប័នគយនៃដែនដីនោះ ។

**តើស្ថាប័នគយនៃដែនដីមានន័យយ៉ាងណា?**

មានបូរណភាពដែនដីខ្លះមិនទទួលស្គាល់រដ្ឋដែលជាសមាជិក និងខ្លះមិនមែនជាសមាជិកអង្គការសហប្រជាជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ មានបែបបទរដ្ឋបាលខ្លះនៅក្នុងដែនដីនោះ និងការចុះបញ្ជីម៉ាក ។ ឧទាហរណ៍ដ៏ល្អគឺទីក្រុងហុងកុងដែលមានប្រពន្ធ័ចុះបញ្ជីម៉ាកមានលក្ខណៈខុសភាពប្រទេសចិន ។ ដូចនេះប្រសិនបើយើងចង់ការពារម៉ាកនៅហុងកុងគេមាននីតិវិធីចុះបញ្ជីតាមទម្រង់របស់គេ ។

ដូចនេះវាសំខាន់ណាស់ដើម្បីការពារម៉ាកនៅគ្រប់ប្រទេសដែលលោកអ្នកចង់ប្រើប្រាស់ គឺមាននីតិវិធីផ្សេងៗគ្នានៅក្នុងប្រពន្ធ័ច្បាប់ជាតិ ។

អង្គការកម្មសិទ្ធិបញ្ញាពិភពលោកបានប្រឹងប្រែងដើម្បីឱ្យប្រពន្ធ័ច្បាប់ជាតិ និងច្បាប់តំបន់សំរាប់ការចុះបញ្ជីការពារម៉ាកឱ្យកាន់តែមានភាពងាយស្រួល និងនីតិវិធីសាមញ្ញ ។

សន្ធិសញ្ញាស្តីពីច្បាប់ម៉ាកសញ្ញាត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៤ និងចែងពីពត៍មានជាតិនៃរដ្ឋជាសមាជិកត្រូវតែអនុវត្តតាមនិតិវិធីដើម្បីចុះបញ្ជីការពារម៉ាកនៅតាមការិយាល័យចុះបញ្ជីម៉ាកនៃរដ្ឋដែលជាសមាជិក ។

## សង្ខេប

ម៉ាកគឺជាសញ្ញាទំនិញ ឬសេវាកនៃផលិផលរបស់សហគ្រាសមួយដែលមានភាពខុសគ្នាពីអ្នកប្រកួតប្រជែងផ្សេងៗទៀត ។

ផ្នែកនេះបានគ្របដណ្តប់លើមូលដ្ឋាននៃម៉ាក លោកបានដឹងរួចហើយ ម៉ាកមួយគឺជាពាក្យជារូបសញ្ញា ចំនួនលេខ អក្សរ ឬពាក្យស្លោក សម្លេង ពណ៌ ជួនកាលរហូតដល់ក្លិនដែលកំណត់ពីអត្តសញ្ញាណ ប្រភពនៃទំនិញ ឬសេវា ដែលម៉ាកសញ្ញានេះត្រូវបានគេប្រើ ។

ម៉ាកគឺជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា និងគោលបំណងរបស់វា គឺការពារឈ្មោះនៃផលិតផលជាជាងការពារតក្កកម្ម ឬគំនិតនៅពីខាងក្រោយនៃផលិផល ។ ម៉ាកអាចជាម្ចាស់បុគ្គលម្នាក់ឬក្រុមហ៊ុនមួយ ហើយត្រូវបានចុះបញ្ជីនៅការិយាល័យចុះបញ្ជី ។ នៅពេលដែលម៉ាកសញ្ញាមួយត្រូវបានគេប្រើ ប្រាស់ភ្ជាប់ជាមួយសេវា ពេលនោះគេហៅថាសេវាសញ្ញា ។

ជាទូទៅម៉ាកសញ្ញាត្រូវតែមានភាពខុសគ្នា និងត្រូវតែមិនមែនមានលក្ខណៈពិពណ៌នានៃទំនិញ ឬសេវា ។ ជាឧទាហរណ៍ ពាក្យថា "បន្លែ" មិនអាចចុះបញ្ជីជាម៉ាករបស់ហាងSupermarket ទេដោយសារតែវាជាការពិពណ៌នាពីការលក់ផលិតផលក្នុងហាងSupermarketនោះ ។ ជាបន្ថែមទៀត គេមិនអាចធ្វើការចុះបញ្ជីឱ្យឈ្មោះ ការ៉ុត ជាម៉ាកបានទេព្រោះវាជាប្រភេទពាក្យបច្ចេកទេស ម៉្យាងវិញទៀតពាក្យថា "បន្លែ" អាចយកមកប្រើជាម៉ាកលើកង់ដោយសារតែវាគ្មានការទាក់ទងគ្នា ។

ម៉ាកមិនអាចប្រើពាក្យជាភូមិសាស្រ្ត ឬឈ្មោះត្រកូលសំខាន់ ។ ដូច្នេះទីក្រុងបារីសមិនអាចដាក់ជាម៉ាកលើផលិតផលទឹកអប់បានទេ ។ នៅក្នុងប្រទេសជាច្រើនម៉ាក អាចរួមបញ្ចូលអក្សរនិងលេខ ។

ក្នុងករណីជាច្រើន ម៉ាកអាចបញ្ចូលគ្នារវាង ការពិពណ៌នា ឈ្មោះត្រកូល ឈ្មោះទីតាំងភូមិសាស្រ្តឬច្របល់ចូលគ្នា ។

ម៉ាកខ្លះជាឈ្មោះសាខា គឺជាសកម្មភាពជីវិតប្រចាំថ្ងៃ ។ ជាមធ្យមអតិថិជនជួបប្រទះជាង ១ ៥០០ ម៉ាកក្នុងមួយថ្ងៃៗ ដែលមានអត្តសញ្ញាណ និងភាពខុសគ្នា គោលបំណងសំខាន់របស់ម៉ាកគឺការកំណត់នូវប្រភពផលិតផល និងភាពខុសគ្នានៃផលិតផលដែលផលិតពីប្រភពផ្សេងៗគ្នា ឧទាហរណ៍

ម៉ាកមួយអាចជួយអ្នកក្នុងការជ្រើសរើសរវាង សាប៊ូពីរប្រភេទផ្សេងៗគ្នា ។

ជាទូទៅម៉ាករួម និងម៉ាកគុណភាពត្រូវបានការពារនៅលើប្រទេមយយចំនួនច្រើន ។ ជាពិសេសម៉ាកល្បីត្រូវបានគេផ្តល់នូវកិច្ចការពារពិសេស ។

# ជំពូកទី៥
# ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ

__វត្ថុបំណង__

បន្ទាប់ពីអ្នកសិក្សានូវផ្នែកនេះអ្នកអាច ៖

១-ពិពណ៌នាបាន១០០ពាក្យនៃប្រភេទ និងគោលបំណងនៃម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ

២-ផ្តល់ឧទាហរណ៍ខ្លះៗស្តីពីម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ

៣-ពិពណ៌នាបាន១០០ពាក្យពីភាពខុសគ្នារវាងម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ និងប្រភពដើម

៤-ពិពណ៌នាអំពីនីតិវិធីជាតិនៃកិច្ចការពារផលិតផល ឬសេវាក្នុងតំបន់

## សេចក្តីផ្តើម

ការប្រើប្រាស់ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ គឺជាវិធីមួយដ៏សំខាន់ក្នុងការកំណត់ពីប្រភពនៃទំនិញ និង សេវា ។ គោលបំណងមួយក្នុងគោលបំណងជាច្រើននៃការប្រើប្រាស់ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រនេះគឺជំរុញខាងផ្នែកពាណិជ្ជកម្ម តាមរយៈការផ្តល់ពត៌មានដល់អតិថិជនពីប្រភពដើមនៃផលិតផល ។ ជាទូទៅគេអាចបញ្ជាក់ពីគុណភាព ដែលអតិថិជនអាចស្វែងរកទីតាំងទាំងនេះ ហើយក៏អាចត្រូវបានគេប្រើក្នុងវិស័យឧស្សាហកម្ម និង ផលិតផលកសិកម្ម ។ កិច្ចការពារម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រគឺជាមូលដ្ឋានជាតិមួយ ប៉ុន្តែវាមានសន្ធិសញ្ញាអន្តរជាតិដែលចូលរួមក្នុងកិច្ចការពារនៅក្នុងប្រទេសជាច្រើន ។



# ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ

ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រតាមន័យទូលាយគឺរួមបញ្ចូលទាំងប្រភពដើម និងទីកន្លែងដើម ។ Paris Convenntion មិនបានប្រើពាក្យបច្ចេកទេសម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រនេះទេ គឺយើងឃើញប្រើពាក្យប្រភពដើម និងទីកន្លែងដើម ។

ប្រភពដើមមានន័យជាការបង្ហាញណាមួយ ឬសញ្ញាដែលបានប្រើកំណត់ផលិតផល ឬសេវាមួយចេញពីប្រភពដើមនៃប្រទេសមួយ តំបន់មួយ និងទីកន្លែងពិសេសដែលផលិតចេញ ឧទាហរណ៍ធ្វើនៅប្រទេសជប៉ុន ។

ទីកន្លែងដើមមានន័យជាឈ្មោះភូមិសាស្ត្រនៃប្រទេស តំបន់ និងកន្លែងពិសេសដែលបម្រើដល់ការផលិតចេញនូវផលិតផលដើម ដោយមានគុណភាពផ្តាច់មុខ ឬពិសេសនៅក្នុងបរិស្ថានភូមិសាស្ត្រនោះ រួមទាំងកត្តាធម្មជាតិ និងធនធានមនុស្ស ឧទាហរណ៍ស្រាChampagne ។

### តើអ្វីទៅដែលហៅថាម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ?

ជាមូលដ្ឋានម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រមួយ គឺជាការសំគាល់ប្រភពដើមនៃផលិតផលក្នុងតំបន់មួយ ដូចជាម៉ាកសម្គាល់ភូមិសាស្ត្រលើការប្រើប្រាស់ម៉ាកស្រា ឧទាហរណ៍ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រChampagne ត្រូវបានគេប្រើឈ្មោះជាប្រភេទស្រាពិសេសនៃស្រា Sparkling ដែលមានប្រភពដើមនៅតំបន់Champagneនៃប្រទេសបារាំង ។ នៅក្នុងវិធីដូចគ្នានេះ ស្រាគោញ៉ាក់ Cognac ត្រូវបានគេប្រើជាសាខាពីតំបន់នៃជនជាតិបារាំង ជុំវិញទីក្រុងCognac តែទោះបីយ៉ាងណាក៏ដោយ ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រត្រូវគេប្រើសំរាប់ម៉ាកផលិតផលផ្សេងៗទៀត ដូចជាផលិតផលថ្នាំជក់នៅប្រទេសគុយបា ឬផលិតប្រហ្វូម៉ា ហើយអាចត្រូវបានគេប្រើសំរាប់ម៉ាកផលិតផលឧស្សាហកម្មផងដែរ ។

### ចូរអ្នករាប់ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រចំនួន២ ឬ៣ ដែលបានប្រើនៅក្នុងប្រទេសរបស់អ្នក?

ខ្ញុំសង្ឃឹមថាអ្នកអាចរកឃើញ ប្រសិនបើអ្នកមិនបាច់ព្យាយាមគិតថាហេតុអ្វី ។ តើនេះគឺជាគំនិតនៃកម្មសិទ្ធិបញ្ញាដែលគ្មានការទទួលស្គាល់នៃអ្នកផលិតក្នុងតំបន់ ឬក៏ គេមិនអាចយល់ពីតំលៃនៃម៉ាកសម្គាល់ទីតាំងទាំងនេះឬ?

ដូចជាស្រាChampagne ស្រាCogna “Roquefort”, “Chianti”, “Porto” , “Havana”, and “Tequila” គឺមានម៉ាកខ្លះល្បីឈ្មោះនៅលើពិភពលោកជាមួយផលិតផលដែលមានគុណភាព ។

### តើខុសគ្នាយ៉ាងណារវាងម៉ាកសម្គាល់ទីតាំងភូមិសាស្ត និងម៉ាកមួយ ?

ម៉ាកសញ្ញាគឺជាសញ្ញាមួយសំរាប់ពាណិជ្ជករ ឬសំរាប់ក្រុមហ៊ុនប្រើប្រាស់សំរាប់បង្ហាញភាពខុសគ្នានៃទំនិញផ្ទាល់ខ្លួន ឬ សេវាកម្មរវាងទំនិញឬសេវារបស់សហគ្រាសមួយទៀត ។ ម៉ាកសម្គាល់

ទីតាំងភូមិសាស្ត្រ គឺត្រូវបានគេប្រើសំរាប់បង្ហាញនូវផលិតផលចេញពីប្រភពដើមនៃតំបន់ណាមួយ ។ ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ អាចប្រើប្រាស់សម្រាប់អ្នកផលិតទាំងអស់ នៅក្នុងតំបន់នៃប្រភពដើមនោះ ។ ជាឧទាហរណ៍ទីក្រុងBordeaux និងទីក្រុង Champagne អាចត្រូវបានប្រើដោយអ្នកផលិតស្រាទាំងអស់នៅក្នុងទីក្រុង Bordeaux និងទីក្រុង Champagne ។

ខ្ញុំសង្ឃឹមថាឥឡូវនេះលោកអាចយល់ពីផលប្រយោជន៍ ពីការប្រើប្រាស់ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ។

**តើគេអាចការពារម៉ាកទីតាំងភូមិសាស្ត្រយ៉ាងម៉េច?**

វាមិនដូចម៉ាកនិងប្រកាសនីយបត្រតក្កកម្មទេ មានប្រភេទជាច្រើនដើម្បីការពារលើម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ។ គេអាចការពារតាមរយៈច្បាប់ ″ Sui generis ″ នោះគឺជាប្រព័ន្ធដែលប្រទេសបារាំង និងប្រទេសពរ័ទុយហ្គាល់ ឬអាចការពារតាមវិធីផ្សេងៗ គឺត្រូវតែចុះបញ្ជីម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ។

លទ្ធភាពមួយទៀតគឺអាស្រ័យលើច្បាប់ ប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់ ឬពាក់ពន្ធ័នឹងការធ្វើពាណិជ្ជកម្មដោយមិនយុត្តិធម៌គួរតែបញ្ឈប់ ។ ការប្រើប្រាស់ ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រសំរាប់ផលិតផលដែលមិនមែនផលិតចេញពីប្រភពដើមនៃតំបន់ នោះគឺជាការអនុវត្តពាណិជ្ជកម្មមិនស្មោះត្រង់ ។ ប្រសិនបើការការពារនេះស្ថិតនៅក្រោមច្បាប់ស្តីពីការធ្វើពាណិជ្ជកម្មដោយមិនត្រឹមត្រូវនោះមិនចាំបាច់ចុះបញ្ជី ឬ អនុក្រឹត្យ ភាគីដែលរងគ្រោះអាចប្តឹងទៅតុលាការចំពោះរឿងនេះ ។

ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រអាចត្រូវការពារតាមរយៈការចុះបញ្ជីម៉ាករួម ឬម៉ាកគុណភាព ។ ម៉ាករួមគឺជាម្ចាស់កម្មសិទ្ធិរបស់ក្រុមពាណិជ្ជករ ឬអ្នកផលិតច្រើន ។ ម៉្យាងវិញទៀត ម៉ាកគុណភាពមិនមែនជាកម្មសិទ្ធិរបស់នរណាម្នាក់ឡើយ វាស្ថិតនៅលើការចុះបញ្ជីដែលនរណាម្នាក់ ត្រូវការបញ្ជាក់នូវលក្ខខណ្ឌពិសេសដែលត្រូវប្រើប្រាស់ ។ ជាឧទាហរណ៍ ការប្រើប្រាស់ម៉ាកគុណភាព ហ្វ្រូម៉ា Stilton គឺទាល់តែគោរពតាមលក្ខខណ្ឌដែលបានកំណត់ដើម្បីអនុញ្ញាតឱ្យប្រើ ។

ដូច្នេះមានមធ្យោបាយផ្សេងគ្នាជាច្រើន ដែលម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រត្រូវបានទទួលបាននូវកិច្ចការពារ អាស្រ័យលើច្បាប់ជាតិ និងមានវិធីផ្សេងៗគ្នាក្នុងកិច្ចការពារទៅតាមប្រពន្ធ័ច្បាប់អន្តរជាតិ ។

**មានវិធីផ្សេងៗដើម្បីការពារម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រនៅក្នុងប្រទេសរបស់លោក តើវាអាចទទួលបាននូវកាការពារក្នុងពិភពលោកឬទេ?**

តាមទ្រឹស្តីវាអាចទទួលបាននូវកិច្ចការពារ ប៉ុន្តែតាមការអនុវត្តវាពិបាកណាស់ ប្រកាសនីយបត្រតក្កកម្ម និងម៉ាកមាននីតិវិធីជាច្រើន ប៉ុន្តែស្ថានភាពពិតជាមានការខុសគ្នាខ្លាំងណាស់ដោយសារតែ

ប្រពន្ធ័ផ្សេងៗគ្នាក្នុងកាការពារ ។ ប្រពន្ធ័នៅក្នុងស្រុកមិនផ្តល់នូវការចុះបញ្ជីម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ឬផ្តល់នូវសិទ្ធិដើម្បីប្រើប្រាស់ឈ្មោះប្រភពដើម ទាំងនោះគឺជាបញ្ហា ។ ភាពខុសគ្នា ជាទូទៅអាចមានស្ថានភាពពីរ គឺតាមរយៈទ្វេភាគី និងតាមរយៈពហុភាគី ។ នៅក្នុងកិច្ចសន្យាទ្វេភាគី ប្រទេសមួយធ្វើកិច្ចសន្យាជាមួយប្រទេសមួយទៀត ដើម្បីការពារទៅវិញទៅមកនូវម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ បន្ទាប់មកគឺកាផ្លាស់ប្តូរឈ្មោះទីតាំងភូមិសាស្ត្រដែលទាក់ទង ហើយបន្ទាប់មកត្រូវបានការពារនៅពេលបានទទួលបញ្ជីឈ្មោះទាំងនោះ ។ ជាឧទាហរណ៍ ប្រសិនបើប្រទេសបារាំងបានចុះកិច្ចសន្យាជាមួយប្រទេសអេស្ប៉ាញ ពេលនោះប្រទេសអេស្ប៉ាញត្រូវបញ្ជូនឈ្មោះបញ្ជីនៃទីតាំងនោះទៅប្រទេសបារាំង ចំណែកបារាំងក៏បញ្ជូនបញ្ជីនោះទៅប្រទេសអេស្ប៉ាញវិញដែរ ដើម្បីឱ្យឈ្មោះទីតាំងនៃប្រទេសទាំងពីរត្រូវទទួលបាននូវកិច្ចការពារទៅវិញទៅមក ។

កិច្ចការនេះសម្រាប់ប្រទេសទាំងពីរដែលបានចុះកិច្ចព្រមព្រៀង មិនមែនសម្រាប់គ្រប់ប្រទេសនោះទេ វាមានកិច្ចព្រមព្រៀងពហុភាគីផងដែរ ជាការពិតវិធីមួយក្នុងចំណោមវិធី នោះត្រូវបានគ្រប់គ្រងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ហៅថាកិច្ចព្រមព្រៀង លីសបិន សម្រាប់ការពារឈ្មោះប្រភពដើម និង ការចុះបញ្ជីអន្តរជាតិ ។

**តើលោកអាចប្រាប់ពីភាពខុសគ្នានៃឈ្មោះប្រភពដើម និងម៉ាកសម្គាល់ទីតាំងភូមិសាស្ត្របានទេ?**

ឈ្មោះប្រភពដើមគឺមានលក្ខណៈជាក់លាក់ជាងម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ។ ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ គឺជាការសំគាល់នូវផលិតផលដែលផលិតចេញពីតំបន់ពិសេស ។ ជាឧទាហរណ៍ ការបញ្ជាក់ថាធ្វើមកពីប្រទេសស្វីសហ្សឺឡែន គឺជាឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ដែលដឹងថាទំនិញនោះមកពីប្រទេសនោះ ។ ចំណែកឈ្មោះនៃប្រភពដើមគឺជាការបញ្ជាក់ច្បាស់ជាងម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រដែលមានគុណភាព ឬមានគុណភាពពិសេសដោយសារប្រភពដើម ។ ដោយផលិតផលនោះប្រកបដោយគុណភាពពិសេសចេញពីទីកន្លែងដែលបានផលិត ។ ជាសាមញ្ញបំផុតលើផលិតផលកសិកម្ម ដូចជាប្រហូម៉ានៅ Roquefort ។ មនុស្សដែលផលិតប្រហូម៉ានៅតំបន់ Roquefort មានរស់ជាតិពិសេសខុសគេ ។ ប្រសិនបើលោកប្រើនូវវិធីដូចគ្នានៃការធ្វើប្រហូម៉ានេះនៅកន្លែងផ្សេងៗគ្នាពេលនោះរស់ជាតិខុសគ្នា ហើយលទ្ធផលគឺមិនមែនប្រហូម៉ា Roquefort ទេ ដោយសារតែឥទ្ធិពលលក្ខខ័ណ្ឌធម្មជាតិ អាកាសធាតុ ដី ។ល។

ជាទូទៅឈ្មោះនៃប្រភពដើម គឺជាឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រដែលបញ្ជាក់ពីគុណភាពនៃទំនិញសម្រាប់ប្រើប្រាស់ផ្តាច់មុខនៃផលិតផលតំបន់ណាមួយ ។

**ប្រភពដើមChampagne តើជាឈ្មោះប្រភពដើម ឬជាឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ?**

វាអាចជាទាំងពីរ ឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រគឺជាពាក្យទូលាយជាង តែទោះបីជា

យ៉ាងណាក៏ដោយ ក៏វាទៅក្នុងមធ្យោបាយផ្សេង គ្រប់ឈ្មោះនៃប្រភពដើមគឺជាឈ្មោះនៃម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ប៉ុន្តែគ្រប់ឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រមិនមែនសុទ្ធតែឈ្មោះប្រភពដើមទេ ។

<u>សំណួរវាយតំលៃខ្លួនឯង</u>

ចូរអ្នកជ្រើសរើសឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រខាងក្រោម តើមួយណាជាឈ្មោះនៃប្រភពដើម ?

a) Bordeaux wine
b) Stilton Cheese
c) Roquefort Cheese
d) Champagne
e) Sheffield steel
**f)** Made in Japan

<u>ចម្លើយ</u>

a c d Stilton បញ្ជាក់ពីវិធីដែលប្រហូម៉ាធ្វើឡើងមិនមែនបញ្ជាក់ ពីប្រភពដើមទេ Sheffield steel គឺជាឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ប៉ុន្តែមិនបញ្ជាក់ពីគុណភាពមកពីស្ថានភាពនៃ Sheffield នៅប៉ែកខាងជើងនៃប្រទេសអង់គ្លេសទេ ដូចគ្នានឹងឈ្មោះផលិតនៅប្រទេសជប៉ុន ។

ជាសង្ខេបមកឈ្មោះប្រភពដើម គឺជាឈ្មោះនៃម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រដែលបញ្ជាក់ពីគុណភាពនៃទំនិញដែលត្រូវបានគេប្រើផ្តាច់មុខនៅកន្លែងផលិតក្នុងតំបន់មួយ ។

ដូចបានបង្ហាញក្នុងជំពូកនេះពាក្យផ្សេងៗទៀតដែលបានប្រើនៅក្នុង Paris Convention គឺបង្ហាញពីភាពខុសគ្នានៃពាក្យប្រភពដើម ។ ម៉ាកសម្គាល់ភូមិសាស្ត្រគឺមានន័យទូលាយដែលជាកន្លែងផលិតផលបានផលិតចេញ ។ ប៉ុន្តែពាក្យប្រភពដើមនៃទីកន្លែងគឺទាមទារឲ្យមានគុណភាពភ្ជាប់ជាមួយផលិតផលនៅក្នុងតំបនើនោះផង ។

**ភាពខុសគ្នារវាងឈ្មោះប្រភពដើម និងឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ តើវាអាចការពារតាមប្រពន្ធ័អន្តរជាតិឬទេ?**

ជាការពិតមានវិធីជាច្រើន រួមមានលក្ខណៈទូទៅមួយ ដែលបានការពារតាមអនុសញ្ញាក្រុងប៉ារីស ដែលបានចែងថាឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ត្រូវតែបានការពារក្នុងការប្រើប្រាស់ដោយគ្មានការអនុញ្ញាតដែលជាការបន្លំ ។ ចំពោះឈ្មោះនៃប្រភពដើមមានកិច្ចព្រមព្រៀងពិសេសមួយគ្រប់គ្រងដោយអង្គការកម្មសិទ្ធិបញ្ញា ពិភពលោកដែលស្គាល់ថាជាកិច្ចព្រមព្រៀងលីសប៊ិន ដើម្បីការពារនូវឈ្មោះនៃប្រភពដើម និងការចុះបញ្ជីលក្ខណៈអន្តរជាតិ ។ កិច្ចព្រមព្រៀងអន្តរជាតិនេះ ផ្តល់នូវប្រពន្ធ័ចុះបញ្ជីអន្តរជាតិសម្រាប់ឈ្មោះនៃប្រភពដើម ។ ប្រទេសដែលអនុវត្តតាមប្រពន្ធ័ជាតិ សម្រាប់

ការពារឈ្មោះនៃប្រភពដើម អាចដាក់ពាក្យសុំចុះបញ្ជីអន្តរជាតិនៃកិច្ចការពារឈ្មោះនៃប្រភពដើមក្នុងចំណោមរដ្ឋជាសមាជិកនៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងនេះបានអនុវត្តបានល្អ ប៉ុន្តែមានព្រំដែនកំណត់ក្នុងរដ្ឋដែលមានប្រព័ន្ធច្បាប់ជាតិកំណត់សម្រាប់ឈ្មោះនៃប្រភពដើម ។

ឥឡូវនេះមានកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតគឺកិច្ចព្រមព្រៀងTRIPSដែលជាផ្នែកនៃប្រពន្ធ័អង្គការពាណិជ្ជកម្មពិភពលោក ។ កិច្ចព្រមព្រៀងនេះតម្រូវឱ្យសមាជិកទាំងអស់នៃអង្គការពាណិជ្ជកម្មពិភពលោកការពារនូវឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្រ្ត ប្រសិនបើប្រើដោយគ្មានការអនុញ្ញាត ការក្លែងបន្លំ ឬប្រព្រឹត្តប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់ ។ កិច្ចព្រមព្រៀងទ្រីពផ្តល់នូវកំរិតការពារខ្ពស់លើ ឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្រ្តចំពោះផលិតផលស្រា ជៀសវាងការភាន់ច្រឡំ ឬការប្រកួតប្រជែងមិនស្មោះត្រង់ ។

ទោះបីយ៉ាងណាក៏ដោយ ការការពារយ៉ាងទូលាយនេះ គឺមានករណីលើកលែងខ្លះនៃឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្រ្តដែលត្រូវបានគេប្រើយូរមកហើយ ឬត្រូវបានគេប្រើក្នុងបំណងល្អ ។

## សង្ខេប

ឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្រ្តមួយ គឺជាការសំគាល់លើផលិតផលប្រភពដើមនៃតំបន់ភូមិសាស្រ្ត ។ ឈ្មោះនៃប្រភពដើមមួយ គឺមានលក្ខណៈជាក់ច្បាស់ជាងម៉ាកសម្គាល់ទីតាំងភូមិសាស្រ្តដោយមានភ្ជាប់នូវគុណភាពដែលបានផលិតនៅក្នុងតំបន់នោះផ្ទាល់ ។

ដូចបានបញ្ជាក់ខាងលើតាមន័យចង្អៀតគេប្រើឈ្មោះប្រភពដើម និងឈ្មោះកន្លែងប្រភពដើមតាមន័យទូលាយគឺគេប្រើពាក្យម៉ាកសម្គាល់ទីតាំងភូមិសាស្រ្ត ។

ម៉ាកសម្គាល់ទីតាំងភូមិសាស្រ្តអាចត្រូវបានការពារតាមអនុក្រឹត្យ ឬតាមការចុះបញ្ជីក្នុងច្បាប់ជាតិ ។

ជាលក្ខណៈអន្តរជាតិ វាត្រូវបានការពារតាមរយៈការរៀបចំរវាងប្រទេសនៃឈ្មោះម៉ាកសម្គាល់ទីតាំងភូមិសាស្រ្ត ឬកិច្ចព្រមព្រៀងលីសប៊ីន ។ ជាបន្ថែមទៀតកិច្ចព្រមព្រៀង នេះតម្រូវឱ្យសមាជិកទាំងអស់នៃអង្គការពាណិជ្ជម្មពិភពលោកការពារ ។

# ជំពូទី៦
# គំនូរឧស្សាហកម្ម

**<u>វត្ថុបំណង</u>**

បន្ទាប់ពីសិក្សាចប់ជំពូកនេះអ្នកអាច

១-ពន្យល់ពីអ្វីដែលហៅថាគំនូរឧស្សាហកម្មបានចំនួន៥០ពាក្យ

២-ពន្យល់ពីភាពខុសគ្នារវាងកិច្ចការពារគំនូរឧស្សាហកម្ម និងកិច្ចការពារប្រកាសនីយបត្រតក្កកម្ម និង ម៉ាកសញ្ញា

៣-ចូរធ្វើបញ្ជីពីផលប្រយោជន៍នៃកិច្ចការពារគំនូរឧស្សាហកម្មសម្រាប់

-ម្ចាស់ផលិតផល

-អ្នកប្រើប្រាស់ផលិតផល

-សេដ្ឋកិច្ច

៤-ពិពណ៌នាពីវិធីមួយណាដែលគំនូរឧស្សាហកម្មអាចត្រូវទទួលបាននូវកិច្ចការពារ?

## សេចក្តីផ្តើម

ជំពូកនេះពិពណ៌នាពីកិច្ចការពារដែលមាននៅក្នុងកម្មសិទ្ធិបញ្ញាហៅថាគំនូរឧស្សាហកម្ម ។ ទស្សនៈគំនូរឧស្សាហកម្មពិពណ៌នាពីផលប្រយោជន៍ដែល អាចទទួលបានពីកិច្ចការពារ ។

### អ្វីដែលហៅថាគំនូរឧស្សាហកម្ម?

គំនូរឧស្សាហកម្មមួយគឺជាទិដ្ឋភាពនៃអត្ថបទដែលមានប្រយោជន៍សម្រាប់ការតុបតែង ឬបង្កើនសម្រស់ វាអាចផ្សំនៅលក្ខណៈពិសេសបីដូចជាផ្ទៃមុខ ឬលក្ខណៈពិសេសពីរបន្ថែមដូចជាខ្សែរ ពណ៌ ។

គំនូរឧស្សាហកម្ម គឺធ្វើទៅតាមភាពផ្សេងៗគ្នានៃផលិតផលឧស្សាហកម្ម ឬសិប្បកម្ម ដូចជានាឡិកាដៃ គ្រឿងអាល្លែងកា ភាពទំនើប ឬអ្វីៗដែលអស្ចារ្យផ្សេងៗទៀត ជាពិសេសគ្រឿងឧស្សាហកម្ម និងបរិក្ខារពេទ្យ សំភារៈនៅក្នុងផ្ទះ គ្រឿងសង្ហារឹម អគ្គីសនី រថយន្ត និងសំភារៈស្ថាបត្យកម្មផ្សេងៗ គំនូរឧស្សាហកម្មដោយដៃ និងទំនិញផ្សេងៗ ដើម្បីកំសាន្ត និងតុក្កតានានា ។



ជាឧទាហរណ៍រូបរាងកៅអី ទូរសព្ទ័ រថយន្ត កុំព្យូទ័រ យន្តហោះ ទូរទស្សន៍ នាឡិកា កាំមេរ៉ា ។

**ម៉ាកគឺជាសញ្ញាដែលមើលឃើញមានភ្ជាប់ជាមួយទំនិញឬសេវា ចំណែកប្រកាសនីយបត្រតក្កកម្មគឺ ប្រើដើម្បីការពារតក្កកម្មនៃការផលិត តើខុសគ្នាយ៉ាងម៉េចរវាងម៉ាក និង គំនូរឧស្សាហកម្ម ?**

គំនូរឧស្សាហកម្មគឺខុសគ្នាពីម៉ាក ពីព្រោះវាលេចរូបរាងនៅលើផលិតផល ។ ម៉ាកអាចរួមផ្សំសញ្ញាដែលអាចមើលឃើញ អាចតុបតែង ឬមិនអាចតុបតែងលំអ តែត្រូវតែប្លែកពីគ្នាដោយសារតែម៉ាកដែលធ្វើឲ្យមានលក្ខណៈខុសពីគ្នានៃ ទំនិញ និងសេវារបស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងៗទៀត ។ អាស្រ័យហេតុនេះតួនាទី និងការវាយតម្លៃសម្រាប់ការពារគំនូរឧស្សាហកម្ម និងម៉ាកពិតជាមានលក្ខណៈខុសគ្នា ។

កម្មវត្ថុនៃកិច្ចការពារគំនូរឧស្សាហកម្ម គឺខុសគ្នាពីកិច្ចការពារប្រកាសនីយបត្រតក្កកម្ម ដោយសារតែគំនូរឧស្សាហកម្មត្រូវតែទាក់ទងរូបរាងខាងក្រៅ ដែលមិនមែនជាការកំណត់បច្ចេកទេស ឬការចាំបាច់នៃតួនាទី ។ ផ្ទុយទៅវិញកម្មវត្ថុនៃ កិច្ចការពារប្រកាសនីយបត្រតក្កកម្ម គឺកំណត់តួនាទីដំណើរការផលិតចាប់តាំងតែពីបានតក្កកម្ម ។

<u>សំណួរវាយតម្លៃខ្លួនឯង</u>

១-តើទម្រង់ដែលសាមញ្ញបំផុតនៃកិច្ចការពារផលិតផលដូចខាងក្រោមគឺអ្វី

ក-ប៉ាន់តែមួយ



ខ-ទម្រង់ថ្មីមួយនៃម៉ូទ័រអេឡិចត្រិច

គ-រូបសញ្ញាLOGOនៃសាកលវិទ្យាល័យដែលបើកថ្មី

<u>ចម្លើយ</u>

ក-មធ្យោបាយដែលស្រួលបំផុតដើម្បីការពារកម្មសិទ្ធបញ្ញា គឺការការពារនៃគំនូរឧស្សាហកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើប៉ាន់តែនោះមានលក្ខណៈតក្កកម្មថ្មី អាចត្រូវទទួលបានកិច្ចការពារតាមប្រកាសនីយបត្រតក្កកម្ម ។

ខ-មធ្យោបាយដែលងាយបំផុតគឺតាមរយៈការប្រើប្រាស់ប្រកាសនិយបត្រតក្កកម្ម ។

គ-រូបសញ្ញានេះគឺត្រូវគេប្រើជាម៉ាកដូចនេះអាចការពារតាមម៉ាក ។

**ហេតុអ្វីបានជាត្រូវការពារគំនូរឧស្សាហកម្ម?**

តាមរយៈកិច្ចការពារគំនូរឧស្សាហកម្ម ម្ចាស់គំនូរឧស្សាហកម្មត្រូវបានគេផ្តល់ឱ្យនូវសិទ្ធិប្រឆាំង

ការចម្លងដោយគ្មានការអនុញ្ញាត ឬការបន្លំពីភាគីទី៣ ។ ម្យ៉ាងទៀតម្ចាស់កម្មសិទ្ធិដែលទទួលបាននូវកិច្ចការពារ មានសិទ្ធិការពាររាល់ការធ្វើ លក់ ឬនាំចូលនូវម៉ាករបស់ខ្លួន ។

ដោយសារតែគំនូរឧស្សាហកម្ម គឺជាទិដ្ឋភាពមួយដែលបង្ហាញនូវការតុបតែង និងការទាក់ទាញ ហើយបន្ថែមនូវតម្លៃនៃផលិតផល និងភាពងាយស្រួលនៅលើទីផ្សារ ព្រមទាំងការធ្វើពាណិជ្ជកម្ម ។

ដើម្បីការពារក្រោមច្បាប់ជាតិ គំនូរឧស្សាហកម្មត្រូវតែមើលឃើញដោយភ្នែក ។ គំនូរឧស្សាហកម្មមិនការពារលើលក្ខណៈបច្ចេកទេសទេ ។

## ការពារគំនូរឧស្សាហកម្មផ្តល់ប្រយោជន៍ដល់ម្ចាស់សិទ្ធិ តើវាមានប្រយោជន៍ដល់អ្នកផ្សេងទេ?

ជាការពិត ម្ចាស់សិទ្ធិគំនូរឧស្សាហកម្មតាមរយៈការអភិវឌ្ឍន៍ផលិតផលរបស់គាត់ និងកិច្ចការពារ បានជួយធានារកចំណូលចូលវិញដោយយុត្តិធម៌លើការវិនិយោគគាត់ ។

ទោះបីយ៉ាងណាក៏ដោយ អ្នកប្រើប្រាស់ និងសាធារណៈជនអាចទទួលផលប្រយោជន៍ផងដែរ តាមរយៈកិច្ចការពារគំនូរឧស្សាហកម្ម គឺការប្រកួតប្រជែងដោយយុត្តិធម៌ និងធ្វើពាណិជ្ជកម្មដោយស្មោះត្រង់ លើកទឹកចិត្តបង្កើតថ្មី ដើម្បីតុបតែងធ្វើឲ្យមានការទាក់ទាញលើផលិតផលទាំងនោះ ។

ជាបន្ថែមកិច្ចការពារគំនូរឧស្សាហកម្មរួមចំណែកក្នុងឧស្សាហកម្ម និងរោងចក្រសហគ្រាស ដើម្បីពង្រីកសកម្មភាពពាណិជ្ជកម្ម និងលើកទឹកចិត្តលើការនាំចេញនូវផលិតផលក្នុងស្រុក ។

ដូចនេះកិច្ចការពារគំនូរឧស្សាហកម្មមានផលប្រយោជន៍ដល់ម្ចាស់សិទ្ធិ ជាទូទៅដល់អ្នកប្រើប្រាស់ និងសេដ្ឋកិច្ចជាតិ សារសំខាន់មួយទៀតគឺទាក់ទងដល់ការអភិវឌ្ឍន៍ ។ ហេតុនេះពួកគេអាចចូលទៅក្នុងទម្រង់ឧស្សាហកម្មធន់មធ្យមដោយសមស្រប ទោះបីជាសិល្បករ ឬសិប្បករផ្ទាល់ខ្លួនទាំងវិស័យឧស្សាហកម្ម និងការអភិវឌ្ឍន៍ប្រទេសជាតិ ។

## តើគំនូរឧស្សាហកម្មអាចត្រូវបានការពារយ៉ាងដូចម្តេច?

ក្នុងប្រទេសជាច្រើនគំនូរឧស្សាហកម្មមួយ ត្រូវតែចុះបញ្ជីក្នុងគោលបំណងការពារក្រោមច្បាប់គំនូរឧស្សាហកម្ម ។ ជាវិធានទូទៅដើម្បីចុះបញ្ជីបាន គំនូរឧស្សាហកម្មនោះត្រូវតែ ថ្មី ហើយOriginal ។ ឥឡូវនេះភាពថ្មី និងOriginal អាចខុសពីប្រទេសមួយទៅប្រទេសមួយទៀត ហើយដំណើរការចុះបញ្ជីមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ជាពិសេសអាចទាក់ទងដល់ការត្រួតពិនិត្យឬមិនត្រួតពិនិត្យ ទៅតាមទម្រង់នៃពាក្យសុំចុះបបញ្ជីគំនូរឧស្សាហកម្ម ជាពិសេសការកំណត់ភាពថ្មី និងភាព Original ។

គំនូរឧស្សាហកម្មត្រូវតែអាចដំណើរការផលិតឡើងវិញតាមមធ្យោបាយឧស្សាហកម្ម ។ វាក៏អាចអនុវត្តបានចំពោះទម្រង់ពីរវិមាត្រ ឬ ទាំងបីវិមាត្រ ។



ជាគោលការណ៍ គំនូរឧស្សាហកម្មត្រូវតែផ្សព្វផ្សាយទាំងមុនពេលដំណើរការ និងពេលដំណើរការចុះបញ្ជី ។ អាស្រ័យលើច្បាប់ជាតិ និងជួនកាលអាស្រ័យលើការសម្រេចរបស់អ្នកដាក់ពាក្យសុំ ។

ជាងនោះទៅទៀត គួរតែចាំថាការចុះបញ្ជីគំនូរឧស្សាហកម្មគឺមិនមែនជាមធ្យោបាយចាំបាច់តែមួយដើម្បីការពារទេ ។ ជាការពិតប្រសិនបើលក្ខ័ណ្ឌតម្រូវ កិច្ចការពារគំនូរ ឧស្សាហកម្មអាចស្ថិតនៅក្រោមច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឬច្បាប់ប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

អ្នកផលិតក្រណាត់ចង់ផ្សព្វផ្សាយនូវម៉ូតទាន់សម័យថ្មី ឬអាវយឺតតាមសីរីរបស់គាត់ក្នុងរូបភាព៣ខុសគ្នានៃពណ៌ គឺខៀវ ស និងបៃតង ។ តើអាវយឺតទាំងនេះអាចទទួលបាននូវកិច្ចការពារឬទេ តាមរយៈគំនូរឧស្សាហកម្មឬទេ ?

<u>ចម្លើយ</u>

មិនអាចការពារទេ ដោយសារអាវយឺតមិនបានបង្ហាញនូវដំណើរការថ្មី ឬOriginal ។ តែទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើសំភារៈដែលបានប្រើប្រាស់ក្នុងការផលិតអាវយឺតនោះថ្មី ឬ Original ឬរូបរាងអាវយឺតនោះថ្មី អាចត្រូវបានការពារ ។

**តើកិច្ចការពារនោះមានរយៈពេលប៉ុន្មានឆ្នាំ?**

មានភាពខុសគ្នារវាងប្រទេសមួយទៅប្រទេសមួយ ប៉ុន្តែរយៈពេលការពារគឺរយៈពេល៥ឆ្នាំ ដោយអាចចុះបញ្ជីការពារថ្មីឡើងវិញរហូតដល់១៥ទៅ២៥ឆ្នាំ ។ រយៈពេលការពារជាអប្បបរមា១០ឆ្នាំ តាមកិច្ចព្រមព្រៀងទ្រីព ។

**តើគំនូរឧស្សាហកម្មអាចការពារតាមច្បាប់សិទ្ធិអ្នកនិពន្ធបានឬទេ?**

វាអាស្រ័យលើច្បាប់ និងប្រភេទគំនូរឧស្សាហកម្ម គំនូរឧស្សាហកម្មមួយអាចត្រូវបានកាពារជាស្នាដៃសិល្បៈក្រោមច្បាប់សិទ្ធិអ្នកនិពន្ធ ។ ក្នុងករណីប្រទេសខ្លះ ច្បាប់គំនូរឧស្សាហកម្ម និងច្បាប់សិទ្ធិអ្នកនិពន្ធអាចមានប្រសិទ្ធភាពដូចគ្នា នេះមានន័យថាប្រភេទ នៃកិច្ចការពារទាំងពីរនេះអាចមានរួមគ្នា ។ ទោះបីជាយ៉ាងណាក៏ដោយក្នុងប្រទេសផ្សេងៗទៀត ប្រសិនបើសិទ្ធិអ្នកនិពន្ធត្រូវបាន

អនុញ្ញាតការពារគំនូរឧស្សាហកម្ម ។ នេះមានន័យថាម្ចាស់សិទ្ធិអាចជ្រើសរើសយកសិទ្ធិដែលត្រូវការពារមួយក្នុងចំណោមទាំងពីរ ។

**តើមានការពារអ្វីទៀតសម្រាប់គំនូរឧស្សាហកម្ម?**

ក្នុងស្ថានភាពខ្លះ និងក្នុងប្រទេសខ្លះគំនូរឧស្សាហកម្ម អាចត្រូវបានកាពារក្រោមច្បាប់ប្រកួតប្រជែងមិនស្មោះត្រង់ ។ ប៉ុន្តែវាអាចទទួលសំណងរដ្ឋប្បវេណីផ្សេងៗតាមទម្រង់ការពារទាំងនេះ ។

**តើអាចកាពារគំនូរឧស្សាហកម្មជាលក្ខណៈពិភពលោកបានទេ?**

តាមវិធានទូទៅ ដោយយោងតាមអនុសញ្ញា Paris convention កិច្ចការពារគំនូរឧស្សាហកម្ម គឺមានកំណត់ចំពោះប្រទេសដែលបានផ្តល់ឱ្យ ។ ប្រសិនបើកិច្ចការពារចង់ធ្វើនៅប្រទេសជាច្រើន ពាក្យសុំតាមប្រទេសនីមួយៗត្រូវធ្វើផ្សេងៗគ្នា(ឬតម្កល់)ត្រូវតែធ្វើឡើង និងមាននីតិវិធីខុសគ្នានៅប្រទេសមួយៗ ។ ទោះបីជាកិច្ចព្រមព្រៀងទីក្រុង Hague ទាក់ទងទៅនឹងការតម្កល់គំនូរឧស្សាហកម្មសម្រាប់និតិវីធីងាយស្រួលក៏ដោយ ។

## សង្ខេប

គំនូរឧស្សាហកម្មមួយគឺជាទិដ្ឋភាពដ៏សំខាន់ ដែលមានការតុបតែង ។ វាអាចរួមមានលក្ខណៈពិសេសបីផ្សេងគ្នា ដូចជារូបរាងផ្ទៃខាងក្រៅ ឬលក្ខណៈពិសេសពីរ ដូចជាបានលេចឡើងនូវខ្សែបន្ទាត់ ឬពណ៌ ដោយមានទម្រង់ផ្សេងទៀតនៃកម្មសិទ្ធិបញ្ញាត្រូវបានការពារ ។

តាមរយៈកិច្ចការពារគំនូរឧស្សាហកម្ម ម្ចាស់សិទ្ធិគឺត្រូវបានធានា និងមានសិទ្ធិផ្តាច់មុខប្រឆាំងនឹងការចម្លងដោយគ្មានការអនុញ្ញាត ឬបន្លំពីភាគីទី៣ ហើយមានរយៈពេលការពារ៥ឆ្នាំ ដោយអាចចុះបញ្ជីកាពារសារឡើងវិញ និងមានរយៈពេលអតិប្បរមា១៥ ទៅ២៥ ឆ្នាំ យោងទៅតាមច្បាប់ជាតិ ។ ចំណែកកិច្ចព្រមព្រៀងទ្រីព មានរយៈពេលការពារអប្បរមា១០ឆ្នាំ ។

នៅក្នុងប្រទេសជាច្រើន គំនូរឧស្សាហកម្មត្រូវតែចុះបញ្ជី ក្នុងគោលបំណងការពារក្រោមច្បាប់គំនូរឧស្សាហកម្ម ជាវិធានទូទៅដើម្បីចុះបញ្ជីគំនូរត្រូវតែថ្មី ឬOriginal ។ ឥឡូវនេះតើ មានភាពខុសគ្នាយ៉ាងណារវាងពាក្យថ្មីOriginal នៅប្រទេសមួយទៅប្រទេសមួយ? ជាការពិតគឺដំណើរការនៃការចុះបញ្ជីមានលក្ខណៈផ្សេងៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ។ ជាពិសេសទាក់ទងការត្រួតពិនិត្យ ឬអត់មិនត្រួតពិនិត្យនូវបែបបទស្នើសុំ ដើម្បីកំណត់ពីភាពថ្មី ឬOriginal ។ ហើយគំនូរឧស្សាហកម្មត្រូវតែអាចដំណើរការបានតាមរយៈ មធ្យោបាយឧស្សាហកម្ម ។

# ជំពូកទី៧
# ប្រកាសនីយបត្រតក្កកម្ម

__វត្ថុបំណង__

បន្ទាប់ពីបានសិក្សាចប់នៃជំពូកនេះលោកអ្នកអាច ៖

១-ពិពណ៌នាបាន១០០ពាក្យពីគោលបំណងនៃប្រកាសនីយបត្រតក្កកម្ម

២-ធ្វើបញ្ជីទទួលស្គាល់ជាទូទៅនូវលក្ខខណ្ឌប្រកាសនីយបត្រតក្កកម្ម

៣-ប្រាប់ឈ្មោះនៃសិទ្ធិផ្តាច់មុខដោយយោងតាមប្រកាសនីយបត្រតក្កកម្ម

៤-តើនរណាទទួលខុសត្រូវលើការផ្តួចផ្តើមអនុវត្តប្រកាសនីយបត្រតក្កកម្ម

៥-ពន្យល់ហេតុអ្វីបានជាត្រូវមានប្រកាសនីយបត្រតក្កកម្មក្នុងប្រទេសណាមួយ មុនពេលដែលអ្នកអាចប្តឹងចំពោះការរំលោភបំពាននៅក្នុងប្រទេសនោះ

៦-ពិពណ៌នាពីនិតិវិធី នៅពេលដែលពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មមួយ ត្រូវបំពេញក្នុងថ្នាក់ជាតិ ឬតំបន់ ឬ PCT ។

## សេចក្តីផ្តើម

ប្រកាសនីយបត្រតក្កកម្ម គឺជាផ្នែកមួយនៃទម្រង់ចាស់ជាងគេបំផុតនៃកម្មសិទ្ធិបញ្ញា គោលបំណងនៃប្រកាសនីយបត្រតក្កកម្ម គឺលើកទឹកចិត្តលើផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍន៍បច្ចេកវិទ្យា តាមរយៈការលើកទឹកចិត្តសកម្មភាពកម្មសិទ្ធិបញ្ញា ។ ជំពូកនេះ នឹងពន្យល់អ្នកពី: គោលបំណងនៃប្រកាសនីយបត្រតក្កកម្ម ផលប្រយោជន៍ដែលទទួលបានពីប្រកាសនីយបត្រតក្កកម្ម តើប្រភេទវត្ថុអ្វីដែលអាចចុះប្រកាសនីយបត្រតក្កកម្ម និងរយៈពេលការពាររួមទាំងអាចពន្យល់ពីប្រភេទប្រព័ន្ធការពារជាអន្តរជាតិ ។

## ប្រកាសនីយបត្រតក្កកម្ម

### តើប្រកាសនីយបត្រតក្កកម្មគឺអ្វី?

ចូរយើងចាប់ផ្តើមដមបូងនូវសំណួរតើប្រកាសនីយបត្រតក្កកម្មជាអ្វី? គឺអាស្រ័យលើពាក្យសុំឬការិយាល័យប្រកាសនីយបត្រតក្កកម្មរបស់រដ្ឋាភិបាល ប្រកាសនីយបត្រតក្កកម្មគឺជាឯកសារដែលពិពណ៌នាអំពីតក្កកម្ម និងការបង្កើតថ្មីក្នុងស្ថានភាពស្របច្បាប់ ដែលតក្កកម្មនោះអាចត្រូវបានគេធ្វើអាជីវកម្មដោយមានការអនុញ្ញាតពីម្ចាស់ ។ ម្យ៉ាងទៀតប្រកាសនីយបត្រតក្កកម្មការពារតក្កកម្ម

និងផ្តល់សិទ្ធិដល់ម្ចាស់សិទ្ធិនៅសិទ្ធិផ្តាច់មុខដើម្បីប្រើប្រាស់នូវតក្កកម្មរបស់ខ្លួនក្នុងរយៈពេលកំណត់ ហើយតក្កកម្មនោះអាចមានដំណោះស្រាយថ្មីលើបញ្ហាបច្ចេកទេស ។

ឧទាហរណ៍តក្កកម្មជាច្រើនដូចជាៈជំនួយខាងឧបករណ៍តន្ត្រី ឆ្នាំងអ៊ុតអគ្គីសនី ទូរសព្ទ័ជាដើម

## តើអ្វីជាគោលបំណងប្រកាសនីយបត្រតក្កកម្ម?

គោលបំណងប្រកាសនីយបត្រតក្កកម្មគឺផ្តល់ទម្រង់ការពារបច្ចេកវិទ្យាទំនើប ។ តាមទ្រឹស្តីកិច្ចការពារប្រកាសនីយបត្រតក្កកម្ម គឺផ្តល់ការលើកទឹកចិត្តមិនមែនត្រឹមតែការបង្កើតតក្កកម្មថ្មីប៉ុណ្ណោះ ទេថែមទាំងការអភិវឌ្ឍន៍តក្កកម្មដែលជាចំណុចបច្ចេកទេស និងទីផ្សារ ប្រភេទនេះជំរុញបន្ថែមលើសកម្មភាពលើកទឹកចិត្តដល់ក្រុមហ៊ុនដើម្បីបន្តអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីដល់ទីផ្សារ និងមានប្រយោជន៍ដល់សាធារណៈ ។

## តើប្រពន្ធ័ប្រកាសនីយបត្រតក្កកម្មចាប់ផ្តើមពីពេលណា?

វាបានវិវឌ្ឍជាច្រើនសតវត្សមកហើយ មានតាំងពីឆ្នាំ១៧០០មកម្ល៉េះ ។ ប្រពន្ធ័នេះមានដំណើរការជាច្រើនឆ្នាំមកម្លេះ ហើយឥឡូវនេះយើងមានប្រពន្ធ័ទំនើបមួយ ។ យើងកំពុងតែអភិវឌ្ឍប្រពន្ធ័អន្តរជាតិ ដើម្បីធ្វើវាឱ្យកាន់តែទំនើបទៅតាមប្រពន្ធ័នៃការផ្លាស់ប្តូរបច្ចេកវិទ្យា និង ផ្លាស់ប្តូរប្រពន្ធ័សេដ្ឋកិច្ច ។




<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

## តើអ្វីទៅជាគោលបំណងចំបងនៃប្រកាសនីយបត្រតក្កកម្ម?

គោលបំណងប្រកាសនីយបត្រតក្កកម្មគឺការពារការបង្កើតបច្ចេវិទ្យាថ្មីទំនើប ។ វាផ្តល់ការលើកទឹកចិត្តលើការបង្ហាញតក្កកម្មថ្មីព្រមទាំងការអភិវឌ្ឍន៍បន្ថែមទៀត ឬការបង្កើតបច្ចេកវិទ្យាថ្មី ។ ជាសរុបតាមរយៈប្រកាសនីយបត្រតក្កកម្មអាចធ្វើឱ្យមានការផ្លាស់ប្តូរបច្ចេវិទ្យាល្អ ដើម្បីភាពរីកចំរើន ។

## តើវត្ថុអ្វីដែលអាចទទួលបាននូវប្រកាសនីយបត្រតក្កកម្ម?




តាមរយៈកិច្ចព្រមព្រៀងអន្តរជាតិ រាល់តក្កកម្មអាចជាប្រកាសនីយបត្រតក្កកម្មទាំងដំណើរការផលិតកម្ម និងផលិតផលនៅគ្រប់ផ្នែកនៃបច្ចេកវិទ្យា ។ សមាសធាតុគីមីក៏អាចទទួលបានប្រកាសនីយបត្រតក្កកម្មដែរ ម៉ាស៊ីនក៏អាចទទួលបានប្រកាសនីយបត្រតក្កកម្ម ។ ដំណើរការអភិវឌ្ឍ ឬការធ្វើអ្វីមួយ អាចជាប្រកាសនីយបត្រតក្កកម្ម ។ វាមានតិចតួចណាស់ដែលមិនអាចជាប្រកាសនីយបត្រតក្កកម្ម ហើយទាំងអស់នេះជាករណីលើកលែង ។ ជាឧទាហរណ៍ ហ្សែនរបស់មនុស្ស មិនអាចជាប្រកាសនីយបត្រតក្កកម្មទេ វត្ថុដែលមានក្នុងធម្មជាតិរួចមក ហើយមានករណីលើកលែងខ្លះដែលមិនអាចប្រកាសនីយបត្រតក្កកម្ម ។ ចលនាជាអចិន្ត្រៃយ៍នៃម៉ាស៊ីនដែលប្រព្រឹត្តផ្ទុយនឹងធម្មជាតិ មិនអាចប្រកាសនីយបត្រតក្កកម្ម លុះត្រាតែគេអាចបង្ហាញពីការងាររបស់វាដែលជំនួសច្បាប់ថ្មីវិញ ។ មានតក្កកម្មខ្លះមិនអាចជាប្រកាសនីយបត្រតក្កកម្មទេដោយសារវាផ្ទុយនឹងផលប្រយោជន៍សាធារណៈ និងផ្ទុយនឹងសីលធម៌សង្គម ។

ប្រកាសនីយបត្រតក្កកម្មគឺមានបំណងបញ្ជូនចូលតាមបច្ចេកវិទ្យា ប៉ុន្តែក៏អាចចូលតាមតិចណូឡូស៊ីតូចតាច ដូចនេះការអភិវឌ្ឍកើតមានក្នុងតំបន់នៃបច្ចេកវិទ្យាដែលអាចផ្តល់ប្រកាសនីយបត្រតក្កកម្មដែលជាតំបន់អភិវឌ្ឍ ដូចជាការរកឃើញថ្នាំប៉េនីសលីន ឬការអភិវឌ្ឍតិចតួច ដូចជាម៉ាស៊ីនដែលអាចធ្វើការបានលឿនជាងមុនបន្តិច ប្រភេទទាំងនេះគឺអាចទទួលបានប្រកាសនីយបត្រតក្កកម្ម ។

ដូចនេះប្រកាសនីយបត្រតក្កកម្មគឺការពារតក្កកម្មថ្មី និងមានប្រយោជន៍ ។ លោកអាចដឹងនូវប្រភេទតក្កកម្មខ្លះដែលទទួលបានប្រកាសនីយបត្រតក្កកម្ម និង មានករណីខ្លះលើកលែង ។ ដើម្បីទទួលបាននូវប្រកាសនីយបត្រតក្កកម្ម ទាល់តែតក្កកម្មនោះថ្មី និងមានលក្ខណៈពិសេសផ្សេងទៀត ។ នៅក្នុងកិច្ចព្រមព្រៀងTRIPS Agreement មានកំណត់លក្ខណៈ៣ប្រភេទនិងលក្ខខណ្ឌផ្សេងទៀតសម្រាប់តក្កកម្មដែលអាចជាប្រកាសនីយបត្រតក្កកម្ម ។

### តើលក្ខណៈអ្វីដែលអាចទទួលបានប្រកាសនីយបត្រតក្កកម្ម ?

មានលក្ខណៈជាច្រើនដែលការិយាល័យប្រកាសនីយបត្រតក្កកម្មកំណត់ថា តើតក្កកម្មនោះអាចទទួលបានប្រកាសនីយបត្រតក្កកម្ម ឬអត់ សំខាន់ត្រូវមានពាក្យសុំ ។ ក្នុងករណីជាច្រើន ការស្នើសុំត្រូវបានត្រួតពិនិត្យតាមរយៈ អ្នកជំនាញដើម្បី ធានាថាត្រឹមត្រូវ ។

ទី១-គឺតក្កកម្មនោះត្រូវតែថ្មី មានន័យថាតក្កកម្មនោះ មិន មានពីមុន ឬប្រើប្រាស់មកឡើយ ។

ទី២-គឺត្រូវតែមានជំហ៊ានបង្កើតថ្មី ម៉្យាងទៀតវាត្រូវតែបង្ហាញឱ្យបានគ្រប់គ្រាន់ពីប្រយោជន៍សង្គម មុននឹងទទួលបានប្រកាសនីយបត្រតក្កកម្ម និងជាអ្នកមានជំនាញក្នុងវិស័យនោះ ប្រសិនបើគ្មានជំនាញគេមិនអាច បញ្ជាក់ពីគុណភាពសំរាប់ការការពារប្រកាសនីយបត្រតក្កកម្មទេ ។

ទី៣-គឺអាចយកមកអនុវត្តក្នុងវិស័យឧស្សាហកម្ម ត្រូវតែមានភាពងាយស្រួលក្នុងការប្រើប្រាស់តាមមធ្យោបាយខ្លះ ។ អ្វីៗទាំងអស់អាចត្រូវបានប្រើប្រាស់ ទោះបីជាស្ថិតនៅក្នុងដំណាក់កាលស្រាវជ្រាវក៏ដោយ ប៉ុន្តែអ្វីដែលបានបញ្ជាក់ខាងលើគឺមិនស្របទៅតាមចលនាម៉ាស៊ីនទេព្រោះវាមិនធ្វើការ ។

ជាសង្ខេបមកដើម្បីទទួលបាននូវប្រកាសនីយបត្រតក្កកម្ម តក្កកម្មត្រូវតែថ្មី មានជំហានរកឃើញថ្មី និងអាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**តើជំហ៊ានរកឃើញថ្មីត្រូវទទួលស្គាល់យ៉ាងម៉េច ?**

ជំហ៊ានរកឃើញថ្មីគឺជាការចាំបាច់ណាស់ដែលត្រូវផ្តល់ប្រកាសនីយបត្រតក្កកម្ម ។ តែទោះបីជាយ៉ាងណាក៏ដោយ តក្កកម្មត្រូវតែមានលក្ខណៈគ្រប់គ្រាន់ និងជឿនលឿនដែលត្រូវចាត់ទុកថាលក្ខណៈពិសេស តាមរយៈមនុស្សដែលមានជំនាញខ្ពស់ ហើយមនុស្សដែលគ្មានជំនាញក៏អាចប្រើបាន នោះជាប្រកាសនីយបត្រតក្កកម្ម ។

**តើការសុំគំនូរឧស្សាហកម្មយ៉ាងម៉េច?**

ដើម្បីដាក់ស្នើសុំប្រកាសនីយបត្រតក្កកម្មក្រោម" ពាក្យស្នើសុំគំនូរឧស្សាហកម្ម" គឺតក្កកម្ម ត្រូវតែអាចប្រើប្រាស់នៅក្នុងទម្រង់ណាមួយនៃការអនុវត្តន៍ ដូចជាក្នុងចលនាម៉ាស៊ីនដែលត្រូវបានផ្តល់ឲ្យតាមរយៈការបង្ហាញខាងលើ ។

នៅក្នុងប្រទេសជាច្រើន តក្កកម្មគឺទាក់ទងនឹងដំណោះស្រាយថ្មីខាងបញ្ហាបច្ចេកវិទ្យា ។ កិច្ចការពារក្រោមច្បាប់ប្រកាសនីយបត្រតក្កកម្ម មិនតំរូវឱ្យតក្កកម្មនោះ ត្រូវមានរូបរាងនៅក្នុងរូបវិទ្យាទេ ។ ជាងនោះទៅទៀតវាមិនបញ្ចូលប្រភេទណាមួយក្នុងករណីលើកលែង ឬក្នុងច្បាប់ជាតិ ។

មានការណែនាំទូទៅខ្លះដែលទាក់ទងប្រភេទវត្ថុដែលអាច ឬ មិនអាចទទួលបានប្រកាសនីយបត្រតក្កកម្មដែលត្រូវបានពិភាក្សា ។

ករណីលើកលែងដែលបានបង្ហាញខាងលើគឺ ៖

-វត្ថុដែលមាននៅក្នុងធមជាតិដែលជារបកញ៉ំហើញដែលមិនមែនជាតក្កកម្ម ជាឧទាហរណ៍មួយដែលមិនអាចទទួលបានប្រកាសនីយបត្រតក្កកម្មគឺការរកឃើញផែនដីថ្មី ។ ម៉ាស៊ីនដែលបំពានច្បាប់ធម្មជាតិដូចជាការធ្វើចលនាជាអចិន្ត្រៃយ៍នៃម៉ាស៊ីន ។

ករណីលើកលែងផ្សេងៗទៀតក្រោមច្បាប់ជាតិ ឬកិច្ចព្រមព្រៀងទ្វេពគឺ:

-ទ្រឹស្តីវិទ្យាសាស្ត្រ ឬវិធីសាស្ត្រគណិតវិទ្យា

-គ្រោងការច្បាប់ ឬវិធីសាស្ត្រ សម្រាប់ធ្វើពាណិជ្ជកម្ម ការសម្តែងចេញពីគំនិត ឬហ្គាមផ្សេងៗ

-វិធីសាស្ត្រនៃការព្យាបាលជំងឺមនុស្ស ឬសត្វ ឬវិធីវិភាគរោគ (ប៉ុន្តែផលិតផល ប្រើប្រាស់ក្នុងការវិភាគរោគអាចទទួលបានប្រកាសនីយបត្រតក្កកម្ម) ។

-មីក្រូសរីរាង្គរុក្ខជាតិ សត្វ និងដំណើរការជីវវិទ្យាសម្រាប់ផលិផលនោះ ។

ដើម្បីទទួលបាននូវប្រកាសនីយបត្រតក្កកម្ម អ្នកស្នើសុំត្រូវតែបំពេញជាដំបូងនៅពាក្យសុំយោងតាមច្បាប់របស់ ការិយាល័យប្រកាសនីយបត្រតក្កកម្ម អាចត្រួតពិនិត្យពាក្យសុំដើម្បីកំណត់វិនិច្ឆ័យបញ្ជីខាងលើមានលក្ខណៈគ្រប់គ្រាន់មុនពេលសំរេចផ្តល់ ។ ដូចបានបញ្ជាក់ខាងលើ វាមានប្រភេទជាច្រើនដែលស្នើសុំនេះត្រូវបដិសេធន៍ មានឧទាហរណ៍ប្រភេទខ្លះត្រូវបានគេរកឃើញនៅក្នុងច្បាប់ជាតិជាច្រើន ។

ពាក្យសុំប្រកាសនីយបត្រតក្កកម្មត្រូវតែស្របតាមបែបបទ ។ ជាទូទៅប្រកាសនីយបត្រតក្កកម្មមួយដែលត្រូវបានគេផ្តល់ឲ្យគឺជាបុគ្គលទី១ដែលបានដាក់ពាក្យសុំ ។ នេះជាប្រព័ន្ធស្នើសុំមុនទទួលបានមុនដោយសារថ្ងៃបំពេញពាក្យសុំនោះសំខាន់ណាស់ ។

ការិយាល័យប្រកាសនីយបត្រតក្កកម្មអាចត្រួតពិនិត្យពាក្យសុំ ដើម្បីកំណត់ថាតើវាគ្រប់គ្រាន់ការបង្ហាញតក្កកម្មដែលមនុស្សម្នាក់មានជំនាញក្នុងតំបន់ឬវិស័យនេះ ក្នុងការទាក់ទងការធ្វើ ឬ ការប្រើប្រាស់ ។ ផ្តល់នូវការពិពណ៌នាគ្រប់គ្រាន់ដែលអាចឱ្យមនុស្សម្នាក់អនុវត្តបាននូវតក្កកម្មនេះ គឺជាទូទៅអ្វីដែលអ្នកស្នើសុំប្រកាសនីយបត្រតក្កកម្មត្រូវផ្តល់ការផ្លាស់ប្តូរ ដើម្បីទទួលបាននូវផលប្រយោជន៍ ។

Paris Convention ដើម្បីការពារកម្មសិទ្ធិខាងឧស្សាហកម្ម (១៨៨៣) គឺជាអនុសញ្ញាដែលចាស់ជាងគេដែលគ្រប់គ្រងដោយអង្គការ WIPO ទាក់ទងជាមួយកម្មសិទ្ធិឧស្សាហកម្ម បានចែងថាសិទ្ធិអត្តិភាព ។ សិទ្ធិនេះមានន័យថា ជាមូលដ្ឋានការបំពេញពាក្យសុំមុនក្នុងរដ្ឋដែលជាសមាជិក ក្នុងរយៈពេល១២ខែនឹងទទួលបានកិច្ចការពារមុននៅប្រទេសផ្សេងទៀតដែលជារដ្ឋសមាជិក ។ ក្រោយមកពាក្យស្នើសុំនោះត្រូវបានគេចាត់ទុកថាបានបំពេញនៅថ្ងៃដូចគ្នានោះដែរ ។

អ្នកអាចសួរថាតើផលប្រយោជន៍អ្វីចំពោះប្រកាសនីយបត្រតក្កកម្ម ជាពិសេសនៅពេលតក្កកម្មនោះត្រូវបានបង្ហាញ ។ ជាទូទៅគឺសម្រាប់ឲ្យម្ចាស់ប្រកាសនីយបត្រតក្កកម្មក្នុងការលក់ ឬការប្រើប្រាស់ ការនាំចូលតក្កកម្ម ។ តែទោះបីជាយ៉ាងណា ម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិ ឬមានសិទ្ធិផ្តាច់មុខក្នុងការលក់ ឬការផ្តល់អាជ្ញាបណ្ណទៅអ្នកផ្សេងទៀត ។

**តើអ្នកអាចសង្ខេបពីផលប្រយោជន៍នៃការទទួលបានប្រកាសនីយបត្រតក្កកម្ម?**

ផលប្រយោជន៍នៃការទទួលប្រកាសនីយបត្រតក្កកម្ម គឺពិសេសណាស់ គឺម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិផ្តាច់មុខនៅលើវង្វង់ដែនដីរបស់ខ្លួនតាមរយៈការប្រើប្រាស់ ការលក់ ឬការនាំចូលនៃតក្កកម្ម ។ នោះវាមិនចាំបាច់ផ្តល់ឱ្យតក្កករ ឬម្ចាស់សិទ្ធិមានសិទ្ធិប្រើប្រាស់តក្កកម្មនោះទេ ជាឧទាហរណ៍ការ ការប្រើប្រាស់ខុសច្បាប់ ការប្រើប្រាស់ម៉ាស៊ីនហ្គាម ប៉ុន្តែម្ចាស់សិទ្ធិ អាចការពារមិនឲ្យគេបង្កើតម៉ាស៊ីននោះមួយរយៈពេល ។

រយៈពេល២០ឆ្នាំចាប់ពីថ្ងៃបានបំពេញពាក្យសុំ និងអ្វីដែលផ្តល់ឱ្យអ្នក អភិវឌ្ឍន៍បច្ចេកវិទ្យាមានសិទ្ធិមួយរយៈពេល សំរាប់ផ្លាស់ប្តូរក្នុងការបង្ហាញជាសាធារណៈពីររបៀបប្រើប្រាស់ ។ នៅពេលផុតកំណត់ បច្ចេកវិទ្យានោះក្លាយជាសម្បត្តិសាធារណៈ ហើយសាធារណៈជនអាចប្រើប្រាស់ដោយសេរីសំរាប់ទំនិញរបស់ពួកគេ ។

**តើការពាររយៈពេល២០ឆ្នាំ គឺដូចប្រទេសនីមួយៗក្នុងពិភពលោកឬ ?**

ជាការពិត រយៈពេលនេះផ្តល់តាមរយៈសន្ធិសញ្ញាអន្តរជាតិរយៈពេលយ៉ាងតិច២០ឆ្នាំចាប់ពីថ្ងៃបំពេញពាក្យសុំ ។

មានករណីខ្លះសិទ្ធិផ្តាច់មុខនេះត្រូវបានគេប្រើដោយមិនចាំបាច់សុំការអនុញ្ញាត ។ ក្នុងករណីខ្លះទៀតការប្រើប្រាស់តក្កកម្មត្រូវបានអនុញ្ញាតដោយសេចក្តីសម្រេចរបស់តុលាការ ឬដោយការិយាល័យប្រកាសនីយបត្រតក្កកម្មអាស្រ័យតាមច្បាប់ជាតិគឺការអនុញ្ញាតដោយបង្ខំ ។ ដូចមានចែងក្នុង Paris Convention និងTRIPS Agreement ការអនុញ្ញាតដោយបង្ខំនេះគឺការពារ ការមិនអនុញ្ញាតឲ្យប្រើប្រាស់ពីម្ចាស់កម្មសិទ្ធិ ។

ដូចមានចែងក្នុងTRIPS Agreement (មាត្រា៣១) លក្ខខណ្ឌ និងស្ថានភាពពិសេសត្រូវតែគោរពមុនពេលផ្តល់ការអនុញ្ញាតដោយបង្ខំជូនភាគីទី៣ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

តើនរណាត្រូវបានគេផ្តល់សិទ្ធិផ្តាច់មុខនូវការបង្កើត ការលក់ ការប្រើប្រាស់ ឬការនាំចូលតក្កកម្ម?

គឺម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិផ្តាច់មុខនូវការបង្កើត ការប្រើប្រាស់ ការនាំចូលតក្កកម្ម ហើយមានសិទ្ធិធ្វើពាណិជ្ជកម្ម ។

ម្យ៉ាងទៀតប្រកាសនីយបត្រតក្កកម្មគឺជាទំនាក់ទំនងរវាងសាធារណៈ និងម្ចាស់កម្មសិទ្ធិ ។ ជាមួយការផ្តល់ប្រកាសនីយបត្រតក្កកម្មតាមលក្ខខណ្ឌដែលបានពិភាក្សាខាងលើ ហើយម្ចាស់ប្រកាសនីយបត្រតក្កកម្មមានសិទ្ធិការពារពីការអនុវត្តលើតក្កកម្មរបស់ខ្លួន ។ តាមរយៈលក្ខខណ្ឌ និងការផ្តល់

កិច្ចការពារប្រកាសនីយបត្រតក្កកម្ម រដ្ឋាភិបាលធានាការពារពត៌មានដែលទាក់ទងការបង្ហាញតក្កកម្មជាសាធារណៈរហូតផុតកំណត់២០ឆ្នាំចាប់ពីថ្ងៃបំពេញពាក្យសុំ ។

នៅក្នុងប្រទេសជាច្រើន ម្ចាស់ប្រកាសនីយបត្រតក្កកម្មអាចជ្រើសរើសកិច្ចការពារតក្កកម្មរបស់ខ្លួន បញ្ហាសំខាន់គឺការអនុវត្តច្បាប់បន្ទាប់ពីទទួលបានប្រកាសនីយបត្រតក្កកម្ម ។

ជាដំបូងម្ចាស់ប្រកាសនីយបត្រតក្កកម្មត្រូវតែរឹបអូសយកនូវអ្វីដែលជាការរំលោភបំពាន ដើម្បីការពារនូវប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន ។

ក្នុងស្ថានភាពចាំបាច់ លិខិតត្រូវបានបញ្ជូនដើម្បីឱ្យអនុវត្តច្បាប់ ដូចនេះលិខិតស្នាមមានសារៈសំខាន់ណាស់ទាំងការគាបសង្កត់លើអំពើល្មើស និងការបង្ហាញអាជ្ញាបណ្ណ ។

តែទោះបីជាយ៉ាងណាក៏ដោយ ក៏មានករណីជាច្រើន មិនមានកិច្ចព្រមព្រៀងផលប្រយោជន៍ទៅវិញទៅមកទេ ដំណោះស្រាយដោយចរចារគ្នាក៏អាចធ្វើបានទោះបីជាមានការប៉ុនប៉ងធ្ងន់ធ្ងរក្នុងការរំលោភបំពានក៏ដោយ ។ ក្នុងកំឡុងពេលមានការរំលោភបំពាន នៅក្នុងដំណាក់កាល មុនប្តឹងទៅតុលាការ គេអាចធ្វើការសម្របសម្រួល ឬរកអាជ្ញាកណ្តាលដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

ដូចដែលបានលើកបង្ហាញខាងលើ បញ្ហាការអនុវត្តច្បាប់ជាបញ្ហាស្មុគស្មាញ លោកអាចពិនិត្យមើលច្បាប់នៅក្នុងប្រទេសដែលអ្នកកំពុងស្នាក់នៅ ។

ដើម្បីការពារប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសផ្សេងៗគ្នា ទៅតាមតម្រូវការនៃប្រទេសនីមួយៗ ដូចនេះតើវាអាចការពារនៅក្នុងពិភពលោកបានដែរឬទេ?

**តើប្រកាសនីយបត្រតក្កកម្មអាចទទួលបាននូវកិច្ចការពារក្នុងពិភពលោកឬទេ?**

នៅក្នុងស្ថានភាពបច្ចុប្បន្ន គ្មានប្រកាសនីយបត្រតក្កកម្មណាអាចទទួលបាននូវកិច្ចការពារក្នុងគ្រប់ប្រទេសទាំងអស់ទេ ប្រកាសនីយបត្រតក្កកម្មគឺអាចការពារបានតែក្នុងរង្វង់ដែនដីប៉ុណ្ណោះ ។ ដើម្បីការពារក្នុងប្រទេសណាមួយ ប្រកាសនីយបត្រតក្កកម្មរបស់អ្នកត្រូវតែមានការចុះបញ្ជីនៅក្នុងប្រទេសនោះ ឥឡូវនេះដោយសារភាវូបនីយកម្មសេដ្ឋកិច្ច ពិភពលោកបានរំកិលចូលមកក្នុងប្រពន្ធ័អន្តរជាតិ យើងមានសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់នូវការបំពេញបែបបទតែមួយជាលក្ខណៈអន្តរជាតិ ដែលអាចទទួលបាននៅក្នុងរដ្ឋជាច្រើន ប៉ុន្តែមិនមែនជាការផ្តល់ប្រកាសនីយបត្រតក្កកម្ម គឺជាទម្រង់បែបបទពាក្យសុំតែប៉ុណ្ណោះ ហើយត្រូវបានត្រួតពិនិត្យតាមប្រទេសនីមួយៗ ។

មានប្រពន្ធ័តាមតំបន់ខ្លះៗ ដូចជាអង្គការប្រកាសនីយបត្រតក្កកម្មសហគមន៍អឺរ៉ុបEPC ស្ថិតនៅក្រោមការត្រួតពិនិត្យតែមួយ ប្រសិនបើអាចទទួលបាន គឺទទួលបាននៅគ្រប់ប្រទេសទាំងអស់នៃតំបន់សហគមន៍អឺរ៉ុប ។ មានការជជែកគ្នាខ្លះៗនៅក្នុងសហគមន៍អឺរ៉ុបអំពីប្រកាសនីយបត្រតក្កកម្មតែមួយ

អាចត្រូវបានទទួលស្គាល់នៅក្នុងសហគមន៍អឺរ៉ុបទាំងមូលតែម្តង ទោះបីជាមានការខុសប្លែកគ្នាខ្លាំងក៏ដោយ ។ គ្មានកិច្ចការពារប្រកាសនីយបត្រតក្កកម្មរួមនៅលើពិភពលោកទេ ប៉ុន្តែត្រូវមានការពិភាក្សាគ្នា ដើម្បីកាត់បន្ថយនូវការចំណាយដ៏ច្រើនចំពោះប្រកាសនីយបត្រតក្កកម្មក្នុងពិភពលោក ។ ម្យ៉ាងទៀត មានការចំណាយលើការត្រួតពិនិត្យតក្កកម្មតែមួយ នៅប្រទេសផ្សេងៗគ្នាច្រើន ដូចជារដ្ឋបាល ការបកប្រែ ការរក្សាទុក និងការអនុវត្តច្បាប់ ត្រូវបង់ប្រចាំឆ្នាំ ។

**តើអ្នកត្រូវបង់តំលៃប្រកាសនីយបត្រតក្កកម្មប្រចាំឆ្នាំលើប្រទេសនីមួយៗឬ?**

ជាការពិតត្រូវតែបង់ ប្រសិនបើអ្នកមានប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសចំនួន១០ អ្នកត្រូវតែបង់ឱ្យប្រទេសទាំង១០នោះ ប្រសិនបើអ្នកមិនបានបង់ក្នុងប្រទេសណាមួយ ប្រកាសនីយបត្រតក្កកម្ម ក្នុងប្រទេសនោះនឹងអស់សុពលភាព ។

ទោះបីជាមានសន្ធិសញ្ញាអន្តរជាតិតាមរយៈអង្គការកម្មសិទ្ធិបញ្ញាពិភពលោកក៏ដោយ ដែលហៅថា Patent Cooperation Treaty លើការបំពេញបែបបទ ការស្រាវជ្រាវ ការផ្សព្វផ្សាយជាសាធារណៈ និងការត្រួតពិនិត្យលើពាក្យសុំ ។ សន្ធិសញ្ញា PCT ធ្វើឱ្យមានលក្ខណៈងាយស្រួលចំពោះប្រទេសដែលបានចុះកិច្ចព្រមព្រៀងតាមរយៈការបំពេញបែបបទរួមតែមួយ ដែលស្ថិតនៅក្នុងប្រទេសផ្សេងៗគ្នា ឬតំបន់ផ្សេងៗគ្នា ក្នុងការិយាល័យ PCT ។

ជាទីបញ្ចប់ប្រកាសនីយបត្រតក្កកម្មជាមធ្យោបាយតែមួយដើម្បីការពារនូវតក្កកម្ម ។

**តើមានមធ្យោបាយផ្សេងណាដើម្បីការពារតក្កកម្មថ្មី ប្រសិនបើអ្នកមិនចង់ចុះបញ្ជីប្រកាសនីយបត្រ តក្កកម្មដោយមានមូលហេតុផ្សេង?**

ប្រកាសនីយបត្រតក្កកម្មគឺជាមធ្យោបាយដែលមានប្រសិទ្ធិភាពបំផុតសំរាប់ការពារនូវតកក្កកម្ម ប៉ុន្តែដូចដែលខ្ញុំបាននិយាយខាងលើ សិទ្ធិប្រកាសនីយបត្រតក្កកម្មដែលគេផ្តល់ឱ្យដើម្បីធ្វើការផ្សព្វផ្សាយបច្ចេកទេសរបស់តក្កករជាសាធារណៈ ។ មធ្យោបាយមានប្រសិទ្ធិភាពមួយទៀត គឺរក្សាការសំងាត់ពាណិជ្ជកម្ម ដែលទាក់ទងនឹងពត៌មានសំងាត់តក្កកម្ម ។ កាពិបាកចំពោះបញ្ហានេះ គឺនៅពេលផលិតផលចូលដល់ទីផ្សារ ពេលនោះភាពសំងាត់នេះត្រូវបានគេដឹងតាមរយៈផលិតផលរបស់យើង ហើយកិច្ចការពារភាពសំងាត់ត្រូវបាត់បង់ ។ តែចំពោះប្រកាសនីយបត្រតក្កកម្មវិញ គ្មានបញ្ហាទេ ទោះជានរណាម្នាក់ស្គាល់វិធីធ្វើ ផលិតផលរបស់អ្នកក៏ដោយ ជាការពិតពួកគេយល់នៅពេលអានពាក្យស្នើសុំរបស់លោក ដូចនេះគ្មានបញ្ហាទេនៅពេលអ្នកផ្សព្វផ្សាយ ប្រកាសនីយបត្រតក្កកម្មរបស់អ្នកត្រូវទទួលបាននូវកិច្ចការពារ ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចការពារភាពសំងាត់ពាណិជ្ជកម្ម អាចធ្វើទៅបាន និងសមរម្យលើការអនុវត្តទាក់ទងនឹងចំពោះការដឹងរបៀបធ្វើ ។ អ្នកជំនាញបច្ចេកប្រើបច្ចេកវិទ្យាតាមមធ្យោបាយដែលមានប្រសិទ្ធិភាពខ្ពស់ ។ ជាញឹកញយបច្ចេកវិទ្យានឹងមិនត្រូវបានការពារតាម

រយៈប្រកាសនីយបត្រតក្កកម្ម ព្រោះវាបង្កើតឡើងនូវអ្នកជំនាញក្នុងវិស័យសិល្បៈ ហើយស្គាល់ពីរបៀបសំងាត់ពាណិជ្ជកម្មដើម្បីការពារនូវបច្ចេកទេសនោះ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**ចូរផ្តល់ឧទាហរណ៍ពីកិច្ចការពារលក្ខណៈសម្ងាត់ពាណិជ្ជកម្មនិងតើការពារអ្វី?**

ការពិភាក្សាខាងលើបានបង្ហាញពីលក្ខណៈសម្ងាត់ពាណិជ្ជកម្មខ្លះ ដូចជាCoca-Cola® បានរក្សាការសម្ងាត់ពាណិជ្ជកម្មអស់រយៈពេលចាង១០០ឆ្នាំមកហើយវាបានបន្តរក្សាការសម្ងាត់ពាណិជ្ជកម្មនៃរូបមន្តរបស់ខ្លួន បន្ទាប់មកកិច្ចការពារកម្មសិទ្ធិបញ្ញានឹងធានាបានកាន់តែយូរតទៀតនៃប្រកាសនីយបត្រតក្កកម្ម ។

កិច្ចការពារលក្ខណៈសម្ងាត់ពាណិជ្ជកម្មពីរបៀបធ្វើ និងអ្នកជំនាញបច្ចេកទេស ដូចជាការប្រើប្រាស់ព័តមាននៅក្នុងវិធីពិសេស ។

## សង្ខេប

ជំពូកនេះបានពន្យល់ពីផ្នែកប្រកាសនីយបត្រតក្កកម្មនៃកម្មសិទ្ធិបញ្ញា ។ ប្រកាសនីយបត្រតក្កកម្មគឺជាទំរង់មួយចាស់ជាងគេបំផុតនៃកិច្ចការពារកម្មសិទ្ធិបញ្ញា គោលបំណងរបស់វាគឺដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមរយៈសកម្មភាពកម្មសិទ្ធិបញ្ញា ។

ក្រោមច្បាប់ប្រកាសនីយបត្រតក្កកម្ម គ្របដណ្តប់ទាំងការបង្កើតថ្មី និងការអភិវឌ្ឍន៍ ដូចជាតក្កកម្មនៃថ្នាំប៉េលីសាលីន សំខាន់ត្រូវការពារម៉ាស៊ីនតក្កកម្មដើម្បីធ្វើឱ្យម៉ាស៊ីនផលិតកាន់តែឆាប់ ។ ជាទូទៅការការពារតក្កកម្មជាដំណោះស្រាយមួយលើបញ្ហាបច្ចេកទេស ។ ដំណោះស្រាយនេះគឺជា គំនិតនិងការពារដែលក្រោមច្បាប់ប្រកាសនីយបត្រតក្កកម្ម តែមិនតម្រូវឲ្យបង្ហាញតក្កកម្មនោះទេ ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏មានវត្ថុខ្លះមិនអាចជាប្រកាសនីយបត្រតក្កកម្ម វត្ថុទាំងនោះរួមមានវត្ថុនៃរបកគំឃើញក្នុងធម្មជាតិ ម៉ាស៊ីនដែលប្រឆាំងនឹងច្បាប់ធម្មជាតិ ក្រៅពីនោះមានចែងក្នុងច្បាប់ដូចជាទ្រឹស្តីវិទ្យាសាស្ត្រ និងទ្រឹស្តីគណិតវិទ្យា រូបមន្ត វិធីសាស្ត្រធ្វើពាណិជ្ជកម្ម និងវិធីសាស្ត្រសម្រាប់ព្យាបាលមនុស្ស ឬសត្វ ។

នៅពេលពាក្យសុំប្រកាសនីយបត្រតក្កកម្មត្រូវបានបំពេញ គេមានវិធីសាស្ត្រពីរ ។ នៅប្រទេសខ្លះគេពិនិត្យទម្រង់ឡើងវិញ រួមមានការវាយតម្លៃពីអ្នកជំនាញដើម្បីធានាថាមានលក្ខណៈប្រកាសនីយបត្រតក្កកម្ម ។ លក្ខណៈនៃតក្កកម្ម ៖

-ត្រូវតែថ្មី

-មានជំហានរកឃើញថ្មី

-អាចយកទៅអនុវត្តបាននៅក្នុងវិស័យឧស្សាហកម្ម

ជាសង្ខបមកប្រកាសនីយបត្រតក្កកម្មមួយ គឺមានការទំនាក់ទំនងជាមួយសាធារណៈជន និងតក្កករតាមរយៈការផ្តល់នូវកិច្ចការពារមួយរយៈកំណត់ដើម្បីធានាឱ្យតក្កករទទួលបាននូវការលើកទឹកចិត្ត ។ បន្ទាប់ពីផុតកំណត់ រយៈពេល២០ឆ្នាំនៃថ្ងៃដាក់ពាក្យសុំ តក្កកម្មនេះ ត្រូវបានក្លាយជាប្រយោជន៍សាធារណៈ ។ កិច្ចការពារប្រកាសនីយបត្រតក្កកម្មមួយគឺជាកម្មវត្ថុសំខាន់ ហើយម្ចាស់កម្មសិទ្ធិគឺជាអ្នកចរចារពីរការរំលោភបំពានសិទ្ធិរបស់ខ្លួន ។ នៅពេលគ្មានកិច្ចការពារនៅក្នុងពិភពលោកតក្កករត្រូវតែបង់ប្រាក់ លើការក្សារទុកតក្កកម្មរបស់ខ្លួន នៅក្នុងប្រទេសនីមួយៗដែលខ្លួនមានបំណងចង់ការពារ ។

# ជំពូកទី៨
# សន្និសញ្ញាអង្គការកម្មសិទ្ធិបញ្ញាពិភពលោក
# ស្តីពីប្រពន្ធ័ចុះបញ្ជីអន្តរជាតិ និង PCT
## ម៉ាក ពាណិជ្ជនាម គំនូរឧស្សាហកម្ម ប្រកាសនីយបត្រតក្កកម្ម

**វត្ថុបំណង**

បន្ទាប់ពីសិក្សាចប់ផ្នែកនេះអ្នកអាចយល់ពី ៖

១-ធ្វើបញ្ជីប្រពន្ធ័នៃការចុះបញ្ជីអន្តរជាតិតាមរយៈអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។

២-គូសឌីយាក្រាមពន្យល់អំពីដំណើរការនៃការស្នើសុំដែលអាចប្រើប្រាស់បាន តាមរយៈប្រព័ន្ធ Madrid Systemដើម្បីទទួលបាននូវកិច្ចការពារម៉ាក ពាណិជ្ជនាមក្នុងប្រទេសផ្សេងៗគ្នា ។

៣-ពិពណ៌នាពីតួនាទីរបស់ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញា ពិភពលោកនៅក្នុងដំណើការចុះបញ្ជីម៉ាក ពាណិជ្ជនាម ។

៤-ពន្យល់តើមានបញ្ហាអ្វីកើតឡើង ប្រសិនបើម៉ាក ពាណិជ្ជនាមត្រូវបានប្រទេសមួយជំទាស់ បន្ទាប់ពីការចុះបញ្ជីលក្ខណៈអន្តរជាតិរួច ។

៥-តើម៉ាក ពាណិជ្ជនាមអាចកាពារបានរយៈពេលប៉ុន្មាន ?

៦-ចូរធ្វើបញ្ជីផលប្រយោជន៍នៃកិច្ចការពារគំនូសឧស្សាហកម្មជាលក្ខណៈអន្តរជាតិ ។

៧-ចូរពន្យល់ពីដំណើរការនៃកិច្ចការពារអន្តរជាតិដែលផ្តល់ចំពោះ គំនូរឧស្សាហកម្មតាមរយៈ កិច្ចព្រមព្រៀង Hague ។

៨-ចូរពន្យល់ឱ្យបាន១០០ពាក្យពីគោលបំណងនៃសន្និសញ្ញាPCT ។

៩-ចូរពិពណ៌នាឱ្យបាន២០០ពាក្យពីផលប្រយោជន៍សន្និសញ្ញាPCT ។

១០-ចូរគូសឌីយ៉ាក្រាមពីដំណើរការដែលទាក់ទងនឹងការប្រើប្រាស់សន្និ សញ្ញាPCT ។

១១-ចូរពន្យល់ឱ្យបាន២០០ពាក្យអំពីតួនាទីនៃអង្គការកម្មសិទ្ធិបញ្ញា នៅក្នុង សន្និសញ្ញាPCT ។

## សេចក្តីផ្តើម

វិធានជាច្រើនដែលអង្គការកម្មសិទ្ធិបញ្ញាពិភពលោកគាំទ្រដើម្បីលើកទឹកចិត្តកម្មសិទ្ធិបញ្ញា គឺវិធានរដ្ឋបាលនៃសន្ធិសញ្ញា ឬអនុសញ្ញាជាក់លាក់មួយ ។ កិច្ចការពារ ជាលក្ខណៈអន្តរជាតិនៃម៉ាក ពាណិជ្ជនាម គំនូរឧស្សាហកម្ម និងប្រភពដើម គឺអនុវត្តតាមរយៈប្រពន្ធ័ចុះបញ្ជីបី ៖ ប្រពន្ធ័ម៉ាឌ្រីតសម្រាប់ម៉ាក ពាណិជ្ជនាម និងប្រពន្ធ័ Hague System សម្រាប់គំនូរឧស្សាហកម្ម និងLisbon Agreement សម្រាប់ការពារប្រភពដើម។ ផ្នែកទី១នៃជំពូកនេះ នឹងចាប់ផ្តើម ពិពណ៌នាពីប្រពន្ធ័ការពាររបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកសម្រាប់ម៉ាក ពាណិជ្ជនាម និងកំនូរឧស្សាហកម្ម ។

ផ្នែកទី២នៃជំពូកនេះទាក់ទងនឹងPCT ។ នេះជាសន្ធិសញ្ញានាំមុខនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ជាទូទៅប្រពន្ធ័នេះសម្រួលដល់ការបំពេញបែបបទសុំប្រកាសនីយបត្រតក្កកម្មនៃបណ្តាលប្រទេសផ្សេងៗ។ ក្នុងជំពូកនេះនឹងចាប់ផ្តើមពិពណ៌នាពីប្រព័ន្ធចុះបញ្ជីអន្តរជាតិ ។

## ប្រពន្ធ័ចុះបញ្ជី

### តើមានប្រពន្ធ័ចុះបញ្ជីអន្តរជាតិខុសគ្នាប៉ុន្មានដែលអង្គការកម្មសិទ្ធិបញ្ញា ពិភពលោកគ្រប់គ្រង ?

ជាការពិតមានប្រពន្ធ័៣ គឺប្រពន្ធ័ម៉ាឌ្រីត គឺជាប្រពន្ធ័ចុះបញ្ជីអន្តរជាតិសម្រាប់ម៉ាក ពាណិជ្ជនាម និងប្រពន្ធ័នេះមានសន្ធិសញ្ញា២ទៀតដែលបំពេញគ្នាទៅវិញទៅ មកគឺកិច្ចព្រមព្រៀងម៉ាឌ្រីត និងប្រូតូកូលម៉ាឌ្រីត ។ បន្ទាប់មកមានប្រពន្ធ័នៃការ ចុះបញ្ជីអន្តរជាតិ ឬការតម្កល់លក្ខណៈអន្តរជាតិនៃគំនូរឧស្សាហកម្មដែលស្ថិតនៅ ក្រោមកិច្ចព្រមព្រៀង Haque ។ ប្រពន្ធ័ទី៣ ការចុះបញ្ជីអន្តរជាតិ គឺប្រភពដើមនៃតំបន់ដែលស្ថិនៅក្រោមកិច្ចព្រមព្រៀងលីសប៊ិន ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងចុងក្រោយនេះមិនប៉ះពាល់ដល់ម្ចាស់កម្មសិទ្ធិឯកជននៃកម្មសិទ្ធិឧស្សាហកម្មទេ ការបញ្ជាក់ពីប្រភពដើមត្រូវបានចុះបញ្ជីតាម ។ ជាលទ្ធផលសកម្មភាពរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ការពារលើម៉ាក ពាណិជ្ជនាម គំនូរឧស្សាហកម្ម និងប្រកាសនីយបត្រតក្កកម្មតាមរយៈការចុះបញ្ជីជាអន្តរជាតិ ។

<u>សំណួរវាយតំលៃដោយខ្លួនឯង</u>

ក-តើប្រពន្ធ័កម្មសិទ្ធិបញ្ញាអន្តរជាតិមួយណាដែលទាក់ទងប្រពន្ធ័ Haque ប្រពន្ធ័ម៉ាឌ្រីត និងប្រពន្ធ័លីសប៊ិន ?

ខ-តើសន្ធិសញ្ញា២ណាដែលបង្កើតឡើងនូវប្រពន្ធ័ម៉ាឌ្រីត ?

<u>ចម្លើយ</u>

ក-ប្រពន្ធ័ Haque គ្រប់ដណ្តប់លើការតម្កល់នៃគំនូរឧស្សាហកម្ម ។ ប្រពន្ធ័ម៉ាឌ្រីតចុះបញ្ជីម៉ាក ពាណិជ្ជនាម និងកិច្ចព្រមព្រៀងលីសប៊ិនទាក់ទងទៅនឹងការចុះបញ្ជីឈ្មោះប្រភពដើម ។

ខ-សន្ធិសញ្ញាពីរនៅក្នុងប្រពន្ធ័ម៉ាឌ្រីត គឺកិច្ចព្រមព្រៀងម៉ាឌ្រីត ទាក់ទងនឹងការចុះបញ្ជីអន្តរជាតិនៃម៉ាក ពាណិជ្ជនាម(១៨៩១) និងប្រូតូកូល ម៉ាឌ្រីត(១៩៨៩) ។

## ប្រពន្ធ័ម៉ាឌ្រីតចុះបញ្ជីអន្តរជាតិម៉ាក ពាណិជនាម

### តើពាក្យសុំអាចទទួលជាអន្តរជាតិឬទេចំពោះម៉ាក ពាណិជ្ជនាមនៃប្រពន្ធ័ម៉ាឌ្រីត?

ដើម្បីឆ្លើយសំណួរនេះគួរយល់ដឹងពីប្រពន្ធ័អន្តរជាតិនៃការចុះបញ្ជីម៉ាក ពាណិជ្ជនាម ។ អ្នកខ្លះបំពេញបែបបទនៅការិយាល័យអង្គការកម្មសិទ្ធិបញ្ញានៅក្នុងទីក្រុងហ្សឺណែវ នៅក្នុងនោះគេកំណត់ប្រទេសដែលជាសមាជិកនៃសន្ធិសញ្ញាដែលពួកគេចង់ការពារ ។ យើងចុះបញ្ជីម៉ាកនោះរួចបញ្ជូនទៅកាន់ប្រទេសដែលចង់ការពារ តែប្រទេសនោះអាចទទួល ឬបដិសេធន៍ពាក្យស្នុំសុំនោះ ។ ជាធម្មតាគេអាចត្រួតពិនិត្យពាក្យសុំដោយផ្ទាល់ដោយយោងតាមលក្ខណៈវិនិច្ឆ័យនៃប្រទេសរៀងៗខ្លួន ប្រសិនបើគេជំទាស់ត្រូវធ្វើការបញ្ជាក់មកម្ចាស់ម៉ាក ។ ម៉្យាងទៀតម្ចាស់កម្មសិទ្ធអាចចុះបញ្ជីអន្តរជាតិបាន ប៉ុន្តែអាចទទួលការពារអាស្រ័យទៅលើប្រទេសនីមួយៗ ។

<u>និតិវិធីនៃការចុះបញ្ជីអន្តរជាតិនៃម៉ាក ពាណិជ្ជនាម</u>



**ការិយាល័យអន្តរជាតិមានតួនាទីទទួលពាក្យសុំអន្តរជាតិ បន្ទាប់មកបញ្ជូនទៅកាន់ប្រទេសដែលចង់ការពារ តើការិយាល័យនោះមានការត្រួតពិនិត្យម៉ាក ឬទេ?**

មិនត្រួតពិនិត្យទេ មានសំណួរសំខាន់ពីរដែលអង្កេតដោយការិយាល័យក្នុងប្រទេស ។ ទី១-តើម៉ាកនោះមានលក្ខណៈទទួលបានឬទេ តើម៉ាកនោះអាចបែងចែកដាច់ពីគ្នារវាងទំនិញ និងសេវាឬទេ ម្យ៉ាងទៀតតើមានការប៉ះទង្គិចជាមួយម៉ាកដែលបានការពារពីមុនរបស់អ្នកដំទៃឬទេ? ហើយប្រទេសផ្សេងៗនោះត្រូវត្រួតពិនិត្យភ្លាម ផ្នែកខ្លះត្រូវធ្វើការត្រួតពិនិត្យទាំងស្រុង ខ្លះមិនធ្វើការត្រួតពិនិត្យ ។ ការិយាល័យអន្តរជាតិមិនត្រួតពិនិត្យលើភាពផ្សេងៗគ្នានេះទេ តែទុកលទ្ធភាពឱ្យប្រទេសផ្សេងៗពិនិត្យទៅតាមច្បាប់ប្រទេសដែលទាក់ទង តែទោះបីជាយ៉ាងណាក៏ដោយ ជាដំបូងត្រួតពិនិត្យលើពាក្យសុំនោះតើត្រឹមត្រូវតាមទម្រង់ដែលមានចែងនៅក្នុងសន្ធិសញ្ញា និងបទបញ្ញត្តិដើម្បីឱ្យច្បាស់ថាជាដំណាក់កាលសំខាន់ ។ គេអាចត្រួតពិនិតលើបញ្ជីទំនិញ និងសេវាដោយអមមកជាមួយពាក្យសុំ ។ ទំនិញ និងសេវាទាំងនោះត្រូវធ្វើចំណាត់ថ្នាក់ យោងទៅតាមចំណាត់ថ្នាក់អន្តរជាតិដែលគេទទួលស្គាល់ក្នុងបញ្ជីNice Classification ហើយការិយាល័យ អន្តរជាតិទទួលខុសត្រូវទៅចំពោះពាក្យសុំនៃចំណាត់ថ្នាក់នេះ ។ ដូចនេះការិយាល័យអន្តរជាតិធ្វើការត្រួតពិនិត្យលើទម្រង់ និងចំណាត់ថ្នាក់នៃទំនិញ និងសេវា ព្រោះដឹងថាពិនិត្យទម្រង់បែបបទនៃពាក្យសុំ និងចំណាត់ថ្នាក់បានត្រឹមត្រូវ ។

ដូចនេះតួនាទីរបស់ការិយាល័យអន្តរជាតិរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ទទួលពាក្យសុំដើម្បីការពារម៉ាកនៅក្នុងប្រទេសដែលបានកំណត់ត្រូវការពារ ។ អង្គការកម្មសិទ្ធិបញ្ញាពិភពលោកធ្វើការត្រួតពិនិត្យ តើពាក្យសុំនោះត្រឹមត្រូវឬទេ ប្រសិនបើត្រឹមត្រូវ ត្រូវចុះបញ្ជី ហើយបញ្ជូនវាទៅកាន់ប្រទេសដែលកំណត់ ។ ការត្រួតពិនិត្យភាពខុសគ្នាត្រូវធ្វើនៅក្នុងប្រទេសនីមួយៗទៅតាមច្បាប់នៃប្រទេសនោះ ។

**តាមប្រពន្ធ័ម៉ាឌ្រីត តើចាំបាច់ចុះបញ្ជីម៉ាកក្នុងប្រទេសរបស់ខ្លួន មុនពេលស្នើសុំចុះបញ្ជីអន្តរជាតិឬ?**

នេះជាការតម្រូវការជាមូលដ្ឋានដំបូងនៃប្រពន្ធ័ចុះបញ្ជីអន្តរជាតិ ជាងពី១០០ឆ្នាំកន្លងទៅ នៅពេលដែលប្រពន្ធ័នេះបានចាប់ផ្តើមវាមានបំណងផ្តល់នូវកិច្ចការពាររយៈពេលយូរជាងការចុះបញ្ជីការពារក្នុងស្រុក ។ ចាប់តាំងពីពេលនោះមកប្រពន្ធ័នេះចាប់ផ្តើមមានភាពស្មុគស្មាញ ប៉ុន្តែជាគោលការណ៍ត្រូវតែចុះបញ្ជីនៅ ក្នុងប្រទេសរបស់ខ្លួន ។

**គេប្រើប្រពន្ធ័ម៉ាឌ្រីតនៃការចុះបញ្ជីអន្តរជាតិ បន្ទាប់មកគេដាក់សុំអន្តរជាតិ ប្រសិនបើនៅក្នុងប្រទេសរបស់ខ្លួនបដិសេធន៍តើមានរឿងអ្វីកើតឡើង?**

ប្រសិនបើពាក្យសុំក្នុងប្រទេសរបស់ខ្លួនត្រូវបានបដិសេធន៍ វាត្រូវតែប៉ះពាល់ដល់ការចុះបញ្ជី

អន្តរជាតិ ។ វាអាស្រ័យលើការទំនាក់ទំនងរវាងកិច្ចការពារក្នុងស្រុកមួយ និងកិច្ចការពារអន្តរជាតិសម្រាប់រយៈពេល៥ឆ្នាំ ប៉ុន្តែក្នុងករណីដែលគេលើកឡើងនេះនៅពេលពាក្យសុំនោះ ត្រូវបានប្រទេសរបស់ខ្លួនបដិសេធន៍ ភ្លាមនោះការចុះបញ្ជីអន្តរជាតិដែលមានរយៈពេល៥ឆ្នាំត្រូវបានលុបចេញ ។ ប្រសិនបើការបដិសេធន៍នៅក្នុងប្រទេសតែមួយផ្នែកណា នោះការចុះបញ្ជីអន្តរជាតិក៏លុបមួយចំណែកនោះដែរ ។

<u>សំណួរវាយតំលៃដោយខ្លួនឯង</u>

ឧបមាថាលោកបានចុះបញ្ជីម៉ាកនៅក្នុងប្រទេសរបស់លោក បន្ទាប់មកលោកចង់ការពារនៅកំរិតអន្តរជាតិ រួមទាំងនៅក្នុងប្រទេសហ្គេនយ៉ា ក្រោយមួយឆ្នាំមក លោកដឹងថាប្រទេសរបស់លោកបានលុបចោលការចុះបញ្ជីរបស់លោក តើម៉ាករបស់លោកនៅតែទទួលបាននូវកិច្ចកាការពារក្នុងប្រទេសហ្គេនតាមប្រព័ន្ធម៉ាដឌ្រីតឬទេ?

<u>ចម្លើយ</u>

ចំលើយគឺមិនអាចការពារបានទៀតទេ ប្រសិនបើមូលដ្ឋាននៃការចុះបញ្ជីត្រូវបានគេលុបចេញដោយមូលហេតុផ្សេង ក្នុងកំឡុងពេល៥ឆ្នាំដំបូងនៃរយៈពេលចុះបញ្ជីអន្តរជាតិ វាឈានទៅចុះបញ្ជីអន្តរជាតិ ។ នេះជាករណីការចុះបញ្ជីអន្តរជាតិយោងតាមបែបបទនៃការចុះបញ្ជីក្នុងប្រទេស ហើយពាក្យសុំនោះត្រូវបានគេលុបចេញក្នុងពេលនោះដែរ ។ តែទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីរយៈពេលផុតកំណត់៥ឆ្នាំ ការចុះបញ្ជីអន្តរជាតិក្លាយទៅជាឯករាជ្យ ហើយបន្តមានប្រសិទ្ធិភាពទោះបីជាម៉ាកនោះត្រូវបានលុបចេញនៅក្នុងប្រទេសរបស់ខ្លួនក៏ដោយ ។

**តើម៉ាក ពាណិជ្ជនាមទទួលបាននូវកិច្ចការពាររយៈពេលប៉ុន្មាន?**

អ្នកអាចការពារគ្មានកំណត់ ប៉ុន្តែតាមប្រពន្ធ័អន្តរជាតិ និងប្រពន្ធ័ជាតិអ្នកអាចធ្វើការចុះបញ្ជីការពារឡើងវិញ ។ ការចុះបញ្ជីអន្តរជាតិដើម្បីការពារឡើងឯវិញគឺត្រូវបង់កំរៃរាល់១០ឆ្នាំម្តង ហើយរយៈពេល១០ឆ្នាំគឺជាកំរិតស្តង់ដារជាតិ ហើយអាចធ្វើឡើងវិញបែបបនេះបានរហូត គ្មានពេលកំណត់។

ដូចនេះប្រពន្ធ័ម៉ាឌ្រីតគឺជាមធ្យោបាយដ៏សំខាន់សម្រាប់ឱ្យអ្នកប្រើប្រាស់ម៉ាកអាចស្នើសុំការពារនៅក្នុងប្រទេសជាច្រើនក្នុងពេលតែមួយ ។ ទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចបន្តការពារ ឬមិនបន្តការពារវាអាស្រ័យលើប្រព័ន្ធច្បាប់ជាតិនោះ ។

ប្រព័ន្ធចុះបញ្ជីអន្តរជាតិនៃម៉ាក ពាណិជ្ជនាមគឺមានសារសំខាន់ណាស់ចំពោះម្ចាស់កម្មសិទ្ធិ ។ បន្ទាប់ពីចុះបញ្ជីម៉ាក ឬបំពេញពាក្យសុំ ម្ចាស់ម៉ាកគ្រាន់តែបំពេញពាក្យសុំតែមួយ ភាសាតែមួយក្នុងការិយាល័យតែមួយ ហើយបង់ប្រាក់នៅការិយាល័យតែមួយ ។ នេះតត្រូវធ្វើឡើងជំនួសឲ្យការបំពេញពាក្យសុំក្នុងការិយាល័យផ្សេងៗច្រើនក្នុងប្រទេសផ្សេងៗ ច្រើនភាសា ច្រើនការិយាល័យ ។

## ប្រពន្ធ័ Hague:
## ជាប្រព័ន្ធការពារអន្តរជាតិនៃគំនូរឧស្សាហកម្ម

ដូចដែលយើងបានបញ្ជាក់នៅក្នុងជំពូកនៃប្រពន្ធ័ Hague នៃកិច្ចការពារគំនូរឧស្សាហកម្ម ។

### តើគំនូរឧស្សាហកម្មអាចទទួលបាននូវកិច្ចការពារក្នុងពិភពលោកឬទេ?

ជាបទប្បញ្ញត្តិទូទៅ កិច្ចការពារគំនូរឧស្សាហកម្មគឺមានព្រំដែនកំណត់នៅក្នុងប្រទេសមួយ ។ ប្រសិនបើចង់ការពារនៅប្រទេសផ្សេងៗទៀតច្រើន ត្រូវបំពេញពាក្យសុំច្រើន ហើយនីតិវិធីអាចផ្សេងៗគ្នាទៅតាមប្រទេសនីមួយៗនោះ ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងHague ទាក់ទងជាមួយការតម្កល់អន្តរជាតិនៃគំនូរឧស្សាហកម្មខេលជួយសម្រួលដល់ដំណើការនេះ ។

### តើគោលបំណងអ្វីចំពោះការតម្កល់អន្តរជាតិនៃគំនូរឧស្សាហកម្ម?

គោលបំណងនៃប្រព័ន្ធHagueគឺអាចការពារគំនូរឧស្សាហកម្មមួយឬ ច្រើននៅក្នុងប្រទេសច្រើនតាមរយៈការបំពេញនៅការិយាល័យអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។ ម្យ៉ាងទៀតកិច្ចព្រមព្រៀង Hague គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការWIPOដែលអនុញ្ញាតឲ្យជាតិ ឬក្រុមហ៊ុន សហគ្រាសដែលបង្កើតឡើងនៅក្នុងរដ្ឋជាសមាជិកទទួលបាននូវកិច្ចការពារគំនូរឧស្សាហកម្មក្នុងប្រទេសជាច្រើនតាមរយៈនីតិវិធីដ៏សាមញ្ញ ។ ការតម្កល់អន្តរជាតិតែមួយ មួយភាសា(អង់គ្លេស ឬបារាំង) បង់ប្រាក់តែមួយប្រភេទ និងបំពេញពាក្យនៅការិយាល័យតែមួយ ។

ការិយាល័យនោះអាចជាការិយាល័យអង្គការ WIPO ឬចាការិយាល័យជាតិនៃរដ្ឋដែលជាភាគីចុះហត្ថលេខីប្រសិនបើរដ្ឋនោះត្រូវបានគេអនុញ្ញាត ។ ការតម្កល់អន្តរជាតិមិនទាមទារឲ្យមានការតម្កល់ជាតិឡើយ ។ នៅពេលគំនូរឧស្សាហកម្មជាកម្មវត្ថុនៃការតម្កល់អន្តរជាតិ កិច្ចការពារនោះត្រូវទទួលបាននៅក្នុងប្រទេសនីមួយៗដែលមានក្នុងបញ្ជី ដោយចែងថានៅពេលអ្នកស្នើសុំដាក់ពាក្យស្នើសុំទៅប្រទេសណា ប្រទេសនោះមិនអាចបដិសេធន៍ទេ ។

### តើមានប្រយោជន៍អ្វីចំពោះប្រព័ន្ធHague ?

ប្រព័ន្ធនេះផ្តល់ឲ្យម្ចាស់សិទ្ធិអាចការពារគំនូរឧស្សាហកម្មបានច្រើនប្រទេស តាមរយៈការបំពេញបែបបទយ៉ាងសាមញ្ញតែមួយនៅការិយាល័យអង្គការWIPO តែមួយភាសា តម្លៃមួយកញ្ចប់រួមគ្នា រូបបិយបណ្ណតែមួយ ។ ប្រព័ន្ធHague ធ្វើយ៉ាងសាមញ្ញលើការគ្រប់គ្រងគំនូរឧស្សាហកម្ម គឺអាចរក្សាទុកឬ ផ្លាស់ប្តូរ ឬតម្កល់ឡើងវិញតាមរយៈនិតិវិធីតែមួយយ៉ាងសាមញ្ញនៅការិយាល័យអង្គការ WIPO ។

**តើអ្នកអាចសង្ខេបពីប្រយោជន៍អ្វីដែលតម្រូវឲ្យមានការពារគំនូរឧស្សាហកម្ម?**

ជាមួយកម្មសិទ្ធិឧស្សាហកម្ម អ្នកទាមទារសិទ្ធិផ្តាច់មុខដើម្បីប្រើប្រាស់នូវគំនូរឧស្សាហកម្ម ។ ម្យ៉ាងទៀត ម្ចាស់ដែលអ្នកបង្កើតរូបគំនូរថ្មីនេះ ដូចបានពិពិណនារួចមកហើយ ឬ អ្នកបង្កើតគ្រឿងសង្ហារឹម ឬសំលៀកបំពាក់ទាមទារនូវសិទ្ធិផ្តាច់មុខដើម្បីធ្វើ និងលក់ ក៏ដូចគ្នានឹងម្ចាស់ប្រកាសនីយបត្រតក្កកម្មគឺត្រូវការសិទ្ធិផ្តាច់មុខ ។

**ប្រកាសនីយបត្រតក្កកម្មប្រើសម្រាប់រយៈពេលមួយកំណត់តើវាដូចគ្នានឹងការចុះបញ្ជីគំនូរឧស្សាហកម្មឬទេ?**

វាប្រើមានរយៈពេលកំណត់ ប៉ុន្តែរយៈពេលវែងមិនទាន់មានការឯកភាពគ្នានៅឡើយ តែរយៈពេលខ្លីដែលត្រូវការពារនៅក្នុងប្រទេសមួយៗគឺ១០ឆ្នាំ ។ ជាធម្មតាពី ១៥ទៅ២០ឆ្នាំ ហើយនៅក្នុងច្បាប់របស់សហគមអឺរ៉ុបមានរយៈពេល២៥ឆ្នាំ ដូចនេះវាក្លាយជារយៈពេលស្តង់ដារមួយនៅសហគមអឺរ៉ុប ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**តើរយៈពេលការពារគំនូរឧស្សាហកម្មរបស់សហគមអឺរ៉ុបមានរយៈពេលប៉ុន្មានឆ្នាំ និងរយៈពេលអប្បរមាប៉ុន្មាន?**

<u>ចម្លើយ</u>

បច្ចុប្បន្ននេះរយៈពេលការពារមានភាពផ្សេងៗនៅក្នុងសហគមអឺរ៉ុប ប៉ុន្តែគេកំពុងតែកែសម្រួល ២៥ឆ្នាំ ។

**តើមានកិច្ចការពារគំនូរឧស្សាហកម្មក្នុងពិភពលោកតាមកិច្ចព្រមព្រៀងHagueឬទេ?**

វាមិនមានលក្ខណៈការពារក្នុងពិភពលោកទេ តែមានផ្តល់ការចុះបញ្ជីការពារក្នុងប្រទេសមួយចំនួនច្រើន គឺដូចគ្នានឹងប្រព័ន្ធម៉ាដឌ្រីតដែលអ្នកត្រូវបំពេញពាក្យសុំជាលក្ខណៈអន្តរជាតិដើម្បីចុះបញ្ជីអន្តរជាតិ ហើយបោះផ្សាយដោយអន្តរជាតិ រួចបញ្ជាក់ទៅប្រទេសដែលទាក់ទងដែលពេលនោះមានសិទ្ធិផ្តល់ ឬបដិសេធន៍ក្នុងកិច្ចការពារ ។ នៅពេលកិច្ចព្រមព្រៀងHagueត្រូវបានគេចាប់អារម្មណ៍មានប្រទេសពីរ ឬបីដែលត្រួតពិនិត្យពាក្យសុំ ហើយស្ទើតែគ្មានប្រទេសណាមួយបដិសេធន៍ ។ គឺនេះវាផ្ទុយនឹងការចុះបញ្ជីម៉ាក ពាណិជ្ជនាម ។

ភាពខុសគ្នារវាងកិច្ចការពារគំនូរឧស្សាហកម្មក្រោមកិច្ចព្រមព្រៀងHague និងកិច្ចការពារម៉ាកក្រោមកិច្ចព្រមព្រៀងMadrid និង Protocolគឺអ្នកមិនចាំបាច់ផ្តើមការពារនៅក្នុងប្រទេសរបស់អ្នកទេ ។ ឧទាហរណ៍អ្នកបង្កើតគំនូរឧស្សាហកម្មនៅប្រទេសបារាំងអាចតម្កល់អន្តរជាតិ ដូចជានៅស្វីស អ៊ីតាលី អេស្ប៉ាញក៏អាចការពារនៅប្រទេសបារាំងបានដែរ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**តើតាមរយៈកិច្ចព្រមព្រៀងHagueអាចទទួលបាននូវកិច្ចការពារគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោកឬទេ?**

<u>ចម្លើយ</u>

ទេមិនអាចការពារបានគ្រប់ប្រទេស មានតែសមាជិករដ្ឋហត្ថលេខីប៉ុណ្ណោះ ។

## សេចក្តីសង្ខេប

### ប្រព័ន្ធMadrid និងប្រព័ន្ធHagueនៃកិច្ចការពារ និងការចុះបញ្ជី

ដូចនេះតាំងពីមុនរហូតដល់ជំពូកនេះអ្នកបានដឹងកិច្ចព្រមព្រៀងរបស់WIPOមានចំនួន២ដែលទាក់ទងការចុះបញ្ជីអន្តរជាតិសម្រាប់ការពារម៉ាក និងគំនូរឧស្សាហកម្ម ។ តួនាទីរបស់WIPOក្នុងដំណើរការនេះគឺបម្រើរដ្ឋបាលនូវប្រព័ន្ធអន្តរជាតិនៃការចុះបញ្ជី សម្រួលដល់នីតិវិធីបំពេញពាក្យសុំ និងបោះផ្សាយក្នុងទស្សនាវដ្តី(Madrid) និងព្រឹត្តបត្រនៅ(Hague)នៃនីតិវិធីប្រព័ន្ធនេះ ។

ប្រព័ន្ធMadridត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៨៩១ ហើយគោលបំណងគឺលើកទឹកចិត្ត និងសម្រួលការចុះបញ្ជីអន្តរជាតិនៃម៉ាក ។ នៅពេលបុគ្គលម្នាក់ចង់ការពារម៉ាករបស់ខ្លួន គាត់ត្រូវចុះបញ្ជីនៅក្នុងប្រទេសរបស់ខ្លួនសិន ។ ប្រសិនបើគាត់មានបំណងពង្រីកការពារដល់ប្រទេសផ្សេងៗទៀត គឺអាចធ្វើតាមប្រព័ន្ធ Madrid ឬ Protocol ។ វាអាស្រ័យលើរយៈពេលការពារ៥ឆ្នាំដំបូង ប្រសិនម៉ាកនោះត្រូវបានប្រទេសដើមបដិសេធន៍ តែបានផ្តល់ឲ្យដោយប្រទេសដែលបានកំណត់រួចហើយ ពេលនោះកិច្ចការពារនៅអន្តរជាតិក៏ត្រូវលុបចោលដែរ ។ បន្ទាប់ពីរយៈពេល៥ឆ្នាំបានកន្លងផុតកិច្ចការពារនៅអន្តរជាតិនៅតែមានប្រសិទ្ធិភាព ទោះបីជាប្រទេសដើមលុបម៉ាកនោះក៏ដោយ ។ ទោះបីជាយ៉ាងណាក៏ដោយកិច្ចការពារអន្តរជាតិគឺមានកំណត់រយៈពេល តែត្រូវចុះបញ្ជីឡើងវិញរាល់១០ឆ្នាំម្តង ហើយគេអាចចុះឡើងវិញរហូត ។



កិច្ចព្រមព្រៀងHagueបានបង្កើតឡើងនៅប្រព័ន្ធតម្កល់អន្តរជាតិនៃគំនូរឧស្សាហកម្ម គឺដូចប្រព័ន្ធMadridដែរដោយត្រូវបំពេញពាក្យជាលក្ខណៈអន្តរជាតិដើម្បីចុះបញ្ជីអន្តរជាតិ ដែលបានបោះផ្សាយដោយការិយាល័យអន្តរជាតិ និងបញ្ជាក់ទៅប្រទេសពាក់ព័ន្ធដែលជាអ្នកមានសិទ្ធិផ្តល់ ឬមិនផ្តល់កិច្ចការពារ ។ នៅពេលកិច្ចព្រមព្រៀងHagueត្រូវបានគេចាប់អារម្មណ៍ មានប្រទេសតិចតួចណាស់ដែលត្រួតពិនិត្យលើពាក្យសុំ និងស្ទើតែមិនមានប្រទេសណាមួយបដិសេធន៍ កិច្ចការនេះវាផ្ទុយជាមួយ

ការចុះបញ្ជីម៉ាក ។

ភាពខុសគ្នារវាងកិច្ចការពារគំនូរឧស្សាហកម្មក្រោមកិច្ចព្រមព្រៀងHague និងកិច្ចការពារម៉ាកក្រោមកិច្ចព្រមព្រៀងMadrid និង Protocolគឺអ្នកមិនចាំបាច់ផ្តើមការពារនៅក្នុងប្រទេសរបស់អ្នកទេ ។ ឧទាហរណ៍អ្នកបង្កើតគំនូរឧស្សាហកម្មនៅប្រទេសបារាំងអាចតម្កល់អន្តរជាតិ ដូចជានៅស្វីស អ៊ីតាលី អេស្ប៉ាញក៏អាចការពារនៅប្រទេសបារាំងបានដែរ ។

## សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មPCT

ពោះប្រព័ន្ធប្រកាសនីយបត្រតក្កម្មជាតិតម្រូវឲ្យមានបំពេញពាក្យសុំនៅក្នុងប្រទេសនីមួយៗដែលត្រូវការពារ ម្យ៉ាងទៀតជាគោលការណ៍គឺត្រូវអនុវត្តនៅលើបូរណភាពដែនដីនៃរដ្ឋមួយ ។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះPCTត្រូវបានអនុម័តឡើងនៅក្នុងឆ្នាំ១៩៧០ ។ PCTផ្តល់នូវនីតិវិធីយ៉ាងសាមញ្ញចំពោះតក្កករក្នុងការស្នើសុំនៅក្នុងបណ្តាលប្រទេសជាច្រើន ។

ប្រព័ន្ធPCTមានកម្មវត្ថុដ៏សំខាន់មួយគឺធ្វើឲ្យមានភាពងាយស្រួល កាន់តែប្រសិទ្ធិភាព និងសន្សំសំចៃ មានប្រយោជន៍ដល់អ្នកប្រើប្រាស់នៃប្រព័ន្ធប្រកាសនីយបត្រតក្កកម្ម និងការិយាល័យដែលមានការទទួលខុសត្រូវលើកិច្ចការរដ្ឋបាល ដែលជាវិធីសាស្ត្រក្នុងការបំពេញពាក្យសុំសម្រាប់តក្កកម្មរបស់ខ្លួនបានក្នុងប្រទេសជាច្រើន ។

### ចូរអ្នកពន្យល់ពីគោលបំណង និងកម្មវត្ថុនៃPCT?

PCTជាសន្ធិសញ្ញាមួយដែលផ្តល់នូវការបំពេញបែបបទដើម្បីទទួលបាននូវកិច្ចការពារប្រកាសនីយបត្រតក្កកម្មនៅច្រើនប្រទេស ។ វាផ្តល់នូវនីតិវិធីងាយស្រួលសម្រាប់តក្កករ ឬអ្នកស្នើសុំប្រកាសនីយបត្រតក្កកម្ម គោលបំណងមួយក្នុងគោលបំណងជាច្រើនគឺជម្រុញការផ្លាស់ប្តូរព័តមានបច្ចេកវិទ្យាដែលមាននៅក្នុងឯកសារប្រកាសនីយបត្រតក្កកម្មក្នុងចំណោមប្រទេសជាច្រើន និងក្នុងសហាគមវិទ្យា-សាស្ត្រដែលតក្កករ និងឧស្សាហកម្មធ្វើការទំនាក់ទំនងក្នុងវិស័យជាមួយគ្នា ។

ដូចនេះដើម្បីបន្ថែមនីតិវិធីកាន់តែមានភាពងាយស្រួលដើម្បីទទួលប្រកាសនីយបតត្រតក្កកម្ម វាសំខាន់ណាស់សម្រាប់គោលបំណងPCTធ្វើការផ្សព្វផ្សាយកាន់តែមានប្រសិទ្ធិភាពនូវចំណេះដឹងបច្ចេកវិទ្យាដែលមាននៅក្នុងឯកសារប្រកាសនីយបតត្រតក្កកម្ម ។ ទោះបីយ៉ាងណាក៏ដោយ ប្រព័ន្ធ PCT មិនផ្តល់ប្រកាសនីយបតត្រតក្កកម្មក្នុងពិភពលោកទេ ។

### តើប្រព័ន្ធPCTផ្តល់ប្រកាសនីយបត្រតក្កកម្មក្នុងពិភពលោកដល់អ្នកដាក់ពាក្យស្នើសុំឬ?

ទេ មានចំណុច២ដែលត្រូវពន្យល់នៅទីនេះ ទី១-PCTមិនមែនផ្តល់ប្រកាសនីយបតត្រតក្កកម្ម

ទេ ។ នៅចុងបញ្ចប់នៃដំណើរការ គឺការិយាល័យជាតិនៃប្រទេសនីមួយៗជាអ្នកផ្តល់ប្រកាសនីយបត្រតក្កកម្មដោយផ្អែកលើពាក្យសុំនៃPCT ។ ទី២-គឺគ្មានប្រកាសនីយបតត្រតក្កកម្មពិភពលោកទេ ។ ប្រព័ន្ធPCTមិនធ្វើការងារនេះទេ គឺគ្រាន់តែមាននិតីវិធីដូចបានបញ្ជាក់ខាងលើ គឺសម្រាប់តែប្រទេសមួយចំនួនក្នុងតំបន់ ឬប្រកាសនីយបត្រតក្កកម្មជាតិ ។ ប្រហែលមានតែមួយ ប្រសិនបើអ្នកដាក់ពាក្យសុំនៅក្នុងការិយាល័យតែមួយ ប៉ុន្តែគេអាចទទួលបានក្នុង១០ ឬ២៥ ឬ៥០ប្រទេសតាមបំណងដែលគេចង់បាន ។

**តើអាចលើកពីនីតិវិធីដាក់ពាក្យសុំតាមPCT ?**

ជាដំបូងគាត់ត្រូវដាក់ពាក្យសុំនៅការិយាល័យក្នុងប្រទេសរបស់គាត់ បន្ទាប់មកឆ្លងកាត់ច្រើនដំណាក់កាល ។ ដំណាក់កាលទី១-ជាដំណាក់កាលអន្តរជាតិរួមមាន៤ផ្នែកធំៗគឺទី១- ការបំពេញពាក្យ ទី២-ការស្រាវជ្រាវអន្តរជាតិ ទី៣-ការបោះផ្សាយអន្តរជាតិ និងទី៤-ការត្រួតពនិត្យជាបឋមអន្តរជាតិ ។ ផ្នែកចុងក្រោយនេះគឺការត្រួតពិនិត្យត្រូវធ្វើឡើងប្រសិនបើអ្នកដាក់ពាក្យស្នើសុំ ប៉ុន្តែតាមបទពិសោធន៍គឺមានប្រហែល៨០%ត្រូវបានធ្វើឡើង ដូចនេះយើងអាចនិយាយថាពាក្យសុំតាមPCTត្រូវមាន៤ផ្នែកនៅក្នុងដំណាក់កាលអន្តរជាតិ ។ ប៉ុន្តែប្រសិនបើអ្នកស្នើសុំមានបំណងឆ្លងមុនដំណាក់កាលនេះ គឺជាដំណាក់កាលជាតិ គឺមានដំណាក់កាលជាតិមួយដែលត្រូវធ្វើនៅតាមការិយាល័យមុនពេលបញ្ចប់នៅនីតិវិធីប្រកាសនីយបតត្រតក្កកម្ម ។ មានន័យថាអាចមានការិយាល័យ១ ឬ២ ឬ៥ ឬ១០រួមទាំងការិយាល័យជាតិ និងតំបន់ដែលអ្នកស្នើសុំមានបំណងចង់ការពារនៅក្នុងប្រទេសនោះ ។

## ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

ដូចបានបញ្ជាក់ខាងលើ នីតិវិធីនៃPCTក្នុងដំណាក់កាលទី២គឺជាដំណាក់កាលជាតិ ។ នៅក្នុងដំណាក់កាលអន្តរជាតិអ្នកស្នើសុំអាចដំណើរការពាក្យសុំអន្តរជាតិរបស់គាត់មុនដំណាក់កាលជាតិ ឬការិយាល័យប្រកាសនីយបត្រតក្កកម្មថ្នាក់តំបន់ ។ ការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប EPO គឺជាឧទាហរណ៍មួយសម្រាប់ការិយាល័យថ្នាក់តំបន់ ។

EPOត្រូវបង្កើតឡើងដោយអនុសញ្ញាប្រកាសនីយបត្រតក្កកម្មអឺរ៉ុបEPC ។ មាត្រាទី២(១)នៃEPCចែងថារាល់ប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ដោយអនុសញ្ញានេះ ហៅថាប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ។ មាត្រា២(២)ចែងបន្ថែមថថាប្រកាសនីយបត្រតក្កកម្មអឺរ៉ុបគឺរាល់ប្រទេសហត្ថលេខីទាំងអស់ដែលបានផ្តល់គឺមានប្រសិទ្ធិភាព និងមានលក្ខខណ្ឌដូចគ្នាសម្រាប់ប្រកាសនីយបត្រតក្កកម្មជាតិដែលរដ្ឋបានផ្តល់ឲ្យ ប្រសិនបើមិនមានចែងផ្ទុយនឹងអនុសញ្ញានេះទេ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**ចូរអ្នកគូឌីយ៉ាក្រាមបង្ហាញពីដំណើការទាក់ទងការប្រើប្រាស់PCT?**

## ចម្លើយ


អ្នកដាក់ពាក្យ បំពេញបែបបទ កំណត់ប្រទេសដែលចង់ការពារ
ដំណាក់កាលស្រាវជ្រាវអន្តរជាតិ
ដំណាក់កាលអន្តរជាតិ
ការបោះផ្សាយអន្តរជាតិ
ការត្រួតពិនិត្យជាបឋមអន្តរជាតិ
អ្នកដាក់ពាក្យជ្រើសរើសប្រទេសដែលចង់ការពារ
ដំណាក់កាលជាតិ
ប្រទេស A
ប្រទេស B
ប្រទេស C
ប្រទេស D
ប្រទេស E

**មាន៣ ឬ៤ដំណាក់កាលនៅក្នុងដំណាក់កាលអន្តរជាតិ តើកើតឡើងនៅឯណា? តើគេធ្វើវានៅហ្សឺណែវឬ?**

ទេ ភាគច្រើនកើតឡើងចំពោះដំណើការPCTចាប់ផ្តើមនៅកន្លែងណាមួយ ហើយបន្តទៅកន្លែងមួយផ្សេងទៀត ។ ជាដំបូងអ្នកដាក់ពាក្យសុំ ត្រូវបំពេញពាក្យសុំនៅការិយាល័យក្នុងប្រទេសនោះ ទោះបីយ៉ាងណាក៏ដោយ អាចជាការិយាល័យជាតិ ឬការិយាល័យតំបន់និងអាចជាការិយាល័យអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅហ្សឺណែវ ។ ដូចនេះវាអាចកើតមានឡើងនៅការិយាល័យអន្តរជាតិនៅក្នុងដំណាក់កាលទី១ ប៉ុន្តែវាមិនមានលក្ខណៈសាមញ្ញពេកទេ ។

ដំណាក់កាលទី២គឺស្រាវជ្រាវអន្តរជាតិ សព្វថ្ងៃនេះមានការិយាល័យចំនួន១១ដែលកំណត់ដោយPCTដែលអនុវត្តលើដំណាក់កាលស្រាវជ្រាវអន្តរជាតិ ការិយាល័យទាំងនេះហៅថា អាជ្ញាធរស្រាវជ្រាវអន្តរជាតិដែលត្រូវបានជ្រើសរើសដោយមានលក្ខណៈវិនិច្ឆ័យមួយចំនួន ហើយពួកគេជួលសេវាសម្រាប់អ្នកដាក់ពាក្យសុំក្រោមប្រព័ន្ធPCT អាស្រ័យតាមករណីនៃរឿង ឬភាសាដែលពួកគេធ្វើ ។ ដូចនេះមិនគ្រប់ករណីអ្នកស្នើសុំPCTដែលបានបំពេញពាក្យសុំទាំងអស់នោះទេ ឧទាហរណ៍ការិយាល័យប្រកាសនីយបត្រតក្កកម្មជប៉ុនធ្វើការតែសម្រាប់ភាសាជប៉ុន គឺមិនធ្វើការសម្រាប់អ្នកដាក់ពាក្យសុំជាភាសាអង់គ្លេស បារាំងឬអាឡឺម៉ង់ទេ ។ ដូចគ្នាចំពោះការិយាល័យម៉ាក និងប្រកាសនីយបត្រតក្កកម្មអេស្ប៉ាញ ។ ម្យ៉ាងទៀតការិយាល័យខ្លះធ្វើការជា៤ ឬ៥ភាសា ។

ដំណាក់កាលបន្ទាប់គឺបោះផ្សាយដែលធ្វើឡើងដោយការិយាល័យអន្តរជាតិនៅហ្សឺណែវ នេះគឺជាតួនាទីPCTតែមួយគត់ដែលWIPOទទួលខុសត្រូវ ។ អង្គការWIPOបោះផ្សាយពាក្យសុំទាំងអស់PCT ទោះបីមកពីកន្លែងណាក៏ដោយ ឬភាសាណាក៏ដោយ ។

ដំណាក់កាលទី៤គឺត្រួតពិនិត្យជាបឋមអន្តរជាតិ ជាទូទៅWIPOត្រលប់ទៅការិយាល័យនៃប្រទេសដើមវិញដើម្បីធ្វើការស្រាវជ្រាវអន្តរជាតិ ព្រោះអ្នកដាក់ពាក្យសុំអាចមានករណីផ្សេងៗគ្នា និងការិយាល័យផ្សេងៗគ្នា ។ នៅចង់ក្រោយនៃដំណាក់កាលអន្តរជាតិ ឬត្រលប់ចូលមកដំណាក់កាលជាតិ គឺការិយាល័យអន្តរជាតិមិនមានការពាក់ព័ន្ធទេ អ្នកដាក់ពាក្យសុំអាចទៅផ្ទាល់ការិយាល័យនីមួយៗ ដើម្បីផ្តល់ឯកសារទាក់ទង ។

ទោះបីជាយ៉ាងណាក៏ដោយ គេអាចនិយាយថាការិយាល័យអន្តរជាតិមានការពាក់ព័ន្ធជួយគាំទ្រលើនីតិវិធីនេះ ព្រោះវាទទួលខុសត្រូវជួយរៀបចំឯកសារឲ្យការិយាល័យទាំងនោះចំពោះអ្នកស្នុំសុំ និងសម្រាប់ទំនាក់ទំនងឯកសារខ្លះៗក្រោមសន្ធិសញ្ញានេះ ។ ដូចនេះទោះបីជាការិយាល័យអន្តរជាតិមិនបានអនុវត្តការងារដោយផ្ទាល់ក៏ដោយ ក៏អាចកើតឡើងចំពោះអ្នកដាក់ពាក្យសុំ វាអាស្រ័យលើការទំនាក់ទំនងការិយាល័យក្នុងការផ្តល់ឯកសារនោះ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**តើសកម្មភាពមួយណាដែលធ្វើឡើងដោយការិយាល័យអន្តរជាតិនៅហ្សឺណែវ ហើយសកម្មភាពមួយណាដែលមិនអាចធ្វើឡើងដោយការិយាល័យអន្តរជាតិ?**

a-ការទទួលពាក្យសុំប្រកាសនីយបត្រតក្កកម្ម

b-ការទទួលពាក្យសុំPCT

c-ការស្រាវជ្រាវអន្តរជាតិ

d-ការបោះផ្សាយអន្តរជាតិ

e-ការត្រួតពិនិត្យជាបឋមអន្តរជាតិ

f-ការផ្តល់នូវប្រកាសនីយបត្រតក្កកម្មជាតិ ឬតំបន់

<u>ចម្លើយ</u>

a-មិនដែល

b-អាចមាន

c-មិនដែល

d-តែងតែមាន

e-មិនដែល

f-មិនដែល

ដូចបញ្ជាក់ក្នុងសេចក្តីផ្តើមរួចហើយ គោលបំណងជាបឋមរបស់PCT គឺធ្វើនីតិវិធីឲ្យសាមញ្ញទាក់ទងជាមួយការទទួលបានប្រកាសនីយបត្រតក្កកម្មក្នុងប្រទេសផ្សេងៗគ្នាច្រើន ។ ផលប្រយោជន៍មួយទៀតចំពោះអ្នកដាក់ពាក្យសុំធ្វើការសម្រេចតើប្រើនីតិវិធីដោយឡែកតាមប្រទេសមួយ ឬប្រើនីតិវិធីតាមប្រព័ន្ធPCT ។

**តើមានគុណសម្បត្តិអ្វីចំពោះការសុំតាមប្រទេសដោយឡែក និងតាមPCT?**

គុណប្រយោជន៍ចំពោះការសុំប្រកាសនីយបត្រតក្កកម្មនៅការិយាល័យមួយ គឺភាគច្រើនធ្វើនៅការិយាល័យជាតិ គាត់នឹងទទួលបាននៅថ្ងៃបំពេញពាក្យអន្តរជាតិចំពោះពាក្យសុំរបស់គាត់ ហើយថ្ងៃដែលបំពេញពាក្យសុំនោះ នឹងមមានប្រសិទ្ធិភាពតាមច្បាប់ជាតិគ្រប់ប្រទេសដែលបានកំណត់ ។ ដូចនេះលក្ខខណ្ឌតម្រូវគឺអ្នកដាក់ពាក្យសុំត្រូវអនុវត្តតាមតិចតួច ដូចជាធ្វើសំណើសុំPCT ការចាប់ផ្តើមពីប្រទេសរបស់ខ្លួន ឬតំបន់ដើម្បីបញ្ជាក់ថាគាត់ស្របច្បាប់ក្នុងការបំពេញពាក្យសុំ ការពិពណ៌នាការប្រកាសទាមទារ ។

គុណប្រយោជន៍មួយទៀត តាមរយៈការបំពេញពាក្យសុំរបស់គាត់ អ្នកដាក់ពាក្យសុំបាន

ចំណេញពេលវេលាច្រើនមុនពេលគាត់សម្រេចដាក់ពាក្យសុំទៅប្រទេសណាមួយទៀត ។ ពេលវេលាដែលទទួលបានតាមរយៈនីតិវិធីនេះប្រហែលជា១៨ខែដែលធ្វើតាមPCT ។

បន្ថែមទៀតគឺមានគុណប្រយោជន៍សម្រាប់ការិយាល័យប្រកាសនីយបត្រតក្កកម្មជាតិដូចជាៈ

-ការិយាល័យប្រកាសនីយបត្រតក្កកម្មអាចដោះស្រាយពាក្យសុំបានច្រើនដោយសារតែPCT មានភាពងាយស្រួលធ្វើ ជាពិសេសត្រួតពិនិត្យទម្រង់បែបបទ ព្រោះជាទូទៅបែបបទនេះត្រូវបានពិនិត្យក្នុងដំណាក់កាលអន្តរជាតិ ។

ការិយាល័យប្រកាសនីយបត្រតក្កកម្មអាចសន្សំសំចៃតម្លៃបោះផ្សាយ ប្រសិនបើពាក្យស្នើសុំអន្តរជាតិត្រូវបានបោះផ្សាយជាភាសាផ្លូវការនៃប្រទេសមួយ ។ វាក៏អាចបោះផ្សាយរួមគ្នាជាភាសាផ្លូវការផ្សេងៗគ្នា ឬក៏បកប្រែភាសាណាមួយដោយយោងតាមពាក្យសុំអន្តរជាតិ ។ ការថតចម្លងអត្ថបទទាំងស្រុងនៃពាក្យសុំអន្តរជាតិតាមសំណើរបស់ភាគីដែលមានប្រយោជន៍ ។

ប្រព័ន្ធPCTមិនមានប៉ះពាល់ដល់ប្រាក់ចំណូលការិយាល័យនៃប្រទេសនីមួយៗទេ ប្រសិនបើគេមិនស្ម័គ្រចិត្តបង់ប្រាក់តម្លៃសេវានោះមកការិយាល័យPCT និងដើម្បីប្រើប្រាស់ពាក្យសុំអន្តរជាតិ ។ ដោយឡែកប្រាក់បង់ប្រចាំឆ្នាំ ឬប្រាក់ចុះបញ្ជីឡើងវិញចំពោះការិយាល័យនៃប្រទេសនីមួយៗមិនប៉ះពាល់ដល់ប្រព័ន្ធPCTទេ ។

ផលប្រយោជន៍ការត្រួតពិនិត្យរបស់ការិយាល័យប្រកាសនីយបត្រតក្កកម្ម គឺគោរពតាមពាក្យសុំពីបរទេស ពីរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និងរបាយការណ៍ត្រួតពិនិត្យបឋមអន្តរជាតិ ។

នៅពេលទទួលបានពាក្យសុំដែលបានត្រួតពិនិត្យបែបបទ ដោយយោងតាមរបាយការណ៍ស្រាវជ្រាវអន្តរជាតិ និងរបាយការណ៍ត្រួតពិនិត្យបឋមអន្តរជាតិ ពេលនោះការិយាល័យជាតិមិនចាំបាច់ត្រួតពិនិត្យទេ ។

## សង្ខេប

PCTផ្តល់នីតិវិធីងាយស្រួលសម្រាប់តក្កករ ឬអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មនៅក្នុងប្រទេសច្រើន ។ ជាបន្ថែមទៀតវាជម្រុញ និងសម្រួលដល់ការផ្លាស់ប្តូរព័តមានវិទ្យាដែលមានក្នុងឯកសារប្រកាសនីយបត្រតក្កកម្មចំពោះឧស្សាហកម្ម និងកម្មករដែលទាក់ទងជំនាញក្នុងវិស័យនេះ ។

ផលប្រយោជន៍ចំពោះអ្នកដាក់ពាក្យសុំប្រើប្រាស់តាមPCTគឺបំពេញពាក្យសុំនៅការិយាល័យតែមួយ តែមួយភាសា គាត់ទទួលបាននៅថ្ងៃបំពេញអន្តរជាតិ ហើយថ្ងៃបំពេញពាក្យសុំនោះនឹងមានប្រសិទ្ធភាពចំពោះប្រទេសដែលចង់ដាក់ការពារ ។ ជាបន្ថែមទៀតPCTផ្តល់នូវរយៈពេលមួយដែលអ្នកដាក់ពាក្យសុំអាចសម្រេចថាតើបន្តដំណើការនៅក្នុងប្រទេសដែលត្រូវកំណត់ដាក់ពាក្យសុំ ។

តួនាទីចម្បងរបស់WIPOក្នុងនីតិវិធីPCTគឺធ្វើឲ្យមានភាពងាយស្រួលចំពោះសន្ធិសញ្ញានេះតាម

រយៈការទំនាក់ទំនងPCTស្នើទៅប្រទេសដែលត្រូវដាក់ពាក្យ និងបោះផ្សាយពាក្យសុំPCT។

នេះជានីតិវិធីដែលស្នើសុំតាមប្រព័ន្ធPCT



# ជំពូកទី៩
# ការប្រកួតប្រជែងមិនស្មោះត្រង់

<u>វត្ថុបំណង</u>

បន្ទាប់ពីសិក្សាចប់ជំពូកនេះអ្នកនឹងអាចៈ

១-ផ្តល់ឧទាហរណ៍ពីការប្រគួតប្រជែងមិនស្មោះត្រង់

២-ធ្វើបញ្ជី និងពន្យល់ពីប្រភេទចម្បងនៃការប្រកួតប្រជែងមិនស្មោះត្រង់

៣-ពន្យល់ពីវិធីផ្សេងៗក្នុងប្រទេសជាច្រើន ក្នុងការអនុវត្តនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។

## សេចក្តីផ្តើម

ជំពូកនេះទាក់ទងជាមួយទស្សនៈនៃការប្រកួតប្រជែងមិនស្មោះត្រង់ ពន្យល់ពីអំពើដែលចាត់ទុកថាជាការប្រកួតប្រជែងមិនស្មោះត្រង់ និងពន្យល់ពីសំណងរដ្ឋប្បវេណីដែលត្រូវបានគេប្រើ រួមជាមួយការបំពេញកាតព្វកិច្ចនៃប្រទេសដើម្បីធានានូវភាពត្រឹមត្រូវនៃការប្រកួតប្រជែង ។ គំនិតនៃការប្រកួតប្រជែងមិនស្មោះត្រង់កើតឡើងតាំងពីឆ្នាំ១៩០០ នៅទីក្រុងBrusselsនៃអនុសញ្ញាទីក្រុងប៉ារីស ។

### អ្វីទៅជាការប្រកួតប្រជែងមិនស្មោះត្រង់?

មាត្រា 10bis(2)នៃអនុសញ្ញាទីក្រុងប៉ារីសកំណត់ អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ គឺជាអំពើប្រកួតប្រជែងណាផ្ទុយទៅនឹងភាពស្មោះត្រង់ក្នុងការអនុវត្តន៍លើឧស្សាហកម្ម ឬ ពាណិជ្ជកម្ម ។

មាត្រា 10bis (3) កំណត់ច្បាស់អំពីអំពើដែលត្រូវហាមឃាត់:

១-រាល់អំពីនៃការធ្វើឱ្យមានការភាន់ច្រលំតាមគ្រប់មធ្យោបាយលើ ទំនិញ ឬឧស្សាហកម្ម ឬសកម្មភាពខាងពាណិជ្ជកម្មនៃអ្នកប្រកួតប្រជែង ។

២-ធ្វើការក្លែងបន្លំពាណិជ្ជកម្មដើម្បីបង្ខូចនូវទំនិញ ឧស្សាហកម្ម ឬ សកម្មភាពពាណិជ្ជកម្មនៃអ្នកប្រកួតប្រជែង ។

៣-កាផ្សាយបំផ្លើសពីការប្រើប្រាស់ក្នុងពាណិជ្ជកម្ម ដែលធ្វើឱ្យសាធារណជនយល់ខុសទៅលើប្រភេទដំណើរការផលិត ធាតុផ្សំ គុណភាព និងបរិមាណនៃទំនិញ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

បន្ទាប់ទៀត អ្នកនឹងទទួលបាននូវការពន្យល់លំអិតពីប្រភេទបញ្ហាដែលទាក់ទងនឹងការប្រកួតប្រជែងមិនស្មោះត្រង់ ប៉ុន្តែពេលនោះសូមព្យាយាមឆ្លើយនូវៈ

**តើអំពើខាងក្រោមនេះមួយណាចាត់ទុកថា ជាអំពើប្រកួតប្រជែងមិនមិនស្មោះត្រង់?**

១-ការផ្សាយពាណិជ្ជកម្មថាការ៉េមYogurtរបស់អ្នកប្រកួតប្រជែងមួយមិនបានផលិតមកពីទឹកដោះគោទេ។

២-ធ្វើរបាយការណ៍មិនពិតមួយថា អ្នកប្រកួតតប្រជែងរបស់ខ្លួនត្រូវក្ស័យទុន។

៣-ធ្វើការជ្រើសរើសរូបLogoមួយ ដែលខុសគ្នាបន្តិចបន្តួចពីអ្នកប្រកួតប្រជែងមួយទៀត ។

៤-ការលួចគំរូសំងាត់នៃផលិតផលរបស់អ្នកប្រកួតប្រជែង ។

៥-លួចឯកសារនៃការបង្កើតផលិតថ្មីទាំងស្រុងរបស់អ្នកប្រកួតប្រជែង ។

<u>ចម្លើយ</u>

រាល់ឧទាហរណ៍ទាំងអស់ដែលបានផ្តល់នៅក្នុងសំណួរនេះ គឺជាភាពមិនស្មោះត្រង់ ចំលើយ ១-៤ គឺជាប្រភេទនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងត្រូវប្រើច្បាប់ស្តីពីការប្រកួតប្រជែងមិនស្មោះត្រង់ ។ ឧទាហរណ៍ទី៥ ចុងក្រោយ គឺវាទាក់ទងនឹងអំពើលួចអាចចាត់ទុកថាជាបទឧក្រិដ្ឋ ។

ដូចនេះការប្រកួតប្រជែងមិនស្មោះត្រង់គឺជាភាពមិនស្មោះត្រង់ក្នុងការអនុវត្ត ។ ជាការពិតទស្សនៈការអនុវត្តមិនស្មោះត្រង់នេះ គឺមានការពិបាកបន្តិចក្នុងការកំណត់និយមន័យ ហើយត្រូវកំណត់យ៉ាងច្បាស់ក្នុងច្បាប់ជាតិ ។ ច្បាប់ជាតិទាំងនេះ កំណត់ពីពាណិជ្ជកម្ម និងបរិស្ថានជុំវិញ ដើម្បីធានានូវភាពយុត្តិធម៌ក្នុងការប្រកួតប្រជែង និងជាលទ្ធផលមួយការពារផ្នែកកម្មសិទ្ធិបញ្ញា ។

## <u>ការចាំបាច់ដើម្បីការពារ</u>

តាមបទពិសោធន៍ខ្លះបង្ហាញថា មានក្តីសង្ឃឹមតិចណាស់នៃភាពយុត្តិធម៌ក្នុងការប្រកួតប្រជែងដើម្បីទទួលជោគជ័យតាមរយៈការប្រកួតប្រជែងដោយសេរីនៅលើទីផ្សារ ។ តាមទ្រឹស្តី អតិថិជនគឺជាអ្នកមានតួនាទីកំណត់ពីការប្រកួតប្រជែងសេដ្ឋកិច្ចទីផ្សារ អាចជម្រុញឲ្យសហគ្រិនមានភាពស្មោះត្រង់ចំពោះទំនិញ ឬសេវា ឲ្យដំណើរការបានល្អ ។ ទោះបីយ៉ាងណាក៏ដោយ ការពិតគឺមានភាពខុសគ្នានៅពេលស្ថានភាពសេដ្ឋកិច្ចកាន់តែស្មុគស្មាញ កាន់តែបាត់បង់អតិថិជន ពេលនោះពួកគេមិនអាចដឹងថាខ្លួនគេកំពុងប្រព្រឹត្តនូវអំពើប្រកួប្រជែងមិនស្មោះត្រង់នោះទេ តាមពិតអតិថិជនស្មោះត្រង់ត្រូវ តែទទួលបាននូវកិច្ចការពារពីការប្រកួតប្រជែងមិនស្មោះត្រង់ ។

ការប្រកួតប្រជែងដោយត្រឹមត្រូវលើទីផ្សារមិនអាចធានាតាមរយៈ កិច្ចការពារពីសិទ្ធិកម្មសិទ្ធិឧស្សាហកម្មបានទេ ។ អំពើប្រកួតប្រជែងផ្សេងៗទៀតមានដូចជា ការផ្សាយពាណិជ្ជកម្មបំផ្លើស និងការរំលោភបំពានលើលក្ខណៈសម្ងាត់ពាណិជ្ជកម្ម ជាទូទៅមិនទាក់ទងច្បាប់កម្មសិទ្ធិឧស្សាហកម្មទេ ច្បាប់ប្រកួតប្រជែងមិនស្មោះត្រង់គឺសំខាន់បំពេញបន្ថែមទាំងច្បាប់កម្មសិទ្ធិឧស្សាហកម្ម ទាំងការផ្តល់កិច្ចការពារ ។

**តើច្បាប់ការប្រកួតប្រជែងមិនស្មោះត្រង់ទាក់ទងនឹង ច្បាប់ស្តីពីការរំលោភបំពានលើការចូលកាន់ទីផ្សារយ៉ាងដូចម្តេច?**

វិធានការការពារការប្រកួតប្រជែងមិនស្មោះត្រង់ ហើយវិធានការទាំង នោះស្តីពីកិច្ចការពារលើការប្រតិបត្តិពាណិជ្ជកម្ម (ច្បាប់ប្រឆាំងការទុកចិត្ត) គឺជាអន្តរទំនាក់ទំនង ។ បទប្បញ្ញត្តិទាំង២នេះ មានគោលបំណងធានាលើប្រតិបត្តិការអោយមានប្រសិទ្ធិភាពលើសេដ្ឋកិច្ចទីផ្សារ ទោះបីជាដូចនេះក៏ដោយ ក៏ច្បាប់នេះមានវិធីផ្សេង ច្បាប់ប្រឆាំងការទុកចិត្តនេះមានទំនាក់ទំនងជាមួយសេរីភាពនៃការប្រកួតប្រជែងតាមរយៈការទប់ផ្នែកពាណិជ្ជកម្ម និងការរំលោភបំពាននៃសេដ្ឋកិច្ច ។ ម៉្យាងទៀតច្បាប់ស្តីពីការប្រកួតប្រជែងមិនស្មោះត្រង់ទាក់ទងដល់ការធានាយុត្តិធម៌ក្នុងការប្រកួតប្រជែង ដោយបង្ខំឱ្យអ្នកចូលរួមអនុវត្តទៅតាមវិធានការតែមួយ ទោះបីជាច្បាប់ទាំងពីរនៅក្នុងទិដ្ឋភាពផ្សេងគ្នា ។

<u>សំណួរវាយតម្លៃខ្លួនឯង</u>

**ខាងក្រោមនេះតើមូលហេតុសុពលភាពមួយណាជាតម្រូវការច្បាប់ដែលទាក់ទងដល់ ការប្រកួតប្រជែងមិនស្មោះត្រង់?**

១-ផ្តល់នូវកម្រិតប្រគួតប្រជែងតាមផ្នែកដែលសំខាន់ និងមានពីមុនមក

២-ជៀសវាងការរំលោភបំពានពីសិទ្ធិផ្តាច់មុខ

៣-ជួយធានាការងារទីផ្សារសេរី

៤-ជៀសវាងការរំលោភបំពានលើប្រកាសនីយបត្រតក្កកម្ម

៥-បង្ខំឱ្យអនុវត្តការពារម៉ាក

<u>ចម្លើយ</u>

១-បាទ ការប្រើប្រាស់ភាពដូចគ្នារវាងការប្រកួតប្រជែងសេដ្ឋកិច្ច និងការប្រកួតប្រជែងកីឡាដើម្បីទទួលបានលទ្ធផលល្អ និងស្មោះត្រង់ក្នុងការប្រកួតប្រជែងសេដ្ឋកិច្ច និងកីឡា ទាមទារឱ្យអ្នកប្រកួតប្រជែងទាំងអស់គោរពវិធានការរួម ។

២-ទេ នេះវាស្ថិតនៅក្រោមច្បាប់ប្រឆាំងការទុកចិត្ត ឬច្បាប់ប្រឆាំងការធ្វើផ្តាច់មុខ Monopoly ។

៣-បាទ ជាការពិត

៤-ទេ នេះបង្ខំឱ្យអនុវត្តតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម

៥-ទេ វាអាចស្ថិតនៅក្រោមច្បាប់ម៉ាក

## អំពើនៃការប្រកួតប្រជែងមិនសោះត្រង់

វាជាការពិតណាស់ការពិពណ៌នាលើការប្រកួតប្រជែងមិនស្មោះត្រង់ជាអំពើ ផ្ទុយនឹងការធ្វើពាណិជ្ជកម្មត្រឹមត្រូវ ភាពយុត្តិធម៌ រហូតដល់ពាក្យ ភាពយុត្តិធម៌ និងស្មោះត្រង់នោះត្រូវបានគេទទួល

យកជាកម្រិតស្តង់ដារមួយ ។ " ភាពយុត្តិធម៌ " ឬ "ភាពស្មោះត្រង់" នៅក្នុងការប្រកួតប្រជែងមិនបានឆ្លើយតបទៅនឹងទស្សនៈសង្គមសេដ្ឋកិច្ច និង ក្រមសីលធម៌សង្គមទេ ហើយអាចខុសប្លែកពីប្រទេសមួយទៅប្រទេសមួយ (ហើយជួនកាលនៅក្នុងប្រទេសតែមួយក៏មានលក្ខណៈខុសគ្នាដែរ) ហើយកំរិតស្តង់ដារនោះអាចផ្លាស់ប្តូរបានគ្រប់ពេល ។ ជាបន្ថែមទៀតតែងតែមានអំពើថ្មីៗ នៃការប្រកួតប្រជែងមិនស្មោះត្រង់ ចាប់តាំងពីគ្មានការកំណត់ព្រំដែនលើការបង្កើតថ្មីក្នុងការប្រកួតប្រជែង ។ ក្នុងគោលបំណងដាក់បញ្ចូលរាល់អំពើពីមុន និងអនាគត នៃការប្រកួតប្រជែងនៅក្នុងនិយមន័យទូលាយមួយដែលក្នុងពេលនោះបានកំណត់ ពិការហាមឃាត់ ហើយអាចកែប្រែបាននៅលើទីផ្សារ ។

ទោះបីជាយ៉ាងណាក៏ដោយ នេះមិនមែនមានន័យថាអំពើនៃការប្រកួតប្រជែងគ្មាននិយមន័យទូទៅណាមួយទេ ។ កំណត់សំគាល់សំខាន់បំផុតនៃអំពើទាំងនេះ គឺបណ្តាលឱ្យមានការភាន់ច្រលំការបង្ខូចឈ្មោះ និងការផ្សាយបំផ្លើសខុសពីការពិត ។ ឧទាហរណ៍ ទីផ្សារដែលមានលក្ខណៈមិនស្មោះត្រង់ គឺក្នុងគោលបំណងទទួលបានជោគជ័យក្នុងការប្រកួតប្រជែង ដោយមិនពឹងផ្អែកលើជោគជ័យនៃគុណភាព តម្លៃផលិតផល និង សេវាកម្ម ។ ការធ្វើឲ្យមានឥទ្ធិពលតាមតម្រូវការរបស់អតិថិជនតាមរយៈការផ្សាយបំផ្លើស ដែលការអនុវត្តបែបបទនេះទាក់ទងជាមួយការប្រកួតប្រជែងមិនស្មោះត្រង់ ។

ទោះបីជាយ៉ាងណាក៏ដោយ កត្តាដែលសំខាន់បំផុត ដើម្បីកំណត់ " ភាពមិនស្មោះត្រង់" នៅក្នុងទីផ្សារគឺមានប្រភពមកពីគោលបំណងនៃច្បាប់ការប្រកួតប្រជែងមិនស្មោះត្រង់ ។ នៅក្នុងទស្សនៈនេះច្បាប់ការប្រកួតប្រជែងមិនស្មោះត្រង់ ត្រូវបានកំណត់ឡើងដើម្បីការពារអ្នករកស៊ីដែលស្មោះត្រង់ទន្ទឹមនោះគឺជួយការពារអតិថិជនជាកាត្តាសំខាន់ ។ ជាងនេះទៅទៀតប្រទេសខ្លះបានកំណត់ច្បាប់ពិសេសដើម្បីការពារជាសាធារណៈ និងផលប្រយោជន៍របស់ពួកគេ នៅក្នុងការប្រកួតប្រជែងសេរី ។ ច្បាប់ទំនើបនៃការប្រកួតប្រជែងមិនស្មោះត្រង់ ក្នុងគោលបំណងបម្រើ៣យ៉ាង ការពារអ្នកប្រកួតប្រជែង, ការការពារអតិថិជន និងធានាសុវត្ថិភាពផលប្រយោជន៍នៃការប្រកួតប្រជែងជាសាធារណៈជាធំ ។

ម៉្យាងវិញទៀត មានកិច្ចព្រមព្រៀងធំមួយថែងថា អំពើ និងការអនុវត្តត្រូវមានលក្ខណៈស្របជាមួយភាពយុត្តិធម៌ក្នុងប្រកួតប្រជែង ។ ទាំងនេះត្រូវបានពិភាក្សាលំអិត ដូចខាងក្រោម ៖

## ប្រភេទនៃអំពើប្រកួតប្រជែងមិនស្មោះត្រង់

ខាងក្រោមនេះជាអំពើដ៏សាមញ្ញដែលចាត់ទុកថាជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់:

- បង្កឱ្យមានការភាន់ច្រលំ
- ផ្សាយបំផ្លើសពីការពិត

- បង្ខូចឈ្មោះអ្នកប្រកួតប្រជែង
- បង្ហាញឱ្យដឹងនូវពត៌មានសម្ងាត់
- ទាញយកប្រយោជន៍ ពីជោគជ័យរបស់អ្នកប្រកួតប្រជែងផ្សេងទៀត
- ផ្សព្វផ្សាយពាណិជ្ជកម្ម ដោយប្រៀបធៀបផលិតផលរបស់អ្នកប្រកួតប្រជែងផ្សេង

**១-បង្កឱ្យមានការភាន់ច្រលំ**

អនុសញ្ញាទីក្រុង Paris (មាត្រា10bis(3)) តម្រូវឱ្យរដ្ឋសមាជិកហាមឃាត់រាល់អំពើធ្វើឱ្យមានការភាន់ច្រលំតាមគ្រប់មធ្យោបាយ ទោះបីជាក្នុងការបង្កើតទំនិញ ឬឧស្សាហកម្ម ឬសកម្មភាពពាណិជ្ជកម្មនៃអ្នកប្រកួតប្រជែង ។ វិសាលភាពនៃមាត្រានេះ ទូលាយណាស់ គឺគ្រប់ដណ្ដប់ រាល់អំពើពាណិជ្ជកម្មដែលទាក់ទងដល់ ម៉ាក, សញ្ញា, ផ្លាក, បដា, កញ្ចប់, រូបរាង ឬពណ៌នៃទំនិញ ឬសញ្ញាខុសគ្នាផ្សេងទៀតដែលបានប្រើដោយអ្នកជំនួញ ។ ដូចនេះមិនត្រឹមតែសញ្ញាទំនិញបែងចែកពីគ្នា សេវាកម្មជំនួញប៉ុណ្ណោះទេ ថែមទាំងរូបរាងទំនិញ និងសេវាកម្មត្រូវ ចាត់ទុកថាទាក់ទងដល់ការហាមឃាត់រាល់ការភាន់ច្រលំ ។ ទោះបីយ៉ាងណាក៏ដោយ មានផ្នែកពីរសំខាន់ ដែល មានការភាន់ច្រលំជារឿយៗ ។

ទាំងនេះ គឺជាប្រភពដើមនៃពាណិជ្ជកម្ម និងរូបរាងទំនិញ ។ ទោះបីជាយ៉ាងណាក៏ដោយនេះមិនរាំងស្ទះ ឬព្រំដែនកំណត់ក្នុងកិច្ចការពារ ជាមួយការភាន់ច្រលំទេ ។

ជាឧទាហរណ៍ អំពើធ្វើឲ្យភាន់ច្រលំអាចជាស្ថានភាពដែលបែងចែកគ្នាទាំងស្រុង ពីហាងតុក្កាអាមេរិចដែលទទួលស្គាល់ដោយម៉ាកពាណិជ្ជកម្ម " Toys 'R' Us” ហើយអាចលក់Game នៅក្នុងហាងដែលហៅថា Games 'R' Us ។

**តើគំនូរឧស្សាហកម្មអាចការពារស្នាដៃយ៉ាងដូចម្ដេច?**

ជាទូទៅបទប្បញ្ញត្តិហាមឃាត់ផលិតផលដូចគ្នា ឬស្រដៀងគ្នាចំពោះទំនិញដូចគ្នា ។ ទោះបីយ៉ាងណាក៏ដោយបទប្បញ្ញត្តិម៉ាក ការពារក្រោមច្បាប់ពិសេសជាច្រើន ដូចជាច្បាប់គំនូរឧស្សាហកម្មត្រូវបានកំណត់ក្នុងវិធីជាច្រើនដែលខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ក្នុងលក្ខណៈដូចគ្នាច្បាប់ការពារពិសេស ក្រោមច្បាប់ម៉ាកនោះ ការកំណត់នេះអាចទាក់ទងដល់ការអនុវត្តតាមច្បាប់គំនូរឧស្សាហកម្មចំពោះផលិតផលដែលមានរូបរាង និងទំហំការពារដែលមានចែងក្នុងបទប្បញ្ញត្តិ ។ ជាឧទាហរណ៍ ប្រសិនបើការពារលើគំនូររូបខាងក្រៅនៃការតុបតែងផ្ទៃខាងក្រៅលើផលិតផលដែលបានចុះបញ្ជី កិច្ចការពារការចម្លងគំរូសំរាប់តុបតែងផលិតផលរបស់ពួកគេ អាចស្ថិតនៅក្រោមច្បាប់ការប្រកួតប្រជែងមិនស្មោះត្រង់ ប្រសិនបើគំនូរដែលថតចម្លងនោះធ្វើឱ្យខុស ឬធ្វើឱ្យមានការភាន់ច្រលំប្រភពដើមនៃពាណិជ្ជកម្ម ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**តើអំពើភាន់ច្រលំមួយណា ដែលចាត់ទុកថាជាការប្រកួតប្រជែងមិនស្មោះត្រង់ ?**

១-ផលិតផលមួយមានរូបថតប្រមុខរដ្ឋនៅលើកញ្ចប់ ។

២-ក្រុមហ៊ុនភេសជ្ជៈមួយ ប្រើប្រាស់ដបដូចដប **Coca-Cola** ។

៣-ការប្រើម៉ាកដែលដូចគ្នានឹងម៉ាកមួយផ្សេងទៀតដែលមិនទាន់បានចុះបញ្ជី។

៤-ភោជនីយដ្ឋានមួយតុបតែង និងបំពាក់គ្រឿងសង្ហារឹមស្ទើរតែដូចគ្នានឹងអ្នកប្រកួតប្រជែង ដែលល្បីល្បាញ ។

<u>ចម្លើយ</u>

ទី១- ក្នុងករណីនេះ គ្មានអ្វីទាក់ទងនឹងការប្រកួតប្រជែងមិនស្មោះត្រង់ទេ ប្រមុខរដ្ឋអាចប្ដឹងពីការរំលោភផ្ទាល់ខ្លួន ។

ទី២-៤- គឺជាការភាន់ច្រលំ ហើយអាចជាអំពើប្រកួតប្រជែងមិនស្មោះត្រង់

ទី២-ក្នុងករណីនេះ អាចទាក់ទងដល់ការរំលោភបំពានម៉ាក

ទី៣-ម៉ាកដែលមិនបានចុះបញ្ជីគឺមិនទាក់ទងទេ ចំណុចសំខាន់គឺការធ្វើឲ្យមានការភាន់ច្រលំ ។

**<u>២-ការផ្សាយបំផ្លើសខុសពីការពិត</u>**

ការផ្សាយបំផ្លើសខុសពីការពិតអាចកំណត់ថាជាការបង្ហាញបំផ្លើសពីផលិតផល ឬសេវាកម្មរបស់អ្នកប្រកួតប្រជែង ។ ជាទូទៅការប្រកួតប្រជែងមិនស្មោះត្រង់គឺមិនបង្កបញ្ហា ផ្ទុយទៅវិញ ការផ្សាយបំផ្លើសការពិតនាំឱ្យមានផលវិបាកច្រើនដល់អតិថិជនដែលបានផ្ដល់ពត៌មានមិនពិត អាចប៉ះពាល់ហិរញ្ញវត្ថុ ។ ដៃគូប្រកួតប្រជែងស្មោះត្រង់អាចបាត់បង់នូវអតិថិជន តម្លាតភាពទីផ្សារធ្លាក់ចុះដោយសារវិបត្តិសេដ្ឋកិច្ច និងស្ថេរភាពសេដ្ឋកិច្ច ។

មានការធ្វើជំរឿនស្ថិតិជាច្រើន យោងទៅតាមទស្សនៈនៃការផ្សាយបំផ្លើស មានទាំងរបាយការណ៍ភូត ទាំងរបាយការណ៍មិនពិតដល់អតិថិជន ។ វាជាការពិចារណាលើការផ្សាយមិនពិត សូម្បីតែរបាយការណ៍ធ្វើជាលាយលក្ខណ៍អក្សរត្រឹមត្រូវក៏អាចខុសបានដែរ ។

ជាឧទាហរណ៍ គ្រឿងផ្សំគីមី ត្រូវបានគេហាមប្រើក្នុងនំប៉័ង តុលាការនៃប្រទេសជាច្រើនបានចាត់ទុកថា ការផ្សាយពាណិជ្ជកម្មថា នំប៉័ងមិនលាយជាតិគីមីទេ នេះជាការផ្សាយធ្វើឲ្យយល់ខុសព្រោះតាមពិតវាមិនប្រើជាតិគីមីទេ នេះជាការធ្វើឲ្យយល់ច្រលំចំពោះការផ្សាយពាណិជ្ជកម្ម ។

វាមិនចាំបាច់បង្កើតឲ្យមានចំងល់ផលិតផលទេ ដរាបណាការបញ្ជាក់នោះធ្វើឱ្យមានឥទ្ធិពលចំពោះអតិថិជន ។ ឧទាហរណ៍ ប្រសិនបើសាធារណជនចូលចិត្តទំនិញក្នុងស្រុក ជាងទំនិញបរទេស ដៃគូប្រកួតប្រជែងផ្សាយថា ទំនិញនាំចូលល្អជាងទំនិញក្នុងស្រុកនោះ គឺជាការផ្សាយបំផ្លើស ធ្វើឱ្យ

គេយល់ខុសថាទំនិញនាំចូលមានគុណភាពខ្ពស់ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**តើអំពើខាងក្រោមនេះមួយណាជាអំពើបំផ្លើសការពិត? ដោយផ្សាយថានំប័ុងនេះមានជាតិ Calory តិចជាងនំប័ុងមួយដុំផ្សេងទៀត ហើយធ្វើឲ្យមានរាងស្អាត ។**

<u>ចម្លើយ</u>

បាទ ការផ្សាយពតិមានថានំប័ុងមានជាតិ Calory តិចជាងនំប័ុងផ្សេងជាការផ្សាយបំផ្លើស ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**ក្រុមហ៊ុនមួយផលិតស្រាបៀរថ្មីមួយ ហៅថា Bavaria តើអាចជាកំហុសចំពោះអតិថជនឬទេ ?**

<u>ចម្លើយ</u>

ប្រសិនបើស្រាបៀមិនបានផលិតនៅក្នុងប្រទេសអាល្លឺម៉ង់នៃតំបន់ Bavariaទេ វាអាចភូត ព្រោះគេអាចគិតថាស្រាបៀនោះផលិតនៅអាល្លឺម៉ង មានគុណភាពតាមស្តង់ដារ ។

នៅក្នុងប្រទេសខ្លះបញ្ហានេះ វាអាចទាក់ទងដល់ការរំលោភបំពានម៉ាកសម្គាល់ភូមិសាស្រ្ត។

**តើទស្សនៈផ្សាយបំផ្លើស មានការខុសប្លែកពីប្រទេសមួយទៅប្រទេសមួយយ៉ាងម៉េច?**

ជាទូទៅទស្សនៈផ្សាយបំផ្លើសមានភាពខុសគ្នាពីប្រទេស១ ទៅប្រទេស១ ហើយបញ្ហានេះអាចកំណត់ច្បាស់នៅក្នុងសន្ធិសញ្ញាជាតិស្តីពីការបំផ្លើស ។ ទោះបីជាការបំផ្លើសនោះ មិនចាត់ទុកថាអំពើឆបោក ព្រោះការផ្សាយបែបនេះធ្វើឲ្យគេងាយចាប់អារម្មណ៍តាមរយៈ "លក់ដោយនិយាយ" គ្រាន់តែមួយភ្លែត ។ នៅក្នុងប្រទេសខ្លះ (អាល្លឺម៉ង) សាធារណជនជឿលើការផ្សព្វផ្សាយពាណិជ្ជកម្មជាពិសេសផ្សាយថាមានតែមួយគត់ " ល្អបំផុត ដំបូងគេ ។ល។" ជាផលវិបាកត្រូវទាមទារនូវកំរិតស្តង់ដារមួយតឹងរឹង ។ ប្រទេសផ្សេងៗទៀត ដូចជាអ៊ីតាលី និងសហរដ្ឋអាមេរិច មានជំហាផ្ទុយនិងជាទូទៅអភ័យទោសដល់ការផ្សាយថាមានតែមួយគត់ ។ ដូចនេះនៅក្នុង USA ជាទូទៅតុលាការគ្រាន់តែធ្វើ អន្តរាគមន៍ប៉ុណ្ណោះ ប្រសិនបើផលិតផលដែលផ្សាយថាជាផលិតផលល្អបំផុត ។

<u>**៣-ការបង្ខូចដល់ដៃប្រកួតប្រជែង**</u>

ការបង្ខូចគឺអំពើបង្កឱ្យយល់ខុសដល់ដៃគូប្រកួតប្រជែង ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់បំណងល្អផ្នែកពាណិជ្ជកម្មរបស់គាត់ ដូចជាការផ្សាយមិនពិត ការផ្តល់ពតិមានមិនពិតដល់អតិថិជន ។

តែទោះបីជាអំពើនេះ មិនផ្តល់បាយការណ៍ខុស ឬរបាយការណ៍ ឆោបោកពីផលិតផលរបស់ដៃគូប្រកួតប្រជែងជាក់ស្តែងក៏ដោយ ក៏វាជាអំពើបំផ្លើស មិនត្រឹមត្រូវ លើដៃគូរបស់ខ្លួនទាំងផលិតផល ឬសេវា ។ ហេតុនេះអំពើបំផ្លើសនេះតែងតែប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកជំនួញ ដោយសារតែការផ្សាយពតិមានមិនពិតនៃផលិតផលរបស់គាត់ ហើយអតិថិជនអាចទទួលរងការប៉ះពាល់ ។

**តើទស្សនៈនៃការផ្សាយបង្ខូច ខុសគ្នាពីប្រទេស១ទៅប្រទេស១ ទៀតយ៉ាងណា?**

ជាការពិត នៅក្នុងប្រទេសខ្លះ ការផ្សាយជាលាយលក្ខណ៍អក្សរនូវរបាយការណ៍របស់ដៃគូប្រកួតប្រជែងអាចចាត់ទុកជាអំពើប្រកួតប្រជែងមិនស្មោះត្រង់ ប្រសិនបើពាក្យក្នុងយុទ្ធនាការផ្សព្វផ្សាយនោះត្រូវបានធ្វើឱ្យប៉ះពាល់ដល់អតិថិជន ។ ម៉្យាងវិញទៀត ប្រទេសខ្លះបានកំណត់យ៉ាងតឹងរឹងនៃអំពើបង្ខូចនេះ គឺភាពមិនត្រឹមត្រូវ ឬរបាយការណ៍ដែលធ្វើឱ្យមានការយល់ខុស ។

លក្ខណៈខុសគ្នានេះ ត្រូវបានគេរកឃើញតាមរយៈការវាយតម្លៃលើពាណិជ្ជកម្មស្មោះត្រង់ ។ នៅទីណាដែលច្បាប់ប្រកួតប្រជែងមិនស្មោះត្រង់ បានការពារលើកេរ្តិ៍ឈ្មោះរបស់ពាណិជ្ជករ ដូចដែលមាននៅក្នុងប្រទេសអឺរុប ។ បទប្បញ្ញត្តិនៃការបង្ខូចការងារជំនួញពិសេសត្រូវបានធ្វើឡើងដែលជាគោលការណ៍ គឺកំណត់ច្បាស់លាស់ស្តីពីការប្រកួតប្រជែង ដោយកំណត់ពីសេរីភាពនៃការឃោសនា ។ នៅប្រទេសជាច្រើន ជាពិសេសប្រទេសដែលមិនទាន់មានការយល់ដឹងពីច្បាប់ស្តីពីការប្រកួតប្រជែងមិនស្មោះត្រង់ ពេលនោះវាមានជំហាជំទាស់គ្នា ព្រោះគេយល់ថាការប្រកួតប្រជែង គឺជាការវាយសំរុកទៅលើដៃគូរបស់ខ្លួនដែលមិនអាចជៀសបាន គឺពួកគេត្រូវតែមានការអធ្យាស្រ័យគ្នាព្រោះនោះគឺជាបន្ទាត់នយោបាយទីផ្សាររបស់ពួកគេ ។ នៅក្នុងប្រទេសទាំងនោះជាទូទៅ ដើមចោទត្រូវបង្ហាញភស្តុតាងនូវរបាយការណ៍មិនពិតទាំងនោះ ដែលពេលខ្លះមិនអាចធ្វើទៅបាន ។

**តើអំពើខាងក្រោមនេះ មួយណាជាការប្រកួតប្រជែងមិនស្មោះត្រង់ ដោយសារការផ្សាយបង្ខូច?**

១-និយាយថាការ៉េម Yogurt របស់ដៃគូប្រកួតប្រជែងធ្វើពីទឹកដោះគោមិនស្រស់។

២-និយាយថា ផលិតផលដៃគូរបស់ខ្លួនគឺល្អសំរាប់សុខភាពរបស់អតិថិជន ។

៣-ការប្រើប្រាស Logoស្រដៀងទៅនឹង Logo នៃផលិតផលរបស់ដៃគូខ្លួន ។

<u>ចម្លើយ</u>

ទាំងអស់នោះ គឺជាឧទាហរណ៍នៃការប្រកួតប្រជែងមិនស្មោះត្រង់ ប៉ុន្តែសំណួរលេខ១ គឺជាឧទាហរណ៍ នៃការផ្សាយបង្ខូចព្រោះរបាយការណ៍នោះមិនពិត ។ សំណួរលេខ២ គឺជាអំពើផ្សាយបំផ្លើសពីការពិត ហើយសំណួរលេខ៣ គឺជាការឱ្យភាន់ច្រលំ ។

## <u>៤-ការបង្ហាញនូវពត៌មានសំងាត់</u>

ការប្រកួតប្រជែងពាណិជ្ជកម្មនៃសហគ្រាស គឺអាចធ្វើឡើងតាមព័ត៌មានថ្មីៗដែលសហគ្រាសនោះមានផ្ទាល់ខ្លួន ជាឧទាហរណ៍បញ្ជីឈ្មោះអតិថិជនរបស់ក្រុមហ៊ុន ហើយបញ្ជីនេះអាចយកប្រៀបលើក្រុមហ៊ុនប្រកួតប្រជែងរបស់ខ្លួន ដែលជាបញ្ជីមិនមានគុណភាពល្អ ។ ជាឧទាហរណ៍បន្ថែមទៀត សហគ្រាសមួយបានអភិវឌ្ឍលក្ខណៈសំងាត់នៃដំណើរការឧស្សាហាកម្ម ដែលមានលទ្ធភាពលក់នូវគុណភាពល្អ ឬតម្លៃថោក ។ ខ្ញុំសង្ឃឹមថាអ្នកយល់ដូចខ្ញុំ ប្រសិនព័ត៌មានទាំងនេះត្រូវបានគេផ្តល់ទៅ

ឱ្យដៃគូរបស់ខ្លួនដោយគ្មានការអនុញ្ញាតពីម្ចាស់ វាជាអំពើប្រកួតប្រជែងមិនស្មោះត្រង់ ។ ជាការពិតការបង្ហាញនូវពត៌មានសម្ងាត់គឺចាត់ទុកថា ជាការប្រកួតប្រជែងមិនស្មោះត្រង់ តាមរយៈកិច្ចព្រមព្រៀង TRIPS ឆ្នាំ១៩៩៤ ដែលតម្រូវទៅតាមសមាជិកអង្គការពាណិជ្ជកម្មពិភពលោកដែលបានផ្តល់នូវកិច្ចការពារ " ពត៌មានសម្ងាត់" ។

កិច្ចព្រមព្រៀង TRIPS ពិពណ៌នាពីកិច្ចការពារពត៌មានសម្ងាត់ថា ជាអំពើចាំបាច់ត្រូវការពារប្រឆាំងទៅនឹងការប្រកួតប្រជែងមិនស្មោះត្រង់ ។

**ហេតុអ្វីបានជាការពារប្រកាសនីយបត្រតក្កកម្ម មិនអាចប្រើប្រាស់ដើម្បីការពារព័ត៌មានសម្ងាត់នេះ ?**

ជាទូទៅកម្លាំងប្រកួតប្រជែង អាស្រ័យលើការបង្កើតបច្ចេកទេស និងដឹងពីរបៀបធ្វើក្នុងវិស័យឧស្សាហកម្ម ឬពាណិជ្ជកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយបច្ចេកវិទ្យា និងដឹងពីរបៀបធ្វើមិនតែងតែការពារដោយប្រកាសនីយបត្រតក្កកម្មទេ ។ ជាដំបូង ប្រកាសនីយបត្រតក្កកម្មគឺសម្រាប់តែតក្កកម្មក្នុងវិស័យបច្ចេកវិទ្យា មិនមែនសម្រាប់លទ្ធផលនៃការបង្កើតឡើងដែលទាក់ទងនឹងដំណើការពាណិជ្ជកម្មទេ ។ ជាងនេះទៅទៀត ការរកឃើញនូវបច្ចេកវិទ្យាខ្លះៗ ឬពត៌មាន នៅពេលមានប្រយោជន៍ខាងពាណិជ្ជកម្មចំពោះពាណិជ្ជករ បច្ចេកទេសនេះអាចខ្វះនៅ លក្ខណៈថ្មី ឬជំហានរកឃើញថ្មីដែលទាមទារឱ្យពួកគេមានប្រកាសនីយបត្រតក្កកម្ម ។ លើសពីនេះទៀតនៅពេលពាក្យសុំប្រកាសនីយបត្រតក្កកម្មត្រូវបានគេផ្អាក ហើយពត៌មានទាំងនេះមិនទាន់បានផ្សាយជាសាធារណៈ ម្ចាស់ប្រកាសនីយបត្រតក្កកម្មនេះគួរតែត្រូវបានការពារប្រឆាំងទៅនឹងការបង្ហាញពត៌មានមិនត្រឹមត្រូវពីអ្នកដទៃ ព្រោះគេមិនទាន់ប្រាកដថាអ្នកដាក់ពាក្យសុំនឹងទទួលបានប្រកាសនីយបត្រតក្កកម្មឬទេ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**តើខាងក្រោមនេះអាចចាត់ទុកជាពត៌មាន សម្រាប់ការពារក្រោមកិច្ចព្រមព្រៀង TRIPS ឬទេ ?**

១-វិក័យប័ត្រទឹកក្រូច

២-ពត៌មានប្រកាសនីយបត្រតក្កកម្មដែលហួសរយៈពេលការពារ

៣-ពត៌មានដែលមិនទាន់ទទួលបានប្រកាសនីយបត្រតក្កកម្ម

៤-បញ្ជីឈ្មោះអតិថិជន

<u>ចម្លើយ</u>

មានតែសំណួរលេខ២ មិនអាចចាត់ទុកថាជាលក្ខណៈសម្ងាត់ពាណិជ្ជកម្ម ដូចជាពត៌មានក្នុងប្រកាសនីយបត្រកម្មត្រូវបានប្រកាស ហើយក្នុងវិស័យសាធារណៈឬអាចប្រើដោយសេរី បន្ទាប់ពីហួសរយៈពេលការពារ ។

## ការទាញយកផលប្រយោជន៍មិនត្រឹមត្រូវពីសមិទ្ធិផលរបស់ដៃគូ

សញ្ញាណនៃ "សេរី" មានលក្ខណៈធម្មតាជាមួយនឹងសញ្ញាណនៃការបង្កឱ្យមានការភាន់ច្រលំ និងការផ្សាយបំផ្លើស វាអាចត្រូវបានកំណត់និយមន័យទូលាយនៃការប្រកួតប្រជែងដោយក្លែងបន្លំ ។ ទោះបីជាយ៉ាងណាក៏ដោយ ជាគោលការណ៍ទីផ្សារសេរី ការធ្វើពាណិជ្ជកម្មលើសមិទ្ធផលរបស់អ្នកដ៏ទៃគឺអយុត្តិធម៌ ។ ម៉្យាងទៀតអំពើដែលនាំឱ្យមានការភាន់ច្រលំ ឬផ្សាយបំផ្លើស គឺជាការធ្វើដោយសេរីលើសមិទ្ធផលរបស់អ្នដ៏ទៃ ប៉ុន្តែជាទូទៅត្រូវទទួលស្គាល់ជាអំពើអយុត្តិធម៌ ។

មានប្រភេទជាច្រើននៃ "សេរីភាព" រួមមានភាពខុសគ្នាគុណភាព និងតម្លៃនៃម៉ាករបស់ដៃគូប្រកួតប្រជែង ។ អំពើនេះអាចកើតឡើងប្រសិនបើម៉ាកដូចគ្នាត្រូវបានប្រើលើទំនិញ ឬសេវាផ្សេងគ្នា ។

## ការផ្សាយពាណិជ្ជកម្មដោយប្រៀបធៀប

ការផ្សាយពាណិជ្ជកម្មដោយធ្វើការប្រៀបធៀបអាចមាន២ទម្រង់ ជាវិជ្ជមាន ដោយយោងតាមផលិតផលរបស់អ្នកដ៏ទៃ (ប្រកាសថាផលិតផលនេះល្អដូច) ឬក្នុងន័យអវិជ្ជមាន ផ្សាយថាផលិតផលនេះល្អជាង។ ក្នុងទម្រង់ទីមួយៈ នៅពេលផលិតផលរបស់អ្នកប្រកួតប្រជែងនេះល្បី វាជាភាពមិនត្រឹមត្រូវនៃគោលបំណងល្អរបស់អ្នកប្រកួតប្រជែងដ៏ទៃទៀត ។ ទម្រង់ទី២ ផលិតផលរបស់អ្នកប្រកួតប្រជែងត្រូវបានគេរិះគន់ វាគឺជាការបង្អាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ ទម្រង់ប្រៀបធៀបទាំង២នេះទាក់ទងទៅនឹងអ្នកប្រកួតប្រជែងដែលបានបញ្ចេញទាំងឈ្មោះជាសាធារណៈ។

ទោះបីជាយ៉ាងណាក៏ដោយត្រូវចងចាំថា មានភាពខុសគ្នាក្នុងការវាតម្លៃសញ្ញាណ "ការផ្សាយបំផ្លើស" ជាពិសេស"ការផ្សាយបង្ខូចកេរ្តិ៍ឈ្មោះ" ដូចបានបញ្ជាក់ខាងលើ ប្រទេសខ្លះចាត់ទុករបាយការណ៍ផ្សព្វផ្សាយអស្ចារ្យ ឬមានតែ១ "គឺល្អបំផុត" គឺជាការផ្សាយបំផ្លើស ប្រសិនបើមិនអាចធ្វើឲ្យបានដូចការផ្សាយនោះ ។ ការវាយតម្លៃផ្សេងៗគ្នានៃសញ្ញាណ " ផ្សាយបង្ខូចកេរ្តិ៍ឈ្មោះ និងមិនត្រឹមត្រូវ" វាជាព្រឹត្តិការណ៍មួយដ៏សំខាន់ ។ នៅក្នុងប្រទេសជាច្រើន មានការអនុញ្ញាត ប៉ុន្តែផ្ទុយមកវិញវាជារបាយការណ៍បង្អាប់ ការផ្សព្វផ្សាយពាណិជ្ជកម្មដោយប្រៀបធៀប គឺមានការអាស្រ័យឱ្យគ្នាទៅវិញទៅមក ។ បើអ្វីដែលបាននិយាយវាជាការពិត ពេលនោះតុលាការមិនយកចិត្តទុកដាក់ទេ តែបើពិនិត្យមើលខាងអ្នកប្រកួតប្រជែង ឬផលិតផលរបស់គាត់កំពុងត្រូវគេបង្ខូច ឬត្រូវធ្វើអាជីវកម្មលើបំណងល្អរបស់គាត់ ពេលនោះតុលាកាត្រូវតែអន្តរាគមន៍ ។ ក្នុងប្រទេសដែលការពារខ្លាំងលើភាពស្មោះត្រង់របស់អ្នកជំនួញ និងកេរ្តិ៍ឈ្មោះរបស់អ្នកជំនួញ ការផ្សាយពាណិជ្ជកម្មដោយ ធ្វើការប្រៀបធៀបត្រូវបានហាមឃាត់យ៉ាងតឹងរឹង ជូនកាលគ្រាន់តែអ្នកប្រកួតប្រជែងត្រូវបានគេប្រើឈ្មោះប្រឆាំងនឹងបំណងរបស់ខ្លួនក៏ចាត់ទុកជាការបង្ខូចកេរ្តិ៍ឈ្មោះ និងជាការប្រកួតប្រជែងមិនស្មោះត្រង់ ។ ដោយយោលទៅតាមបទប្បញ្ញត្តិចែងថាៈ " អ្នកជំនួញសោះត្រង់មានសិទ្ធិមិនបញ្ចេញឈ្មោះ ប្រសិន

បើការពិតត្រូវបានគេនិយាយ " បទប្បញ្ញត្តិនៃប្រទេសខ្លះបានហាមឃាត់ពីការប្រៀបធៀបគ្នាថា មិនចាំបាច់បញ្ជាក់អត្តសញ្ញាណអ្នកប្រកួតប្រជែងឡើយ ។ ការឈ្លោះប្រកែកគ្នាដូចនេះត្រូវតែផ្តល់សិទ្ធិឱ្យតុលាការ ដើម្បីស្វែងរកការផ្សព្វផ្សាយពាណិជ្ជកម្មដោយប្រៀបធៀបរបស់ដៃគូប្រកួតប្រជែងច្រើនឬតិច ជាស្វ័យប្រវត្តិប្រឆាំងទៅនឹងការប្រត្តិបត្តិពាណិជ្ជកម្មស្មោះត្រង់ ។

ទោះបីយ៉ាងណាក៏ដោយ ប្រទេសជាច្រើនចាត់វិធានការយ៉ាងតឹងរឹងលើការផ្សាយពាណិជ្ជកម្មដោយប្រៀបធៀប គឺជាការប្រតិបត្តិមិនស្មោះត្រង់ ។ នាពេលថ្មីៗនេះមាននិន្នាការមួយ ការបដិសេធន៍លើការផ្សាយពាណិជ្ជកម្មបានផ្លាស់ប្តូរ ។ វាត្រូវបានគេទទួលស្គាល់ថាការប្រៀបធៀបពិតនៃហេតុការណ៍ វាមិនត្រឹមតែកាត់បន្ថយ នូវតម្លៃស្រាវជ្រាវពត៌មានរបស់អតិថិជនប៉ុណ្ណោះទេ ថែមទាំងមានប្រសិទ្ធិភាពលើទីផ្សារតាមរយៈការជំរុញតម្លាភាពនៃទីផ្សារ ។ តុលាការនៃប្រទេសទាំងនោះយល់ថាការផ្សាយពាណិជ្ជកម្មដោយប្រៀបធៀបដោយបង្អាប់ ត្រូវមានការហាមឃាត់យ៉ាងម៉ត់ចត់រាល់របាយការណ៍ពីអត្តសញ្ញាណរបស់ដៃគូប្រកួតប្រជែង ។ ជាឧទាហរណ៍ ការប្រៀបធៀបតម្លៃប្រសិនបើពិតនិងសម្ភារៈផ្សេងៗត្រូវបានអនុញ្ញាត ជាគោលការណ៍ វាហាក់បីដូចជាមាននិន្នាការច្បាស់លាស់មួយឆ្ពោះទៅរកការផ្សព្វផ្សាយពាណិជ្ជកម្ម ដោយប្រៀបធៀបពិតប្រាកដ ។

## អំពើផ្សេងៗទៀតនៃការប្រកួតប្រជែងមិនស្មោះត្រង់

ដូចអ្នកបានវាយតម្លៃពីវិស័យនៃការប្រកួតប្រជែងមិនសោះត្រង់ គឺមានលក្ខណៈទូលាយនិងវិធីការពាររបស់ប្រទេសជាច្រើន ។ ដូចនេះក្នុងគោលបំណងបំពេញបញ្ជីនៃអំពើមិនស្មោះត្រង់ច្រើនដែលអាចធ្វើទៅបាន មានឧទាហរណ៍ សង្ខេបខាងក្រោម ។

-ការផ្សាយពាណិជ្ជកម្មធ្វើឱ្យរំខាន ដូចជាការផ្សាយពាណិជ្ជកម្មជ្រុលខ្លាំងពេកធ្វើអោយប៉ះពាល់ ដល់ការលក់

-ការប្រើប្រាស់បច្ចេកទេសផ្សាយពាណិជ្ជកម្មលក់ ដូចជាមានឆ្នោតអំណោយសំណាង និងការផ្តល់រង្វាន់លើកទឹកចិត្ត ទាំងនេះគឺជាបទប្បញ្ញត្តិជៀសវាង ។

-ការបង្អាក់នៃសកម្មភាពទីផ្សារ ដូចជាការបំផ្លាញដបទឹកដែលអាចផលិតឡើងវិញរបស់ដៃគូប្រកួតប្រជែង

## សង្ខេប

គំនិតប្រកួតប្រជែងមិនយុត្តិធម៌ត្រូវបានកើតឡើងជុំវិញនៃកិច្ចការពារកម្មសិទ្ធិបញ្ញា ទស្សវត្សឆ្នាំ១៩០០ក្នុងទីក្រុង Brussel នៃអនុសញ្ញា Paris Convention ។ វាអាចបញ្ជាក់ច្បាស់ពីការប្រតិបត្តិការដោយសេរីនៃកម្មសិទ្ធិបញ្ញា និងប្រព័ន្ធលើកទឹកចិត្តដែលបានចែងថា:

អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ គឺជាអំពើណាមួយនៃការប្រកួតប្រជែងផ្ទុយនឹងការប្រតិបត្តិស្មោះត្រង់ក្នុងឧស្សាហកម្ម ឬពាណិជ្ជកម្ម ។ ឧទាហរណ៍ខាងក្រោមនេះត្រូវបានហាមឃាត់ ៖

-រាល់អំពើធ្វើឱ្យមានការភាន់ច្រឡំគ្រប់មធ្យោបាយទោះបីជាការបង្កើត ទំនិញ ឬសកម្មភាពពាណិជ្ជកម្ម សេវាកម្មរបស់ដៃគូប្រកួតប្រជែង ។

ការផ្សាយមិនពិតក្នុងពាណិជ្ជកម្ម ដូចជាផ្សាយបង្ខូចលើការបង្កើត ទំនិញ ឬឧស្សាហកម្មពាណិជ្ជកម្មរបស់ដៃគូប្រកួតប្រជែង ។

ការបង្ហាញពីការប្រើប្រាស់ក្នុងពាណិជ្ជកម្ម នូវការបំផ្លើសមិនពិតដល់សាធារណៈជន ពីប្រភេទដំណើរការផលិត លក្ខណៈវិនិច្ឆ័យ គោលបំណង ឬ បរិមាណនៃទំនិញ ។

មានប្រភេទផ្សេងៗគ្នានៃអំពើប្រកួតប្រជែងមិនស្មោះត្រង់រួមមាន:

-ការបង្កឱ្យភាន់ច្រឡំ

-ការផ្សាយបំផ្លើស

-ការផ្សាយបង្ខូច

-ការរំលោភបំពានលក្ខណៈសំងាត់ពាណិជ្ជកម្ម

-ការយកចំណេញផលប្រយោជន៍ពីសមិទ្ធផលដៃគូប្រកួតប្រជែង

-ការផ្សាយពាណិជ្ជកម្មដោយប្រៀបធៀប។

# ជំពូកទី ១០
# ការពារប្រភេទពូជរុក្ខជាតិថ្មី

<u>វត្ថុបំណង</u>

បន្ទាប់ពីសិក្សាចប់ជំពូកនេះអ្នកអាច

១-ពន្យល់អំពីតួនាទី អនុសញ្ញាអន្តរជាតិការពារប្រភេទរុក្ខជាតិថ្មី UPOV។

២-ពន្យល់មូលហេតុអ្វីបានជាប្រភេទពូជរុក្ខជាតិថ្មីទទួលបាននូវកិច្ចការពារ ។

៣-ចូរធ្វើបញ្ជីនូវតម្រូវការដែលត្រូវតែមាន ដើម្បីការពារប្រភេទពូជរុកជាតិថ្មី ។

៤-បញ្ជាក់ពីសិទ្ធិសំខាន់ៗដែលម្ចាស់សិទ្ធិមាន ។

៥-កំណត់ពីរយៈពេលដែលត្រូវការពារ ។

## សេចក្តីផ្តើម

កិច្ចការពារប្រភេទពូជរុក្ខជាតិថ្មី គឺជាទិដ្ឋភាពមួយទៀតនៃកម្មសិទ្ធិបញ្ញា ហើយឈានទៅទទួលស្គាល់សមិទ្ធផលនៃការបង្កើតប្រភេទពូជរុក្ខជាតិថ្មី មួយរយៈពេលកំណត់នៃសិទ្ធិផ្តាច់មុខ ។ ដើម្បីទទួលបាននូវកិច្ចការពារប្រភេទពូជរុក្ខជាតិថ្មីនេះត្រូវមានលក្ខណៈ ស្ថេរភាពជាក់លាក់ ។

អង្គការត្រួតពិនិត្យលើកិច្ចការពារប្រភេទពូជរុក្ខជាតិថ្មី គឺទាក់ទងដល់សន្ធិសញ្ញា UPOV ដែលជាពាក្យសរសេកាត់មកពីឈ្មោះបារាំងមានន័យថាៈ អង្គការសម្ព័ន្ធអន្តរជាតិដើម្បីការពារប្រភេទពូជរុក្ខជាតិ ។

### ហេតុអ្វីត្រូវការពារប្រភេទពូជរុក្ខជាតិថ្មី?

កិច្ចការពារ គឺអាចធ្វើទៅបានចំពោះប្រភេទពូជរុក្ខជាតិថ្មី ដើម្បីការពារផលប្រយោជន៍របស់អ្នកបង្កាត់ពូជរុក្ខជាតិ ក៏ដូចជាជំរុញឱ្យមានប្រភេទពូជរុក្ខជាតិថ្មីសម្រាប់វិស័យកសិកម្ម សាកវប្បកម្ម និងរុក្ខជាតិ ។ ការជំរុញឱ្យមានប្រភេទរុក្ខជាតិផ្សេងៗគ្នានេះ គឺជាកត្តាចំបាច់ណាស់ ដើម្បីធ្វើឱ្យមានគុណភាពនៃរុក្ខជាតិគ្រប់ប្រភេទ។

ការបង្កាត់ពូជរុក្ខជាតិប្រភេទថ្មី ទាមទារឱ្យមានការវិនិយោគក្នុងលក្ខ័ខណ្ឌ ជំនាញពិសោធន៍ ប្រភពសម្ភារៈ ថវិកា និងពេលវេលា ។ សិទ្ធិផ្តាច់មុខក្នុងវិស័យប្រភេទពូជរុក្ខជាតិថ្មីផ្តល់ភាពជោគជ័យដល់អ្នកបង្កាត់ពូជរុក្ខជាតិ មានឱកាសសមរម្យទទួលតម្លៃ និងលុយដើម្បីវិនិយោគបន្ថែម ។ ក្នុងករណីគ្មានសិទ្ធិអ្នកបង្កាត់ពូជនេះ គោលបំណងខាងលើមិនអាចសម្រេចបានទេ គ្មានអ្វីការពារលើ

គ្រាប់ពូជរបស់អ្នកបង្កាត់ពូជឡើយ ជាហេតុធ្វើឲ្យបាត់ចំណូលដល់អ្នកបង្កាត់ពូជ។

**តើប្រភេទរុក្ខជាតិថ្មី អាចត្រូវបានការពារយ៉ាងដូម្តេច?**

កិច្ចព្រមព្រៀង TRIPS អនុញ្ញាតឱ្យការពារ ៣ប្រភេទ

១-តាមរយៈយន្តការប្រកាសនីយបត្រតក្កកម្ម

២-តាមរយៈប្រព័ន្ធពិសេសដែលទាក់ទងរុក្ខជាតិ

៣-តាមរយៈការផ្សំចូលគ្នា តាមពីររបៀបខាងលើ

តាមទស្សនៈទូលាយៈ ប្រភេទរុក្ខជាតិថ្មីបំផុត មិនតម្រូវឲ្យពូជនោះមិនដែលមានពីមុនមកទេនៃប្រព័ន្ធការពារប្រកាសនីយបត្រតក្កកម្ម ។ នៅពេលពួកគេផ្តើមចេញពីសកម្មភាពច្បាស់ ហើយប្រើនូវបច្ចេកទេសច្បាស់ ។ នេះមានន័យថាប្រើប្រាស់នូវប្រព័ន្ធច្បាប់ ប្រកាសនីយបត្រតក្កកម្មអាចជួបការពិបាក ។ ទទឹមនឹងនោះប្រទេសជាច្រើនមានប្រព័ន្ធ (Sui genris) ពិសេសដើម្បីការពារលើប្រភេទរុក្ខជាតិ ។

<u>សំណួរវាយតម្លៃដោយខ្លួនឯង</u>

**តើមានគោលបំណងអ្វីបានជាត្រូវការពារអ្នកបង្កាត់ពូជរុក្ខជាតិ?**

១-ដើម្បីធានាការបង្កើតបន្តនៃប្រភេទរុក្ខជាតិថ្មី ដោយការពារផលប្រយោជន៍របស់អ្នកបង្កាត់ពូជរុក្ខជាតិ ។

២-ដើម្បីធានាផ្គត់ផ្គង់គ្រាប់ពូជពិត និងមិនពុករលួយ

<u>ចម្លើយ</u>

សំណួរទី១គឺត្រឹមត្រូវ សំណួរទី២ទាក់ទងដល់ការត្រួតពិនិត្យគុណភាពគ្រាប់ពូជ និងរុក្ខជាតិ ។

**តើលក្ខណៈអ្វីខ្លះដែលប្រភេទពូជរុក្ខជាតិថ្មីអាចទទួលបាននូវកិច្ចការពារ?**

ក្រោមច្បាប់ឆ្នាំ ១៩៩១នៃអនុសញ្ញា UPOV មានលក្ខណៈដូចខាងក្រោម:

១-ថ្មី

២-ប្លែកពីគេ

៣-មានឯកសណ្ឋានដូចគ្នាតែមួយ

៤-បិតបេរ

៥-មានឈ្មោះជាក់លាក់

ការទាមទារឱ្យរុក្ខជាតិនោះថ្មី ហើយធានាថាប្រភេទរុក្ខជាតិនេះមិនទាន់បានធ្វើអាជីវកម្មពីមុនមក ។ នេះគឺត្រូវវាយតម្លៃដោយច្បាប់យ៉ាងជាក់ស្តែង មិនមែនវាយតម្លៃដោយបច្ចេកទេសទេ។

ប្រភេទថ្មីនេះ ត្រូវទាមទារឱ្យមានឈ្មោះជាក់លាក់តាមប្រភេទរបស់វា មានការវាយតម្លៃតាមបច្ចេកទេស៣ ភាពប្លែកពីគេ, ភាពឯកសណ្ឋានដូចគ្នាទាំងស្រុង, ភាពបិតបេរ ។

## ភាពប្លែកពីគេ

ភាពផ្សេងនេះ ត្រូវតែប្លែពីគេ ប្រសិនបើប្លែកពីគេទាំងស្រុងគឺមិនមាននរណាម្នាក់ស្គាល់ពីមុនមក រហូតដល់ពេលដាក់ពាក្យស្នើសុំ ការឲ្យនិយមន័យបច្ចេកទេសជាក់លាក់នៃភាពប្លែកពីគេនេះគឺស្ថិតនៅក្រោមការពិពណ៌នាដោយជីវវិទ្យា និងទំហំក្នុងជំពូកនេះ ។ វាជាការគ្រប់គ្រាន់ក្នុងការនិយាយថា អ្នកជំនាញការបច្ចេកទេសម្នាក់ត្រូវ បានគេទាមទារផ្តល់យោលបល់លើបញ្ហានេះ ។



## ភាពឯកសណ្ឋានដូចគ្នាតែមួយ

ភាពផ្សេងនេះត្រូវមានឯកសណ្ឋានដូចគ្នាតែមួយ ប្រសិនបើមានការមិនដូចគ្នាអាចជាលក្ខណៈពិសេសបន្ថែមនៃការបណ្តុះ គឺវាត្រូវមានឯកសណ្ឋានដូចគ្នាតែមួយចំពោះលក្ខណៈរបស់វា ។

ជាសង្ខេបនេះមានន័យថា ប្រភេទពូជរុក្ខជាតិត្រូវមានឯកសណ្ឋានដូចគ្នា ឬសាមញ្ញទៅតាមប្រភេទនៃវិធីបណ្តុះពូជ។

## ភាពបិតបេរ

ប្រភេទផ្សេងគ្នានេះ ត្រូវតែបិតបេរ ប្រសិនបើលក្ខណៈវាមិនផ្លាស់ប្តូរបន្ទាប់ពីបណ្តុះបន្តឬក្នុងករណីពិសេសនៃការបណ្តុះឡើងវិញ ។

ជាសង្ខេបវាមានន័យថា ប្រភេទផ្សេងៗគ្នារក្សានៅលក្ខណៈដូចដើមបន្ទាប់ពីបណ្តុះឡើងវិញពីគ្រាប់ពូជ ឬតាមវិធីផ្សេង ។

ជាការពិតលក្ខណៈវិនិច្ឆ័យបច្ចេកទេសបីចុងក្រោយទាំងនេះត្រូវតែមានការត្រួតពិនិត្យមុនផ្តល់សិទ្ធិឲ្យម្ចាស់សិទ្ធិ ។ ការត្រួតពិនិត្យ បច្ចេកទេសនេះត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ។

**តើសិទ្ធិអ្វីដែលម្ចាស់សិទ្ធិមាន?**

ក្រោមច្បាប់ឆ្នាំ ១៩៩១ នៃអនុសញ្ញា UPOV ការពារចំពោះអ្នកបង្កាត់ពូជ ខាងក្រោមនេះគឺជាសិទ្ធិអត្តិភាពដែលម្ចាស់សិទ្ធិមាន:

១-ការផលិត ឬការផលិតឡើងវិញ

២-លក្ខខ័ណ្ឌសម្រាប់គោលបំណងនៃការបណ្ដុះសាយភាយ

៣-ផ្ដល់ឲ្យសម្រាប់លក់

៤-ការលក់ ឬទីផ្សារផ្សេងទៀត

៥-ការនាំចេញ

៦-ការនាំចូល

៧-ស្ដុកទុកសម្រាប់គោលបំណងខាងលើ

វាសំខាន់ណាស់ក្នុងការបញ្ជាក់ថា: សិទ្ធិរបស់ម្ចាស់អ្នកបង្កាត់ពូជរុក្ខជាតិ មិនទាមទារនូវ:

-អំពើជាលក្ខណៈឯកជន និងមិនមានគោលបំណងធ្វើពាណិជ្ជកម្ម

-អំពើដែលធ្វើសម្រាប់គោលបំណងពិសោធន៍

-អំពើដែលធ្វើសម្រាប់គោលបំណងបង្កាត់ពូជ និងអាជីវកម្មនូវប្រភេទរុក្ខជាតិផ្សេងៗទៀត លើកលែងតែក្នុងករណីរកឃើញលក្ខណៈពិសេស និងប្រភេទរុក្ខជាតិខ្លះមិនអាចធ្វើអាជីវកម្មដោយគ្មានការអនុញ្ញាតពីអ្នកបង្កាត់ពូជដើមដំបូង ។

តាមន័យត្រង់កិច្ចការពារត្រង់ចំនុចមួយមានន័យថា កសិករត្រូវការអនុញ្ញាពីម្ចាស់សិទ្ធិ ដើម្បីរក្សាទុកគ្រាប់ពូជសម្រាប់ដាំបន្ត ។

តែទោះបីជាយ៉ាងណាក៏ដោយ បទប្បញ្ញាតិឆ្នាំ១៩៩១នៃអនុសញ្ញា UPOV រួមមានចែងពីករណីលើកលែងចំពោះកសិករអាចទុកពូជ និងអភិវឌ្ឍនៅក្នុងចំការរបស់ខ្លួន ដែលបានអនុម័តជាពិសេសចំពោះវិស័យកសិកម្មជាតិ ។ ជាការពិតគ្រប់ប្រទេសទាំងអស់ ដែលជាប់ទាក់ទងនឹងប្បញ្ញត្តិឆ្នាំ១៩៩១ បានកែសម្រួលនូវ " សិទ្ធិរបស់ម្ចាស់កសិដ្ឋាន" ។

**តើម្ចាស់សិទ្ធិ(អ្នកបង្កាត់ពូជ) មានសិទ្ធិប្រើប្រាស់បានរយៈពេលប៉ុន្មានឆ្នាំ?**

រយៈពេលអប្បបរិមាដែលមានចែងបទប្បញ្ញតិ១៩៩១ គឺ:

-រយៈពេល ២៥ឆ្នាំចំពោះដើមឈើ និងវល្លិ

-រយៈពេល ២០ឆ្នាំ ចំពោះរុក្ខជាតិផ្សេងទៀត

**តើអ្នកបង្កាត់ពូជអាចការពារពេញពិភពលោកបានឬទេ?**

ដោយមានវិធីការពារផ្សេងៗ ក្នុងករណីជាច្រើនសិទ្ធិនេះត្រូវបានផ្ដល់ឱ្យអ្នកបង្កាត់ពូជ ក្នុងប្រទេសដែលម្ចាស់សិទ្ធិនេះស្នើសុំ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ត្រូវមានបទប្បញ្ញត្តិខ្លះ ជំនួសដូចជាសហាគមការិយាល័យប្រភេទពូជរុក្ខជាតិ ដែលជាសមាជិកសហាគមអឺរ៉ុប ឬស្ថិតនៅក្រោមការ

អភិវឌ្ឍន៍។ ទោះបីជាការងារ UPOV ធំធេងនៅក្នុងដំណើការនេះក៏ដោយ គឺត្រូវលើកទឹកចិត្តអោយទទួលស្គាល់ការធ្វើតេសដោយបច្ចេកទេសដែលបានធ្វើឡើងនៅក្នុងរដ្ឋដែលជាសមាជិកផ្សេង ធ្វើបែបនេះ គឺកាត់បន្ថយនៅតម្លៃ និងកិច្ចប្រឹងប្រែងការពារនៅក្នុងប្រទេសជាច្រើន ។

## សង្ខប

កិច្ចការពារ គឺអាចធ្វើទៅបានចំពោះប្រភេទពូជរុក្ខជាតិថ្មី ដើម្បីធានានូវផលប្រយោជន៍ម្ចាស់សិទ្ធិ (អ្នកបង្កាត់ពូជ) និងលើកទឹកចិត្តឱ្យមានការអភិវឌ្ឍន៍ប្រភេទរុក្ខជាតិថ្មីសម្រាប់វិស័យកសិកម្មនិងព្រៃឈើ ។ ការជំរុញប្រភេទផ្សេងនៃរុក្ខជាតិ គឺចាំបាច់ណាស់ និងប្រសិទ្ធិភាពនៃតម្លៃក្នុងការអភិវឌ្ឍន៍ និងគុណភាពរុក្ខជាតិគ្រប់ប្រភេទ ។

ប្រទេសជាច្រើនដែលបានណែនាំពីសិទ្ធិរបស់អ្នកបង្កាត់ពូជ គឺមានកំណត់ក្នុងអនុសញ្ញា UPOV ដែលគ្រប់គ្រងដោយការិយាល័យសហគមន៍ដែលមានទីស្នាក់ការនៅ Geneva ។

ដើម្បីទទួលបាននូវកិច្ចការពារប្រភេទរុក្ខជាតិនោះត្រូវតែ:

-ថ្មី

-ប្លែកពីគេ

-មានឯកសណ្ឋានតែមួយ

-បិតបេរ

-មានឈ្មោះជាក់លាក់

កិច្ចការពារមួយទៀតដែលធ្វើឡើង គឺម្ចាស់សិទ្ធិអ្នកបង្កាត់ពូជមានសិទ្ធិការពារនូវសកម្មភាពដូចខាងក្រោម:

១-ការផលិត ឬការផលិតឡើងវិញ

២-លក្ខខ័ណ្ឌសម្រាប់គោលបំណងនៃការបណ្តុះសាយភាយ

៣-ផ្តល់ឲ្យសម្រាប់លក់

៤-ការលក់ ឬទីផ្សារផ្សេងទៀត

៥-ការនាំចេញ

៦-ការនាំចូល

៧-ស្តុកទុកសម្រាប់គោលបំណងខាងលើ

ប្រទេសជាច្រើនអនុម័តលើបទប្បញ្ញត្តិពិសេស ដែលអនុញ្ញាតឱ្យកសិកររក្សាទុកពូជ សម្រាប់ដាំបន្តទៀត ។

រយៈពេលការពារអប្បបរិមា គឺ

-២៥ឆ្នាំ ចំពោះដើមឈើ និងវល្លិ៍

-២០ឆ្នាំ ចំពោះរុក្ខជាតិ

តួនាទីចម្បងមួយក្នុងចំណោមតួនាទីជាច្រើនសម្រាប់អង្គការUPOV គឺជួយដល់អ្នកបង្កាត់ពូជ ដោយទទួលបាននូវកិច្ចការពារក្នុងប្រទេសជាច្រើន។ តាមរយៈការលើកទឹកចិត្តពីប្រទេសផ្សេង ដើម្បីទទួលលទ្ធផលធ្វើតេស ពីប្រទេសទាំងអស់ដែលជាសមាជិក UPOV ។

# ជំពូកទី១១
# ការពិភាក្សា និងសេចក្តីសង្ខេប

តាមរយៈការសិក្សានៅជំពូកជាច្រើនមកនេះ អ្នកបានដឹងពីប្រភេទផ្សេងៗគ្នានៃកម្មសិទ្ធិបញ្ញា និងប្រភេទការពារផ្សេងៗគ្នា ។ ក្នុងជំពូកទាំងអស់បានបង្ហាញនូវផលប្រយោជន៍ការពារតាមទម្រង់ជាច្រើនរបស់ម្ចាស់សិទ្ធិ ហើយបានសម្គាល់ឃើញអ្នកបង្កើតស្នាដៃទាំងអស់សុទ្ធតែទទួលបាននូវថវិកាតាមរយៈការធ្វើអាជីវកម្មសិទ្ធិរបស់ខ្លួន ។ ម្ចាស់សិទ្ធិទទួលបានប្រាក់ចំណូលតាមរយៈប្រភេទផ្សេងៗនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម រួមទាំងការចេញអាជ្ញាប័ណ្ណ ការប្រគល់សិទ្ធិ ។ មានន័យថារាល់កិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងនេះគឺជាកម្មវត្ថុនៃការសងត្រលប់មកវិញនូវទ្រព្យកម្មសិទ្ធិបញ្ញា ។

### តើខុសគ្នាយ៉ាងណារវាងកម្មសិទ្ធិខាងបញ្ញា និងមូលធន់ខាងបញ្ញា?

កម្មសិទ្ធិបញ្ញាគឺផ្អែកលើច្បាប់ចែងការពារការបង្កើតឡើងដោយបញ្ញា ដូចជាតក្កកម្ម ខ្សែភាពយន្ត អត្ថបទសៀវភៅ តន្ត្រី ។ល។ មូលធន់ខាងបញ្ញារួមទាំងកម្មសិទ្ធិបញ្ញា ប៉ុន្តែថែមទាំងផលិតផលរបស់ក្រុមហ៊ុននៅលើទីផ្សារ ឧទាហរណ៍បញ្ជីឈ្មោះអតិថិជន វិធីបណ្តុះបណ្តាល ឬដំណើការធ្វើតេសពីគុណភាព ។ ទាំងអស់គឺជាមូលធន់បញ្ញា ប៉ុន្តែយើងមិនគួរភ្លេចទុនដ៏សំខាន់របស់ក្រុមហ៊ុនគឺកំលាំងពលកម្ម ។

កម្មសិទ្ធិបញ្ញាមិនមែនសុទ្ធតែមូលធន់បញ្ញានោះទេ ដោយប្រកាសនីយបត្រតក្កកម្មសម្រាប់តក្កកម្មដែលមិនមានមុខនៅលើទីផ្សារ និងបានប្រើសម្រាប់រកប្រាក់ចំណូលរបស់ក្រុមមហ៊ុន វាមិនមែនគ្រាន់តែជាឯកសារសម្រាប់ព្រីនចេញមកក្រៅនោះទេ ។ ប្រកាសនីយបត្រតក្កកម្មសម្រាប់តក្កកម្មត្រូវបានប្រើក្នុងបរិបទពាណិជ្ជកម្ម វានឹងផ្តល់ឲ្យក្រុមហ៊ុនមានការប្រកួតប្រជែងមួយតាមរយៈការប្រើប្រាស់វា និងហាមអ្នកផ្សេងមិនឲ្យប្រើប្រាស់ផលិផលដូចគ្នានៅលើទីផ្សារ ពេលនោះក្រុមហ៊ុនអាចបង្កើនប្រាក់ចំណូល ដូចជាមួយការដាក់ពាក្យសុំម៉ាក ពាណិជ្ជនាម ។ ម៉ាកដែលមិនល្បីគឺមិនសូវមានតម្លៃទេ ប៉ុន្តែម៉ាកល្បី Coca Cola មានតម្លៃរាប់លាន ។ មានអ្នកខ្លះនិយាយាថាម៉ាកCoca Cola គ្មានតម្លៃទេ ព្រោះម៉ាកនេះមិនត្រូវបានគេលក់ ដូចនេះយើងត្រូវកំណត់ពីភាពខុសគ្នានៃពាក្យថ្លៃ ប៉ុន្មាន និងតម្លៃ ។

### តើខុសគ្នាយ៉ាងម៉េចពាក្យខាងលើ?

តម្លៃនៃម៉ាកគឺស្ថិតលើថាតើអតិថិជនស្គាល់ និងចង់ទិញផលិតផលនោះកំរិតណា ។ ឧទហរណ៍

អតិថិជនចង់ទិញផលិតផលរាប់លាននៃម៉ាក តែគេមិនទិញម៉ាកទេ ព្រោះម្ចាស់ម៉ាក មិនលក់ទេ ។ ពេលនោះកម្មសិទ្ធិបញ្ញាកាន់តែមានតម្លៃនៅលើទីផ្សារដោយសារមានអតិថិជនស្គាល់ និងត្រៀមចាំទិញផលិតផលនៃម៉ាកនោះ ។

ជាឧទាហរណ៍ខ្សែក្រវាត់ក្រណាត់Velcroត្រូវបានរកឃើញតក្កកម្ម ដោយតក្កករជនជាតិស្វីស ដែលកាលពីមុនមិនអាចរកចរិកាបានច្រើនពីតក្កកម្មរបស់គាត់ ព្រោះប្រកាសនីយបត្រតក្កកម្មរបស់គាត់បានចូលក្នុងទីផ្សារ តែបច្ចុប្បន្នត្រូវបានគេប្រើច្រើនគ្រប់ទីកន្លែង ។ តាមពិតចំណូលគាត់បានច្រើនដោយសារអង្គការNASAប្រើប្រាស់ប្រកាសនីយបត្រតក្កកម្មរបស់គាតសម្រាប់យានអារកាស ។ ទន្ទឹមពេលនោះ តក្កកម្មនោះបានក្លាយជាភាពអស្ចារ្យសម្រាប់អ្នកប្រើប្រាស់ ចាប់តាំងពីពេលវាក្លាយជាប្រយោជន៍សាធារណៈ ក្រុមហ៊ុនជាច្រើនដែលប្រើខ្សែក្រវាត់Velcroមិនបានបង់ប្រាក់ឲ្យតក្កករឡើយ ។ នេះជាឧទាហរណ៍ដែល១ ដែលតក្កកម្មផ្សេងៗទៀតស្ថិតក្នុងការពិចារណាជាប្រាក់ចំណូលរបស់ម្ចាស់កម្មសិទ្ធិ ។ យើងអាចមានឧទាហរណ៍មួយទៀតគឺប្រព័ន្ធDolbyសម្រាប់កាត់បន្ថយសម្លេងនៃឧបករណ៍ Stereophonic ដែលត្រូវបានគេបង្កើតឡើង នៅលើទីផ្សារតាមរយៈកិច្ចសន្យាអាជ្ញាបណ្ណ័ រវាងវិស័យឧស្សាហកម្ម និងក្រុមហ៊ុនចាត់ចែងប្រព័ន្ធ Dolby សម្រាប់ការអនុញ្ញាតអាជ្ញាបណ្ណ័នៅពេលបច្ចេកវិទ្យាបានឆ្លងកាត់អតិថិជនប្រើប្រាស់ មានឈ្មោះថាអតិថិជនស្រាវជ្រាវដើម្បីត្រួតពិនិត្យតន្ត្រី ។

**ចូរសង្ខេបពីប្រព័ន្ធអនុញ្ញាតឲ្យប្រតិបត្តិករដែលប្រតិបត្តិការលើបច្ចេកវិទ្យានេះ តើត្រូវបង់កម្រៃដល់Dolbyឬ?**

បាទជាការត្រឹមត្រូវ រាល់ប្រតិបត្តិករទាំងអស់ត្រូវបង់ប្រាក់តាមប្រព័ន្ធDolby ដោយមិនចាំបាច់សុំអាជ្ញាបណ្ណពីម្ចាស់កម្មសិទ្ធិ ។

តើអ្នកអាចដឹងបន្ថែមថាតើកម្មសិទ្ធិបញ្ញាអាចធ្វើពាណិជ្ជកម្មបានជោគជ័យយ៉ាងដូចម្តេច?

យើងអាចចដឹងថាក្រុមហ៊ុនផលិតថ្នាំពេទ្យគឺស្ថិតក្នុងវិស័យកម្មសិទ្ធិបញ្ញា នៅពេលគេវិនិយោគលើការព្យាបាលជំងឺដោយផលិតជា ថ្នាំពេទ្យ ឪសថ នោះគេសង្ឃឹមថាអ្នកចែកចាយជាច្រើននៅលើទីផ្សារនឹងទទួលបានផលប្រយោជន៍ជាងក្រុមហ៊ុនតែមួយដែលផ្តល់នូវផលិតផលដូចគ្នា ។

អ្នកនឹងសម្គាល់ឃើញថាឪសថខ្លះ លេចឡើងលើទីផ្សារមានតម្លៃថ្លៃដោយសារការផ្តល់ការលើកទឹកចិត្តនៃប្រកាសនីយបត្រតក្កម្ម បន្ទាប់មកទើបតម្លៃចាប់ផ្តើមធ្លាក់ចុះនៅលើទីផ្សារ ។ នៅពេលថ្នាំ ពេទ្យទាំងនោះត្រូវបានប្រើរូបមន្តផលិតដូចគ្នានៃប្រកាសនីយបត្រតក្កកម្ម ដោយសារប្រកាស*នីយបត្រតក្កកម្ម*នោះក្លាយជាប្រយោជន៍សាធារណៈ ពេលនោះក្រុមហ៊ុនផលិតឧសថព្យាយាមការពារឪសថនោះតាមរយៈម៉ាកវិញ ។ គ្មានក្រុមហ៊ុនណាមួយអាចផលិតថ្នាំម៉ាក Aspririn ទេ លើកលែងតែក្រុមហ៊ុន Bayer មួយគត់ដែជាម្ចាស់ម៉ាក Aspririn ប៉ុន្តែយើងអាចត្រូវគេបញ្ចុះបញ្ចូលឲ្យទិញថ្នាំប្រភេទ

ដូចគ្នាតែម៉ាកផ្សេងក្នុងតម្លៃដូចគ្នា ឬតម្លៃថោកជាង ។

**ដូចនេះតាមរយៈឧទាហរណ៍ខាងលើអ្នកអាចឃើញទម្រង់ពីរដើម្បីការពារ គឺតាមរយៈប្រកាសនីយបត្រតក្កម្ម នៅពេលប្រកាសនីយបត្រតក្កម្មផុតពេលការពារ តើគេអាចបន្តការពារតាមរយៈម៉ាកបានឬទេ?**

ជាការត្រឹមត្រូវ ម៉ាកអាចការពារបានរហូត ខុសពីប្រកាសនីយបត្រតក្កម្ម ។ គឺមានសារសំខាន់ណាស់ចំពោះក្រុមហ៊ុនដែលចង់រក្សាផលិតផលរបស់ខ្លួននៅបានយូរ ម៉ាកវាតែងតែស្ថិតនៅជាប់ជាមួយផលិតផលនោះ គឺសម្រាប់ផលិតផលណាដែលមិនពិសេស ។ ចំពោះផលិតផលពិសេសដូចជាឧបករណ៍គ្រឿងចក្រ ម៉ាស៊ីន ក្នុងករណីនេះអតិថិជនមិនចង់បានម៉ាកទេ គឺត្រូវទិញបច្ចេកវិទ្យាដែលមានរយៈពេលការពារតែ១០ ឬ១៥ឆ្នាំប៉ុណ្ណោះ ។ គាត់ត្រូវស្វែងរកបច្ចេកវិទ្យា មានគុណភាពល្អ ឧបករណ៍ល្អ ទើបគិតដល់ម៉ាកជាក្រោយ ។ ដោយមានសម្ភារៈច្រើននៅលើទីផ្សារ ដូចនេះម៉ាកក៏មានឥទ្ធិពលលើទំនិញដែរ មានន័យថាគេទិញតាមរយៈការមើលឃើញ និងភ្នែក ចាប់កាន់នឹងដៃ បន្ទាប់មកគេអាចបើកមើលខាងក្នុងទំនិញនោះ ។

ដូចនេះគន្លឹះសំខាន់ក្នុងការធ្វើពាណិជ្ជកម្មគឺទាមទារឲ្យមានការពិចារណា ប្រសិនបើកិច្ចការពារសំខាន់គេត្រូវសុំចុះបញ្ជីការពារ ។

**តើកម្មសិទ្ធិបញ្ញាមានផលប្រយោជន៍អ្វីខ្លះចំពោះសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍ?**

ជាការពិត ប្រទេសកំពុងអភិវឌ្ឍអាចទទួលផលប្រយោជន៍ពីប្រព័ន្ធកម្មសិទ្ធិបញ្ញាដូចប្រទេសអភិវឌ្ឍដែរ ។ គុណវិបត្តិសម្រាប់ប្រទេសកំពុងអភិវឌ្ឍគឺមានក្រុមហ៊ុនជាច្រើនមិនអាចដឹងពីរបៀបប្រើប្រព័ន្ធកម្មសិទ្ធិបញ្ញាឲ្យបានត្រឹមត្រូវទៅនឹងផលប្រយោជន៍របស់ពួកគេ ។ ប៉ុន្តែការផ្សព្វផ្សាយត្រូវបានបង្កើន ផលិផលខ្លះបានចាប់ផ្តើមបង្ហាញលើទីផ្សារ ដូចជាប្រទេសឥណ្ឌាបានលក់ផលិតដែលមានទំនាក់ទំនងគ្នា ហើយអតិថិជនរបស់គេអាចស្វែងរកផលិតផលនេះនៅលើទីផ្សារ ដោយសារពួកគេដឹងពីផលិតផលដើម និងមានគុណភាព ។

ក្នុងវិស័យបច្ចេកវិទ្យា ប្រសិនបើមជ្ឈមណ្ឌលស្រាវជ្រាវក្នុងប្រទេសកំពុងអភិវឌ្ឍ ធ្វើការអភិវឌ្ឍបច្ចេកវិទ្យាដែលមានប្រយោជន៍ដល់ប្រទេសផ្សេង ហើយមិនធ្វើការធានាប្រកាសនីយបត្រតក្កកម្មទេ វាធ្វើឲ្យបាត់ផលប្រយោជន៍ វានឹងបាត់បង់នូវការលក់ប្រកាសនីយបត្រតក្កកម្ម និងចំណូលពីផលិតផលកម្មសិទ្ធិបញ្ញា ។

**តើខុសគ្នាយ៉ាងណារវាងអាជ្ញាបណ្ណ័ និងប្រមូលលាភការ?**

អាជ្ញាបណ្ណ័ជាដំណើរការដែលអ្វីមួយត្រូវបានអនុញ្ញាត គឺជាការផ្តល់ការអនុញ្ញាត ។ មានតែ

ម្ចាស់កម្មសិទ្ធិបញ្ញាតែមួយគត់ដែលមានសិទ្ធិអនុញ្ញាតឲ្យប្រើប្រាស់កម្មសិទ្ធិបញ្ញារបស់ខ្លួន ។ ប្រសិនបើនរណាម្នាក់ចង់ប្រើបច្ចេកវិទ្យារបស់ខ្ញុំត្រូវតែធ្វើកិច្ចសន្យាទិញអាជ្ញាបណ្ណ័ពីខ្ញុំ ពេលនោះនឹងមានលក្ខខណ្ឌជាក់លាក់ក្នុងការប្រើដោយបញ្ជាក់ពីរបៀបប្រើ នៅទីណា ពេលណា ។ ចំនួនអនុញ្ញាតនេះត្រូវកំណត់ដោយច្បាប់ ហើយវាជាមធ្យោបាយស្របច្បាប់ក្នុងការធ្វើអាជីវកម្ម ប្រសិនបើនរណាម្នាក់ប្រើបច្ចេកវិទ្យារបស់ខ្ញុំ ឬតក្កកម្មរបស់ខ្ញុំដោយគ្មានការអនុញ្ញាតគឺជាការប្រើប្រាស់ខុសច្បាប់ ឬជាអំពើរំលោភបំពាន ឬជាករក្លែងបន្លំ ហើយវាអាចក្លាយជាស្របច្បាប់នៅពេលចុះកិច្ចព្រមព្រៀងទិញអាជ្ញាបណ្ណ័ពីខ្ញុំ ។

ម្យ៉ាងវិញទៀតការបង់លាភការគឺជាការបង់តាមកិច្ចព្រមព្រៀងទិញអាជ្ញាបណ្ណ័គឺជាទូទៅគណនាទៅតាមចំនួនផលិតផលដែលបានផលិត ។ ជាឧទាហរណ៍អ្នកអាចធ្វើកិច្ចសន្យាលក់អាជ្ញាបណ្ណ័ជាប្រាក់សរុបតែម្តង ឬគិតទៅតាមចំនួនផលិតផលដែលបានផលិតចេញនៃការប្រើបច្ចេកវិទ្យារបស់អ្នក ។

**តើអ្នកអាចប្រាប់ថាអ្វីជាមជ្ឈមណ្ឌលស្រាវជ្រាវបង្កើតថ្មី?**

មជ្ឈមណ្ឌលស្រាវជ្រាវបង្កើតថ្មីគឺជាទស្សនកើតឡើងនៅក្នុងទសវត្ស៍១៩៧០-១៩៨០នៅក្នុងប្រទេសអភិវឌ្ឍមួយចំនួន ។ ជាមូលដ្ឋានវាកើតឡើងជាដំបូងសម្រាប់ភ្ជាប់ទំនាក់ទំនងស្រាវជ្រាវសាកលជាមួយមន្ទីរពិសោធន៍ស្រាវដែលមានថវិការបស់រដ្ឋាភិបាល នៅប្រទេសអឺរ៉ុបខាងលិច និងអាមេរិកខាងជើង ។ តួនាទីចម្បងនៃមជ្ឈមណ្ឌលស្រាវជ្រាវនេះនាំមកនូវបច្ចេកវិទ្យាថ្មី និងការអភិវឌ្ឍពីអ្នកស្រាវជ្រាវ និងពីមន្ទីរពិសោធន៍ចូលទៅក្នុងទីផ្សារ មានន័យថាផ្ទេរបច្ចេកវិទ្យា ។ វាពិបាកខ្លាំងណាស់ព្រោះដំណាក់កាលអភិវឌ្ឍន៍តក្កកម្មត្រូវការថវិកាច្រើនណាស់ដើម្បីផ្ទេរ ។

ប្រសិនបើអ្នកមានតក្កកម្មមួយ ហើយអភិវឌ្ឍវា នឹងត្រូវទទួលបានប្រកាសនីយបត្រតក្កកម្ម ពេលនោះអ្នកត្រូវមានជំហានដំបូង ព្រោះមិនប្រាកដថាបច្ចេកវិទ្យានោះអាចដំណើការទៅបានទេ ។ វាអាចដំណើការបានល្អក្នុងមន្ទិពិសោធន៍ តែមិនអាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ហើយជូនកាលនៅលើទីផ្សារមិនអាចទទួលយកបាន ជូនកាលមានបញ្ញាលក្ខខណ្ឌ និងកាត្តាធនធានមនុស្សដែលអ្នកមិនអាចផ្ទេរបច្ចេកវិទ្យានេះបាន ។ ដូចនេះមជ្ឈមណ្ឌលស្រាវជ្រាវបង្កើតថ្មីដូចជាមជ្ឈមណ្ឌលពាណិជ្ជកម្មរបស់រដ្ឋាភិបាល ឬ របស់សភាពាណិជ្ជកម្ម ។

មជ្ឈមណ្ឌលស្រាវជ្រាវបង្កើតថ្មីជួយតក្កករឬអ្នកស្រាវជ្រាវនាំយកតក្កកម្មចូលមកក្នុងទីផ្សារ ។ វាអាចផ្តល់នូវសេវាជាច្រើនខាងកម្មសិទ្ធិបញ្ញា ការវាយតម្លៃតក្កកម្មសម្រាប់សេដ្ឋកិច្ច និងវាយតម្លៃបច្ចេកវិទ្យា ឬក៏ទំនាក់ទំនងដោយស្របច្បាប់ចំពោះតក្កកម្មដែលកំពុងស្រាវជ្រាវ ហើយជួយតក្កករ ឬអ្នកស្រាវជ្រាវក្នុងការអភិវឌ្ឍផែនការពាណិជ្ជកម្មនៅគំនិតកានើតែល្អចមពោះតក្កកម្មដែលត្រូវធ្វើអាជីវ

កម្មលើទីផ្សារ ។ ជាគោលការណ៍វាអាចជួយបម្រើដល់ការស្រាវជ្រាវ ការអភិវឌ្ឍ និងសហគ្រាស ។

## ជាសរុបសង្ខេប

តាមរយៈការសិក្សាច្រើនជំពូក អ្នកបានសិក្សាពីជំពូកផ្សេងៗនៃកម្មសិទ្ធិបញ្ញា និងប្រភេទផ្សេងៗនៃកិច្ចការពារ ។ ជំពូកទាំងនោះក៏បានបង្ហាញនូវផលប្រយោជន៍ពីកិច្ចការពាររបស់ម្ចាស់សិទ្ធិដោយបង្ហាញឲ្យឃើញថាអ្នកបង្កើតស្នាដៃកម្មសិទ្ធិបញ្ញាអាចទទួលបានថវិកាត្រលប់មកវិញតាមរយៈសិទ្ធិរបស់គាត់ ដោយកិច្ចសន្យាពាណិជ្ជកម្ម ព្រមទាំងការលក់អាជ្ញាបណ្ណ ។ ក្នុងន័យនេះរាល់កិច្ចព្រមព្រៀងធ្វើពាណិជ្ជកម្មទាំងអស់គឺក្នុងគោលបំណងបង្វិលកម្មសិទ្ធិបញ្ញាមកជាមូលទុនបញ្ញា ។

អ្នកបានសិក្សាពីរចនាសម្ព័ន្ធទូទៅនៃច្បាប់កម្មសិទ្ធិបញ្ញា និងពីទស្សនៈទូទៅនៃ:

-ស្នាដៃដែលបានការពារដោយសិទ្ធិអ្នកនិពន្ធ

-សិទ្ធិដែលបានផ្តល់ឲ្យម្ចាស់ស្នាដៃ

-ព្រំដែនកំណត់នៃសិទ្ធិទាំងនោះ

-ភាពជាម្ចាស់សិទ្ធិ និងការផ្ទេរសិទ្ធិ

-ការពង្រឹងអនុវត្តច្បាប់

តាមអនុសញ្ញាក្រុងBerne ចែងថា សិទ្ធិអ្នកនិពន្ធគឺគ្របដណ្តប់លើផលិតផលទាំងអស់ ទាំងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ និងសិល្បៈគ្រប់ទម្រង់ទាំងអស់នៃការសម្តែងចេញ ។ ដោយន័យទូលាយក្នុងការគ្របដណ្តប់បែបនេះ គឺរាល់ស្នាដៃដើមរបស់អ្នកនិពន្ធនៃស្នាដៃអក្សរសាស្ត្រ សិល្បៈដែលបានបង្កើតឡើង ។ ម្ចាស់ស្នាដៃដែលទទួលបាននូវកិច្ចការពារអាចប្រើប្រាស់ស្នាដៃរបស់ខ្លួន ទៅតាមបំណង ហើយអាចការពារមិនឲ្យអ្នកដទៃប្រើដោយគ្មានការអនុញ្ញាត ។ សិទ្ធិទាំងនេះហៅថាសិទ្ធិផ្តាច់មុខ ។ សិទ្ធិអ្នកនិពន្ធគឺការពារទាំងសិទ្ធិបេតិកភណ្ឌ (សិទ្ធិសេដ្ឋកិច្ច) និងសិទ្ធិសិលធម៌ ។

ជាបន្ថែមលើការបញ្ជាក់ខាងលើ កិច្ចព្រមព្រៀងTRIPSរួមមានប្រភេទស្នាដៃជាច្រើនទៀតដែលត្រូវបានគ្របដណ្តប់ដោយសិទ្ធិអ្នកនិពន្ធ ។ នេះជាផលិផលចម្រុះដែលមិនមាននិយមន័យចែងច្បាស់លាស់ គឺជាការផ្សំចូលគ្នានៃសម្លេង អត្ថបទ និងរូបភាពនៅក្នុងទម្រង់ឌីជីថលដែលអាចដំណើការបានដោយកម្មវិធី Computerដែលត្រូវគេចាត់ទុកជាស្នាដៃដើមហើយស្ថិតនៅក្រោមច្បាប់សិទ្ធិអ្នកនិពន្ធ ។

សិទ្ធិប្រហាក់ប្រហែលជាសិទ្ធិការពារស្របច្បាប់របស់បុគ្គលខ្លះ ឬអង្គភាពដែលរួមចំណែកធ្វើការផ្សព្វផ្សាយសាធារណៈ ឬជាអង្គការដែលមានជំនាញបច្ចេកទេស ។

ជាទូទៅ សិទ្ធិប្រហាក់ប្រហែលត្រូវបានគេផ្តល់ឲ្យប្រភេទ៣នៃអ្នកទទួលផលប្រយោជន៍គឺ: អ្នកសម្តែង ផលិតករ និងអង្គភាពទូរផ្សាយ ។ កិច្ចការពារ៣ក្រុមនេះគឺកំណត់ដោយអនុសញ្ញាក្រុង ROME ១៩៦១ ដែលមានបំណងបង្កើតឡើងនូវបទប្បញ្ញត្តិអន្តរជាតិក្នុងក្នុងវិស័យថ្មីមួយ ដែលច្បាប់

ជាតិមានរួចហើយ ។ ម្យ៉ាងទៀតប្រទេសជាច្រើន បានធ្វើសេចក្តីព្រាង និងអនុម័តច្បាប់មុនពេលចូលអនុសញ្ញានេះ ។ ទោះបីយ៉ាងណាក៏ដោយ អនុសញ្ញាRomeមិនអនុវត្តបានល្អទាំងស្រុងទេ ហើយត្រូវការកែសម្រួលឡើងវិញ ។ ដូចគ្នា សិទ្ធិអ្នកនិពន្ធដែរ អនុសញ្ញាក្រុងRome និងច្បាប់ជាតិមានព្រំដែនកំណត់ពីសិទ្ធិសម្រាប់ប្រើប្រាស់ជាឯកជន ប្រើសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ ឬការបង្រៀន ។

រយៈពេលការពារសិទ្ធិប្រហាក់ប្រហែលដូចបញ្ជាក់ក្នុងអនុសញ្ញាក្រុង Rome មានរយៈពេល ២០ឆ្នាំចុងបញ្ចប់នៃ:

-ការថតបញ្ចូលបានធ្វើឡើង

-ការសម្តែងបានធ្វើឡើង

-ការផ្សាយបានធ្វើឡើង

វិធានការបណ្តោះអាសន្នទាក់ទងការរំលោភបំពានស្នាដៃសិទ្ធិប្រហាក់ប្រហែល រួមមានសំណងរដ្ឋប្បវេណី ដាក់ទោសឧក្រិដ្ឋ វិធានការតាមមាត់ច្រព្រំដែន និងដាក់ទណ្ឌកម្មប្រឆាំងការប្រើប្រាស់ឧបករណ៍បច្ចេកទេសដែលខុសច្បាប់ ។

សិទ្ធិប្រហាក់ប្រហែល ក៏ការពារយ៉ាងទូលាយលើការសម្តែងវប្បធម៌ដែលមិនមានការសរសេរ ឬការថតបញ្ចូលរបស់ប្រទេសកំពុងអភិវឌ្ឍខ្លះ ។ កិច្ចការពារសិទ្ធិប្រហាក់ប្រហែលខ្លះបានក្លាយទៅជារូបភាពដ៏សំខាន់ និងចាំបាច់សម្រាប់ចូលរួមក្នុងប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគ ។

ទាក់ទងនឹងប្រកាសនីយបត្រតក្កកម្មគឺគ្របដណ្តប់លើព័ត៌មានជាមូលដ្ឋាន ។ ប្រកាសនីយបត្រតក្កកម្មគឺជាទម្រង់មួយចាស់ជាងគេនៃកិច្ចការពារកម្មសិទ្ធិបញ្ញា ហើយគោលបំណងគឺលើកទឹកចិត្តការអភិវឌ្ឍវិស័យសេដ្ឋកិច្ចតាមរយៈការផ្តល់ជាឱកាសងវិញតាមរយៈសកម្មភាពកម្មសិទ្ធិបញ្ញា ។

ទាំងការបង្កើតថ្មី និងការអភិវឌ្ឍគឺស្ថិតនៅក្រោមកិច្ចការពារប្រកាសនីយបត្រតក្កកម្ម ។ ក្នុងវិស័យវិទ្យាសាស្ត្រ តក្កកម្មថ្នាំ Penicillin គឺមានសារសំខាន់ណាស់ និងការពារនូវតក្កកម្មនៃម៉ាស៊ីននេះដើម្បីឲ្យដំណើរការផលិតបានលឿនជាងមុន ។ ប្រកាសនីយបត្រតក្កកម្មការពារលើតក្កកម្ម គឺទាល់តែតក្កកម្មនោះអាចមានដំណោះស្រាយបញ្ហាបច្ចេកវិទ្យា ។ ដំណោះស្រាយជាគំនិតនិងត្រូវការការពារដោយច្បាប់ប្រកាសនីយបត្រតក្កកម្ម ដែលមិនតម្រូវឲ្យតក្កកម្មនោះលេចចេញជារូបរាងទេ ។ តែទោះបីជាយ៉ាងណាក៏ដោយក៏មានបទប្បញ្ញត្តិជាច្រើន និងករណីលើកលែងវត្ថុមួយចំនួនមិនអាច ទទួលបានប្រកាសនីយបត្រតក្កម្មទេ រួមមានហ្សែនរបស់មនុស្ស វត្ថុដែលរកឃើញក្នុងធម្មជាតិ ម៉ាស៊ីនដែលផ្ទុយនឹងច្បាប់ធម្មជាតិ និងករណីលើកលែងផ្សេងទៀតមានចែងក្នុងច្បាប់ជាតិគឺជាទ្រឹស្តីវិទ្យាសាស្ត្រ វិធីសាស្ត្រគណិតវិទ្យា ក្បួន វិធីធ្វើពាណិជ្ជកម្ម វិធិព្យាបាលមនុស្ស សត្វ ។

នៅពេលដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ត្រូវមានការត្រួតពិនិត្យដោយអ្នកជំនាញដើម្បីធានាថាវាបំពេញតាមលក្ខខណ្ឌមួយចំនួនដូចជា:

១-ត្រូវតែថ្មី

២-មានជំហានរកឃើញថ្មី

៣-អាចអនុវត្តបានក្នុងវិស័យឧស្សាហកម្ម ។

ជាសង្ខេប ប្រកាសនីយបត្រតក្កកម្មគឺមានទំនាក់ទំនងជាមួយរដ្ឋាភិបាលនិងតក្កករ ។ រដ្ឋដែលផ្តល់ការការពារត្រូវធានាដល់តក្កករដើម្បីផ្តល់ការលើកទឹកចិត្ត ។ បន្ទាប់ពីផុតរយៈពេលការពារ ២០ឆ្នាំ តក្កកម្មនេះក្លាយជាប្រយោជន៍សាធារណៈ ។ ដោយមិនទាន់មានការការពារក្នុងពិភពលោក តក្កករត្រូវតែបង់តម្លៃប្រចាំឆ្នាំនៅក្នុងប្រទេសនីមួយៗដែលគេចង់ការពារ ។

ម្យ៉ាងទៀតនៅក្នុងជំពូកស្តីពីម៉ាកអ្នកបានដឹងថា ម៉ាកអាចជាពាក្យ Logo លេខ អក្សរ ពាក្យស្លោក សម្លេង ពណ៌ ឬជួនកាលក្លិនដែលកំណត់ពីប្រភពទំនិញ ឬសេវា ។

ម៉ាកគឺជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញា គោលបំណងរបស់វាគឺការពារឈ្មោះផលិតផលជាងការពារតក្កកម្ម ឬក៏គំនិតដែលនៅពីក្រោយផលិតផលនោះ ជាទូទៅម៉ាកគឺបង្ហាញពីភាពខុសគ្នានៃទំនិញរបស់សហគ្រាសមួយ ដោយមិនធ្វើការពិពណ៌នា ។

ការប្រើម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបញ្ជាក់ពីប្រភពដើមទំនិញ និងសេវា គោលបំណងប្រើសម្រាប់ជម្រុញពាណិជ្ជកម្មតាមរយៈ ការផ្តល់ព័តមានឲ្យអតិថិជនដឹងពីប្រភពផលិតផលដើម ដែលមានគុណភាព ហើយអតិថិជនតែងតែស្វែងរកទំនិញនោះ ។ ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រទំនិញក៏អាចត្រូវបានគេប្រើសម្រាប់ផលិតផលឧស្សាហកម្ម និងកសិកម្ម ។ កិច្ចការពារនេះគឺអាស្រ័យលើច្បាប់ជាតិ ប៉ុន្តែវាមានសន្ធិសញ្ញាអន្តរជាតិជាច្រើនដែលរួមចំណែកក្នុងការការពារនៅក្នុងប្រទេស ។

អ្នកក៏បានដឹងផងដែលពីសន្ធិសញ្ញាWIPOទាក់ទងជាមួយប្រព័ន្ធចុះបញ្ជីអន្តរជាតិដើម្បីការពារម៉ាក និងគំនូរឧស្សាហកម្ម ។ តួនាទីWIPOក្នុងដំណើរការនេះគឺបម្រើផ្នែករដ្ឋបាលសម្រាប់ការចុះបញ្ជី ។

ប្រព័ន្ធ Madrid ត្រូវបានបង្កើតឡើងជាង១០០ឆ្នាំមកហើយ គោលបំណងរបស់វាគឺត្រួតពិនិត្យការចុះបញ្ជីម៉ាកអន្តរជាតិ ។ ប្រសិនបើបុគ្គលណាមួយចង់ការពារម៉ាករបស់ខ្លួននៅក្នុងប្រទេសច្រើនគាត់ត្រូវចុះបញ្ជីជាដំបូងនៅក្នុងប្រទេសរបស់ខ្លួនសិន ។ ក្នុងរយៈពេល៥ឆ្នាំដំបូងប្រសិនបើក្នុងប្រទេសរបស់ខ្លួនបដិសេធន៍ ជាហេតុធ្វើឲ្យការចុះបញ្ជីនៅប្រទេសផ្សេងៗទៀតត្រូវលុបចេញវិញដែរ ។ តែទោះបីជាយ៉ាងណាក៏ដោយ ការចុះបញ្ជីនៅបរទេសត្រូវចុះសារឡើងវិញក្នុងរយៈពេល១០ឆ្នាំម្តងហើយគ្មានការកំណត់ ។

កិច្ចព្រមព្រៀងHagueបានបង្កើតឡើងនៅប្រព័ន្ធចុះបញ្ជីគំនូរឧស្សាហកម្មអន្តរជាតិ ។ គំនូរឧស្សាហកម្មទាក់ទងជាមួយរូបរាងខាងក្រៅ ហើយខុសពីប្រកាសនីយបត្រតក្កកម្ម ។ ចំណុចខុសគ្នាចម្បងគឺប្រកាសនីយបត្រតក្កកម្មការពារបច្ចេកវិទ្យា និងតក្កកម្ម ដោយឡែកគំនូរឧស្សាហកម្មការពារលើរូបរាងនៃវត្ថុ ។ ម្ចាស់សិទ្ធិគំនូរឧស្សាហកម្មត្រូវទទួលបានកិច្ចការពារមួយរយៈពេលកំណត់ពី១៥ឆ្នាំទៅ២០ឆ្នាំ ដោយឡែកនៅប្រទេសអឺរ៉ុបរយៈពេលការពារ២៥ឆ្នាំ ។

ប្រព័ន្ធPCTផ្តល់នូវនីតិវិធីយ៉ាងសាមញ្ញសម្រាប់តក្កករ ឬអ្នកដាក់ពាក្យសុំដើម្បីទទួលបានប្រកាសនីយបត្រតក្កកម្មក្នុងប្រទេសជាច្រើន ។ ជាពិសេសវាជម្រុញ និងផ្តល់ភាពងាយស្រួលក្នុងការផ្លាស់ប្តូរបច្ចេកវិទ្យាដែលមានក្នុងឯកសារប្រកាសនីយបត្រតក្កកម្ម ទៅកាន់ឧស្សាហករ និងកម្មករក្នុងវិស័យទំនាក់ទំនងគ្នា ។

ដើម្បីងាយស្រួលយល់ពីវិសាលភាពការពារកម្មសិទ្ធិបញ្ញានៅលើទីផ្សារ អ្នកត្រូវយល់បន្ថែមពីការប្រកួតប្រជែងមិនស្មោះត្រង់ និងអំពើទាំងឡាយដែលត្រូវចាត់ទុកថាជាអំពើប្រកួតប្រជែងមិនស្មោះត្រង់ ។ គោលបំណងនៃច្បាប់ប្រកួតប្រជែងមិនស្មោះត្រង់គឺ ការពារអ្នកប្រកួតប្រជែង អតិថិជន និងផលប្រយោជន៍សាធារណៈ ។ ការវិភាគអំពើផ្សេងៗគ្នាដែលបង្ហាញក្នុងការប្រកួតប្រជែងមិនស្មោះត្រង់ អ្នកអាចយល់បានពីភាពខុសគ្នានៃកម្មសិទ្ធិបញ្ញា និងច្បាប់ប្រកួតប្រជែងមិនស្មោះត្រង់ ។

ជាទីបញ្ចប់អ្នកអាចសន្និដ្ឋានបាននៅក្នុងឯកសារនេះអំពីប្រភេទពូជរុក្ខជាតិថ្មី គឺជាទិដ្ឋភាពថ្មីមួយនៃកម្មសិទ្ធិបញ្ញា ។ កិច្ចការពារ Sui Generis យោងតាមច្បាប់ប្រភេទពូជរុក្ខជាតិ នៅពេលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលគ្រាប់ពូជនោះត្រូវបានគេយកមកវិនិយោគនៅក្នុងវិស័យកសិកម្ម ប្រពលវប្បកម្ម និងរុក្ខាកម្ម គឺអាចទទួលបាននៅសិទ្ធិផ្តាច់មុខ និងទទួលបានការលើកទឹកចិត្តក្នុងការអភិវឌ្ឍ និងគុណភាពដំណាំគ្រប់ប្រភេទ ។

# ជំពូកទី១២
# សំណួរបញ្ចប់មេរៀន

## សំណួរជំពូកទី២

១-សិទ្ធិអ្នកនិពន្ធគឺការពារលើតែគំនិតដើម មិនការពារលើគំនិតដែលបានសម្តែងចេញមកខាងក្រៅទេ ។

a)-ត្រឹមត្រូវ

b)-ខុស

២-រយៈពេលការពារអប្បរមានៃសិទ្ធិអ្នកនិពន្ធដែលមានចែងក្នុងសន្ធិសញ្ញាក្រុងBerneគឺ

a)-២០ឆ្នាំចាប់ពីការបង្កើតស្នាដៃ

b)-50ឆ្នាំចាប់ពីឆ្នាំចុងបញ្ចប់ដែលអ្នកនិពន្ធបានស្លាប់

c)-៧០ឆ្នាំចាប់ពីឆ្នាំចុងបញ្ចប់ដែលអ្នកនិពន្ធបានស្លាប់

d)-៥០ឆ្នាំចាប់ពីថ្ងៃបង្កើតស្នាដៃ

៣-តើអ្នកនិពន្ធនៅមានសិទ្ធិអ្វីបន្ទាប់ពីគាត់បានផ្ទេរសិទ្ធិសេដ្ឋកិច្ច?

a)-សិទ្ធិផលិតឡើងវិញ

b)-សិទ្ធិផ្សព្វផ្សាយចាសាធារណៈ

c)-សិទ្ធិខាងសិលធម៌

d)-សិទ្ធិសម្តែង

៤-ខាងក្រោមនេះគឺសុទ្ធជាករណីលើកលែង និងព្រំដែនកំណត់នៃសិទ្ធិ លើកលែងតែមួយចំណុច តើមួយណា?

a)-ការដកស្រង់ខ្លឹមសារ៣ទំព័រចេញពីសៀវភៅ គឺជាទស្សនាវដ្តីផ្នែកស្នាដៃអក្សរសាស្ត្រ

b)-ចេញពីកាហ្សែតវិដេអូដែលអ្នកចូលចិត្ត ហើយដែលមិនបានបញ្ចាំងតាមTVសោះ

c)-ថតចម្លងរូបភាពចេញពីWebsite Internet ដែលអ្នកចង់ប្រើសម្រាប់Website ពាណិជ្ជកម្មថ្មីរបស់អ្នក

d)-ផលិតជាCDសម្រាប់ចាក់ស្តាប់នៅក្នុងរថយន្តរបស់អ្នក

៥-ជនល្មើសបានថតចម្លងដោយខុសច្បាប់នូវបទចម្រៀងដ៏ល្បីរបស់អ្នកដែលផលិតក្នុងស្រុករួចយកទៅលក់នៅប្រទេសមួយទៀត អ្នកមានជម្រើស១ក្នុងជម្រើស៤ ដើម្បីចាត់វិធានការក្នុងការអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធ តើវិធានការមួយណាជាដំបូង?

a-ស្វែងរកតុលាការរដ្ឋប្បវេណីក្នុងការចាត់វិធានការលើការប៉ះពាល់សេដ្ឋកិច្ចចំពោះជនល្មើស

b-ទៅរកក្រុមប្រឹក្សាTRIPS សម្រាប់ការចុះបញ្ជីការរំលោភបំពាន

c-អាចធ្វើទៅបាននៅគ្រប់ទីកន្លែងប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចនៅបទល្មើសដែលបានកើតឡើង និងប្រើប្រាស់វិធានការបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើសេចក្តីជូនដំណឹងទៅជនល្មើស ដើម្បីការពារការនាំចូលនូវទំនិញរំលោភបំពានសិទ្ធិអ្នកនិពន្ធមកធ្វើពាណិជ្ជកម្ម ។

d-ស្នើសុំប្រទេសជិតខាងសមត្ថកិច្ចព្រំដែនដើម្បីត្រួតពិនិត្យ និងបញ្ឈប់ការនាំចូលនូវទំនិញទាំងនោះ ។

៦-តើសកម្មភាពមួយណាដែលមិនមែនជាសម្តែងជាសាធារណៈ?

a-ការសម្តែងធ្វើឡើងនៅកណ្តាលវាល (សម្តែងនៅសួនសាធារណៈ)

b-ស្នាដៃត្រូវបានយកមកសម្តែងនៅពីមុខគ្រួសារ និងក្រុមគ្រួសារចំនួន៥០នាក់

c-បទចម្រៀងCDត្រូវបានចាក់ស្តាប់នៅឯភោជនីយដ្ឋានមួយ

d-រោងកុនបញ្ចាំងខ្សែភាពយន្តថ្មីដែលទើបចេញ ដោយទិញសំបុត្រចូលមើល

៧-អ្នកបានអភិវឌ្ឍគំនិតសម្រាប់ប្រព័ន្ធរក្សាទុកហិរញ្ញវត្ថុ អ្នកអាចក្លាយទៅជាអ្នកមាន ។ គំនិតនេះគឺសាមញ្ញបំផុត គឺអ្នកសរសេរជាសៀវភៅដែលត្រូវទទួលការពារដោយសិទ្ធិអ្នកនិពន្ធ ។ ដោយទទួលបានជោគជ័យ រាប់លានអ្នកបានទិញស្នាដៃរបស់អ្នក បន្ទាប់មកក៏មានបញ្ហាកើតឡើង ។ បញ្ជីបញ្ហាខាងក្រោមចូរជ្រើសរើសបញ្ជីមួយដែលជាការរមលោភបំពាន អ្នកអាចប្តឹង:

a-វាបង្ហាញថាអ្នកថែរក្សាសៀវភៅបានថតចម្លងសៀវភៅរបស់អ្នកទុកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

b-អ្នកផ្សេងបានយកគំនិតរបស់អ្នក ហើយសរសេរសៀវភៅមួយទៀតដែលប្រហាក់ប្រហែលការណែនាំរបស់អ្នកដោយធ្វើជាទម្រង់ថ្មី ថតបញ្ចូលក្នុងឌីស

c-Website internet មួយដែលមិនរកប្រាក់ចំណេញបានផ្តល់នូវការ download ដោយសេរីសៀវភៅរបស់អ្នក

d-អ្នកបានឃើញសៀវភៅរបស់អ្នកនៅឯបណ្ណាគារហាងជជុះលក់បញ្ចុះតម្លៃ៥០%

8-សិទ្ធិចែកចាយត្រូវបានទទួលស្គាល់ដោយច្បាប់នៃប្រទេសរបស់អ្នក ។ នៅក្នុងបណ្ណាគារជជុះមួយអ្នកបានឃើញស្នាដៃរបស់អ្នកដែលមិនទាន់បានបោះពុម្ព ។ ជាធម្មតាតើក្នុងករណីមួយណាដែលអ្នកមិនអាចចាត់វិធានការលើម្ចាស់បណ្ណាគារ ចំពោះការរំលោភបំពានលើសិទ្ធិចែកចាយរបស់អ្នក?

a-វាគឺជាការថតចម្លងមួយច្បាប់ដែលអ្នកបានចុះហត្ថលេខាសម្រាប់អ្នកផ្សព្វផ្សាយស្នាដៃរបស់អ្នកនៅពេលសៀវភៅនោះត្រូវបានបោះពុម្ព

b-នោះមិនមែនជាសៀវភៅសម្រាប់ដាក់លក់ទេ ប៉ុន្តែសៀវភៅដែលសរសេរដោយដៃនោះគឺអ្នកគិតថាម្តាយរបស់អ្នកបានក្រវាត់ចោល ប៉ុន្តែត្រូវបានប្អូនរបស់អ្នករើសទុក

c-វាជាការថតចម្លងខុសច្បាប់នៅស្នាដៃរបស់អ្នក

d-វាជាការថតចម្លងមួយច្បាប់ដែលធ្វើឡើងដោយបណ្ណាល័យក្រោមបទប្បញ្ញត្តិច្បាប់អនុញ្ញាត បន្ទាប់មកបណ្ណាល័យបានទទួលសៀវភៅថតចម្លងពីស្នាដៃជជុះ នោះរួចបានលក់ទៅកន្លែងហ្វូតូកូពី ។

**<u>ចម្លើយ</u>**

១-b; ២-b; ៣-c; ៤-c; ៥-c; ៦-b; ៧-c; ៨-a

**<u>សំណួរជំពូកទី៣</u>**

១-សិទ្ធិប្រហាក់ប្រហែលគឺទាក់ទងនឹង:

a-ប្រកាសនីយបត្រតក្កកម្ម

b-សិទ្ធិអ្នកនិពន្ធ

c-ម៉ាក ពាណិជ្ជនាម

២-តើក្រុមមួយណាដែលមិនទាក់ទងនឹងសិទ្ធិប្រហាក់ប្រហែល

a-អ្នកសម្តែងសិល្ប:

b-ផលិករហ្វូណូក្រាម

c-អ្នកផ្តល់សេវាអ៊ីនធឺណិត

d-អង្គភាពទូរផ្សាយ

៣-រយ:ពេលការពារសិទ្ធិប្រហាក់ប្រហែលក្រោមអនុសញ្ញាក្រុងRomeគឺ:

a-៥០ឆ្នាំចាប់ពីឆ្នាំចុងក្រោយនៃមរណភាពរបស់អ្នកសម្តែង

b-៥០ឆ្នាំចាប់ពីឆ្នាំចុងក្រោយនៃការសម្តែងធ្វើឡើង

c-២០ឆ្នាំចាប់ពីឆ្នាំចុងក្រោយនៃការសម្តែងនោះធ្វើឡើង

៤-ការសម្តែងចេញនៅវស្នាដៃប្រពៃណី

a-អាចទទួលបាននូវកិច្ចការពារក្រោមច្បាប់សិទ្ធិប្រហាក់ប្រហែល

b-មិនអាចទទួលបានកិច្ចការពារក្រោមច្បាប់សិទ្ធិប្រហាក់ប្រហែលទេ ។

## ចម្លើយ

១-b; ២-c; ៣-c; ៤-a

## សំណួរជំពូកទី៤

១-បន្ថែមលើពាក្យ អក្សរ ឈ្មោះ អក្សរកាត់ និងLogo តើអ្វីមានអ្វីទៀតដែលចាត់ទុកថាជាម៉ាក?

a-វត្ថុមានរាង៣ខ្នាត ដូចជាប្រអប់

b-ម៉ាកមានចលនា

c-ក្លិន

d-ទាំងអស់ខាងលើ

២-ឧទាហរណ៍ម៉ាកដែលមានលក្ខណៈពិពណ៌នា

a-ម៉ាកសញ្ញារួមមានឈ្មោះតំបន់ដែលផលិតផលនោះមិនមែនផលិតចេញពីតំបន់នោះ (Bordeaux)

b-រូបភាពមិនជាប់ទាក់ទងជាមួយផលិតផល (ឧទាហរណ៍ រូបផ្លែប៉ោម សម្រាប់ផលិតផល Computer)

c-ឈ្មោះដែលពិពណ៌នាពីផលិតផល (i.e. Mootel for portable cowsheds).

៣-មួយក្នុងចំណោមលក្ខខណ្ឌ២ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងTRIPS

a-ម៉ាកត្រូវតែខុសពីគ្នា និងមិនមានលក្ខណៈពិពណ៌នាពីផលិតផល

b-ម៉ាកមួយត្រូវពិពណ៌នាពីទំនិញ ឬសេវារបស់ទំនិញនោះ

c-ម៉ាកមួយត្រូវតែចុះបញ្ជីដោយគណៈកម្មាធិការពិភពលោកចុះបញ្ជីម៉ាក

៤-ម៉ាកមួយដែលមិនបានចុះបញ្ជីគឺស្ថិតនៅក្រោមកិច្ចការពារម៉ាកប្រសិនៈ

a-សេចក្តីសម្រេចរបស់តុលាការនៃច្បាប់ជាតិទទួលស្គាល់ថាម៉ាកនោះគឺជាម៉ាកOriginal

b-ពេលកន្លងមកគេដឹងថាម៉ាកនោះមានលក្ខណៈខុសពីគេ និងមានកេរ្តិ៍ឈ្មោះល្អលើទីផ្សារ

c-ផលិតផលនោះគឺជាម្ហូប និងបន្លែ

៥-និមិត្តសញ្ញារូបសេះបង្ហាញជាសាខាទេសចរតាមកប៉ាល់ត្រូវគេចាត់ទុកថា

a-ខុសប្លែកពីគេ

b-ការពិពណ៌នា

c-ខុសពីការពិត

៦-ម្ចាស់ម៉ាកមានសិទ្ធិផ្តាច់មុខលើការប្រើប្រាស់ម៉ាករបស់ខ្លួន

a-ត្រូវ

b-ខុស

**<u>ចម្លើយ</u>**

១-d ២-a ៣-a ៤-b ៥-a ៦-a

**<u>សំណួរជំពូកទី៥</u>**

១-តើគោលបំណងនៃម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រគឺអ្វី?

a-ជម្រុញពាណិជ្ជកម្មតាមរយៈការផ្តល់ព័តមានដល់អតិថិជនពីប្រភពដើមនៃទំនិញ

b-ផ្តល់តម្លៃថោកក្នុងការទទួលបានម៉ាក

c-ការពារដំណើរការឧស្សាហកម្ម

d-ផ្តល់សិទ្ធិអ្នកនិពន្ធនៅLogoមួយ

២-ចូរជ្រើសរើសម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រដូចខាងក្រោម:

a) Ford
b) Lego
c) Bordeaux wine
d) Coca Cola
e) France

៣-ជ្រើសរើសវិធី២ដែលត្រូវបានគេប្រើនៅបណ្តាលប្រទេសផ្សេងៗដើម្បីការពារម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រក្នុងប្រទេសរបស់អ្នក

a-អនុក្រឹត្យ

b-ច្បាប់សិទ្ធិអ្នកនិពន្ធ

c-កិច្ចព្រមព្រៀងTRIPS

d-ការចុះបញ្ជី

*ចម្លើយ*

1) a & b
2) a & c
3) a & d
4) b & c
5) b & d

៤-ចូរជ្រើសរើសក្នុងបញ្ជីឈ្មោះសន្ធិសញ្ញារដ្ឋបាលWIPO ដែលទាក់ទងដល់កិច្ចការពារឈ្មោះប្រភពដើម

a) The Hague Agreement
b) The Madrid Agreement
c) The Lisbon Agreement
d) The Rome Agreement

**<u>ចម្លើយ</u>**

១-a ២-c ៣-3 ៤-c

**<u>សំណួរជំពូកទី៦</u>**

១-តើខាងក្រោមមួយណាដែលមិនអាចការពារជាគំនូរឧស្សាហកម្ម

a-វិសមូល

b-ប្រអប់CD

c-Logo

d-កៅអី

e-ប្រភេទពិសេសមានលើផ្ទៃមុខផ្លាស់ស្ទិច

២-ដើម្បីការពារបានទាល់តែគំនូរឧស្សាហកម្មនោះមានទម្រង់បីខ្នាត

a-ត្រូវ

b-ខុស

៣-រយៈពេលការពារអប្បរមាមានចែងក្នុងកិច្ចព្រមព្រៀងTRIPSសម្រាប់គំនូរឧស្សាហកម្មគឺ:

a-៥ឆ្នាំ

b-១០ឆ្នាំ

c-១៥ឆ្នាំ

d-២០ឆ្នាំ

៤-តើកិច្ចព្រមព្រៀងអន្តរជាតិឈ្មោះអ្វីដែលទាក់ទងការតម្កល់គំនូរឧស្សាហកម្ម?

a-កិច្ចព្រមព្រៀងParis

b-កិច្ចព្រមព្រៀgeneva

c-The Amsterdam Protocol

d-កិច្ចព្រមព្រៀងHague

**ចម្លើយ**

១-c ២-b ៣-c ៤-d

**សំណួរជំពូកទី៧**

១-ជ្រើសរើសក្នុងបញ្ជីនូវចម្លើយពីរត្រឹមត្រូវនៃចម្លើយចំពោះសំណួរ តើពេលណាប្រកាសនីយបត្រតក្កកម្មផុតកំណត់

a-ការពារដោយស្វ័យប្រវត្តិសម្រាប់រយៈពេលបន្ថែម២០ឆ្នាំ

b-ដាក់ចូលជាប្រយោជន៍សាធារណៈ ប្រើដោយសេរី

c-ក្លាយជាលក្ខណៈសំងាត់ពាណិជ្ជកម្ម

d-អាចត្រូវបានធ្វើអាជីវកម្មដោយមិនចាំបាច់សុំការអនុញ្ញាតពីម្ចាស់សិទ្ធិ

*ចម្លើយ*

1) a & b
2) a & d
3) b & c
4) b & d
5) c & d

២-មានប្រកាសនីយបត្រតក្កម្មពិភពលោក

a-ត្រូវ

b-ខុស

៣-តាមរយៈប្រព័ន្ធPCTវាងាយស្រួល និងថោកដើម្បីទទួលការពារក្នុងការិយាល័យជាច្រើនដែលបានជ្រើសរើសនៅក្នុងពេលតែមួយ ជាងដំណើរការដាក់ពាក្យសុំនៅបណ្តាលការិយាល័យនៃប្រទេសមួយៗ ។

a-ត្រូវ

b-ខុស

៤-តើមានបញ្ហាអីកើតឡើងប្រសិនបើអ្នកមិនបានបង់ប្រាក់ការពារប្រកាសនីយបត្រតក្កកម្មប្រចាំឆ្នាំនៅក្នុងប្រទេសដែលអ្នកទទួលបានប្រកាសនីយបត្រតក្កម្ម ។

a-អ្នកទទួលបានកិច្ចការពារដោយស្វ័យប្រវត្តិ និងការពារជាបន្តបន្ទាប់

b-កិច្ចការពារប្រកាសនីយបត្រតក្កកម្មមិនមានសុពលភាពយូរទេនៅក្នុងប្រទេសនោះ ហើយត្រូវក្លាយជាប្រយោជន៍សាធារណៈ ប្រើប្រាស់ដោយសេរី

c-យ៉ាងហោចណាស់រយៈពេល២០ឆ្នាំមុនពេលប្រកាសនីយបត្រតក្កកម្មផុតកំណត់ ។

៥-តើធ្លាពីរខាងក្រោមមួយណាអាចមានលក្ខណៈសម្បត្តិទទួលបានប្រកាសនីយបត្រតក្កកម្ម?

a-ដំណើការប្រតិកម្មគីមីថ្មីមួយ

b-គំនូរមួយ

c-សៀវភៅមួយ

d-ចម្រៀងមួយបទ

e-ម៉ាស៊ីនចម្រាញ់ទឹកអប់

*ចម្លើយ*

1) a & b
2) a & d
3) b & d
4) a & e
5) c & e

៦-យោងតាមច្បាប់ប្រកាសនីយបត្រតក្កកម្មដែលអ្នកបានសិក្សារួច ចូរជ្រើសរើសក្នុងបញ្ជីខាងក្រោម រាល់មូលហេតុទាំងអស់នៃម៉ាស៊ីនដែលធ្វើចលនារហូត មិនអាចទទួលបាននូវកិច្ចការពារ?

a-ពីព្រោះប្រកាសនីយបត្រតក្កកម្មមិនការពារតក្កកម្មនៃម៉ាស៊ីនទេ

b-ពីព្រោះវាជាតក្កកម្មរួចហើយ

c-ពីព្រោះម៉ាស៊ីននោះវាខុសច្បាប់សម្រាប់ប្រើជាសាធារណៈ

d-ពីព្រោះម៉ាស៊ីនទាំងនោះវាប្រឆាំងនឹងច្បាប់ធម្មជាតិ ។

**ចម្លើយ**

១-4 ២-b ៣-a ៤-b ៥-4 ៦-d

**សំណួរជំពូកទី៨**

១-គោលបំណងចម្បងរបស់ប្រព័ន្ធMadridគឺ

a-ត្រួតពិនិត្យដំណើការផ្តល់គំនូរឧស្សាហកម្មដល់តក្កករជនជាតិអឺរ៉ុប

b-សម្របសម្រួលផ្តល់ប្រកាសនីយបត្រតក្កកម្មក្នុងប្រទេសផ្សេងៗក្នុងពិភពលោក

c-ត្រួតពិនិត្យការចុះបញ្ជីម៉ាកអន្តរជាតិ

២-ម៉ាកអាចត្រូវបានការពារជាលក្ខណៈអន្តរជាតិសម្រាប់

a-៧៥ឆ្នាំចាប់ពីពេលម៉ាកត្រូវបានគេផ្តល់ឲ្យ

b-រយៈពេល១០០ឆ្នាំ ហើយចុះបញ្ជីឡើងវិញរាល់២០ឆ្នាំម្តង

c-គ្មានពេលកំណត់ ដោយចុះបញ្ជីឡើងវិញរាល់១០ឆ្នាំម្តង

៣-ប្រព័ន្ធចុះបញ្ជីអន្តរជាតិនៃគំនូរឧស្សាហកម្មហៅថា

a) The Madrid System
b) The Hague Agreement
c) The Rome Convention

៤-ភាពខុសគ្នាចម្បងរវាងប្រកាសនីយបត្រតក្កកម្ម និងគំនូរឧស្សាហកម្មគឺ

a-ប្រកាសនីយបត្រតក្កកម្មការពារលើកាច្នៃប្រឌិត និងតក្កកម្ម គំនូរឧស្សាហកម្មការពារលើរូបរាងខាងក្រៅនៃវត្ថុ

b-ប្រកាសនីយបត្រតក្កកម្មការពារលើរូបរាងខាងក្រៅនៃវត្ថុ គំនូរឧស្សាហកម្មការពារលើការច្នៃប្រឌិត និងតក្កកម្ម

c-គ្មានភាពខុសគ្នាទេរវាងប្រកាសនីយបត្រតក្កកម្ម និងគំនូរឧស្សសាហកម្ម

៥-ម្ចាស់សិទ្ធិគំនូរឧស្សាហកម្មត្រូវបានគេការពារសម្រាប់

a-រយៈពេល២០ឆ្នាំក្នុងប្រទេសសហគមអឺរ៉ុប

b-រយៈពេល៥០ឆ្នាំ ដោយមានលទ្ធភាពចុះបញ្ជីសារឡើងវិញ២៥ឆ្នាំបន្ថែមទៀត

c-រយៈពេល១០ឆ្នាំ ១៥ឆ្នាំ ឬ២០ឆ្នាំតាមប្រទេសនីមួយៗ

៦-គោលបំណងចម្បងរបស់PCTគឺ

a-ធ្វើឲ្យកាន់តែងាយស្រួល និងកាន់តែមានប្រសិទ្ធិភាពដំណើការសុំការពារប្រកាសនីយបត្រតក្កកម្មក្នុងប្រទេសច្រើន

b-ផ្តល់ប្រកាសនីយបត្រតក្កកម្មក្នុងពិភពលោក

c-ត្រួតពិនិត្យ និងបំពេញពាក្យសុំទូទាំងពិភពលោក

៧-មានជំហាន៤ក្នុងដំណើការPCTគឺ

a-ការបំពេញពាក្យ ការត្រួតពិនិត្យអន្តរជាតិ ការបោះផ្សាយអន្តរជាតិ ការស្រាវជ្រាវអន្តរជាតិ និងដំណាក់កាលជាតិ

b-ការបំពេញពាក្យ ការមើលឡើងវិញជាអន្តរជាតិចំពោះប្រកាសនីយបត្រតក្កកម្មដូចគ្នា ការស្រាវជ្រាវអន្តរជាតិ ការបោះផ្សាយអន្តរជាតិ និងដំនាក់កាលជាតិ

c-ការបំពេញពាក្យ ការស្រាវជ្រាវអន្តរជាតិ ការបោះផ្សាយអន្តរជាតិ ការត្រួតពិនិត្យអន្តរជាតិ និងដំណាក់កាលជាតិ

៨-PCTមិនផ្តល់ប្រកាសនីយបត្រតក្កកម្មទេ

a-ត្រូវ

b-ខុស

**<u>ចម្លើយ</u>**

១-c ២-c ៣-b ៤-a ៥-c ៦-a ៧-c ៨-a

**<u>សំណួរជំពូកទី៩</u>**

១-តើអំពើខាងក្រោមមួយណាដែលមិនចាត់ទុកជាអំពើប្រកួតប្រជែងមិនស្មោះត្រង់?

a-ធ្វើរបាយការណ៍ថាម្ហូបរបស់ដៃគូប្រកួតប្រជែងមិនធ្វើមកពីចាតិសាច់ទេ តែតាមពិតគេធ្វើមកពីជាតិសាច់

b-ធ្វើរបាយការណ៍មិនពិតថាដៃគូប្រកួតប្រជែងរបស់ខ្លួនថាបិទអាជីវកម្ម

c-ថតចម្លងCDរួចលក់ក្នុងតម្លៃថោក

d-ប្រើប្រាស់ម៉ាកដែលដូចទៅនឹងម៉ាករបស់ដៃគូប្រកួតប្រជែង

e-យកបញ្ជីអតិថិជនតាមខ្លួនហើយមានបំណងប្រើប្រាស់ក្នុងក្រុមហ៊ុនដែលជាដៃគូប្រកួតប្រជែង

២-តើមួយណាជាអំពើប្រកួតប្រជែងមិនស្មោះត្រង់ ហើយមួយណាអាចចាត់ជាចំណាត់ថ្នាក់កាផ្សព្វផ្សាយឲ្យយល់ច្រលំ?

a-កម្រិតស្ករតិច ដោយសារវាមានទំហំតូច

b-ផលិតផលខ្ទប់រិចដោយប្រើរូបផ្កាយ និងទង់ជាតិអាមេរិក ដែលមិនធ្វើឡើងនៅក្នុងប្រទេសអាមេរិច

c-ធ្វើរបាយការណ៍ថាដៃគូរបស់ខ្លួនប្រហែលក្ស័យធន់ តែមិនមែនជាការពិត

d-បន្លំធ្វើរូបភាពដូចគ្នារូបភាពរបស់ដៃគូប្រកួតប្រជែង

*ចម្លើយ*

1) a & b
2) a & c
3) b & c

4) b & d
5) a & d

៣-តើអំពើពីរខាងក្រោមណាដែលជាអំពើប៉ះពាល់ដល់កិត្តិយសដៃគូប្រកួតប្រជែង

-ដំឡូងជាងត្រូវបានស្មោលាយជាតិសាច់គោ តែតាមពិតមិនមែន

-លួចរូបមន្តលាយធ្វើទឹកក្រូច

-បញ្ជាក់ថាផលិតផលរបស់ដៃគូប្រកួតប្រជែងមានគ្រោះថ្នាក់

-បោះផ្សាយលទ្ធផលការសិក្សាឯករាជ្យដែលទាក់ទងនឹងផលិតផលរបស់ដៃគូប្រកួតប្រជែង

*ចម្លើយ*

1) a & b
2) a & c
3) a & d
4) b & c
5) c & d

៤-ព័ត៌មានសំងាត់ពាណិជ្ជកម្មតែងតែអាចការពារដោយប្រកាសនីយបត្រតក្កកម្ម

a-ត្រូវ

b-ខុស

៥-តើមួយណាដែលអាចចាត់ទុកថាព័ត៌មានដើម្បីការពារតាមមាត្រា39(2) TRIPS?

-ជាLogo

-ជាបញ្ជីអាស័យដ្ឋានអតិថិជន

-គ្រឿងផ្សំស្តង់ដារនៃនំប៉ុង

-សីតុណ្ហភាពដែលផលិតផលផ្លាស់ស្ទិកអាចដំណើការបាន

*ចម្លើយ*

1) a & b
2) a & c
3) b & d
4) c & d
5) a & d

៦-តើអំពើមួយណាដែលចាត់ទុកថាជាអំពើទាញយកផលប្រយោជន៍ដោយធ្វើឲ្យគេយល់ច្រលំ

a-ភោជនីយដ្ឋានមួយបានទាញយកប្រយោជន៍ពីការផ្សាយលើគំនូរបង្ហាញផ្លូវចូលដោយផ្អែកលើទីតាំងល្បីមួយរបស់ដៃគូប្រកួតប្រជែង

b-ធ្វើឲ្យមានលក្ខណ:ដូចគ្នានឹងរូបភាពហាងរបស់ដៃគូប្រកួតប្រជែង

c-យោងតាមការផ្សាយពាណិជ្ជកម្មទូរទស្សន៍របស់ដៃគូប្រកួតប្រជែង

**ចម្លើយ**

១-c ២-1 ៣-2 ៤-b ៥-3 ៦-b

**សំណួរជំពូកទី១០**

១-តើរយៈពេលការពារអប្បរមាម្ចាស់សិទ្ធិពូជដំណាំមានរយៈពេលប៉ុន្មានឆ្នាំយោងតាមអនុសញ្ញាឆ្នាំ១៩៩១

a-១០

b-១៥

c-២០

d-២៥

e-៧០

២-តើអំពើខាងក្រោមមួយណាដែលម្ចាស់សិទ្ធិបង្កាត់ពូជមិនអាចការពារ

a-ការនាំពូជចូលក្នុងប្រទេស

b-ប្រើប្រាស់រុក្ខជាតិនោះដើម្បីបង្កាតើប្រភេទរុក្ខជាតិថ្មី

c-ជ្រើសរើសពូជនោះដើម្បីលក់ឡើងវិញ

៣-ជាការចាំបាច់ណាស់សម្រាប់ប្រភេទពូជរុក្ខជាតិមួយត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យបច្ចេកទេសនៅក្នុងប្រទេសនីមួយៗដែលម្ចាស់ពូជចង់ការពារ

a-ចាំបាច់

b-មិនចាំបាច់

c-មិនទាំងពីរខាងលើ

**ចម្លើយ**

១-d ២-b ៣-c

**អត្ថបទយោង**

-សន្ធិសញ្ញា Berne Convention ដើម្បីការពារលើស្នាដៃអក្សរសាស្ត្រ និងសិល្បៈ

កិច្ចព្រមព្រៀង TRIPS

-សន្ធិសញ្ញាការសម្តែង និងហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WPPT)

-សន្ធិសញ្ញាសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WCT)

-អនុសញ្ញាទីក្រុងរ៉ូម(Rome Convention)សម្រាប់កិច្ចការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ

-កិច្ចព្រមព្រៀងទ្រីព (TRIPS Agreement)

-អនុសញ្ញាទីក្រុងប្រ៊ុសសែល ស្តីពីការចែកចាយសញ្ញាកម្មវិធីបញ្ជូនតាមផ្កាយរណប Brussels Convention Relating to the Distribution of Programmer carrying signals transmitted by satellite។

-កិច្ចព្រមព្រៀងម៉ាតឌ្រីតដែលទាក់ទងនឹងការចុះបញ្ជីអន្តរជាតិនៃម៉ាក

-កិច្ចព្រមព្រៀងលីសបិ៊ន Lisbon Agreement សម្រាប់ការពារឈ្មោះ ប្រភពដើម និងការចុះបញ្ជីអន្តរជាតិ

-កិច្ចព្រមព្រៀង Hague ដែលទាក់ទងនឹងការតម្កល់អន្តរជាតិនៃគំនូរឧស្សាហកម្ម

-សន្ធិសញ្ញាសហប្រតិបត្តការប្រកាសនីយបត្រតក្កកម្មPCT